**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Economiques**
**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# នីត្យានុកូលភាពនៃកិច្ចការរដ្ឋបាល

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **យ៉យ គឹមយ៉ាន់**
**យិន ទាសនា**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៧ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០១៨
ឆ្នាំសរសេរសារណា ២០២២

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics


# សារណាបញ្ចប់ការសិក្សា

# នីត្យានុកូលភាពនៃកិច្ចការរដ្ឋបាល

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **យ៉យ គីមយាន់**

**យិន ទាសនា**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៧ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **យ៉យ គឹមយាន់** និង **យិន វាសនា** ជានិស្សិតផ្នែកបរិញ្ញាបត្រនីតិសាស្ត្រ (អាហារូបករណ៍) ជំនាន់ទី២៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨-២០២២។

**សូមគោរពដឹងគុណ និងថ្លែងអំណរគុណជាអនេកប្បការជូនចំពោះ៖**

- **លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅជួយទំនុកបម្រុងដល់រូបកូនៗ ទាំងស្មារតី និងសម្ភារៈគ្រប់បែបយ៉ាង ជាពិសេសរួមទាំងការផ្តល់ដំបូន្មានល្អៗរបស់លោកដល់រូបកូន ចាប់តាំងពីពេលកូននៅជាកុមាររហូតដល់ធំដឹងក្តី និងបានទទួលបានការបណ្តុះបណ្តាលថ្នាក់ឧត្តមសិក្សា ហើយបានបញ្ចប់ការសិក្សាជាស្ថាពរជាមួយនឹងការទទួលបានលទ្ធផលជាទីគាប់ប្រសើរថែមទៀត។ លោកទាំងពីរបានប្រឹងអស់ទាំងកម្លាំងកាយ និងកម្លាំងចិត្តរបស់លោកទាំងពីរមិនរុញរា លោកខិតខំពុះពារទាំងថ្ងៃទាំងយប់ ធ្វើយ៉ាងណាឱ្យកូនទទួលបានលទ្ធផលល្អដូចសព្វថ្ងៃ តាមរយៈការខិតខំអស់ពីកម្លាំងកាយចិត្តរបស់លោកទាំងពីរនេះហើយ បានធ្វើឱ្យកូនមិនអាចបំភ្លេចជារៀងរហូត។
- ឯកឧត្តមបណ្ឌិត **លុយ ចន្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យដែលមានសមត្ថភាពខ្ពង់ខ្ពស់ និងជួយតម្រង់ទិសខ្ញុំបាទតាំងពីឆ្នាំសិក្សាមូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយគុណភាព។
- សាស្ត្រាចារ្យបណ្ឌិត **អ៊ុន សកក្កដា** ដែលជាសាស្ត្រាចារ្យដ៏ឆ្នើម និងជាសាស្ត្រាចារ្យគំរូប្រកបដោយព្រហ្មវិហារធម៌ គុណធម៌ សីលធម៌ លោកគ្រូបានដឹកនាំបង្ហាត់បង្ហាញពីគំនិត និងវិធីសាស្ត្រល្អៗទាក់ទងនឹងប្រធានបទ រួមទាំងការចំណាយពេលវេលាដ៏មានតម្លៃរបស់លោកគ្រូ តាំងពីដើមរហូតដល់បញ្ចប់ការសិក្សាស្រាវជ្រាវនេះ។

ជាចុងក្រោយខ្ញុំទាំងពីរនាក់ពិតជាមិនអាចបំភ្លេច បាននូវគុណូបការៈដ៏ធំធេងនេះបានឡើយ ហើយសូមប្រសិទ្ធិពរជ័យជូនលោកឪពុក អ្នកម្តាយ ឯកឧត្តម លោកគ្រូ អ្នកគ្រូ ឱ្យមានសុខភាពល្អជាពិសេសទទួលបាននូវជោគជ័យគ្រប់ភារកិច្ចហើយសូមឱ្យជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ **នីត្យានុកូលភាពនៃកិច្ចការរដ្ឋបាល** គឺជាប្រធានបទមួយដែលត្រូវបានស្រាវជ្រាវដោយខ្ញុំបាទ យ៉យ គឹមយាន់ និង យិន វាសនា ជានិស្សិត ជំនាញនីតិសាស្ត្រ (អាហារូបករណ៍) ជំនាន់ទី២៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រោមការដឹកនាំរបស់សាស្ត្រាចារ្យបណ្ឌិត **អ៊ុន សកក្ខដា**។

សារណានេះពិតជាមានសារៈសំខាន់ណាស់សម្រាប់និស្សិតនីតិសាស្ត្រដូចខ្ញុំទាំងពីរនាក់ ក្នុងការសិក្សាឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅ និងចងក្រងទុកជាឯកសារ។ ខ្ញុំបាទពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងក្នុងការចំណាយនូវកម្លាំងកាយចិត្ត ពេលវេលា និងធនធានផ្ទាល់ខ្លួន ដើម្បីរៀបចំចងក្រងនូវកិច្ចការនៃសារណាមួយនេះឱ្យលេញចេញជារូបរាងឡើង ព្រោះកិច្ចការមួយនេះបានធ្វើឱ្យខ្ញុំចេះធ្វើកិច្ចការស្រាវជ្រាវយ៉ាងសកម្មដែលបានបង្កើតនូវចំណេះដឹងមូលដ្ឋាន បណ្តុះគំនិតប្រាជ្ញា និងមានការយល់ដឹងកាន់តែច្បាស់អំពីប្រធានបទមួយនេះ។

ខ្ញុំបាទសង្ឃឹមជាមុនថា កិច្ចការមួយនេះនឹងក្លាយទៅជាប្រយោជន៍សម្រាប់មជ្ឈដ្ឋានអ្នកស្នេហាការសិក្សាទាំងឡាយ មិត្តនិស្សិត ក៏ដូចជានិស្សិតជំនាន់ក្រោយ ដោយចូលរួមក្នុងការបង្កើននូវពុទ្ធិ ចំណេះដឹងមូលដ្ឋានរបស់អ្នកគ្រប់គ្នា។ តាមរយៈសារណានេះដែរ ក៏អាចចូលរួមចំណែកក្នុងការពង្រឹងនីត្យានុកូលភាពនៃកិច្ចការរដ្ឋបាលផងដែរ។

ដោយសារតែចំណេះដឹងនៅមានកម្រិត ដូច្នេះក្រុមខ្ញុំបាទនៅជឿជាក់ថាកំហុសនៅតែកើតមានឡើងដោយជៀសពុំរួចនោះឡើយ ទាំងអត្ថន័យខ្លឹមសារ ពាក្យពេជន៍ឃ្លាឃ្លោង ទាំងអក្ខរាវិរុទ្ធ និងបច្ចេកទេសនៃការចងក្រងនៅមានកម្រិតផងនោះ។

អាស្រ័យហេតុដូចនេះ ខ្ញុំបាទសូមការខន្តីអភ័យទោសចំពោះកំហុសខុសឆ្គងដែលនឹងអាចកើតមានឡើងដោយប្រការណាមួយពីសំណាក់ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ ហើយមានសេចក្តីសោមនស្សរីករាយឥតឧបមាក្នុងការទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនា និងកែលំអរ ដើម្បីបំពេញចន្លោះខ្វះខាតនៅក្នុងអត្ថបទសារណានេះ ដើម្បីធ្វើអោយខ្លឹមសារ និងអត្ថបទសារណានេះកាន់តែល្អ និងប្រកបដោយគុណភាព។

# មាតិកា


**ទំព័រ**

**សេចក្តីផ្តើម** ............ ១

**ជំពូកទី១**

**គោលការណ៍នីត្យានុកូលភាព**

**១.១. សញ្ញាណទូទៅនៃឋានានុក្រមធម្មនិយាមគតិយុត្ត** ............ ៥

**១.១.១. លំដាប់ថ្នាក់ក្នុងអង្គនីតិប្បញ្ញត្តិ** ............ ៥

១.១.១.១. រដ្ឋធម្មនុញ្ញ ............ ៥

១.១.១.២. សន្ធិសញ្ញា ............ ១០

១.១.១.៣. ច្បាប់ ............ ១២

១.១.១.៤. គោលការណ៍ទូទៅនៃនីតិ និងយុត្តិសាស្ត្រ ............ ១៣

**១.១.២. លំដាប់ថ្នាក់ក្នុងអង្គនីតិប្រតិបត្តិ** ............ ១៤

១.១.២.១. ថ្នាក់ជាតិ ............ ១៤

១.១.២.២. ថ្នាក់ក្រោមជាតិ ............ ២២

**១.១.៣. ទម្រង់ និងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត** ............ ២៤

១.១.៣.១. ការយកទម្រង់នៃលិខិតបទដ្ឋានគតិយុត្ត ............ ២៥

១.១.៣.២. ការផ្សព្វផ្សាយ ............ ២៥

**១.២. ភាតព្វកិច្ចក្រោមវិធានគតិយុត្ត និងសមត្ថកិច្ចជាប់ចំណង** ............ ២៦

**១.២.១. ភាតព្វកិច្ចរបស់រាជការក្រោមវិធានគតិយុត្ត** ............ ២៦

១.២.១.១. ធ្វើសកម្មភាពប្រកបដោយច្បាប់ ............ ២៧

១.២.១.២. ត្រូវគោរពគោលការណ៍នៃវិធានគតិយុត្ត ............ ២៧

**១.២.២. សមត្ថកិច្ចជាប់ចំណង** ............ ២៩

១.២.២.១. ចំណងតឹង ............ ៣០

១.២.២.២. ចំណងធូរ ............ ៣០

**ជំពូកទី២**

**អំណាចឆន្ទានុសិទ្ធិ និងនីត្យានុកូលភាពនៃអញ្ញត្រកម្ម**

**២.១. សញ្ញាណទូទៅនៃអំណាច** ............ ៣១

**២.១.១. សញ្ញាណ និងនិយមន័យ** ............ ៣២

២.១.១.១. សញ្ញាណនៃអំណាចឆន្ទានុសិទ្ធិ ............ ៣២

២.១.១.២. និយមន័យ ........ ៣៣
**២.១.២. ព្រំដែននៃការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិ** ........ ៣៣
២.១.២.១. នីត្យានុកូលភាពផ្ទៃក្រៅ ........ ៣៤
២.១.២.២. នីត្យានុកូលភាពផ្ទៃក្នុង ........ ៤២
**២.២. នីត្យានុកូលភាពនៃអញ្ញត្រកម្ម** ........ ៤៦
**២.២.១. កាលៈទេសៈពិសេស** ........ ៤៧
២.២.១.១. ទ្រឹស្តី និងលក្ខខណ្ឌនៃកាលៈទេសៈពិសេស ........ ៤៧
២.២.១.២. កាលៈទេសៈពិសេសក្រោមច្បាប់កម្ពុជា ........ ៤៩
**២.២.២. រដ្ឋាភិបាលកិច្ច** ........ ៥៣
២.២.២.១. ក្នុងប្រទេស ........ ៥៤
២.២.២.២. ក្រៅប្រទេស ........ ៥៤
**សេចក្តីសន្និដ្ឋាន** ........ ៥៥
**អនុសាសន៍** ........ ៥៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

រដ្ឋបាល មានសកម្មភាពជាយូរណាស់មកហើយ តែពាក្យរដ្ឋបាលទើបតែឃើញគេប្រើប្រាស់នៅចុងសតវត្សរ៍ទី១៨ក្នុងប្រទេសបារាំង។ តាមន័យទូលាយពាក្យថា រដ្ឋបាល ជួនកាលសំដៅលើសកម្មភាពគ្រប់គ្រង ជួនកាលលើអង្គការដែលគ្រប់គ្រង។ ន័យទាំងពីរនេះ អាចប្រើបានទាំងខាងវិស័យឯកជន ទាំងខាងវិស័យសាធារណៈ។ តាមន័យសកម្មភាពមានដូចជាកិច្ចការរដ្ឋបាលរបស់ក្រុមហ៊ុនកាត់ដេរ កិច្ចរដ្ឋបាលរបស់ក្រសួងទេសចរណ៍ រីឯតាមន័យអង្គការដូចជាក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនអាហារ័ណនិហារ័ណ ក្រសួងទេសចរណ៍ជាដើម។ តាមន័យទូលាយនេះ សកម្មភាពរដ្ឋបាលឯកជនក៏មានរបស់រាជការក៏មាន ដែលជាហេតុនាំឱ្យនឹកគិតថា មិនចាំបាច់ទៅបង្កើតវិធានអ្វីឱ្យខុសប្លែកពីគ្នាទេ ពីព្រោះការគ្រប់គ្រងនៅតែជាការគ្រប់គ្រងដដែល។ គំនិតហ្នឹងហើយ ដែលពួកនិយមខាងប្រព័ន្ធខូម៉ុនឡ (Common Law) គេយល់ថាមិនចាំបាច់មាននីតិរដ្ឋបាលមួយដោយឡែកសម្រាប់រាជការទេ។ ចំណែកឯពួកនិយមប្រព័ន្ធច្បាប់ស៊ីវិលឡ (Civil Law) គេយល់ថារដ្ឋ ឬសមូហភាពសាធារណៈបំរើប្រយោជន៍សាធារណៈ គឺមានគោលដៅមិនរកផលប្រយោជន៍ចំណេញផ្ទាល់ខ្លួនដូចជាបុគ្គលឯកជនឡើយ ដូច្នេះគេត្រូវមានវិធានគ្រប់គ្រងរដ្ឋបាលផ្សេងពីឯកជន។

ក្នុងការទំនាក់ទំនងរវាងរាជការ និងឯកជន រាជការមានសិទ្ធិអំណាចធំជាងឯកជន ដោយហេតុថារាជការជាអ្នកបម្រើផលប្រយោជន៍ទូទៅ បើសិនជាឱ្យរាជការ និងឯកជនមានសមភាពគតិយុត្ត នោះរាជការនឹងជួបការលំបាកក្នុងការធ្វើឱ្យសម្រេចនូវគោលដៅនៃផលប្រយោជន៍ទូទៅ ពីព្រោះផលប្រយោជន៍ឯកជនម្នាក់ៗមិនអាចស្របទាំងស្រុងគ្រប់កាលៈទេសៈទៅនឹងផលប្រយោជន៍របស់សង្គមជាតិបានឡើយ ផ្ទុយទៅវិញ ច្រើនតែប្រឆាំងគ្នានឹងផលប្រយោជន៍ទូទៅ។ សិទ្ធិអំណាចដ៏ធំនេះគេហៅថា បុព្វសិទ្ធិនៃអំណាចសាធារណៈ។ បុព្វសិទ្ធិនេះអនុញ្ញាតឱ្យរាជការមានប្រៀបជាងឯកជនជានិច្ចក្នុងការទំនាក់ទំនងសង្គម។ តាមរយៈការប្រើប្រាស់នូវបុព្វសិទ្ធិនៃអំណាចសាធារណៈនេះហើយ បានស្តែងឡើងឱ្យឃើញអំពើរបស់រាជការតាមរយៈច្បាប់ លិខិតបទដ្ឋានគតិយុត្ត (ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកា) និងសកម្មភាពរបស់រាជការ។ ប៉ុន្តែ ការប្រើប្រាស់បុព្វសិទ្ធិនេះ មិនអនុញ្ញាតឱ្យរាជការធ្វើអ្វីទៅតាមទំនើងចិត្តបាននោះទេ ផ្ទុយទៅវិញ រាជការត្រូវតែមានការប្រុងប្រយ័ត្នឱ្យបានខ្ពស់បំផុត ជាពិសេសធានាឱ្យបានថាអំពើរបស់ខ្លួនដែលធ្វើឡើងគឺមានភាពត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខខណ្ឌផ្សេងៗទៀត ដែលនេះហើយជាការធានានូវនីត្យានុកូលភាពនៃកិច្ចការរដ្ឋបាល បើពុំដូច្នេះទេ រាជការនឹងធ្លាក់ទៅក្នុងភាពខុសច្បាប់ដែលតុលាការអាចនឹងប្រកាន់បាន។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

តាមលំនាំបញ្ហា រាល់កិច្ចការរដ្ឋបាល រាជការត្រូវតែគោរព និងធានាឱ្យបាននូវភាពស្របច្បាប់ទៅលើអំពើរបស់ខ្លួនដែលស្តែងឡើងតាមរយៈច្បាប់ លិខិតបទដ្ឋានគតិយុត្ត (ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកា សេចក្តីសម្រេចផ្សេងៗ) និងសកម្មភាពផ្សេងៗ។ ដូច្នេះចំណុចសំខាន់នៃការស្រាវជ្រាវលើប្រធានបទស្តីពីនីត្យានុកូលភាពនៃកិច្ចការរដ្ឋបាលផ្តោតសំខាន់លើបញ្ហាដូចខាងក្រោម៖

តើដើម្បីឱ្យកិច្ចការរដ្ឋបាលមាននីត្យានុកូលភាពត្រូវបំពេញលក្ខខណ្ឌដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

- ស្វែងយល់ពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចការរដ្ឋបាល
- ស្វែងយល់ពីអំពើរបស់រាជការតាមរយៈច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងសកម្មភាពផ្សេងៗ
- ចូលរួមផ្តល់ជាមូលដ្ឋានដើម្បីប្តឹងទៅកាន់តុលាការរដ្ឋបាលអំពីអំពើរបស់រាជការដែលអនីត្យានុកូលភាព
- ចូលរួមចំណែកនៅក្នុងការចងក្រងឯកសារទុកសម្រាប់អ្នកបន្តវេន និងសិស្សប្អូនជំនាន់ក្រោយ
- ចូលរួមក្នុងការពង្រឹងនីត្យានុកូលភាពនៃអំពើរបស់រាជការ។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះមានដែនកំណត់ និងវិសាលភាពគ្របដណ្តប់តែលើទិដ្ឋភាពច្បាប់រួមមាន៖ រដ្ឋធម្មនុញ្ញ សន្ធិសញ្ញា ច្បាប់ គោលការណ៍ទូទៅនៃនីតិ និងយុត្តិសាស្ត្រ ក៏ដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ ប្រកាសផ្សេងៗ និងឯកសារផ្សេងៗទៀត និងការអនុវត្តច្បាប់របស់ស្ថាប័នសាធារណៈរបស់រដ្ឋដែលទាក់ទងទៅនឹងកិច្ចការរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ជាទូទៅ ការសិក្សាស្រាវជ្រាវតែងតែមានគុណតម្លៃដល់អ្នកសិក្សាគ្រប់រូបលើប្រធានបទ ឬជំនាញដែលខ្លួនជ្រើសរើស មានន័យថាសារៈប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ដំបូងគឺឱ្យអ្នកស្រាវជ្រាវបានយល់ដឹង និងចងចាំបានច្បាស់ ហើយកាន់តែលម្អិតលើប្រធានបទ បន្ទាប់មកវាក៏បានផ្តល់សារៈប្រយោជន៍ជាច្រើនទៀតដល់អ្នកអាន និងសាធារណជនទាំងឡាយ ដែលបានអាននូវស្នាដៃស្រាវជ្រាវនេះ។ សារៈប្រយោជន៍ទាំងនេះ រួមមាន៖

### ក. ប្រយោជន៍សម្រាប់សាកលវិទ្យាល័យ

- សាកលវិទ្យាល័យទទួលបានឯកសារសម្រាប់តម្កល់ទុក។
- និស្សិតបានប្រតិបត្តិតាមទិសដៅរបស់សាកលវិទ្យាល័យក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។
- និស្សិតបានស្វែងយល់កាន់តែច្បាស់ពីក្របខ័ណ្ឌច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងការអនុវត្តសកម្មភាពរបស់រាជការ។

- និស្សិតបានចូលរួមចំណែកដោយផ្ទាល់ក្នុងការជួយពង្រឹងនីត្យានុកូលភាពនៃកិច្ចការរដ្ឋបាល។

**ខ. ប្រយោជន៍សម្រាប់សង្គម និងសាធារណជន**

- មិត្តអ្នកអាន និងសាធារណជនអាចស្វែងយល់បន្ថែមពីទ្រឹស្តីមួយចំនួនពាក់ព័ន្ធក្នុងកិច្ចការស្រាវជ្រាវនេះ
- ទុកជាឯកសារសម្រាប់សាធារណជនទូទៅងាយស្រួលក្នុងការស្រាវជ្រាវកិច្ចការទាំងឡាយណា ដែលទាក់ទងនឹងនីតិរដ្ឋបាល។
- ផ្តល់ជាពុទ្ធិសម្រាប់ប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់នៃសិទ្ធិរវាងខ្លួន និងរាជការទាំងនៅក្នុងស្ថានភាពធម្មតា និងស្ថានភាពកាលៈទេសៈផ្សេងៗទៀត
- បានបង្ហាញពីការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិតាមរយៈភាពដែលមិនអាចខ្វះបាននូវអំពើរបស់រាជការដោយយោងតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។
- បានចូលរួមក្នុងការចង្អុលបង្ហាញកាន់តែច្បាស់នូវទំនាក់ទំនងរវាងរាជការ និងប្រជាពលរដ្ឋតាមរយៈអំពើរបស់រាជការតាមរយៈការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេច។

## ៦. វិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវ

ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវប្រធានបទនេះ គឺធ្វើឡើងដោយប្រើឯកសារសំខាន់ៗដែលជាលិខិតបទដ្ឋានគតិយុត្តមានដូចជា រដ្ឋធម្មនុញ្ញ សន្ធិសញ្ញា ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ពន្ធ័នឹងប្រធានបទ និងដែលនៅជាធរមាន។

ម្យ៉ាងទៀត ក្រៅតែពីសំអាងទៅលើឯកសារដែលជាលិខិតបទដ្ឋានគតិយុត្តហើយ នោះខ្ញុំបាទបានសុំមតិយោបល់ និងការណែនាំពីសាស្ត្រាចារ្យដឹកនាំ និងអ្នកមានបទពិសោធយល់ដឹងច្រើនពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលដើម្បីឱ្យកិច្ចការស្រាវជ្រាវនេះកាន់តែមានគុណភាព។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវក្រោមប្រធានបទ **នីត្យានុកូលភាពនៃកិច្ចការរដ្ឋបាល** នេះត្រូវបានចងក្រងចែកជាប្លង់ដូចខាងក្រោម៖

- **ជំពូកទី១ គោលការណ៍នីត្យានុកូលភាព៖** នៅក្នុងជំពូកនេះបង្ហាញពីរចំណុចធំៗគឺចំណុចទីមួយបង្ហាញអំពី សញ្ញាណទូទៅនៃឋានានុក្រមនៃធម្មនិយាមគតិយុត្តដែលក្នុងចំណុចនេះដែរបកស្រាយលំអិតអំពីលំដាប់ថ្នាក់ក្នុងអង្គនីតិប្បញ្ញត្តិ (រដ្ឋធម្មនុញ្ញ សន្ធិសញ្ញា ច្បាប់សភា គោលការណ៍ទូទៅ និងយុត្តិសាស្ត្រ) និងលំដាប់ថ្នាក់ក្នុងអង្គនីតិប្រតិបត្តិដែលផ្តោតទៅលើថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រីឯចំណុចទីពីរ បង្ហាញពីកាតព្វកិច្ចរបស់រាជការក្រោមវិធានគតិយុត និងសមត្ថកិច្ចជាប់ចំណង។
- **ជំពូកទី២ អំណាចឆន្ទានុសិទ្ធិ និងនីត្យានុកូលភាពនៃអញ្ញត្រកម្ម៖** ជំពូកនេះបង្ហាញ

ពីរចំណុចធំៗគឺទីមួយ សញ្ញាណទូទៅនៃអំណាច ក្នុងចំណុចនេះដែរបង្ហាញពីសញ្ញាណ និយមន័យ និងព្រំដែននៃការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិ។ ចំណែកឯចំណុចទីពីរ នីត្យានុកូលភាពនៃអញ្ញត្រកម្ម ដែលផ្តោតសំខាន់ទៅលើពីរចំណុចគឺ កាលៈទេសៈពិសេសដែលបង្ហាញអំពីទ្រឹស្តីនៃកាលៈទេសៈពិសេស និងលក្ខខណ្ឌ និងរដ្ឋាភិបាលកិច្ចដែលបង្ហាញអំពីកិច្ចការនយោបាយក្នុងប្រទេស និងក្រៅប្រទេស។

# ជំពូកទី១
# គោលការណ៍នីត្យានុកូលភាព

# ជំពូកទី១
# គោលការណ៍នីត្យានុកូលភាព

នីត្យានុកូលភាព គឺជាភាពស្របច្បាប់ ភាពដែលត្រូវច្បាប់។ ការដែលធ្វើផ្ទុយពីភាពនេះ គេហៅថា ធ្វើខុសច្បាប់។

គោលការណ៍នីត្យានុកូលភាព ជាការកំណត់នូវភាពពេញលក្ខណៈច្បាប់របស់រដ្ឋបាលសាធារណៈនៅក្នុងការបម្រើប្រយោជន៍ទូទៅ។[1] ខ្លឹមសារនៃគោលការណ៍នីត្យានុកូលភាព សំដៅដល់អ្វីៗទាំងអស់ត្រូវតែធ្វើឡើងនៅក្រោមច្បាប់។ គោលការណ៍នីត្យានុកូលភាពនេះ រដ្ឋបាលត្រូវតែគោរពវិធានច្បាប់ដាច់ខាត។

ដើម្បីស្វែងយល់ពីភាពស្របច្បាប់នៃអំពើរបស់រាជការតាមរយៈសកម្មភាព ដែលស្តែងឡើងដោយយោងតាមលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដូច្នេះនៅក្នុងជំពូកនេះនឹងធ្វើការបែងចែកជាពីរផ្នែកធំៗរួមមាន៖ សញ្ញាណទូទៅនៃឋានានុក្រមធម្មនិយាមគតិយុត្ត និងសមត្ថកិច្ចជាប់ចំណង។

## ១.១. សញ្ញាណទូទៅនៃឋានានុក្រមធម្មនិយាមគតិយុត្ត

គោលការណ៍ធម្មនិយាមគតិយុត្តនេះ ត្រូវបានរៀបចំឡើងដោយអាជ្ញាធររដ្ឋតាមលំដាប់ពីលើចុះក្រោម។

ប្រភពនៃនីត្យានុកូលភាពមានច្រើន និងមានលំដាប់ថ្នាក់ពីខ្ពស់មកទាប។ វិធានដែលចេញពីប្រភពខ្ពស់ជាប្រភពធម្មនិយាមសម្រាប់វិធានដែលចេញពីប្រភពដែលស្ថិតនៅក្នុងលំដាប់ទាបជាង។ លំដាប់ថ្នាក់នេះចងគ្នាបង្កើតបានជាឋានានុក្រមនៃវិធានគតិយុត្ត[2]។ រាល់កិច្ចការរបស់រាជការត្រូវនៅក្នុងក្របខ័ណ្ឌនេះជាចាំបាច់ បើពុំដូច្នោះទេរាជការច្បាស់នឹងធ្លាក់ទៅក្នុងភាពខុសច្បាប់ដែលតុលាការអាចនឹងចោទប្រកាន់បាន។

### ១.១.១. លំដាប់ថ្នាក់ក្នុងអង្គនីតិប្បញ្ញត្តិ

នៅក្នុងលំដាប់ថ្នាក់ក្នុងអង្គនីតិប្បញ្ញត្តិនេះ រួមមានរដ្ឋធម្មនុញ្ញ សន្ធិសញ្ញា ច្បាប់ គោលការណ៍ទូទៅនៃនីតិ និងយុត្តិសាស្ត្រ។

#### ១.១.១.១. រដ្ឋធម្មនុញ្ញ

**ក. ប្រវត្តិនៃការបង្កើតរដ្ឋធម្មនុញ្ញកម្ពុជា**

អនុលោមទៅតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ដើម្បីដោះស្រាយបញ្ហាកម្ពុជាតាមផ្លូវនយោបាយ និងប្រជាធិបតេយ្យដែលមានខ្មែរបដិបក្ខទាំងបួនក្រុមចុះហត្ថលេខានៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ រៀបរៀងឡើងដោយអង្គការសហប្រជាជាតិ (UN) នៅទីក្រុងប៉ារីសនៃសាធារណរដ្ឋបាលបារាំងហើយមានការចូលរួមពីបណ្តាប្រទេសចំនួនម្ភៃរួមមាន៖ អូស្ត្រាលី ប្រ៊ុយណេដារុយសាឡឹម កម្ពុជា កាណាដា សាធារណរដ្ឋប្រជាមានិតចិន

[1] សៀវភៅនីតិរដ្ឋបាលទូទៅ, សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី៤ ឆ្នាំ២០១៧ ទំព័រទី២១៣

[2] ***ឋានានុក្រមនៃវិធានគតិយុត្ត*** *មានន័យដូចឋានានុក្រមធម្មនិយាមគតិយុត្ត*

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋបារាំង សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋឥណ្ឌូណេស៊ី ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី រាជាណាចក្រថៃឡង់ដ៍ សាធារណរដ្ឋសង្គមនិយមសូវៀត ចក្រភពអង់គ្លេស អៀឡង់ខាងជើង សហរដ្ឋអាមេរិក វៀតណាម និងយូហ្គោស្លាវី ។[3]

នៅចំពោះមុខអគ្គលេខាធិការនៃអង្គការសហប្រជាជាតិក្នុងគោលបំណងថែរក្សា និងការពារអធិបតេយ្យភាព ឯករាជ្យភាព បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដីអព្យាក្រឹត្យភាព និងឯកភាពជាតិរបស់ប្រទេសកម្ពុជា ហើយក៏ដូចជាក្នុងគោលបំណងស្តារឡើងវិញ និងថែរក្សាសន្តិភាពសម្រាប់ប្រជាជាតិកម្ពុជា ការបង្រួបបង្រួមជាតិ និងធានាឱ្យប្រទេសកម្ពុជាប្រើប្រាស់នូវសិទ្ធិស្វ័យសម្រេចតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ។

ដោយបានកក់សម្គាល់ថា ការបង្កើតឡើងនូវក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា (SNC)[4] នៅហ្សាការតានៃប្រទេសឥណ្ឌូណេស៊ី នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩០ ជាអង្គការស្ថាប័នស្របច្បាប់ និងជាប្រភពអំណាចស្របច្បាប់នៅកម្ពុជាតែមួយគត់ ដែលនៅក្នុងដំណាក់កាលទូទាំងសម័យអន្តរកាលរបស់អង្គការសហប្រជាជាតិទាមទារឱ្យបង្កើតអាជ្ញាធរបណ្តោះអាសន្ននៅកម្ពុជា (UNTAC)[5] បណ្តាលឱ្យ SNC អនុលោមទៅតាមកិច្ចព្រមព្រៀងសន្តិភាពត្រូវប្រគល់អំណាចទាំងអស់ដែលចាំបាច់ទៅឱ្យ UNTAC ដើម្បីធានាការអនុវត្តកិច្ចព្រមព្រៀងសន្តិភាពឆ្នាំ១៩៩១ ដោយគិតទាំងអំណាចដែលទាក់ទងនឹងការរៀបចំការបោះឆ្នោតដោយសេរី ត្រឹមត្រូវ ស្មើភាព និងយុត្តិធម៌ ។

UNTAC តំណាងឱ្យអង្គការសហប្រជាជាតិបានធ្វើអន្តរាគមន៍នៅកម្ពុជាចាប់តាំងពីខែមីនា ឆ្នាំ១៩៩២ ដើម្បីរៀបចំឱ្យមានដំណើរការរៀបចំការបោះឆ្នោតដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៣ ដល់ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣ ដោយមានការចូលរួមពីបណ្តាគណបក្សនយោបាយនានាចំនួនម្ភៃ។ ការបោះឆ្នោតនេះ សំដៅជ្រើសរើសសភាធម្មនុញ្ញ[6] ដែលមានភារកិច្ចរៀបចំនូវគម្រោងរដ្ឋធម្មនុញ្ញមួយ និងអនុម័តជាផ្លូវការ និងក្រោយមកទៀតក្លាយខ្លួនជាសភាជាតិដោយស្វ័យប្រវត្តិបន្ទាប់ពីប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនេះ។ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញបានបើកសម្ពោធដាក់ឱ្យ ដំណើរការលើការងាររបស់ខ្លួនក្រោមអធិបតីភាពសម្តេចព្រះបាទនរោត្តមសីហនុ ក្នុងឋានៈជាព្រះប្រធាននៃឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ និងលោកយ៉ាយូស៊ី អាកាស៊ី ប្រមុខ UNTAC។

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញបានបើកសម័យប្រជុំពេញអង្គលើកទីមួយ ដើម្បីបោះឆ្នោតជ្រើសរើសប្រធាន និងអនុប្រធានទី១ និងទី២នៃសភាធម្មនុញ្ញ។ ជាមួយគ្នានេះ សភាធម្មនុញ្ញបានបង្កើតនូវ

---

[3] សៀវភៅរដ្ឋធម្មនុញ្ញកម្ពុជា, បណ្ឌិត កៅ មុយថង បោះពុម្ពលើកទី១ ឆ្នាំ២០០៦ ទំព័រទី៤៥

[4] **(SNC=Supreme National Council)** *សំដៅដល់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា*

[5] **(UNTAC=United Nations Transitional Authority In Cambodia)** *សំដៅដល់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជា។*

[6] ***សភាធម្មនុញ្ញ*** *គឺជាតំណាងរាស្ត្រដែលកើតចេញពីការបោះឆ្នោតមានតួនាទីក្នុងការរៀបចំ និងអនុម័តរដ្ឋធម្មនុញ្ញជំនាន់ថ្មី។*

គណៈកម្មាការអចិន្ត្រៃយ៍មួយដើម្បីធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញដោយអនុលោមទៅតាមមាត្រា២៣ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។ គណៈកម្មការនេះមានសមាសភាពប្រធាន ០១ រូប ដឹកនាំដោយប្រធានសភាធម្មនុញ្ញ ឬ អនុប្រធានសភាធម្មនុញ្ញ បើប្រធានអវត្តមាន អនុប្រធាន ០១រូប សមាជិក ១០រូប សមាជិកបម្រុង ០៨រូប អ្នកជំនាញការ ០៥រូប ។

ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ សភាធម្មនុញ្ញបានអនុម័តលើគម្រោងរដ្ឋធម្មនុញ្ញមួយដែលចែកចេញជា ១៤ជំពូក មាន ១៣៩មាត្រា ដោយមានសំឡេងគាំទ្រ ១១៣សំឡេង អនុប្បវាទ[7] ០២សំឡេង និងប្រឆាំង ០៥ សំឡេង។ ប៉ុន្តែ ក្រោយពីប្រកាសឱ្យប្រើជាផ្លូវការកម្ពុជាបានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់ខ្លួនជាបន្តបន្ទាប់ រហូតមកទល់បច្ចុប្បន្ន រដ្ឋធម្មនុញ្ញកម្ពុជាបានចែកចេញជា ១៧ជំពូក និង ១៦០មាត្រា។

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញបានត្រូវឡាយព្រះហត្ថលេខា និងប្រកាសឱ្យប្រើជាផ្លូវការ ដោយសម្តេចព្រះបាទ នរោត្តម សីហនុ ក្នុងឋានៈជាព្រះប្រមុខរដ្ឋកម្ពុជា និងជាព្រះប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC)។ ចំណែកឯ សភាធម្មនុញ្ញក៏ប្រកាសរំលាយខ្លួនឯងជាស្វ័យប្រវត្តិក្លាយខ្លួនទៅជាសភាជាតិ ដោយគោរពតាមមាត្រា១២ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដែលបានកំណត់ថា ប្រជាជនកម្ពុជាត្រូវមានសិទ្ធិសម្រេចពីអនាគតនយោបាយរបស់ខ្លួនតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ដើម្បីជ្រើសរើសសភាធម្មនុញ្ញមួយ ដែលមានតួនាទីត្រូវព្រាង និងអនុម័តរដ្ឋធម្មនុញ្ញកម្ពុជាមួយថ្មីស្របតាមមាត្រា២៣ រួចត្រូវក្លាយខ្លួនទៅជាសភានីតិប្បញ្ញត្តិដែលត្រូវបង្កើតរដ្ឋាភិបាលកម្ពុជាមួយថ្មី ។

**ខ. និយមន័យ**

រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។[8]

រដ្ឋធម្មនុញ្ញ ជាច្បាប់គ្រឹះ និងជាច្បាប់កំពូលដែលជាទូទៅតែងកំណត់នូវរចនាសម្ព័ន្ធមុខងារជាមូលដ្ឋាននៃរដ្ឋ និងស្ថាប័នរដ្ឋសំខាន់ៗព្រមទាំងកំណត់នូវសិទ្ធិ ព្រមទាំងកាតព្វកិច្ចជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ។[9]

រដ្ឋធម្មនុញ្ញ ជាប្រភពដើមនៃអំណាចដែលកើតចេញមកពីប្រជាពលរដ្ឋជាច្បាប់កំពូលដែលមានឋានៈខ្ពស់បំផុតនៅក្នុងប្រព័ន្ធច្បាប់ផ្ទៃក្នុង និងជាប្រភពនៃលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ។[10]

---

[7] ***អនុប្បវាទ*** *មានន័យថាមិនគាំទ្រ និងមិនប្រឆាំងដោយនៅស្ងៀម។*

[8] មាត្រា១៥២ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាកម្ពុជាឆ្នាំ១៩៩៣

[9] សៀវភៅរដ្ឋធម្មនុញ្ញកម្ពុជា, បណ្ឌិត កៅ មុយថង បោះពុម្ពលើកទី១ ឆ្នាំ២០០៦ ទំព័រទី៥០

[10] សៀវភៅសេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ, បណ្ឌិត ឈុន ណារ៉េត បោះពុម្ពឆ្នាំ២០១៦ ទំព័រទី១២

**គ. ឋានានុក្រម**

គ្រប់រដ្ឋទាំងអស់នៅលើពិភពលោកតែងតែមានច្បាប់គ្រឹះរៀងៗខ្លួន ដើម្បីគ្រប់គ្រងប្រទេសប្រកបដោយនីតិរដ្ឋ។ ច្បាប់គ្រឹះដែលយើងសំដៅនោះ គឺរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេស។ ដោយឡែក ចំពោះកម្ពុជាក៏មិនខុសពីបណ្ដាលប្រទេសនានានៅលើពិភពលោកប៉ុន្មានដែរដោយមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល។

មូលហេតុដែលរដ្ឋធម្មនុញ្ញត្រូវបានគេចាត់ទុកថាជាច្បាប់កំពូលគឺ៖ ទីមួយ ប្រភពរដ្ឋធម្មនុញ្ញចេញពីអំណាចរបស់ប្រជាពលរដ្ឋ និងទីពីរ តាមទ្រឹស្ដីហាន្ស កែលសិន។

**ទី១. ប្រភពរដ្ឋធម្មនុញ្ញចេញពីអំណាចរបស់ប្រជាពលរដ្ឋ**

យោងតាមមាត្រា១៥២ថ្មី នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានបញ្ញត្តិថារដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់ និងសេចក្ដីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។ មាត្រា៥១ថ្មី វាក្យខ័ណ្ឌទី១ ឃ្លាទី២ និងទី៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានបញ្ញត្តិថាប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ដូចបានបញ្ជាក់ខាងលើ អង្គការសហប្រជាជាតិតំណាងដោយអ៊ុនតាក់បានរៀបចំការបោះឆ្នោតជាសកលជ្រើសរើសសភាធម្មនុញ្ញដែលបានផ្ដល់ឱកាសដល់ប្រជាពលខ្មែរមានសិទ្ធិយ៉ាងពេញទីនៅក្នុងការបោះឆ្នោតជ្រើសរើសតំណាងដែលខ្លួនទុកចិត្តដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ដើម្បីចូលរួមក្នុងការតាក់តែង និងអនុម័តរដ្ឋធម្មនុញ្ញ។ ចំណុចនេះបានសឱ្យឃើញថា ប្រភពរដ្ឋធម្មនុញ្ញកើតចេញពីអំណាចរបស់ប្រជាពលរដ្ឋ ពីព្រោះប្រជាពលរដ្ឋជាអ្នកផ្ដល់អំណាចជូនតំណាងរបស់ខ្លួនតាមរយៈការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ដើម្បីបម្រើឆន្ទៈឱ្យខ្លួនក្នុងការចូលរួមតាក់តែង និងអនុម័តរដ្ឋធម្មនុញ្ញ។

**ទី.២. តាមលំនាំហាន្ស កែលសិន (HANS KELSEN)**

ហាន្ស កែលសិន (HANS KELSEN) ជាជនជាតិអូទ្រីសដែលជាអ្នកបង្កើតឋានានុក្រមនៃច្បាប់។ តាមទ្រឹស្ដីរបស់លោក ហាន្ស កែលសិន បានចាត់ថ្នាក់រដ្ឋធម្មនុញ្ញ គឺជាវិធានគតិយុត្តដែលស្ថិតនៅលើកំពូលតារាងនៃសាជីជ្រុង ពីព្រោះលោកចង់បញ្ជាក់ថារដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូល ឬជាច្បាប់គ្រឹះដែលជាលិខិតបទដ្ឋានគតិយុត្តទាំងឡាយត្រូវតែគោរពតាម។

សរុបមក ដោយផ្អែកលើចំណុចទាំងពីរខាងលើនេះ រដ្ឋធម្មនុញ្ញជាប្រភពដើមនៃអំណាចដែលកើតចេញពីប្រជាពលរដ្ឋ ជាច្បាប់កំពូលដែលមានឋានៈខ្ពស់ជាងគេបំផុតក្នុងប្រព័ន្ធច្បាប់នៃកម្ពុជា និងជាប្រភពនៃលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។ ម្យ៉ាងទៀត តាមទ្រឹស្ដីរបស់លោក ហាន្ស កែលសិន បានចាត់ថ្នាក់រដ្ឋធម្មនុញ្ញ គឺជាវិធានគតិយុត្តដែលស្ថិតនៅលើកំពូលតារាងនៃសាជីជ្រុង (PYRAMIDE) ពីព្រោះលោកចង់បញ្ជាក់ថារដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូល ឬជាច្បាប់គ្រឹះដែលលិខិតបទដ្ឋានគតិយុត្តដែលស្ថិតនៅក្រោមត្រូវតែគោរពតាម។ ហេតុដូច្នេះ

ហើយទើបមាត្រា១៥២ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា១៩៩៣ ចាត់ទុករដ្ឋធម្មនុញ្ញជាច្បាប់កំពូល។ ដូច្នេះ ប្រភពរដ្ឋធម្មនុញ្ញជាប្រភពដែលមានឋានៈខ្ពស់បំផុតក្នុងប្រព័ន្ធច្បាប់ផ្ទៃក្នុង។ ប្រភពរដ្ឋធម្មនុញ្ញបង្កើតរដ្ឋធម្មនុញ្ញដែលជាប្រភពធម្មនិយាមគតិយុត្តកំពូល។ ធម្មនិយាមនេះជាវិជានទូទៅ។

**ឃ. ការការពាររដ្ឋធម្មនុញ្ញ**

ដែលហៅថាជាការការពាររដ្ឋធម្មនុញ្ញនោះ គឺមានន័យថារដ្ឋនោះ ត្រូវតែធ្វើយ៉ាងណាឱ្យច្បាប់ បទប្បញ្ញត្តិផ្សេងៗ សេចក្តីសម្រេចរបស់អង្គការរដ្ឋនានា ឱ្យស្របទៅតាមស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។ ការការពាររដ្ឋធម្មនុញ្ញនេះត្រូវធ្វើឡើងតាមរយៈ ការត្រួតពិនិត្យធម្មនុញ្ញភាព។

ការត្រួតពិនិត្យធម្មនុញ្ញភាព គឺសំដៅដល់ការផ្ទៀងផ្ទាត់ ថាតើច្បាប់ទាំងឡាយដែលស្ថិតនៅក្រោមឋានានុក្រមនៃរដ្ឋធម្មនុញ្ញស្របទៅនឹងច្បាប់កំពូលនេះដែរ ឬទេ។ ការត្រួតពិនិត្យធម្មនុញ្ញភាពនេះត្រូវបានធានាដោយក្រុមប្រឹក្សាធម្មនុញ្ញចំពោះច្បាប់ទាំងឡាយដែលចេញដោយសភា។

ប្រសិនបើបណ្តឹងធ្វើឡើងមុនពេលដែលច្បាប់ត្រូវបានប្រកាសឱ្យប្រើ អ្នកដែលមានសិទ្ធិប្តឹងទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញរួមមាន៖ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ (១/១០) ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាមួយភាគបួន (១/៤)ដោយយោងតាមមាត្រា១៤០ថ្មីនៃរដ្ឋធម្មនុញ្ញ។ ផ្ទុយទៅវិញ ក្រោយពេលដែលច្បាប់ប្រកាស ឱ្យប្រើអ្នកដែលមានសិទ្ធិប្តឹងរួមមាន៖ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាមួយភាគបួន (១/៤) តំណាងរាស្ត្រមួយភាគដប់ (១/១០) តុលាការ និងប្រជារាស្ត្រតាមរយៈតំណាងរាស្ត្រ ឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា។[11]

យោងតាមមាត្រា១៤០នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ការត្រួតពិនិត្យធម្មនុញ្ញភាពមានពីរប្រភេទរួមមាន៖

**ទី១. ការត្រួតពិនិត្យធម្មនុញ្ញភាពជាអាទិកាល**

ក្រោយពីរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ អត្ថបទច្បាប់រៀបចំអង្គការ ឬវិសោធនកម្មនៃច្បាប់រៀបចំអង្គការ បទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុង ឬវិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភាត្រូវដាក់ឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យថាតើអត្ថបទច្បាប់ និងបទបញ្ជាផ្ទៃក្នុងទាំងនោះស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

ឧទាហរណ៍៖ នៅក្នុងឆ្នាំ១៩៩៩ ប្រធានរដ្ឋសភាបានស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់រួមមាន៖ ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីការបង្កើតក្រសួង

[11] មាត្រា១៤១ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាកម្ពុជាឆ្នាំ១៩៩៣

ធនធានទឹក និងឧតុនិយម ច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចជាដើម។

**ទី២. ការត្រួតពិនិត្យធម្មនុញ្ញភាពជាបច្ឆាកាល**

រាល់ច្បាប់ ឬបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា ក្រោយពីប្រកាសឱ្យប្រើក៏អាចបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពបានដែរ ។

ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នមួយដែលមានឥទ្ធិពលខ្លាំងក្លាណាស់តាមរយៈការធានាការគោរពរដ្ឋធម្មនុញ្ញ ការបកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ ហើយរដ្ឋសភា ព្រឹទ្ធសភា ក៏ដូចជាស្ថាប័នដទៃទៀតដែលមានក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែគោរពនឹងបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដែលជាច្បាប់គ្រឹះ និងជាច្បាប់កំពូលនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលត្រូវទទួលការធានាយ៉ាងច្បាស់លាស់មួយ ។

**១.១.១.២. សន្ធិសញ្ញា**

**ក. និយមន័យ**

សន្ធិសញ្ញា គឺជាកិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងរវាងរដ្ឋ និងរដ្ឋ ឬរវាងរដ្ឋ និងអង្គការអន្តរជាតិ ឬ រវាងអង្គការអន្តរជាតិ និងអង្គការអន្តរជាតិនៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ហើយស្ថិតនៅក្រោមច្បាប់អន្តរជាតិ។[12]

អនុសញ្ញាទីក្រុងវីយ៉េនស្តីពីច្បាប់សន្ធិសញ្ញាឆ្នាំ១៩៦៩ (Vienna Convention of Law and the Law of Treaties in 1969) បានឱ្យនិយមន័យថា សន្ធិសញ្ញា គឺជាកិច្ចព្រមព្រៀងអន្តរជាតិដែលធ្វើឡើងរវាងរដ្ឋ និងរដ្ឋ នៅក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ហើយនិងស្ថិតនៅក្រោមច្បាប់អន្តរជាតិ។[13]

**ខ. ឋានានុក្រម**

សន្ធិសញ្ញា ជាកិច្ចព្រមព្រៀងរវាងភាគីពីរ ឬច្រើនដែលជាប្រធាននៃច្បាប់អន្តរជាតិសំដៅបង្កើតឱ្យមានឥទ្ធិពលខាងផ្លូវច្បាប់ និងស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ដោយច្បាប់អន្តរជាតិ។ ដូច្នេះ សន្ធិសញ្ញាត្រូវកើតឡើងដោយការស្ម័គ្រចិត្តរវាងគូភាគីទាំងអស់ ក្នុងន័យនេះផងដែរ សន្ធិសញ្ញាអាចត្រូវបានចាត់ទុកជាកិច្ចសន្យាគតិយុត្តដែលមានកម្លាំងអានុភាពអនុវត្តតាមផ្លូវច្បាប់ជាលក្ខណៈបង្ខំចំពោះគ្រប់ភាគីទាំងអស់។[14]

រដ្ឋធម្មនុញ្ញកម្ពុជាមិនបានកំណត់ឋានៈនៃសន្ធិសញ្ញាឱ្យបានច្បាស់លាស់ឡើយ។ ប៉ុន្តែ សម្រាប់ការអនុវត្តជាក់ស្តែង ពេលខ្លះឃើញថា សន្ធិសញ្ញាមានឋានៈស្មើនឹងរដ្ឋធម្មនុញ្ញ ពេលខ្លះទៀតសន្ធិសញ្ញាមាន ឋានៈ

---

[12] សន្ទានុក្រមវិទ្យាសាស្ត្រនយោបាយ និងការទូត ខ្មែរ-អង់គ្លេស-បារាំង បោះពុម្ពឆ្នាំ២០១៤ ទំព័រទី៤៥

[13] សៀវភៅច្បាប់ការទូត, អនុបណ្ឌិត នួន សុធិមន្ត បោះពុម្ពឆ្នាំ២០០៤ ទំព័រទី១១៦

[14] សៀវភៅច្បាប់ការទូត, អនុបណ្ឌិត នួន សុធិមន្ត បោះពុម្ពឆ្នាំ២០០៤ ទំព័រ១១៧

ទាបជាងរដ្ឋធម្មនុញ្ញដោយស្មើនឹងច្បាប់ (សភា) ។

➢ **សន្ធិសញ្ញាមានឋានៈស្មើនឹងរដ្ឋធម្មនុញ្ញ**

យោងតាមមាត្រា៣១ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយដែលទាក់ទងទៅនឹង សិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

មាត្រានេះបានបង្ហាញថា ក្នុងវិស័យសិទ្ធិមនុស្សក្នុងប្រព័ន្ធច្បាប់ខ្មែរជាប្រព័ន្ធឯកនិយម ពីព្រោះរដ្ឋធម្មនុញ្ញ បានបញ្ចូលក្នុងមាត្រារបស់ខ្លួននូវធម្មនិយាមគតិយុត្តអន្តរជាតិ ដែលអាចទទួលការអនុវត្តន៍ដោយផ្ទាល់បាន។ ហើយដោយសារថាជាមាត្រានៃរដ្ឋធម្មនុញ្ញ ដូច្នេះធម្មនិយាមអន្តរជាតិដែលទាក់ទងនឹងសិទ្ធិមនុស្សនេះមានតម្លៃជា ធម្មនុញ្ញដែលធំជាងច្បាប់ផ្ទៃក្នុងដទៃទៀតទាំងអស់។ ដូច្នេះហើយ ធម្មនិយាមអន្តរជាតិ និងរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ក្នុងវិស័យនេះស្ថិតនៅក្នុងរបៀបរបបគតិយុត្តតែមួយគត់។

➢ **សន្ធិសញ្ញាមានឋានៈស្មើនឹងច្បាប់ (សភា)**

ក្រៅពីវិស័យសិទ្ធិមនុស្ស គេសង្កេតឃើញមានមាត្រា២៦ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ បានចែងថា ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិហើយទ្រង់ ប្រទានសច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និង ព្រឹទ្ធសភា។

មាត្រានេះបង្ហាញថា រាល់ការផ្តល់សច្ចាប័នលើសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិសុទ្ធសឹងធ្វើឡើងក្រោមរូប មន្តជាច្បាប់ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមរបស់ព្រះមហាក្សត្រទាំងអស់។ ត្រង់ចំណុចនេះសឱ្យឃើញថា ធម្មនិយាមអន្តរជាតិដែលកើតចេញពីសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិនោះមានតម្លៃត្រឹមតែច្បាប់ ដែលមាន ឋានានុក្រមទាបជាងរដ្ឋធម្មនុញ្ញ ។

សរុបមកផ្អែកតាមមាត្រា៣១ថ្មី និង២៦ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ឃើញថា សន្ធិសញ្ញាដែលចេញពីប្រភពអន្តរជាតិមានលំដាប់ថ្នាក់ពីរគឺៈ ទីមួយ សន្ធិសញ្ញាទាំងឡាយណាដែលទាក់ទងនឹង វិស័យសិទ្ធិមនុស្សមានឋានៈស្មើនឹងរដ្ឋធម្មនុញ្ញដែលធ្វើឱ្យគ្រប់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលស្ថិតនៅក្រោម រដ្ឋធម្មនុញ្ញត្រូវតែគោរពតាមដូចជាការគោរពរដ្ឋធម្មនុញ្ញដែរ និងទីពីរ សន្ធិសញ្ញាដែលស្ថិតនៅក្រៅពីវិស័យសិទ្ធិ មនុស្សមានឋានៈទាបជាងរដ្ឋធម្មនុញ្ញដោយស្មើនឹងច្បាប់ (សភា) ដែលសន្ធិសញ្ញាប្រភេទនេះត្រូវតែគោរព តាមរដ្ឋធម្មនុញ្ញដែលមានឋានៈខ្ពស់ជាងខ្លួន ហើយចំពោះលិខិតបទដ្ឋានគតិយុត្តដែលស្ថិតនៅក្រោមច្បាប់ត្រូវ តែគោរពសន្ធិសញ្ញានេះដែរ។

### ១.១.១.៣. ច្បាប់

#### ក. និយមន័យ

យើងអាចផ្តល់អត្ថន័យច្បាប់ពីរយ៉ាងគឺ៖

ទីមួយក្នុងន័យទូលាយ ច្បាប់ គឺជាវិធានរបស់សង្គមជាតិដែលអាជ្ញាធរមានសមត្ថកិច្ចតាក់តែងឡើងដើម្បីតម្រូវឱ្យប្រជាពលរដ្ឋទាំងអស់ដែលស្ថិតនៅក្រោមអំណាចច្បាប់នោះគោរព និងប្រតិបត្តិតាម។[15]

ទីពីរក្នុងន័យចង្អៀត ច្បាប់ គឺជាវិធានសរសេរដែលមានលក្ខណៈទូទៅ និងអចិន្ត្រៃយ៍ហើយជាវិធានដែលត្រូវបានអនុម័តដោយសភាតាមសេចក្តីស្នើច្បាប់របស់សភា ឬតាមសេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាល និងត្រូវប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ។[16]

#### ខ. ឋានានុក្រម

នៅក្នុងឋានានុក្រមនៃធម្មនិយាមគតិយុត្ត ច្បាប់ស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញ។

ច្បាប់ដែលចេញពីប្រភពនីតិប្បញ្ញត្តិ គេឃើញមានច្បាប់រៀបចំអង្គការ និងច្បាប់ធម្មតា។ នៅក្នុងមាត្រា ១៤០ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មិនបានតម្រូវឱ្យបញ្ជូនច្បាប់ធម្មតាទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញមុននឹងប្រកាសឱ្យប្រើនោះទេ។

ពាក្យថា ច្បាប់រៀបចំអង្គការត្រូវបានប្រើនៅក្នុងរដ្ឋធម្មនុញ្ញមាត្រា១៤៦បានបញ្ជាក់ថាការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវគ្រប់គ្រងដោយច្បាប់រៀបចំអង្គការ និងមាត្រា១៦ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៨ ប៉ុន្តែ លិខិតបទដ្ឋានទាំងពីរខាងលើពុំបានឱ្យនិយមន័យឡើយ។ អ្វីដែលមានចែងគឺថាច្បាប់រៀបចំអង្គការត្រូវតែបញ្ជូនទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញដើម្បីត្រួតពិនិត្យធម្មនុញ្ញភាព។ ច្បាប់រៀបចំអង្គការអាចមានន័យពីរយ៉ាងរួមមាន៖ ទីមួយក្នុងន័យចង្អៀត ច្បាប់រៀបចំអង្គការ ជាច្បាប់ដែលបញ្ជាក់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការទាំងឡាយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ ក្នុងន័យនេះត្រូវចាត់ទុកជាច្បាប់រៀបចំអង្គការដូចជា៖ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាដើម។ ទីពីរក្នុងន័យទូលាយ ច្បាប់រៀបចំអង្គការ គឺជាច្បាប់បំពេញបន្ថែមឱ្យរដ្ឋធម្មនុញ្ញ។

ចំណែកឯច្បាប់ធម្មតា ជាច្បាប់ទាំងឡាយណាដែលត្រូវបានអនុម័តដោយសភាតាមនីតិវិធីបញ្ញត្តិច្បាប់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

[15] សៀវភៅសេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ, បណ្ឌិត ឈុន ណាវ៉េត បោះពុម្ពឆ្នាំ២០១៦ ទំព័រទី២៣៨

[16] សៀវភៅសេចក្តីផ្តើមនៃនីតិកម្ពុជា, Mlle Beatrice BALIVET បោះពុម្ពឆ្នាំ២០០៦ ទំព័រទី៦៥

ថ្វីបើរដ្ឋធម្មនុញ្ញមិនបានចែងថាច្បាប់រៀបចំអង្គការមានឋានៈធំជាងច្បាប់ធម្មតាក៏ដោយ ក៏ច្បាប់នេះជាច្បាប់ដ៏សំខាន់ ដែលត្រូវធ្វើការត្រួតពិនិត្យធម្មនុញ្ញភាពមុននឹងប្រកាសឱ្យប្រើ។ ដូច្នេះ ក្នុងកម្មវត្ថុដូចគ្នាច្បាប់ធម្មតាមិនអាចបំពានច្បាប់រៀបចំអង្គការបានទេ ពីព្រោះការបំពាននេះអាចនាំឱ្យច្បាប់ធម្មតានោះមិនស្របនឹងរដ្ឋធម្មនុញ្ញផងដែរដោយហេតុថា ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាពនៃច្បាប់រៀបចំអង្គការជាមុនរួចហើយ ដើម្បីកុំឱ្យកើតមានការខុសនឹងរដ្ឋធម្មនុញ្ញ។ ម្យ៉ាងទៀត ច្បាប់រៀបចំអង្គការជាអ្នកបង្កើតអង្គការ គឺជាច្បាប់មេ។ ដូច្នេះ ច្បាប់រៀបចំ អង្គការជាប្រភពធម្មនិយាមគតិយុត្តសម្រាប់ច្បាប់ធម្មតា។ នេះមានន័យថា ច្បាប់រៀបចំអង្គការមានឋានៈធំជាងច្បាប់ធម្មតា។

**១.១.១.៤. គោលការណ៍ទូទៅនៃនីតិ និងយុត្តិសាស្ត្រ**

**ក. គោលការណ៍ទូទៅនៃនីតិ**

គោលការណ៍ទូទៅនៃនីតិ គឺជាគោលការណ៍ឥតសរសេរដែលចៅក្រមមិនបានបង្កើតមកទេ តែចៅក្រមជាអ្នករកឃើញនៅក្នុងច្បាប់ធម្មជាតិ ឬយុត្តិធម៌ធម្មជាតិតាមរយៈវិចារណញ្ញាណ។

គោលការណ៍ទូទៅនៃនីតិមានពីរប្រភេទធំៗរួមមាន៖ គោលការណ៍ទូទៅនៃនីតិដែលមានតម្លៃស្មើនឹងរដ្ឋធម្មនុញ្ញ និងគោលការណ៍ទូទៅនៃនីតិដែលមានតម្លៃក្រោមច្បាប់តែខ្ពស់ជាងបទបញ្ញារដ្ឋបាល។ ថ្វីត្បិតតែកម្ពុជាប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិលឡ (Civil Law) ឬប្រព័ន្ធច្បាប់របស់ពួករ៉ូម៉ាំង ដែលជាប្រព័ន្ធច្បាប់ដែលនិយមការចងក្រងច្បាប់ជាក្រម ពោលគឺជាការសរសេរ តែគេពុំអាចបោះបង់វិធានដែលជាប្រភពមិនសរសេរបាននោះឡើយដោយសារតែច្បាប់តែងតែអាចចែងមានចន្លោះប្រហោងខ្លះដែលទាមទារឱ្យចៅក្រមត្រូវតែប្រើវិចារណញ្ញាណក្នុងការដោះស្រាយ។

គោលការណ៍ទូទៅដែលមានតម្លៃស្មើរដ្ឋធម្មនុញ្ញ គឺជាគោលការណ៍ទូទៅដែលមានឋានៈគតិយុត្តនៅថ្នាក់រដ្ឋធម្មនុញ្ញ ពោលគឺជាគោលការណ៍មួយដែលភ្ជាប់ទៅនឹងរដ្ឋធម្មនុញ្ញរបស់រដ្ឋ។ ដូច្នេះគោលការណ៍ទូទៅនេះបង្ខំឱ្យគ្រប់បទបញ្ញារដ្ឋបាល និងច្បាប់ត្រូវតែគោរពតាម។[17] បើយោងទៅតាមទ្រឹស្តីនេះដោយប្រៀបធៀបជាមួយនឹងប្រព័ន្ធច្បាប់កម្ពុជា គេសង្កេតឃើញថា គោលការណ៍ទូទៅប្រភេទនេះគឺជាគោលការណ៍ទូទៅដែលចេញដោយក្រុមប្រឹក្សាធម្មនុញ្ញ ប៉ុន្តែគេពុំទាន់ឃើញមានសេចក្តីសម្រេចណាមួយដែលបានបញ្ជាក់អំពីគោលការណ៍ទូទៅនេះនៅឡើយទេ។

គោលការណ៍ទូទៅដែលមានតម្លៃក្រោមច្បាប់ តែខ្ពស់ជាងបទបញ្ញាគឺជាគោលការណ៍ទូទៅនៃនីតិថ្វីត្បិតតែនៅក្រោមច្បាប់តែអាចបង្ខំឱ្យគ្រប់បទបញ្ញារដ្ឋបាលទាំងអស់ត្រូវគោរពតាម។

[17] សៀវភៅនីតិរដ្ឋបាលទូទៅ, សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី៤ ឆ្នាំ២០១៧ ទំព័រទី២១១

**ខ. យុត្តិសាស្ត្រ**

យុត្តិសាស្ត្រ ជាវិធានដែលចេញពីការអនុវត្តរបស់តុលាការមានន័យគឺជាសេចក្តីសម្រេចរបស់តុលាការ។ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាបើសិនជាគេនិយាយអំពីយុត្តិសាស្ត្រគឺ ជាសេចក្តីសម្រេចរបស់តុលាការកំពូល និង ក្រុមប្រឹក្សាធម្មនុញ្ញ។

យុត្តិសាស្ត្រមានឋានានុក្រមទាបជាងគោលការណ៍ទូទៅនៃនីតិ។

ចំពោះយុត្តិសាស្ត្រដែលជាសេចក្តីសម្រេចរបស់តុលាការគឺពុំសូវមាននោះទេពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាល។ ដោយឡែងចំពោះក្រុមប្រឹក្សាធម្មនុញ្ញគេឃើញមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៨ ដែលបញ្ជាក់ថាសេចក្តីប្រកាសព័ត៌មានមិនមែនជាសចក្តីសម្រេចរដ្ឋបាលថ្មីឡើយ។

**១.១.២. លំដាប់ថ្នាក់ក្នុងអង្គនីតិប្រតិបត្តិ**

**១.១.២.១. ថ្នាក់ជាតិ**

**ក. ព្រះរាជក្រឹត្យ**

**ចំណុចទី១. និយមន័យ**

ព្រះរាជក្រឹត្យ គឺជាសេចក្តីសម្រេចដែលចេញដោយព្រះមហាក្សត្រតាមសំណើររបស់នាយករដ្ឋមន្ត្រី។[18]

យោងតាមនិយមន័យខាងលើ ហាក់ដូចជាព្រះមហាក្សត្រមានអំណាចក្នុងការត្រាស់បង្គាប់ក្នុងសេចក្តីសម្រេចតាមរយៈព្រះរាជក្រឹត្យ។ នៅក្នុងចំណុចនេះ បានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងមាត្រា៧ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានចែងថា ព្រះមហាក្សត្រកម្ពុជាទ្រង់គ្រងរាជ្យសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចទេ។ រាល់សេចក្តីសម្រេចធ្វើបទបញ្ជាជាភារកិច្ចរបស់រាជរដ្ឋាភិបាលដែលគេហៅថា គណៈរដ្ឋមន្ត្រី។ រដ្ឋធម្មនុញ្ញតម្រូវឱ្យព្រះមហាក្សត្រផ្តល់នីត្យានុកូលភាពតាមរយៈព្រះរាជក្រឹត្យដល់រាល់បញ្ជា ដែលត្រូវបានសម្រេចដោយគណៈរដ្ឋមន្ត្រី ហើយដែលមានវិសាលភាពទូលំទូលាយដែលពាក់ព័ន្ធនឹងអង្គការកំពូលនៃនីតិប្រតិបត្តិ។

**ចំណុចទី២. ប្រភេទព្រះរាជក្រឹត្យ**

ព្រះរាជក្រឹត្យចែកចេញជាពីរប្រភេទរួមមាន៖ ព្រះរាជក្រឹត្យបទបញ្ជា និងព្រះរាជក្រឹត្យឯកត្តភូត។

**ទី១. ព្រះរាជក្រឹត្យបទបញ្ជា**

ព្រះរាជក្រឹត្យបទបញ្ជា ជាប្រភេទព្រះរាជក្រឹត្យដែលចេញសម្រាប់អនុវត្តតាមច្បាប់ដែលតម្រូវឱ្យចេញបទបញ្ជា និងព្រះរាជក្រឹត្យដែលចេញបទបញ្ជាសម្រាប់អនុវត្តកិច្ចការទូទៅ។

ចំពោះចំណុចនេះ ជាគោលការណ៍វាអាស្រ័យទៅលើច្បាប់ជាអ្នកកំណត់ថាត្រូវធ្វើបទបញ្ជាសម្រាប់

[18] ឯកសារស្តីពីចំណេះដឹង ការងាររដ្ឋបាល កិច្ចការលេខាធិការ និងបណ្ណាសារដ្ឋាន, សាស្ត្រាចារ្យ សំ សារ៉ាក់ បោះពុម្ពឆ្នាំ២០១១ ទំព័រទី៤៧

អនុវត្តច្បាប់នោះតាមរយៈព្រះរាជក្រឹត្យ ឬយ៉ាងណា។

ឧទាហរណ៍៖ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៤ មាត្រា៣ ចែងថា ក្របខ័ណ្ឌទាំងឡាយនៃអ្នករាជការត្រូវកំណត់ដោយលក្ខន្តិកៈដោយឡែកតាមរយៈព្រះរាជក្រឹត្យ ។ ដូច្នេះ គេត្រូវធ្វើព្រះរាជក្រឹត្យសម្រាប់លក្ខន្តិកៈដោយឡែក។[19] ក្នុងការអនុវត្តន៍មាត្រា៣នេះ យើងអាចរាប់បាន៖

- ព្រះរាជក្រឹត្យលេខជស/រកត/០៣០០/១៦៦ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ស្តីពីការបង្កើតលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល (មុខងារសាធារណៈ)។
- ព្រះរាជក្រឹត្យលេខនស/រកត/០៤០០/០៥៦ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០០០ ស្តីពីការបង្កើតលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ (មុខងារសាធារណៈ)។
- ព្រះរាជក្រឹត្យលេខនស/រកត/០៥០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីការបង្កើតលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។
- ព្រះរាជក្រឹត្យលេខនស/រកត/០៥០០/០៩៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ ស្តីពីការបង្កើតលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល (ក្រសួងមហាផ្ទៃ)។
- ព្រះរាជក្រឹត្យលេខនស/រកត/០៥០០/០៩៧ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ ស្តីពីការបង្កើតលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌអនុរក្សពន្ធនាគារ (ក្រសួងមហាផ្ទៃ)។ល។

ក្នុងការអនុវត្តជាក់ស្តែង យើងបានសង្កេតឃើញម្យ៉ាងទៀតថា មានព្រះរាជក្រឹត្យខ្លះមិនមែនជាព្រះរាជក្រឹត្យដែលច្បាប់តម្រូវចាំតែម្តងនោះទេ តែជាព្រះរាជក្រឹត្យដែលគេប្រើទម្រង់ដើម្បីចេញបទបញ្ញាដែលមានវិសាលភាពទូលំទូលាយ ហើយដែលពាក់ព័ន្ធនឹងអង្គការកំពូលខ្លះក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។

ឧទាហរណ៍៖ ព្រះរាជក្រឹត្យលេខនស/រកត/០២-៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីដ្ឋាន និងរៀបចំតំបន់អង្គរហៅថា អាជ្ញាធរអប្សរា ដែលជាគ្រឹះស្ថានសាធារណៈមួយប្រកបដោយបុគ្គលភាពគតិយុត្តមានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ។

ព្រះរាជក្រឹត្យនេះមានយោងទៅច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី ដែលច្បាប់នេះពុំបានចែងអំពីការបង្កើតគ្រឹះស្ថានសាធារណៈថាត្រូវធ្វើតាមព្រះរាជក្រឹត្យសោះ។ មាត្រា១ វាក្យខ័ណ្ឌទី១ ក្រោយពីមាន

[19] ***លក្ខន្តិកៈដោយឡែក*** *ជាវិធានសម្រាប់គ្រប់គ្រងរដ្ឋបាលសាធារណៈគ្រប់គ្រងមន្ត្រីរាជឱ្យចំទិសដៅ និងដើម្បីធានាវិស័យមុខងារសាធារណៈរបស់រដ្ឋប្រព្រឹត្តទៅស្របតាមគោលការណ៍នៃការបង្កើតក្របខ័ណ្ឌនីមួយៗ និងរៀបចំអាជីពមន្ត្រីរាជការឱ្យស្របតាមបទប្បត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។*

ការកែប្រែមក វាត្រូវបានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសឱ្យប្រើដោយព្រះមហាក្សត្រតាមរយៈព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី បានចែងថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជាអង្គការនីតិប្រតិបត្តិមានភារកិច្ចកំណត់ និងអនុវត្តយោបាយស្របតាមគោលការណ៍ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។ រាជរដ្ឋាភិបាលធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការអ្វីដែលជាសមត្ថកិច្ចរបស់អង្គការនីតិប្បញ្ញត្តិ និងអង្គការតុលាការ។

ដោយហេតុថារដ្ឋធម្មនុញ្ញមិនបានចែងឱ្យអស់ថាកិច្ចការអ្វីខ្លះដែលជាសមត្ថកិច្ចរបស់អង្គការនីតិប្បញ្ញត្តិនោះ រាជរដ្ឋាភិបាលក៏មានលទ្ធភាពយ៉ាងទូលាយក្នុងការពង្រីកទីលានសមត្ថកិច្ចរបស់ខ្លួន។ ក្នុងន័យនេះ ការបង្កើតអាជ្ញាធរអប្សរាអាចស្ថិតនៅក្នុងចំណោមកិច្ចការទូទៅរបស់រដ្ឋដែលជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល។

ប៉ុន្តែបច្ចុប្បន្ននេះ គ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ត្រូវបង្កើតដោយអនុក្រឹត្យ តាមរយៈសំណើរួមរបស់ក្រសួងស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[20]

ដូច្នេះនៅក្នុងព្រះរាជក្រឹត្យបទបញ្ជាឃើញមាន ព្រះរាជក្រឹត្យដែលអនុវត្តតាមច្បាប់តម្រូវឱ្យចេញបទបញ្ជា និងព្រះរាជក្រឹត្យដែលចេញបទបញ្ជាយោងតាមព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីក្នុងក្របខ័ណ្ឌ កិច្ចការទូទៅរបស់រដ្ឋ។

**ទី.២. ព្រះរាជក្រឹត្យឯកត្តភូត**

ព្រះរាជក្រឹត្យឯកត្តភូតមានពីរបែបគឺ៖ ព្រះរាជក្រឹត្យចាត់តាំង និងព្រះរាជក្រឹត្យតែងតាំង។

- **ព្រះរាជក្រឹត្យចាត់តាំង**

រដ្ឋធម្មនុញ្ញកម្ពុជាបានចែងថាតាមសេចក្តីស្នើពីប្រធានដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភាព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រនៃគណបក្ស ដែលឈ្នះឆ្នោតឱ្យបង្កើតរាជរដ្ឋាភិបាល។[21] ព្រះមហាក្សត្រប្រើព្រះរាជសិទ្ធិនេះដោយទ្រង់ចេញព្រះរាជក្រឹត្យចាត់តាំង។ នេះជាសិទ្ធិផ្ទាល់របស់ព្រះមហាក្សត្រដែលរដ្ឋធម្មនុញ្ញបានថ្វាយព្រះអង្គក្នុងលក្ខខណ្ឌខាងលើ។

ឧទាហរណ៍៖ ព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ព្រះរាជក្រឹត្យនេះជាព្រះរាជក្រឹត្យចាត់តាំង។ ចាត់តាំង ពាក្យនេះមានន័យថាព្រះមហាក្សត្រទ្រង់ចង្អុល

---

[20] មាត្រា៦ កថាខណ្ឌទី១ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល, លេខនស/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥

[21] មាត្រា១១៩ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជាឆ្នាំ១៩៩៣

វរជនសម្រាប់ធ្វើជានាយករដ្ឋមន្ត្រីទៅរដ្ឋសភាដើម្បីសុំសេចក្ដីទុកចិត្តពីរដ្ឋសភា។ វរជននោះនៅមិនទាន់ទៅជានាយករដ្ឋមន្ត្រីនៅឡើយទេក្នុងពេលចាត់តាំងនេះ។ នឹងទៅជានាយករដ្ឋមន្ត្រីបាន លុះត្រាតែមានព្រះរាជក្រឹត្យតែងតាំង ក្រោយពីមានការបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តតាមមតិភាគច្រើនពីរភាគបី (២/៣) នៃសមាជិករដ្ឋសភាទាំងមូល ប៉ុន្តែ ក្រោយពីធ្វើវិសោធនកម្មសំឡេងបោះឆ្នោតផ្ដល់សេចក្ដីទុកចិត្តត្រឹមតែភាគច្រើនដាច់ខាត (៥០%+១) នៃសមាជិករដ្ឋសភាទាំងមូលលើវរជននោះជាមួយសមាជិកទាំងអស់នៃគណៈរដ្ឋមន្ត្រី។

ព្រះរាជក្រឹត្យចាត់តាំងក៏មាននៅក្នុងករណីនៃមាត្រា១០០ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ដែរ។ មាត្រានេះចែងថា សមាជិកព្រឹទ្ធសភាចំនួនពីររូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ។ សមាជិកចាត់តាំងនេះ នឹងទៅជាសមាជិកព្រឹទ្ធសភាពេញសិទ្ធិ នៅពេលត្រូវបានព្រឹទ្ធសភាប្រកាសសុពលភាពដូចមានចែងក្នុងមាត្រា១០៦ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣។ ដូច្នេះព្រះរាជក្រឹត្យចាត់តាំងមានតែក្នុងករណីនៃមាត្រា១១៩ថ្មី និងមាត្រា១០០ថ្មី ប៉ុណ្ណោះ។

- **ព្រះរាជក្រឹត្យតែងតាំង**

ការប្រើពាក្យព្រះរាជក្រឹត្យតែងតាំងនៅត្រង់នេះដើម្បីសម្រួលក្នុងការហៅដែលសំដៅទៅលើព្រះរាជក្រឹត្យតែងតាំង ព្រះរាជក្រឹត្យផ្លាស់ប្ដូរ ព្រះរាជក្រឹត្យបញ្ចប់ភារកិច្ច ឬព្រះរាជក្រឹត្យដក។ នៅក្នុងការអនុវត្ត ឃើញថាព្រះរាជក្រឹត្យតែងតាំងចេញតាមរយៈ៖

មាត្រា២១ នៃរដ្ឋធម្មនុញ្ញចែងថាតាមសេចក្ដីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្ថលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្ដូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព។

ក្រៅពីរដ្ឋធម្មនុញ្ញ គេក៏ឃើញមានមាត្រា៩ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈមន្ត្រី បានបញ្ជាក់បន្ថែមទៀតថាសមាជិករាជរដ្ឋាភិបាលទាំងអស់ត្រូវតែងតាំងដោយព្រះរាជក្រឹត្យក្រោយពីបានសេចក្ដីអនុម័តទុកចិត្តពីរដ្ឋសភា។ មាត្រា២៣ នៃច្បាប់នេះក៏បានចែងមួយអន្លើទៀតថា នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្ដូរ បញ្ចប់ភារកិច្ច ដោយព្រះរាជក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធា ដូចជា៖ ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី អគ្គលេខាធិការរាជរដ្ឋាភិបាល អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ឬមុខតំណែងប្រហាក់ប្រហែល អភិបាលរាជធានី ខេត្ត ឯកអគ្គរាជទូត ឬមុខតំណែងប្រហាក់ប្រហែល ប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងនាយអគ្គសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ។

មុខងារ និងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិចាប់ពី

ថ្នាក់ឧត្តមសេនីយ៍ឡើងទៅត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រីស្របតាមបទប្បញ្ញត្តិជាធរមាន។

រាល់ព្រះរាជក្រឹត្យមិនមែនសុទ្ធតែត្រូវមានសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ទើបស្របនឹងមាត្រា២៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ នោះទេ។

គេសង្កេតឃើញថា មានព្រះរាជក្រឹត្យយ៉ាងច្រើនដែលព្រះមហាក្សត្រទ្រង់ឡាយព្រះហត្ថលេខាដោយគ្មានសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី។ ព្រះរាជក្រឹត្យបែបនេះមានពីរប្រភេទគឺៈ ទីមួយប្រភេទដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់ និងទីពីរប្រភេទដែលគ្មានចែងក្នុងរដ្ឋធម្មនុញ្ញនិងច្បាប់។

**ប្រភេទទី១ ៖** ព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ក្រោយមានការបោះឆ្នោតទុកចិត្តរបស់រដ្ឋសភា, ព្រះរាជក្រឹត្យតែងតាំងសមាជិករាជរដ្ឋាភិបាលក្រោយមានការបោះឆ្នោតទុកចិត្តរបស់រដ្ឋសភា, ព្រះរាជក្រឹត្យតែងតាំងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ, ព្រះរាជក្រឹត្យតែងតាំងចៅក្រមផ្នែកយុត្តាធិការតាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម, ព្រះរាជក្រឹត្យតែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន និងអនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា ហើយនិងសមាជិកដទៃទៀតនៃព្រឹទ្ធសភា ។ល។ តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហត្ថលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ។

**ប្រភេទទី២៖** ប្រភេទនៃព្រះរាជក្រឹត្យនេះ មាននៅក្នុងការតែងតាំងបរមងារឥស្សរជន និងឋានៈ ក្នុងព្រះរាជវង្សានុវង្ស។ ព្រះរាជបុព្វសិទ្ធិដែលអនុញ្ញាតឱ្យព្រះមហាក្សត្រចេញព្រះរាជក្រឹត្យប្រភេទនេះគ្មានចែងក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងលិខិតបទដ្ឋានណាសោះឡើយ។ ឧទាហរណ៍ ព្រះរាជក្រឹត្យស្តីពីការផ្តល់គោរមងារ ឬគ្រឿងឥស្សរយសជាដើម។

**ចំណុចទី៣. ឋានានុក្រម**

នៅក្នុងឋានានុក្រមនៃធម្មនិយាមគតិយុត្ត ព្រះរាជក្រឹត្យបទបញ្ជាត្រូវស្របនឹងព្រះរាជក្រមដែលជាប្រភពធម្មនិយាមខ្ពស់ជាង និងត្រូវគោរពរដ្ឋធម្មនុញ្ញផងដែរ។ ព្រះរាជក្រឹត្យបទបញ្ជា ជាប្រភពធម្មនិយាមរបស់ព្រះរាជក្រឹត្យឯកត្តភូត និងអនុក្រឹត្យបទបញ្ជា។

**ខ. អនុក្រឹត្យ**

**ចំណុចទី១. និមយមន័យ**

អនុក្រឹត្យ គឺជាទម្រង់នៃបទបញ្ជាដែលចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី។

ដូចបានដឹងហើយថាព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី គឺជាប្រភពធម្មនិយាមសម្រាប់ឱ្យ

រាជរដ្ឋាភិបាលចេញបទបញ្ជា ឬសេចក្តីសម្រេចឯកត្តភូតតាមរយៈព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រដូចបានបកស្រាយខាងលើ ហើយនិងតាមរយៈអនុក្រឹត្យរបស់នាយរដ្ឋមន្ត្រី។

នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ គេពុំឃើញមានចែងអំពីអំណាចចេញបទបញ្ជារបស់នាយករដ្ឋមន្ត្រីទេ គឺមានតែនៅក្នុងព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីនោះតែប៉ុណ្ណោះ។

**ចំណុចទី២. ប្រភេទអនុក្រឹត្យ**

អនុក្រឹត្យចែកចេញជាពីរប្រភេទមាន អនុក្រឹត្យបញ្ជា និងឯកត្តភូត។

❖ **អនុក្រឹត្យបទបញ្ជា**

យោងតាមមាត្រា៤ ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី បានចែងថា រាជរដ្ឋាភិបាលធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋលើកលែងតែកិច្ចការអ្វីដែលជាសមត្ថកិច្ចរបស់អង្គការនីតិប្បញ្ញត្តិ និងអង្គការតុលាការ។

ឃ្លានេះអាចឱ្យយល់បានថា រាជរដ្ឋាភិបាលមានសិទ្ធិចេញបទបញ្ជាអនុវត្តច្បាប់ ហើយនិងបទបញ្ជាផ្សេងទៀត ដែលទាក់ទងនឹងកិច្ចការទូទៅរបស់រដ្ឋដែលពុំមែនជាកិច្ចការក្នុងសមត្ថកិច្ចរបស់រដ្ឋសភា ព្រឹទ្ធសភា និងតុលាការ។

ចំពោះបទបញ្ជាអនុវត្តច្បាប់ គឺវាអាស្រ័យលើច្បាប់សភាកំណត់ទុកឱ្យជាមុនថាត្រូវធ្វើព្រះរាជក្រឹត្យ ឬធ្វើអនុក្រឹត្យ។ ច្បាប់ជាច្រើនណាស់ដែលចង្អុលឱ្យធ្វើអនុក្រឹត្យដើម្បីចេញបទបញ្ជាអនុវត្ត។

ឧទាហរណ៍៖ មាត្រា៣៩នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ២០១៨ បានចែងថា ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងចាប់ពីថ្នាក់នាយកដ្ឋានឡើងត្រូវកំណត់ដោយអនុក្រឹត្យ។

ចំពោះបទបញ្ជាដែលអាចចេញអនុក្រឹត្យក្នុងក្របខ័ណ្ឌនៃការដឹកនាំកិច្ចការទូទៅរបស់រដ្ឋនោះ អនុក្រឹត្យនេះមានច្រើន។ គេមិនអាចដឹងអំពីព្រំដែនពិតប្រាកដសម្រាប់អនុក្រឹត្យប្រភេទនេះទេ។ ក្រៅអំពីវិស័យរបស់បទបញ្ជាដែលត្រូវចេញតាមរយៈព្រះរាជក្រឹត្យដូចដែលបានបកស្រាយខាងលើមកហើយនោះ បទបញ្ជាដែលអាចចេញតាមអនុក្រឹត្យមិនត្រូវឱ្យប៉ះពាល់វិស័យរបស់ច្បាប់ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញទេដូចជា៖ ក្រុមប្រឹក្សារាជសម្បត្តិ ឧត្តមក្រុមប្រឹក្សាការពារជាតិ សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ សិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច សិទ្ធិធ្វើកូដកម្ម និងបាតុកម្ម សិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ សញ្ជាតិខ្មែរ បត្យាប័ន ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព។ល។ ក្រៅពីបញ្ជីនេះ នៅមានវិស័យរបស់ច្បាប់ខ្លះទៀតដែលមានចែងក្នុងច្បាប់ផ្សេងៗ។

❖ **អនុក្រឹត្យឯកត្តភូត**

ដូចបានដឹងហើយថា សេចក្តីសម្រេចឯកត្តភូតអាចធ្វើឡើងតាមរយៈទម្រង់ព្រះរាជក្រឹត្យ។ ដូចគ្នាដែរ គេឃើញថាសេចក្តីសម្រេចឯកត្តភូតក៏អាចធ្វើឡើងតាមរយៈទម្រង់ជាអនុក្រឹត្យដែលគេហៅថាអនុក្រឹត្យឯកត្តភូត។

មាត្រា២៤ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី បានចែងថានាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិដែលមិនមានចែងក្នុងមាត្រា២៣ លើកលែងតែមន្ត្រីដែលមានចែងក្នុងកថាខណ្ឌទី១ មាត្រា៤៦ នៃច្បាប់នេះ។ មាត្រា៤៦ កថាខណ្ឌទី១ចែងថា រដ្ឋមន្ត្រីមានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានចាប់ពីប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ និងថ្នាក់វរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ។ យោងតាមមាត្រា២៤ និងមាត្រា៤៦ ខាងលើនេះបានបង្ហាញថា នាយករដ្ឋមន្ត្រីមានសិទ្ធិចេញអនុក្រឹត្យតែងតាំង អនុក្រឹត្យផ្លាស់ប្តូរ និងអនុក្រឹត្យបញ្ចប់ ភារកិច្ច ចំពោះមន្ត្រីរាជរាជការជាន់ខ្ពស់ស៊ីវិល ដែលមិនត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។ អនុក្រឹត្យទាំងនោះជាអនុក្រឹត្យឯកត្តភូត។ អនុក្រឹត្យឯកត្តភូតក៏មានចេញចំពោះបុគ្គលចំឈ្មោះផ្សេងទៀតក្រៅពីពួកមន្ត្រីរាជការដូចជា ការជូនមេដាយប្រភេទចម្រុះ ដល់សប្បុរសជនដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនក្នុងវិស័យស្ថាបនាជាតិ។

**ចំណុចទី៣. ឋានានុក្រម**

នៅក្នុងឋានានុក្រមនៃធម្មនិយាមគតិយុត្តអនុក្រឹត្យបទបញ្ជាគឺត្រូវស្ថិតនៅក្រោមព្រះរាជក្រឹត្យបទបញ្ជា។ ពីព្រោះឋានៈអ្នកដែលចេញព្រះរាជក្រឹត្យគឺព្រះមហាក្សត្រ ឬប្រមុខរដ្ឋស្តីទី ខ្ពស់ជាងឋានៈនាយករដ្ឋមន្ត្រីដែលជាអ្នកចេញអនុក្រឹត្យ។ ដូច្នេះ ព្រះរាជក្រឹត្យ គឺជាប្រភពធម្មនិយាម សម្រាប់អនុក្រឹត្យ។ សរុបមក អនុក្រឹត្យបទបញ្ជាត្រូវស្របនឹងព្រះរាជក្រឹត្យបទបញ្ជា ព្រះរាជក្រម ហើយនិងរដ្ឋធម្មនុញ្ញដែលជាមានឋានៈធំជាង។ អនុក្រឹត្យបទបញ្ជា ជាប្រភពធម្មនិយាមសម្រាប់អនុក្រឹត្យឯកត្តភូត និងប្រកាសបទបញ្ជា។

**គ. ប្រកាស**

**ចំណុចទី១. និយមន័យ**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ពុំមានចែងអំពីការធ្វើប្រកាសទេ។ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីឆ្នាំ២០១៨ ឃើញមាននិយាយអំពីប្រកាសត្រង់មាត្រា៣៩, ៤៦ និង៤៧។

មាត្រា៣៩ កថាខណ្ឌទី៣ ចែងថា ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាស។ មាត្រា៤៦ កថាខណ្ឌទី២ ចែងថា រដ្ឋមន្ត្រីមានសិទ្ធិតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ តាមបែបបទនីតិវិធីជាធរមានដោយប្រកាសចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន

និងថ្នាក់ប្រហាក់ប្រហែល និងថ្នាក់វរសេនីយ៍នៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ។

មាត្រា៤៧ កថាខណ្ឌទី១ ចែងថា រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាស សេចក្ដីសម្រេច សារាចរ និង សេចក្ដីណែនាំ។ យោងតាមមាត្រាទាំងបីខាងលើនេះឃើញថាប្រកាសជាសេចក្ដីសម្រេចឯកត្តភូត ឬបទបញ្ញា ដែលចេញដោយរដ្ឋមន្ត្រីដែលជាសមាជិករដ្ឋាភិបាលក្នុងមុខតំណែងជាប្រធានស្ថាប័ន។[22] សមាជិកទាំងឡាយ នៃរាជរដ្ឋាភិបាលដែលដឹកនាំគ្រប់គ្រងក្រសួងហៅថា រដ្ឋមន្ត្រី។[23]

**ចំណុចទី២. ប្រភេទប្រកាស**

តាមនិយមន័យខាងលើនេះ គេបែងចែកប្រកាសជាពីរប្រភេទគឺ៖ ប្រកាសបទបញ្ញា និងប្រកាសឯកត្តភូត។

➢ **ប្រកាសបទបញ្ញា**

មាត្រា៤៦ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីឆ្នាំ២០១៨ចែងថា រដ្ឋមន្ត្រីមានសិទ្ធិ ចេញប្រកាស សេចក្ដីសម្រេច សារាចរ និងសេចក្ដីណែនាំ។ ប្រកាស សេចក្ដីសម្រេច សារាចរ ឬសេចក្ដីណែនាំ របស់ក្រសួងមិនអាចចែងអំពីអ្វីដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រសួងនោះទេ ហើយក៏ពុំអាចមានទំនាស់ ជាមួយលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលឡើយ។

មាត្រា៤៦ នេះបានបង្ហាញថា រដ្ឋមន្ត្រីនៃសមាជិករាជរដ្ឋាភិបាលដែលជាប្រធានស្ថាប័នមានសិទ្ធិចេញបទ បញ្ញាក្នុងទម្រង់ជាប្រកាសបានតែនៅក្នុងលក្ខខណ្ឌពីរយ៉ាងគឺ៖ ទីមួយក្នុងវង្វង់សមត្ថកិច្ចរបស់ស្ថាប័ន និង ទីពីរ ក្នុងលក្ខខណ្ឌមិនត្រូវឱ្យមានទំនាស់ខុសផ្ទុយនឹងព្រះរាជក្រម ព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

➢ **ប្រកាសឯកត្តភូត**

មាត្រា៤៦ វាក្យខ័ណ្ឌទី២ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រីបានចែងថា រដ្ឋមន្ត្រីមាន សិទ្ធិតែងតាំង ផ្លាស់ប្ដូរ និងបញ្ចប់ភារកិច្ចមន្ត្រីក្រោមឱវាទតាមបែបបទនីតិវិធីជាធរមានដោយប្រកាសចាប់ពីថ្នាក់ ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល និងថ្នាក់ក្រោមវរសេនីយ៍នៃកងយោធពលខេមរភូមិន្ទ និង នគរបាលជាតិ។

យោងតាមមាត្រា៤៦ នេះយើងឃើញថា ប្រកាសឯកត្តភូតមាន៖ ប្រកាសតែងតាំង ប្រកាសផ្លាស់ប្ដូរ និងប្រកាសបញ្ចប់ភារកិច្ចដល់មន្ត្រីរាជការដែលមិនត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ និងអនុក្រឹត្យ។ ក្រៅអំពី ចំពោះមន្ត្រីរាជការ សេចក្ដីសម្រេចឯកត្តភូតតាមប្រកាសមានច្រើនទៀតក្នុងវង្វង់សមត្ថកិច្ចរបស់ស្ថាប័ននីមួយៗ ដូចជា៖ ប្រកាសអនុញ្ញាត ប្រកាសដកអាជ្ញាប័ណ្ណ និងប្រកាសតែងតាំងគណៈកម្មការផ្សេងៗជាដើម។

---

[22] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពឆ្នាំ២០០៦ ទំព័រទី១១៧

[23] មាត្រា៣១ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

**ចំណុចទី៣. ឋានានុក្រម**

នៅក្នុងឋានានុក្រមនៃធម្មនិយាមគតិយុត្តប្រកាសបទបញ្ញាត្រូវស្របនឹងអនុក្រឹត្យបទបញ្ញា ព្រះរាជក្រឹត្យបទបញ្ញា ព្រះរាជក្រម និងរដ្ឋធម្មនុញ្ញ។ ប្រកាសបទបញ្ញាជាប្រភពធម្មនិយាមរបស់ប្រកាសឯកត្តភូត និងដីកាបទបញ្ញា។

**១.១.២.២. ថ្នាក់ក្រោមជាតិ**

**ក. ដីកា**

យោងតាមព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា៥៣ កថាខណ្ឌទី២ បានចែងថា ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនតាមការធ្វើ សេចក្តីសម្រេចដើម្បីដាក់ចេញនូវដីកាតាមការចាំបាច់។ យោងតាមព្រះរាជក្រមលេខនស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ស្តីពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា៤៨ កថាខណ្ឌទី២ បានចែងថា អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌ តួនាទី មុខងារ និងអំណាចរបស់ខ្លួន។ ដូច្នេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជាគេឃើញដីកាត្រូវបានអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិរួមមានៈ ទីមួយ ដីការាជធានី/ខេត្ត ទីពីរ ដីកាក្រុង/ ស្រុក/ខណ្ឌ និងទីបី ដីកាឃុំ/សង្កាត់។

**ចំណុចទី១. និយមន័យ**

ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលអនុម័តដោយក្រុមប្រឹក្សាក្នុងព្រំដែននៃសិទ្ធិអំណាចរបស់ខ្លួនសម្រាប់អនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[24]

ដីកា គឺជាប្រភេទលិខិតបទដ្ឋានគតិយុត្តដែលដាក់ចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។[25]

ដីកា គឺជាវិធានខាងផ្លូវច្បាប់ដែលបានអនុម័តដោយក្រុមប្រឹក្សា។[26]

**ចំណុចទី២. ប្រភេទដីកា**

ដីកាមានពីរប្រភេទ គឺដីកាដែលមានលក្ខណៈជាបទបញ្ញាទូទៅ និងដីកាដែលមានលក្ខណៈឯកត្តភូត។

- **ដីកាដែលមានលក្ខណៈជាបញ្ញាទូទៅ**

ដីកាដែលមានលក្ខណៈជាបទបញ្ញាទូទៅ គឺជាការណែនាំការអនុវត្ត ឬការបញ្ជាក់បន្ថែមខ្លឹមសាររបស់

[24] សៀវភៅការគ្រប់គ្រងរដ្ឋបាលខេត្តតាមបែបខេត្តតាមបែបវិមជ្ឈការ, សាលាជាតិរដ្ឋបាលមូលដ្ឋាន បោះពុម្ពឆ្នាំ២០១៩ ទំព័រទី៣១

[25] ឯកសារបច្ចេកទេសស្តីពីដីកាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខាធិការដ្ឋាន គ.ជ.អ.ប បោះពុម្ពឆ្នាំ២០១៥ ទំព័រទី៨

[26] មាត្រា៥៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, ព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨

ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស និងជាសេចក្ដីណែនាំការអនុវត្តកិច្ចការដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា (ហៅកាត់ថា ដីកាបទបញ្ញាទូទៅ)។ ដីកាដែលមានលក្ខណៈជាបទបញ្ញាទូទៅត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សា។ តម្រូវការនៃការដាក់ចេញដីកាបទបញ្ញាទូទៅត្រូវបានកំណត់ដោយផ្អែកតាមតម្រូវការនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានឋានានុក្រមខ្ពស់ជាង និងតម្រូវការមូលដ្ឋាន។ ចំពោះការចេញដីកាដោយផ្អែកតាមតម្រូវការនៃច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តនានា ដែលមានឋានានុក្រមខ្ពស់ជាងពុំចាំបាច់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាពិនិត្យ និងអនុម័តឡើយ តែប្រសិនបើការចេញដីកាដោយផ្អែកតាមតម្រូវការមូលដ្ឋានត្រូវដាក់ជូនកិច្ចប្រជុំដើម្បីឱ្យក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។

- **ដីកាដែលមានលក្ខណៈឯកត្តភូត**

ដីកាដែលមានលក្ខណៈឯកត្តភូត គឺជាដីកាដែលទាក់ទង ឬសំដៅចំឈ្មោះបុគ្គលក្នុងការតែងតាំង ឬការប្រគល់ភារកិច្ច ឬការផ្លាស់ប្ដូរ ឬការបញ្ចប់ភារកិច្ចរបស់បុគ្គលណាម្នាក់។

ដីកាដែលមានលក្ខណៈឯកត្តភូតត្រូវចុះហត្ថលេខាដោយអភិបាលតាមការសម្រេចចិត្តរបស់ក្រុមប្រឹក្សា។ ឧទាហរណ៍៖ មុខតំណែងនាយករងរដ្ឋបាល នាយកទីចាត់ការ ឬប្រធានអង្គភាព ដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលរាជធានី/ខេត្ត ដែលក្រុមប្រឹក្សារាជធានី/ខេត្តបានអនុម័តយល់ព្រមហើយ អភិបាលនៃគណៈអភិបាលនៃរដ្ឋបាលរាជធានី/ខេត្តត្រូវចេញដីកាតែងតាំងមន្ត្រីក្នុងមុខតំណែងដែលបានស្នើសុំ។[27]

ចំពោះថ្នាក់រដ្ឋបាលឃុំ/សង្កាត់វិញ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ បានកំណត់ថា ក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវធ្វើការជ្រើសរើសមេភូមិនៅគ្រប់ភូមិទាំងអស់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការរៀបចំជ្រើសរើសមេភូមិត្រូវធ្វើឡើងតែនៅភូមិណាដែលក្រសួងមហាផ្ទៃទទួលស្គាល់ជាផ្លូវការ។[28] ដូច្នេះ បេក្ខជនមេភូមិទាំងឡាយណាដែលក្រុមប្រឹក្សាឃុំ ឬក្រុមប្រឹក្សាសង្កាត់បានបោះឆ្នោតជ្រើសរើសរួចហើយ មេឃុំ ឬចៅសង្កាត់ត្រូវចេញសេចក្ដីសម្រេចតែងតាំងមេភូមិនីមួយៗនោះក្នុងរយៈពេល០៧ ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃដែលក្រុមប្រឹក្សាឃុំ ឬក្រុមប្រឹក្សាសង្កាត់បានបោះឆ្នោតយល់ព្រម។ ចំពោះជំនួយការមេភូមិដែលត្រូវកត់សម្គាល់ដោយមេភូមិ ហើយត្រូវក្រុមប្រឹក្សាឃុំ ឬក្រុមប្រឹក្សាសង្កាត់បានបោះឆ្នោតយល់ព្រមរួចហើយ មេឃុំ ឬចៅសង្កាត់ត្រូវតែចេញសេចក្ដីសម្រេចតែងតាំងជំនួយការមេភូមិនីមួយៗ។

[27] សៀវភៅការគ្រប់គ្រងរដ្ឋបាលខេត្តតាមបែបខេត្តតាមបែបវិមជ្ឈការ, សាលាជាតិរដ្ឋបាលមូលដ្ឋាន បោះពុម្ពឆ្នាំ២០១៩ ទំព័រទី៤០ និង៤១

[28] មាត្រា៣០ និងមាត្រា៨៦ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់, ព្រះរាជក្រមលេខនស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

**ចំណុចទី៣. ឋានានុក្រម**

នៅក្នុងឋានានុក្រមនៃធម្មនិយាមគតិយុត្ត ដីកាបទបញ្ជាត្រូវស្របនឹងប្រកាសបទបញ្ជា អនុក្រឹត្យបទបញ្ជា ព្រះរាជក្រឹត្យបទបញ្ជា ព្រះរាជក្រម និងរដ្ឋធម្មនុញ្ញ។ ដីកាបទបញ្ជាជាប្រភពធម្មនិយាមរបស់ដីកាឯកត្តភូត។

សរុបសេចក្តីមកសង្កេតឃើញថា នៅពេលដែលលំដាប់ថ្នាក់ក្នុងឋានានុក្រមកាន់តែចុះក្រោមទៅៗតម្រូវការឱ្យស្របនឹងប្រភពធម្មនិយាមកាន់តែតឹងរឹងឡើងៗជាលំដាប់ដែរ។ ឧទាហរណ៍៖ ដីកាបទបញ្ជាដែលនៅក្រោមគេបង្អស់ត្រូវគោរពលំដាប់ថ្នាក់ដល់ទៅ ៥ ជាន់ដែលនៅពីលើខ្លួន។ បើគិតទាំងសន្ធិសញ្ញា និងគោលការណ៍ទូទៅនៃនីតិផងគឺ ដល់ទៅ ៨ ជាន់ឯណោះ។

នៅបាតសាជីជ្រុងតាមទ្រឹស្តីរបស់ លោក ហាន្ស កែលសិន (HANS KELSEN) គឺមានសុទ្ធតែកិច្ចរដ្ឋបាលឯកត្តភូត។ កិច្ចការរដ្ឋបាលឯកត្តភូតនេះមានលំដាប់ថ្នាក់ពីខ្ពស់មកទាបដូចតទៅ៖ ព្រះរាជក្រឹត្យឯកត្តភូត អនុក្រឹត្យឯកត្តភូត ប្រកាសឯកត្តភូត និងដីកាឯកត្តភូត។ ក្នុងសាជីជ្រុងគេសង្កេតឃើញទៀតថា កិច្ចរដ្ឋបាលឯកត្តភូតទោះបីចេញពីអាជ្ញាធរថ្នាក់ខ្ពស់ប៉ុណ្ណាក៏ដោយ ក៏ត្រូវនៅក្រោមវិធានទូទៅទាំងអស់គិតរាប់តាំងពីដីកាបទបញ្ជាឡើងទៅពីព្រោះយើងដឹងហើយថារាជការត្រូវ គោរពគោលការណ៍មួយដែលថាវិធានទូទៅត្រូវតែមានតម្លៃខ្ពស់ជាងវិធានឯកត្តភូត និងវិធានដោយឡែក។[29] ឧទាហរណ៍៖ តាមព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា១៤១ បានចែងថា អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ដូច្នេះច្បាប់បានចង្អុលបង្ហាញថាអភិបាលរងក្រុង អភិបាលរងស្រុក និងអភិបាលរងខណ្ឌត្រូវតែងតាំងដោយប្រកាស។ ពាក្យថា តែងតាំង ដូចបានបញ្ជាក់ខាងលើមកហើយ គឺសំដៅដល់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ច។ ដូច្នេះហើយ គេមិនអាចចេញព្រះរាជក្រឹត្យ ឬអនុក្រឹត្យដើម្បីតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចរបស់អភិបាលក្រុង អភិបាលស្រុក ឬអភិបាលខណ្ឌបាននោះទេ ដែលគេអាចនិយាយម្យ៉ាងទៀតបានថា ចូលតាមច្រកណាគឺត្រូវចេញតាមច្រកនោះវិញ នេះមានន័យថា បើត្រូវបានតែងតាំងដោយប្រកាសនៅពេលផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចក៏ត្រូវធ្វើឡើងដោយប្រកាសដែរ។

### ១.១.៣. ទម្រង់ និងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត

ការគោរពឋានានុក្រមនៃវិធានគតិយុត្តនៅមិនទាន់គ្រប់គ្រាន់សម្រាប់ធានាការគោរពនីត្យានុកូលភាពឱ្យបានពេញលេញនៅឡើយទេ។ គេត្រូវបំពេញលក្ខខណ្ឌមួយចំនួនទៀតដូចតទៅ៖

[29] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពឆ្នាំ២០០៦ ទំព័រទី១៩៤

**១.១.៣.១. ការយកទម្រង់នៃលិខិតបទដ្ឋានគតិយុត្ត**

នៅក្នុងប្រព័ន្ធច្បាប់ខ្មែរ វិធានទូទៅអាចយកទម្រង់ជាព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងដីកា។ អនុលោមតាមមាត្រា២៨ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ត្រូវប្រើទម្រង់ព្រះរាជក្រម ដែលមានតែព្រះមហាក្សត្រ ឬប្រមុខរដ្ឋស្តីទីដែលបានទទួលសិទ្ធិផ្ទេរអំណាចពីព្រះមហាក្សត្រទេទើបអាចឡាយព្រះហស្តលេខា ឬចុះហត្ថលេខាបាន។ ការប្រើទម្រង់ខុសអំពីនេះជាការធ្វើខុសនឹងច្បាប់។

ការធ្វើបទបញ្ជារដ្ឋបាលដោយយកទម្រង់ព្រះរាជក្រឹត្យមានកំណត់ក្នុងមាត្រា២៨ថ្មី នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ក្នុងព្រះរាជក្រមជាច្រើន និងក្នុងករណីខ្លះ ដូចបានបកស្រាយខាងលើមកហើយគឺក្នុងករណីមិនមានច្បាប់ចែង។ ចំពោះការយកទម្រង់អនុក្រឹត្យ ឬប្រកាស ឬដីកាដើម្បីចេញបទបញ្ជារដ្ឋបាលទៅតាមឋានានុក្រមនៃវិធានគតិយុត្ត គេត្រូវយោងព្រះរាជក្រម និងព្រះរាជក្រឹត្យដែលពាក់ព័ន្ធ។

ចំពោះកិច្ចរដ្ឋបាលឯកត្តភូតទម្រង់រួមមាន៖ ព្រះរាជក្រឹត្យឯកត្តភូត អនុក្រឹត្យឯកត្តភូត ប្រកាសឯកត្តភូត ដីកាឯកត្តភូតដែលត្រូវប្រើ មានខ្លះចែងក្នុងរដ្ឋធម្មនុញ្ញ ខ្លះចែងក្នុងព្រះរាជក្រម (ច្បាប់សភា)។

**១.១.៣.២. ការផ្សព្វផ្សាយ**

គោលការណ៍មួយចែងថា គ្មាននរណាដែលត្រូវគេសន្មតថាមិនដឹងច្បាប់ឡើយ។ គោលការណ៍នេះដូចជាសាហាវណាស់ ពីព្រោះដោយហេតុថាចង់ធ្វើទោសឱ្យបាន គេទៅបង្កើតអ្វីមួយដែលផ្ទុយពីការពិតទាំងស្រុង។

តើមានជនប៉ុន្មាននាក់ទៅដែលដឹងច្បាប់ទាំងអស់ក្នុងសង្គមជាតិនីមួយៗ។ ការពិតគ្មានម្នាក់ទេ ផ្ទុយទៅវិញគេត្រឡប់ជាធ្វើការចាត់ទុកថាគ្រប់ៗគ្នាសុទ្ធតែដឹងច្បាប់ទាំងអស់វិញ។ ដើម្បីបន្ថយភាពសាហាវនេះ ដោយគេត្រូវផ្តល់ព័ត៌មានអំពីច្បាប់ដល់សាធារណជន ដោយធ្វើការផ្សព្វផ្សាយតាមរយៈសារព័ត៌មានផ្លូវការដែលជនគ្រប់រូបអាចទៅរកយកមកអានតាមមធ្យោបាយរៀងៗខ្លួន។ មធ្យោបាយក្នុងការផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតនៃព្រះរាជាណាចក្រកម្ពុជាគឺធ្វើតាមរយៈរាជកិច្ច។

រដ្ឋធម្មនុញ្ញបានចែងថា ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសឱ្យទាន់ពេលកំណត់ខាងលើ។[30] រីឯពេលកំណត់ គឺបើច្បាប់មិនបានចែងថាជាការប្រញាប់ ច្បាប់នោះត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ក្រោយពីថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែ បើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ។[31]

[30] មាត្រា៩៣ថ្មី វាក្យខ័ណ្ឌទី២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាកម្ពុជាឆ្នាំ១៩៩៣

[31] មាត្រា៩៣ថ្មី វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាកម្ពុជាឆ្នាំ១៩៩៣

ចំពោះលិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលមានអនុភាពទូទៅរបស់រាជរដ្ឋាភិបាលត្រូវចុះក្នុងរាជកិច្ច។[32] លិខិតបទដ្ឋានគតិយុត្តដែលមានអានុភាពទូទៅរួមមាន៖ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកា និងសេចក្តីសម្រេចរដ្ឋបាលទាំងអស់ត្រូវចូលជាធរមានភ្លាមនៅថ្ងៃចុះហត្ថលេខាចំពោះរាជការអាជ្ញាធរខ្លួនឯង ប៉ុន្តែចំពោះរាស្ត្រវិញ គេត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈជាមុនសិនតាមរយៈការចុះក្នុងរាជកិច្ច។

ដូច្នេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានអានុភាពទូទៅត្រូវផ្សព្វផ្សាយតាមមធ្យោបាយរាជកិច្ច។ រាជរដ្ឋាភិបាលមានកាតព្វកិច្ចត្រូវបោះពុម្ពផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានអនុភាពទូទៅទាំងអស់ក្នុងរាជកិច្ចឱ្យទាន់ពេលកំណត់។ ក្រៅពីការចុះក្នុងរាជកិច្ច ដែលច្បាប់បានកំណត់ គេឃើញថា ក៏មានមធ្យោបាយផ្សេងៗទៀតដើម្បីជួយសម្រួលក្នុងការផ្សព្វផ្សាយផងដែរដូចជា ការចុះក្នុងព្រឹត្តិបត្រ កាសែត ផ្សាយតាមវិទ្យុ ទូរទស្សន៍ តាមបណ្តាញសង្គមផ្សេងៗ ព្រមទាំងតាមរយៈបិទនៅលើ ក្តាខៀនតាមក្រសួង មន្ទីរ អង្គភាព ការិយាល័យ សាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក សាលាខណ្ឌ សាលាឃុំ សាលាសង្កាត់ជាដើម។

## ១.២. កាតព្វកិច្ចក្រោមវិធានគតិយុត្ត និងសមត្ថកិច្ចជាប់ចំណង

ដើម្បីឱ្យអំពើរបស់រាជការមានភាពស្របច្បាប់ ត្រូវគោរពវិធានគតិយុត្តទាំងឡាយដែលនៅជាធរមាន។ម្យ៉ាងទៀងវិធានគតិយុត្តទាំងនោះហើយដែលបង្កើតឱ្យមានសមត្ថកិច្ចរបស់អាជ្ញាធររដ្ឋបាលតាមវិធានច្បាប់។

### ១.២.១. កាតព្វកិច្ចរបស់រាជការក្រោមវិធានគតិយុត្ត

រាជការធ្វើសកម្មភាពដើម្បីបម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ទូទៅ ដូច្នេះហើយនាំឱ្យទំនាក់ទំនងគតិយុត្តរវាងឯកជន និងរាជការពុំមានសមភាពគតិយុត្តឡើយ។ភាពមិនស្មើគ្នានេះហើយធ្វើឱ្យរាជការអាចសម្រេចនូវផលប្រយោជន៍ទូទៅនៅគ្រប់កាលៈទេសៈដែលយើងអាចនិយាយម្យ៉ាងទៀតថា មធ្យោបាយដែលរាជការប្រើដើម្បីបំពេញតួនាទីរបស់ខ្លួនគឺអ្វីដែលគេហៅថា បុព្វសិទ្ធិនៃអំណាចសាធារណៈ។[33] ថ្វីត្បិតតែរាជការមាននូវបុព្វសិទ្ធិក៏ដោយក៏រាជការត្រូវស្ថិតនៅក្រោមវិធានគតិយុត្តដែរ។ មូលហេតុនេះហើយធ្វើឱ្យស្ថាប័នរដ្ឋបាល និងអាជ្ញាធររដ្ឋបាលគ្រប់លំដាប់ថ្នាក់ត្រូវមានកាតព្វកិច្ចក្រោមវិធានច្បាប់ជាធរមាន។

ដើម្បីឱ្យសកម្មភាពរបស់រាជការធ្វើឡើងស្របនឹងនីត្យានុកូលភាព ឬស្របនឹងច្បាប់ ដែលតុលាការមិនអាចធ្វើការចោទប្រកាន់បានត្រូវធ្វើអ្វីៗប្រកបដោយច្បាប់សំអាង និងត្រូវគោរពគោលការណ៍នៃវិធានគតិយុត្ត។

[32] មាត្រា១៨ វាក្យខ័ណ្ឌទី២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

[33] សៀវភៅនីតិរដ្ឋបាលទូទៅ, សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី៤ ឆ្នាំ២០១៧ ទំព័រទី២១៦

**១.២.១.១. ធ្វើសកម្មភាពស្របតាមច្បាប់**

នៅក្នុងរដ្ឋដែលប្រកាន់លទ្ធិប្រជាធិបតេយ្យដូចជាព្រះរាជាណាចក្រកម្ពុជា គឺអាជ្ញាធររដ្ឋបាលចាំបាច់ត្រូវធ្វើសកម្មភាពរបស់ខ្លួនស្របតាមច្បាប់ និងមិនត្រូវប្រាស់ចាកពីវិធានច្បាប់ឡើយ។

នៅក្នុងរដ្ឋដែលប្រកាន់លទ្ធិប្រជាធិបតេយ្យ គឺមានគំនិតរបស់អ្នកសេរីនិយមថា ប្រសិនបើគ្មានច្បាប់ហាមឃាត់ទេ រាស្ត្រប្រជាមានសិទ្ធិគ្រប់គ្រាន់ដោយអាចធ្វើអ្វីៗដោយស្របតាមបំណងរបស់ខ្លួន ក្នុងករណីនេះអាជ្ញាធររដ្ឋបាលពុំអាចមករារាំងការអនុវត្តសិទ្ធិរបស់រាស្ត្រប្រជាបានឡើយ ហើយប្រសិនបើអាជ្ញាធររារាំងការអនុវត្តសិទ្ធិនេះ អំពើរបស់រាជការនោះគឺផ្ទុយនឹងច្បាប់ដែលតុលាការរដ្ឋបាលអាចប្រកាន់បាន។ ចំណែកនៅក្នុងគំនិតរបស់អ្នកកុំម្មុយនីស្តនិយមវិញ គេគិតថារាស្ត្រប្រជាអាចធ្វើអ្វីៗទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាតតែប៉ុណ្ណោះ។[34] ដូច្នេះហើយ រាល់សកម្មភាពរបស់រាស្ត្រប្រជានៅក្នុងរដ្ឋដែលប្រកាន់លទ្ធិកុំម្មុយនីស្តងាយនឹងត្រូវបានរារាំងដោយអាជ្ញាធររដ្ឋបាលណាស់ ហើយអំពើរបស់អាជ្ញាធររដ្ឋបាលមិនងាយនឹងផ្ទុយច្បាប់ទេ។ ក្នុងគោលគំនិតទាំងពីរនេះគឺមានភាពផ្ទុយគ្នាស្រឡះ។ ដោយឡែកប្រទេសកម្ពុជាគឺជារដ្ឋប្រកាន់លទ្ធិប្រជាធិបតេយ្យ។[35] ដូច្នេះហើយ អាជ្ញាធររដ្ឋបាលមិនអាចធ្វើអ្វីៗទៅតាមអំពើចិត្តរបស់ខ្លួនបាននោះទេ ហើយរាល់សកម្មភាពរបស់រាជការត្រូវតែមានច្បាប់សំអាងជាដាច់ខាត។

**១.២.១.២. ត្រូវគោរពគោលការណ៍នៃវិធានគតិយុត្ត**

**ក. រាជការត្រូវគោរពគោលការណ៍ឋានុក្រមនៃធម្មនិយាមគតិយុត្ត**

ឋានានុក្រមនៃវិធានគតិយុត្ត គឺសំដៅទៅលើលំដាប់ថ្នាក់នៃវិធានច្បាប់។ ឋានានុក្រមនៃវិធានច្បាប់អាចមានលក្ខណៈខុសប្លែកគ្នាតិចតួចនៅតាមប្រទេសមួយចំនួន ប៉ុន្តែជាមូលដ្ឋានទូទៅតាមទ្រឹស្តីរបស់លោកហាន្ស កែលសិន គឺមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ដែលអនុម័តដោយសភា និងបទបញ្ញាទូទៅដែលចេញដោយអង្គការនីតិប្រតិបត្តិ។ នេះគឺជាលំដប់ថ្នាក់ត្រូវបានប្រើច្រើននៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ហើយនៅថ្ងៃអានាគតគេនឹងអាចឃើញនូវយុត្តិសាស្ត្រដែលចេញដោយក្រុមប្រឹក្សាធម្មនុញ្ញ និងតុលាការជាច្រើនទៀត សព្វថ្ងៃនេះគឺពុំមានសម្បូរបែបនៅឡើយ។

ចំពោះលិខិតបទដ្ឋានដែលត្រូវបានប្រើនៅក្នុងព្រះរាជាណាចក្រកម្ពុជារួមមាន៖ រដ្ឋធម្មនុញ្ញ សន្ធិសញ្ញា ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកា និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលមានតម្លៃជាធរមាន។ ដូច្នេះ រាជកាត្រូវគោរពនូវឋានានុក្រមនៃវិធានទាំងនេះ។

[34] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០០៦ ទំព័រទី១៩៣

[35] មាត្រា៥១ វាក្យខ័ណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

### ខ. ត្រូវគោរពវិធានទូទៅដែលមានតម្លៃខ្ពស់ជាងវិធានវិធានពិសេស

ដើម្បីយល់ឱ្យកាន់តែច្បាស់នូវការគោរពនូវវិធានទូទៅ និងវិធានពិសេស ត្រូវស្វែងយល់អំពីអត្ថន័យនៃវិធានទូទៅ និងវិធានពិសេសជាមុនសិន។ វិធានទូទៅ ជាវិធានបទដ្ឋានគតិយុត្តទាំងឡាយណាដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ហើយមិនសំដៅលើបុគ្គលណាមួយជាក់លាក់ មានន័យថា គឺសំដៅទៅលើបុគ្គលគ្រប់រូប ឬអាចនិយាយបានថា ជាវិធានដែលមានតម្លៃជាសកល។ វិធានទូទៅនេះ គឺជាវិធានដែលអាចចេញដោយអង្គការនីតិប្រតិបត្តិ និងអង្គការនីតិប្បញ្ញត្តិ។ អង្គការនីតិប្បញ្ញត្តិចេញវិធានទូទៅតាមរយៈការអនុម័តច្បាប់ទាំងឡាយ ដែលត្រូវប្រើប្រាស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជាដូចជា៖ ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ច្បាប់ការងារ ជាដើម ទាំងអស់នេះគឺត្រូវអនុវត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។ ចំពោះវិធានទូទៅដែលចេញដោយអង្គការនីតិប្រតិបត្តិនៅកម្ពុជា គេឃើញមាន ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។ វិធានដែលចេញដោយរាជរដ្ឋាភិបាលដែលជាអង្គការនីតិប្រតិបត្តិថ្វីត្បិតតែជាវិធានដែលត្រូវយកទៅអនុវត្តក្នុងក្របខ័ណ្ឌទូទាំងប្រទេស តែត្រូវតែគោរព រដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់។ វិធានពិសេស គឺសំដៅទៅលើវិធានដោយឡែក និងវិធានឯកត្តភូត។ វិធានដោយឡែក គឺជាវិធានទាំងឡាយដែលចែងពីលក្ខណៈពិសេស ឬនីតិវិធីលម្អិតទៅលើកម្មវត្ថុអ្វីមួយដែលត្រូវស្របជាមួយវិធានទូទៅ។ ជាក់ស្តែង ដូចជាព្រះរាជក្រឹត្យលេខជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដោយព្រះរាជក្រឹត្យនេះធ្វើឡើងដោយយោងទៅតាមអ្វីដែលមានចែងនៅក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលដែលបានបញ្ញត្តិថា ក្របខ័ណ្ឌទាំងឡាយនៃអ្នករាជការត្រូវកំណត់តាម លក្ខន្តិកៈដោយឡែកតាមព្រះរាជក្រឹត្យ។[36] វិធានឯកត្តភូត គឺជាវិធានទាំងឡាយដែលធ្វើឡើងសំដៅទៅលើបុគ្គលណាមួយជាក់លាក់ដែលនាំឱ្យបង្កើតនូវសិទ្ធិ និងកាតព្វកិច្ចដល់បុគ្គលនោះ។ ជាក់ស្តែងនៅឆ្នាំ២០១៨ ក្រោយពេលបោះឆ្នោតជ្រើសតាំង... ក្រោយពេលវរជនដែលត្រូវបាន ចាត់តាំងដោយព្រះមហាក្សត្របានដឹកនាំសមាជិកដែលផ្គូរផ្គងឱ្យកាន់មុខតំណែងនៅក្នុងរដ្ឋាភិបាលទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា។ ក្រោយពីរដ្ឋសភាបានផ្តល់សេចក្តីទុកចិត្តតាមសំឡេងភាគច្រើនដាច់ខាត (៥០%+១) រួចហើយ ទើបព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។ តាមរយៈព្រះរាជក្រឹត្យតែងតាំងនេះនាំឱ្យសមាជិករាជរដ្ឋាភិបាលទាំងអស់មាននូវសិទ្ធិ និងកាតព្វកិច្ចទៅតាមច្បាប់។

ដូច្នេះ សរុបមកវិញរាជការត្រូវចេញលិខិតបទដ្ឋានគតិយុត្តរបស់ខ្លួនស្របទៅឋានានុក្រម ហើយគោរពជានិច្ចនូវគោលការណ៍ គឺវិធានទូទៅមានតម្លៃជាងវិធានពិសេស។

[36] មាត្រា៣ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល, ព្រះរាជក្រមលេខ០៦.ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤

**គ. ត្រូវគោរពវិធានដែលខ្លួនបានចេញ**

មានន័យថា អាជ្ញាធរដ្ឋបាលត្រូវគោរពនូវបទបញ្ញាទូទៅដែលខ្លួនបានចេញកន្លងមក កាលណាបទបញ្ញា ឬ វិធាននោះនៅជាធរមាន ប្រសិនបើពុំទាន់មានបទបញ្ញាថ្មីដែលកែប្រែ ឬលុបចោលបទបញ្ញាចាស់នោះទេ។ ពីព្រោះថា បទបញ្ញាទូទៅដែលខ្លួនបានចេញកន្លងមកនោះ មិនត្រឹមតែត្រូវបានគោរពដោយប្រជាពលរដ្ឋប៉ុណ្ណោះទេ តែអាជ្ញាធរដែលជាអ្នកចេញបទបញ្ញានោះ ក៏ត្រូវគោរពផងដែរដូចដែលទស្សនៈមួយបានលើកឡើងថា អ្នកត្រូវតែគោរពច្បាប់ដែលអ្នកបង្កើត ។

**ឃ. ត្រូវគោរពបែបនីតិវិធី និងកាតព្វកិច្ចនៃការផ្សាយផ្សព្វច្បាប់**

បែបបទនីតិវិធី គឺសំដៅទៅលើនីតិវិធីដែលត្រូវអនុវត្តតាមជាចាំបាច់ ឧទាហរណ៍ដូចជារបៀបនៃការធ្វើព្រះរាជក្រឹត្យ និងអនុក្រឹត្យជាដើម។

ម្យ៉ាងទៀត ចំពោះកាតព្វកិច្ចនៃការផ្សព្វផ្សាយច្បាប់នេះ មានន័យថា នៅពេលដែលរដ្ឋសភា និង ព្រឹទ្ធសភាបានអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ហើយបញ្ជូនទៅព្រះមហាក្សត្រឡាយព្រះហស្ថលេខារួចហើយ អាជ្ញាធររដ្ឋបាលមានតួនាទីចុះផ្សាយច្បាប់នោះនៅក្នុងរាជកិច្ចទៅតាមពេលវេលាកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ គឺចូលជាធរមានដប់ថ្ងៃគត់នៅរាជធានីភ្នំពេញ និងម្ភៃថ្ងៃគត់នៅទូទាំងប្រទេស។[37]

**ង. ត្រូវបំពេញតួនាទីស្របតាមសមត្ថកិច្ច និងសមត្ថភាព**

សមត្ថកិច្ច គឺជាព្រំដែននៃអំណាចដែលមានចែងនៅក្នុងច្បាប់។ សមត្ថកិច្ច និងសមត្ថភាព គឺនៅជាប់ជាមួយគ្នា បើមានសមត្ថកិច្ចនាំឱ្យមានសមត្ថភាព។

ជាក់ស្តែង នាយករដ្ឋមន្ត្រីក្នុងសមត្ថកិច្ចរបស់ខ្លួនមានសមត្ថភាពចេញអនុក្រឹត្យ រដ្ឋមន្ត្រីប្រធានស្ថាប័នក្នុងសមត្ថកិច្ចរបស់ខ្លួនមានសមត្ថភាពចេញប្រកាសជាដើម។[38]

### ១.២.២. សមត្ថកិច្ចជាប់ចំណង

សមត្ថកិច្ចជាប់ចំណង គឺអាជ្ញាធរសាធារណៈត្រូវតែសម្រេចក្នុងទិសដៅដែលច្បាប់ចង្អុលបង្ហាញ ដោយអាជ្ញាធរគ្មានលទ្ធភាពជ្រើសរើសនូវសេចក្តីសម្រេចរបស់ខ្លួន ឬមធ្យោបាយណាមួយដើម្បីធ្វើសេចក្តីសម្រេច ឬនូវពេលវេលាក្នុងការចេញសេចក្តីសម្រេចឡើយ។ អំពើរបស់រាជការត្រូវអនុវត្តទៅតាមនូវអ្វីដែលច្បាប់បានចែង។ ប៉ុន្តែ បទប្បញ្ញត្តិនៃលិខិតបទដ្ឋានគតិយុត្តខ្លះមានការចែងឡើងដោយតឹងរឹង ហើយមានខ្លះទៀតមានលក្ខណៈមិនសូវតឹងរឹងនោះទេ។ ដោយយោងតាមលក្ខណៈនេះហើយ ទើបសមត្ថកិច្ចជាប់ចំណងត្រូវបានគេបែងចែកជាពីរគឺ៖ **សមត្ថកិច្ចជាប់ចំណងតឹង** និង **សមត្ថកិច្ចជាប់ចំណងធូរ។**

---

[37] មាត្រា៩៣ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[38] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០០៦ ទំព័រទី១៩៥

**១.២.២.១. ចំណងតឹង**

សមត្ថកិច្ចជាប់ចំណងតឹងនៅពេលដែលអាជ្ញាធរគ្មានលទ្ធភាពជ្រើសរើសនូវមធ្យោបាយអនុវត្ត ឬមិនអាចពន្យាពេលបានដោយត្រូវអនុវត្តតាមវិធានច្បាប់កំណត់តែប៉ុណ្ណោះ។ ឧទាហរណ៍៖ យោងតាមមាត្រា១៤៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថា រាជធានី ខេត្ត ក្រុង ស្រុង ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការមួយ។ ដូច្នេះ បើយោងតាមរដ្ឋធម្មនុញ្ញមាត្រា១៤៦នេះ បានបញ្ជាក់ឱ្យឃើញអំពីចំណងតឹង ដែលការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដាច់ខាតត្រូវតែធ្វើឡើងជាទម្រង់ច្បាប់រៀបចំអង្គការ។ ឧទាហរណ៍៖ ខាងលើ គឺជាកិច្ចការដែលត្រូវយកទម្រង់ជាច្បាប់ ចំណែកនៅក្នុងទម្រង់ជាបទបញ្ជាវិញគេឃើញមានដូចជា នៅក្នុងវិស័យមុខសាធារណៈនៅពេលដែលមន្ត្រីរាជការស៊ីវិលដល់អាយុចូលនិវត្តន៍ថ្ងៃខែឆ្នាំណា មន្ត្រីរាជការនោះត្រូវចាកចេញដោយស្វ័យប្រវត្តិតាមសេចក្តីសម្រេចរបស់ក្រសួងស្ថាប័នតាមបទប្បញ្ញត្តិច្បាប់។[39]

**១.២.២.២. ចំណងធូរ**

រាជការមានសមត្ថកិច្ចជាប់ចំណងធូរ នៅពេលណាដែលរាជការមានលទ្ធភាពក្នុងការជ្រើសរើសនូវវិធីសាស្ត្រ ឬមធ្យោបាយ ក៏ដូចជាពេលវេលាដើម្បីអនុវត្ត។ ឧទាហរណ៍៖ រាជរដ្ឋាភិបាលគ្រប់គ្រង បញ្ជា ប្រើប្រាស់ យោធា នគរបាល កម្លាំងប្រដាប់អាវុធផ្សេងៗទៀត និងរដ្ឋបាលក្នុងការធ្វើសកម្មភាពរបស់ខ្លួន។[40] តាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីពុំបានកំណត់អំពីសកម្មភាពនោះមានអ្វីខ្លះទេដោយទុកឱ្យរាជរដ្ឋាភិបាលជាអ្នកកំណត់ដោយខ្លួនឯង។ ជាក់ស្តែងតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រីបានបញ្ញត្តិថា នាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សេចក្តីណែនាំ និងសារាចររបស់រាជរដ្ឋាភិបាល។[41] ដីកាបស់ក្រុមប្រឹក្សា គឺជាលិខិតបទដ្ឋានគតិយុត្ត ឬជាវិធានខាងផ្លូវច្បាប់ដែលអនុម័តដោយក្រុមប្រឹក្សា ហើយត្រូវអនុវត្តនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។[42]

[39] ព្រះរាជក្រមលេខ០៦/នស/៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

[40] មាត្រា៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

[41] មាត្រា១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

[42] សៀវភៅនីតិរដ្ឋបាលទូទៅ, សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី៤ ឆ្នាំ២០១៧ ទំព័រទី៦៧

# ជំពូកទី២
# អំណាចឆន្ទានុសិទ្ធិ
# និងនីត្យានុកូលភាពនៃអញ្ញត្រកម្ម

# ជំពូកទី២
# អំណាចឆន្ទានុសិទ្ធិ និងនីត្យានុកូលភាពនៃអញ្ញត្រកម្ម

## ២.១. សញ្ញាណទូទៅនៃអំណាច

ដើម្បីយល់កាន់តែស៊ីជម្រៅទៅលើអំណាចឆន្ទានុសិទ្ធិ ជាបឋមគួរកប្បីឈ្វេងយល់អ្វីទៅជាសញ្ញាណទូទៅនៃអំណាច ក៏ដូចជាអត្ថន័យនៃអំណាច។

ការស្វែងយល់អំពីសញ្ញាណនៃអំណាចត្រូវដឹងអំពីលក្ខណៈធម្មជាតិ និងប្រភពនៃអំណាចជាមុនសិន។ ដូច្នេះ គេអាចទាញនិយមន័យនៃអំណាចបាន។ ដោយយោងទៅលើលក្ខណៈធម្មជាតិនៃអំណាច ឃើញថាអំណាចកើតមានឡើងទៅតាមលក្ខណៈធម្មជាតិ ជាច្រើនដោយអាស្រ័យទៅតាមប្រភេទរបស់វា។[43] ក្នុងចំណោមលក្ខណៈនៃប្រភេទទាំងនោះគេឃើញមាន លក្ខណៈធម្មជាតិនៃឥទ្ធិពលបាននិយាយថា អំណាច គឺជាប្រភេទឥទ្ធិពលមួយជាពិសេសនៃទំនាក់ទំនងរវាងអ្នកដឹកនាំ និងអ្នកដែលត្រូវគេដឹកនាំ។ អ្នកដឹកនាំ គឺជាប្រធានវិស័យភាព[44] មួយដែលមានឥទ្ធិពលទៅលើអ្នកដែលត្រូវគេដឹកនាំ ដែលជាប្រធានវិស័យភាពមួយទៀត។ ដូច្នេះ នៅពេលដែលប្រធានវិស័យភាពណាមួយអាចបង្ខំឱ្យប្រធានវិស័យភាពណាមួយទៀតធ្វើអ្វីមួយទៅតាមឆន្ទៈរបស់ខ្លួនបាន គេសន្មតថាមានអំណាច។ ឧទាហរណ៍៖ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជម្ងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងៗទៀត ដោយបានចែងអំពីការរឹតត្បឹត ឬការហាមឃាត់ការធ្វើដំណើរ។[45] យោងតាមអនុក្រឹត្យនេះ ឃើញថារាជរដ្ឋាភិបាល គឺជាប្រធានវិស័យភាពមួយដែលអាចបង្ខំឱ្យប្រជាពលរដ្ឋដែលជាប្រធានវិស័យភាពមួយទៀតត្រូវតែគោរពតាម អនុក្រឹត្យនេះ ទោះបីប្រជាពលរដ្ឋមិនពេញចិត្តនូវការរឹតត្បឹតការធ្វើដំណើរនេះ ក៏ដោយ។ នេះគឺបង្ហាញឱ្យឃើញនូវអំណាចនៃអាជ្ញាធររដ្ឋបាលថ្នាក់ជាតិមានលើចំពោះប្រជាពលរដ្ឋ ហើយដែលអំណាចនេះ គឺជាអំណាចស្របច្បាប់ទៀតផង។ ម្យ៉ាងវិញទៀត បន្ទាប់ពីបានដឹងអំពីលក្ខណៈធម្មជាតិនៃអំណាចរួចហើយ នឹងបន្តទៅឈ្វេងយល់អំពីប្រភពនៃអំណាចវិញម្តង។ ប្រភពនៃអំណាចបានន័យថា គឺជាការក្រសោបយកគ្រប់កត្តាទាំងអស់ដែលមានភាពប៉ិនប្រសប់ ក្នុងការធ្វើឱ្យខ្លួនក្លាយទៅជាអ្នកមានឥទ្ធិពលអំណាច ដូចជាការដឹកនាំការងារ ការរៀបចំស្ថាប័ន។ ម្យ៉ាងទៀតបើគេនិយាយអំពី ប្រភពនៃអំណាចដែលកើតចេញពីវិធានច្បាប់ គឺមានន័យថា ច្បាប់បានកំណត់នូវសិទ្ធិ និងកាតព្វកិច្ចចំពោះបុគ្គល ដែលទទួលស្គាល់ដោយច្បាប់។ កម្ពុជា

---

[43] សៀវភៅសេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ, បណ្ឌិត ឈុន ណារ៉េត បោះពុម្ពឆ្នាំ២០១២ ទំព័រទី៩៨

[44] ***ប្រធានវិស័យភាព*** *សំដៅមនុស្ស ឬក្រុមដែលធ្វើឱ្យមានបំរែបំរួលស្ថានភាពនៃប្រធានវិស័យភាពដទៃទៀត។*

[45] មាត្រា៤ នៃអនុក្រឹត្យស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ដទៃទៀត, លេខ៥៧ អនុក្រ.បក.ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

បានធ្វើការគ្រប់គ្រងរដ្ឋដោយធ្វើការបែងចែងអំណាចជាបីដាច់ពីគ្នារួមមានៈ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ គេឃើញថា អំណាចនីតិប្បញ្ញត្តិត្រូវបានកាន់កាប់ដោយរដ្ឋសភា និងព្រឹទ្ធសភា។ យោងតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញបានបញ្ញត្តិថា រដ្ឋសភា និងព្រឹទ្ធសភា ជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។[46] ចំណែកឯអំណាចនីតិប្រតិបត្តិ ត្រូវបានកាន់កាប់ដោយរាជរដ្ឋាភិបាល និងសិទ្ធិអំណាចក្នុងការជម្រះក្តី គឺជាសមត្ថកិច្ចរបស់អង្គការតុលាការ ហើយអំណាចតុលាការត្រូវបាន ធានាដោយរដ្ឋធម្មនុញ្ញដែលពុំអាចផ្ទេរអំណាចនេះឱ្យអង្គការណាមួយបានឡើយ។[47]

យោងតាមការបកស្រាយខាងលើនេះឃើញថាអំណាចមានអត្ថន័យច្រើនទៅតាមបរិបទនៃស្ថានភាពនីមួយៗ។ អំណាច គឺជាភាពប៉ិនប្រសប់ និងសមត្ថភាពរបស់បុគ្គល ឬក្រុមដើម្បីធ្វើឱ្យសម្រេចកិច្ចការតាមគំនិតរបស់ខ្លួនដោយបានសម្តែងនូវទង្វើទៅលើអ្នកដទៃ ជាអត្តនោម័តដោយពុំចាំបាច់មានការយល់ព្រមពីអ្នកនោះឡើយ។

**២.១.១. សញ្ញាណ និងនិយមន័យ**

សញ្ញាណ និងនិយមន័យនៅទីនេះ គឺសំដៅទៅលើសញ្ញាណ និងនិយមន័យនៃអំណាចឆន្ទានុសិទ្ធិ។ ជាការពិត ក្រោយពីបានដឹងអំពីសញ្ញាណ និងអត្ថន័យទូទៅនៃទ្រឹស្តីអំណាចរួចមក នឹងឈានទៅឈ្វេងយល់អំពីសញ្ញាណ និងអត្ថន័យនៃអំណាចឆន្ទានុសិទ្ធិវិញម្តង។

**២.១.១.១. សញ្ញាណនៃអំណាចឆន្ទានុសិទ្ធិ**

ដូចបានបកស្រាយពីខាងលើរួចមកហើយ អំពីសញ្ញាណក៏ដូចជាអត្ថន័យនៃអំណាចក្នុងន័យទូទៅ។ស្រដៀងគ្នានេះដែរនៅក្នុងសកម្មភាព ឬការប្រព្រឹត្តនៃអំពើរបស់រាជការក៏មានការប្រើប្រាស់អំណាចផងដែរពោលគឺ អំណាចឆន្ទានុសិទ្ធិតែម្តងដែលជាសកម្មភាពប្រចាំថ្ងៃរបស់រាជការ។ ការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិនេះ គឺជាចំណុចស្នូលនៃនីតិរដ្ឋបាលទៅហើយ។

ជាការពិតណាស់ដូចបានដឹងរួចមកហើយអំពីសមត្ថកិច្ចជាប់ចំណងរបស់រាជការគឺ ចំណងតឹង និងចំណងធូរ។ ចំណងតឹង នៅពេលណាដែលអាជ្ញាធររដ្ឋបាលត្រូវតែធ្វើសេចក្តីសម្រេច និងអនុវត្តទៅតាមអ្វីដែលច្បាប់បានចង្អុលបង្ហាញ ដោយគ្មានលទ្ធភាពក្នុងការជ្រើសរើសមធ្យោបាយ ឬក៏ពេលវេលាក្នុងការចេញសេចក្តីសម្រេចឡើយ។ ចំណែកឯចំណងធូរ គឺនៅពេលណាដែលវិធានច្បាប់ទុកលទ្ធភាពក៏ដូចជាមធ្យោបាយ ឬពេលវេលា ឬដោយសារតែពុំមានច្បាប់ចែង និងស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនបណ្តាលឱ្យអាជ្ញាធររដ្ឋបាលមានសិទ្ធិ

[46] មាត្រា៩០ថ្មី និងមាត្រា៩៩ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[47] មាត្រា១៣០ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ចេញសេចក្តីសម្រេចណាមួយបាន។

តាមរយៈសមត្ថកិច្ចជាប់ចំណងធូរនេះហើយដែលជាហេតុនាំឱ្យកើតមានអំណាចឆន្ទានុសិទ្ធិកើតឡើង។[48]

**២.១.១.២. និយមន័យ**

អំណាចឆន្ទានុសិទ្ធិ គឺជាអំណាចមិនមានជាប់ចំណងដោយវិធានច្បាប់ ហើយដែលអាចប្រើប្រាស់បានដោយសេរីដើម្បីប្រសិទ្ធភាពនៃការបំពេញសកម្មភាពរបស់ខ្លួន។

យោងតាមអត្ថន័យខាងលើនេះឃើញថា រាជការគឺអាចប្រើប្រាស់អំណាចឆន្ទានុសិទ្ធិក្នុងការចេញសេចក្តីសម្រេច និងធ្វើសកម្មភាពរបស់ខ្លួនដោយមិនមានច្បាប់មកហាមឃាត់ឡើយ។ ផ្ទុយមកវិញ ថ្វីត្បិតតែអំណាចនេះ ត្រូវបានប្រើប្រាស់ដោយសេរីក្នុងគោលបំណងប្រសិទ្ធភាពនៃសកម្មភាពរបស់ខ្លួនក៏ដោយ ក៏ការប្រើប្រាស់អំណាចនេះត្រូវស្ថិតនៅក្នុងលក្ខខណ្ឌពីរដើម្បីធានានីត្យានុកូលភាពនៃអំពើរបស់រាជការ៖

លក្ខខណ្ឌទី១: លក្ខខណ្ឌសមត្ថកិច្ច

លក្ខខណ្ឌទី២: លក្ខខណ្ឌផលប្រយោជន៍សាធារណៈ

លក្ខខណ្ឌសមត្ថកិច្ច គឺជាលក្ខខណ្ឌចម្បងទីមួយ ព្រោះថា សមត្ថកិច្ច គឺជាលក្ខខណ្ឌដែលបង្កើតឱ្យមានដែនអំណាចនៃអាជ្ញាធរដ្ឋបាលដែលអាចធ្វើសេចក្តីសម្រេច និងសកម្មភាពនៅក្នុងដែនអំណាចរបស់ខ្លួន។ ការបង្កើតឱ្យមានសមត្ថកិច្ចនៅត្រង់នេះ គឺកើតឡើងតាមរយៈការចែងក្នុងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តណាមួយដែលនាំឱ្យមានសមត្ថកិច្ច។

លក្ខខណ្ឌផលប្រយោជន៍សាធារណៈ គឺជាលក្ខខណ្ឌចម្បងទីពីរ មានន័យថា អាជ្ញាធររដ្ឋបាលត្រូវធ្វើសកម្មភាពទាំងឡាយក្នុងគោលដៅដើម្បីបម្រើផលប្រយោជន៍ទូទៅតែប៉ុណ្ណោះ។

ដូច្នេះ យោងទៅតាមលក្ខខណ្ឌទាំងពីរខាងលើនេះ រាជការអាចប្រើប្រាស់អំណាចឆន្ទានុសិទ្ធិដោយធ្វើ ឬមិនធ្វើអន្តរាគមន៍ដោយយោងទៅលើលក្ខខណ្ឌទាំងពីនេះ។ ព្រោះលក្ខខណ្ឌទាំងពីរនេះ គឺជាការធានាបាននូវភាពស្របច្បាប់នៃការប្រើប្រាស់អំណាឆន្ទានុសិទ្ធិដូចដែលបានបកស្រាយពីខាងលើមកហើយថា អំពើរបស់រាជការត្រូវមានច្បាប់សំអាង។ ដូច្នេះប្រសិនបើរាជការមិនគោរពលក្ខខណ្ឌទាំងពីរខាងលើនេះទេនោះការ ប្រើប្រាស់អំណាចឆន្ទានុសិទ្ធិរបស់រាជការនឹងក្លាយទៅជាការប្រើប្រាស់អំណាចតាមទំនើងចិត្ត។

**២.១.២. ព្រំដែននៃការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិ**

ដូចដែលបានបញ្ជាក់អំពីអត្ថន័យនៃអំណាចឆន្ទានុសិទ្ធិហើយថា គឺជាអំណាចដែលអាជ្ញាធររដ្ឋបាលប្រើប្រាស់ដោយសេរីដោយមិនមានជាប់ចំណងនឹងវិធានច្បាប់ ដោយគ្រាន់តែគោរពទៅតាមលក្ខខណ្ឌពីរតែប៉ុណ្ណោះរួមមាន៖ លក្ខខណ្ឌសមត្ថកិច្ច និងលក្ខខណ្ឌប្រយោជន៍សាធារណៈ។ ដោយសាតែរាជការប្រើ

[48] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០០៦ ទំព័រទី១៩៧

ប្រាស់អំណាចឆន្ទានុសិទ្ធិជាប្រក្រតីដើម្បីធ្វើសកម្មភាពរបស់ខ្លួន ដូច្នេះអាជ្ញាធររដ្ឋបាលត្រូវតែមានការប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់ដែលកើតឡើងតាមរយៈការប្រើប្រាស់ អំណាចឆន្ទានុសិទ្ធិនេះ។

យោងតាមមូលហេតុខាងលើនេះហើយ សាស្ត្រាចារ្យបារាំងម្នាក់ លោក Marcel Waline សរសេរថា ប្រសិនបើគេឱ្យនិយមន័យខ្លីដល់នីតិរដ្ឋបាល គាត់និយាយថា វាគឺជាការសិក្សាអំពីអំណាចឆន្ទានុសិទ្ធិ និងអំពីការកម្រិតលក្ខខណ្ឌនៃការប្រើប្រាស់អំណាចនេះដើម្បីស្រោចស្រង់សិទ្ធិរាស្ត្រប្រជា។ ចំណែកឯលោកសាស្ត្រាចារ្យ Braibant យល់ថាបញ្ហាអំណាចឆន្ទានុសិទ្ធិជាបញ្ហាសំខាន់មួយក្នុងចំណោមបញ្ហាសំខាន់ៗនៃនីតិរដ្ឋបាលនៅបណ្តាលប្រទេសទាំងអស់នៅលើសាកលលោក។

ដោយសារតែអំណាចឆន្ទានុសិទ្ធិជាអំណាច ដែលប្រើប្រាស់ដោយអាជ្ញាធរដោយពុំមានជាប់ចំណងក្នុងវិធានច្បាប់ ទើបការប្រើប្រាស់អំណាចនេះអាចនាំឱ្យមានផលលំបាកកើតឡើងចំពោះរាស្ត្រប្រជាប្រសិនបើការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិដោយអាជ្ញាធររដ្ឋបាលដោយពុំមានការប្រុងប្រយ័ត្ន។ ការលំបាកនោះនៅត្រង់ថាគឺអាជ្ញាធររដ្ឋាបាលអាចនឹងមាន ការភាន់ច្រឡំចំពោះសេចក្តីសម្រេចដែលខ្លួនបានចេញដោយគិតថាជាការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិ។ ម្យ៉ាងទៀតការត្រួតពិនិត្យការប្រើប្រាស់អំណាចនេះគឺមានការលំបាក។

ជាការពិតណាស់ ចៅក្រមដែលជាអ្នកការពារនូវការគោរពនីត្យានុកូលភាព ពុំមានសិទ្ធិអ្វីទៅធ្វើការត្រួតពិនិត្យនូវការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិ របស់អាជ្ញាធររដ្ឋបាលដែលជាអំណាច មិនជាប់នឹងវិធានច្បាប់ ហើយដែលស្ថិតក្នុងអំណាចនីតិប្រតិបត្តិ ដែលតាមរយៈការបែងចែងអំណាចជាបីតាមអ្វីដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញគឺៈ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការនាំឱ្យចៅក្រមអសមត្ថកិច្ចក្នុងការត្រួតពិនិត្យការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិដោយគោរពទៅតាមការបែងចែងអំណាច។ ថ្វីត្បិតតែការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិមិនជាប់ចំណងនឹងវិធានច្បាប់ តែរាល់ជម្រើស ឬមធ្យោបាយក្នុងកាលានុវត្តភាពមិនត្រូវឱ្យប៉ះទង្គិច ឬបំពាននឹងច្បាប់ ឬបទដ្ឋានគតិយុត្តជាធរមានណាមួយឡើយ។ ដូច្នេះមកដល់ត្រង់ចំណុចនេះនាំឱ្យការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិរបស់អាជ្ញាធររដ្ឋបាលមិនមានភាពងាយស្រួលពេកដែរ ពីព្រោះវាអាចប៉ះទង្គិច ឬបំពាននឹងវិធានច្បាប់ប្រសិនបើរាជការពុំបានប្រុងប្រយ័ត្ន។ ដូច្នេះ ដើម្បីបញ្ចៀសនូវការប៉ះទង្គិច គឺរាជការត្រូវតែមានស្មារតីប្រុងប្រយ័ត្នជាប់ជាមួយនឹងអ្វីដែលហៅថា នីត្យានុកូលភាពផ្ទៃក្រៅ និងនីត្យានុកូលភាពផ្ទៃក្នុង។

**២.១.២.១. នីត្យានុកូលភាពផ្ទៃក្រៅ**

សូមបញ្ជាក់ថាកម្ពុជាពុំសូវមានយុត្តិសាស្ត្រច្រើន ឬស្ទើរតែពុំមានតែម្តងពាក់ព័ន្ធនឹងវិវាទរដ្ឋបាល ដូច្នេះគេពិបាករកអំពីទ្រឹស្តីយុត្តិសាស្ត្រនេះណាស់។ ពាក្យនីត្យានុកូលភាពផ្ទៃក្រៅ គឺជាភាសាច្បាប់ដែលគេប្រើក្នុងនីតិរដ្ឋបាលបារាំង ដូច្នេះដោយកម្ពុជាពុំសូវមានយុត្តិសាស្ត្ររដ្ឋបាលសម្បូរបែបនៅឡើយដូច្នេះសូម

ប្រើប្រើពាក្យ នីត្យានុកូលភាពផ្ទៃក្រៅ ជំនួសសិនដែលអាចជាគតិសម្រាប់ប្រព័ន្ធច្បាប់កម្ពុជាជាពិសេសគឺនីតិរដ្ឋបាលតែម្តងនៅថ្ងៃអនាគត។[49]

ពាក្យ "នីត្យានុកូលភាពផ្ទៃក្រៅ" នេះគឺគេចង់សំដៅទៅលើសមត្ថកិច្ច នីតិវិធី ឬបែបបទ និងទម្រង់។ មិនថាទាំងនៅក្នុងអំណាចឆន្ទានុសិទ្ធិ ឬនៅក្នុងសមត្ថកិច្ចជាប់ចំណងនោះទេ គឺគ្រប់កិច្ចរដ្ឋបាលទាំងអស់ ប្រសិនបើមិនគោរពគោលការណ៍នីត្យានុកូលភាពផ្ទៃក្រៅនេះទេ កិច្ចរដ្ឋបាលនោះច្បាស់នឹងត្រូវមោឃភាពដោយមូលហេតុ អសមត្ថកិច្ច ខុសនីតិវិធី និងទម្រង់។

**ក. សមត្ថកិច្ច**

សមត្ថកិច្ចនៅត្រង់ចំណុចនេះ គឺពុំមែនជាសមត្ថកិច្ចជាប់ចំណងនោះទេ ព្រោះសមត្ថកិច្ចជាប់ចំណងបានចងភ្ជាប់នឹងវិធានច្បាប់ ដូច្នេះមិនងាយនឹងកើតមានអនីត្យានុកូលភាពឡើយ ព្រោះវាបានចូលទៅក្នុងនីតិរដ្ឋបាលទៅហើយ។ សមត្ថកិច្ចនៅទីនេះ គឺសំដៅទៅលើសមត្ថកិច្ចក្នុងវិស័យផ្ទាល់របស់រដ្ឋបាលសាធារណៈ និងសមត្ថកិច្ចក្នុងផ្ទៃក្នុងរដ្ឋបាល។

**ចំណុចទី១. សមត្ថកិច្ចក្នុងវិស័យផ្ទាល់រដ្ឋបាលសាធារណៈ**

សមត្ថកិច្ចក្នុងវិស័យផ្ទាល់របស់រដ្ឋបាលសាធារណៈត្រូវស្ថិតក្នុងព្រំដែនត្រីកោណមួយគឺ៖ ទី១.មិនត្រូវប៉ះពាល់វិស័យច្បាប់ ទី២.មិនត្រូវចូលក្នុងវិស័យតុលាការ និងទី៣.មិនត្រូវចូលក្នុងវិស័យឯកជនដែលច្បាប់បានការពារ ឬចូលទៅជ្រាតជ្រែកក្នុងសកម្មភាព ឬការចាត់ចែងស្របច្បាប់របស់ឯកជន។

**ទី១. មិនត្រូវប៉ះពាល់វិស័យច្បាប់**

នៅក្នុងរដ្ឋធម្មនុញ្ញគេឃើញមាន មាត្រាមួយចំនួនបានកំណត់ពីវិស័យច្បាប់បានច្បាស់លាស់មែនតែឃើញមាត្រាខ្លះនៃរដ្ឋធម្មនុញ្ញបានកំណត់អំពីកិច្ចការណាមួយចំនួនត្រូវតែធ្វើឡើងដោយច្បាប់។ ជាក់ស្តែងយោងតាមមាត្រា១៤៦ថ្មីនៃរដ្ឋធម្មនុញ្ញបានបញ្ញត្តិថា៖ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវស្ថិតនៅក្នុងការគ្រប់គ្រងដោយច្បាប់រៀបចំអង្គការមួយ។ ក្រៅពីនេះពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃសមាជជាតិត្រូវកំណត់ក្នុងច្បាប់នេះបើយោងតាមមាត្រា១៤៩នៃរដ្ឋធម្មនុញ្ញ។ ម្យ៉ាងទៀត សមត្ថកិច្ចនៅក្នុងការអនុម័តច្បាប់ គឺជាសមត្ថកិច្ចរបស់អង្គការនីតិប្បញ្ញត្តិពោល គឺរដ្ឋសភាតែម្តងដោយយោងតាមមាត្រា៩០ថ្មីនៃរដ្ឋធម្មនុញ្ញបានកំណត់ថារដ្ឋសភា គឺជាអង្គការនីតិប្បញ្ញត្តិដែលបំពេញតួនាទី ភារកិច្ចរបស់ខ្លួនដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។ ដូច្នេះ ទោះបីជាច្បាប់បានផ្តល់សិទ្ធិដល់រាជរដ្ឋាភិបាលដែលជាអង្គការនីតិប្រតិបត្តិមានសិទ្ធិក្នុងការធ្វើសេចក្តីព្រាងច្បាប់ក៏ដោយ ក៏ការអនុម័តចុងក្រោយ គឺជារដ្ឋសភាជាអ្នកអនុម័តមិនមែនរដ្ឋាភិបាលនោះទេ។

[49] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០០៦ ទំព័រទី២០១

ដូច្នេះជាខ្លឹមកវិញពាក់ព័ន្ធនឹងកិច្ចការ ឬវិស័យណាដែលត្រូវកំណត់ឬធ្វើឡើងដោយច្បាប់ អាជ្ញាធររដ្ឋបាលក្នុងការចេញនូវបទបញ្ជាផ្សេងៗ ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ដើម្បីកុំឱ្យបំពានទៅលើវិស័យដែលកំណត់ដោយច្បាប់។

**ទី២. មិនត្រូវចូលក្នុងវិស័យតុលាការ**

ចំណុចនេះ គឺអសមត្ថកិច្ចយ៉ាងពិតប្រាកដដែលអាជ្ញាធររដ្ឋបាលមិនងាយនឹងមានការភាន់ច្រឡំបាន។ យោងតាមមាត្រា១៣០ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានបញ្ញត្តិថា គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ។ ក៏ប៉ុន្តែច្បាប់ស្តីពីការគ្រប់គ្រងរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ បានផ្តល់នីតិសម្បទាដល់ក្រុមប្រឹក្សាដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ។

ជាការពិតណាស់ តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ថ្វីត្បិតតែបានផ្តល់ នីតិសម្បទាក្នុងការដោះស្រាយវិវាទនៅមូលដ្ឋានមែន ប៉ុន្តែបានតែរឿងស៊ីវិលតូចតាចដូចជារឿងការប្រាក់រឿងដីធ្លីតែប៉ុណ្ណោះ ផ្ទុយទៅវិញចំពោះរឿងដែលទាក់ទងនឹងការលែងលះ អំពើហឹង្សា និងអំពើផ្សេងទៀតដែលចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈឹមក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក្រុមប្រឹក្សាមិនអាចសម្រេចបានឡើយ។[50] ដូច្នេះ តាមអ្វីដែលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានផ្តល់សិទ្ធិសម្រេចដោះស្រាយវិវាទនេះមិនអាចចាត់ទុកថាជាការផ្ទេរអំណាចតុលាការឡើយ ផ្ទុយទៅវិញ គឺគ្រាន់តែជាការជួយសម្រួលបន្ទុករឿងក្តីកុំឱ្យឡើងទៅតុលាការច្រើនពេក ហើយការដោះស្រាយវិវាទនៅមូលដ្ឋាននេះ គឺវាមានលក្ខណៈសាមញ្ញដែលមិនតម្រូវឱ្យមាននីតិវិធីច្រើនដូចតុលាការនោះទេ។

**ទី៣. មិនត្រូវចូលក្នុងវិស័យឯកជនដែលច្បាប់បានការពារ**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់នូវកម្មសិទ្ធិឯកជនស្របច្បាប់ ទោះជានីតិបុគ្គលក្តី ឬរូបវន្តបុគ្គលក្តី កម្មសិទ្ធិស្របច្បាប់ត្រូវបានការពារដោយច្បាប់។

នេះគឺជាគោលការណ៍គ្រឹះដែលរាជការ ត្រូវតែយកចិត្តទុកដាក់ដើម្បីចៀសវាងការបំពានទៅលើកម្មសិទ្ធិឯកជន។ បើយោងតាមមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញដែលចែងអំពីការទទួលស្គាល់សិទ្ធិស្របច្បាប់ នឹងត្រូវបានគាំពារដោយច្បាប់នៃបុគ្គលឯកជន គឺរដ្ឋធម្មនុញ្ញចង់ផ្តោតទៅលើសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋដែលខ្លួនមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ តែក៏មានបទប្បញ្ញត្តិមួយចំនួននៃរដ្ឋធម្មនុញ្ញ ក៏ដូចជាបទប្បញ្ញត្តិច្បាប់ជាធរមានដទៃទៀតបានចែងអំពីអសមត្ថកិច្ច ឬវិសមិតភាពចំៗតែម្តងចំពោះរាជការ។ ឧទាហរណ៍៖ តាមមាត្រា១៣៩នៃរដ្ឋធម្មនុញ្ញ

[50] មាត្រា៩៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, ព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨

បានចែងថា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានវិសមិតភាពមុខងាររួមមាន៖ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬ អនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព។ ក្រៅពីនេះចំពោះអ្នករាជការនៅក្នុងមុខងារសាធារណៈ វិញក៏ត្រូវបានច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល បានហាមឃាត់ចំពោះអ្នករាជការក្នុងមុខងារ សាធារណៈទាំងអស់មិនអាចចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងហ៊ុនឯកជនដោយផ្ទាល់ ឬដោយប្រយោល។[51] ការចែងអំពីការហាមឃាត់ អំពីវិសមិតភាពមិនមែនមានតែសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងមន្ត្រីរាជការស៊ីវិលក្នុងមុខសាធារណៈ នោះទេ តែសមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល និងមន្ត្រីរាជការដែលស្ថិតនៅក្នុងលក្ខន្តិកៈផ្សេងៗទៀតក៏បានកំណត់នូវការហាមឃាត់នេះផងដែរទៅតាមលក្ខន្តិកៈរៀងៗខ្លួន។

**ចំណុចទី២. សមត្ថកិច្ចក្នុងផ្ទៃក្នុងរដ្ឋបាល**

នៅក្នុងផ្ទៃក្នុងរដ្ឋបាលសមត្ថកិច្ចរបស់អាជ្ញារដ្ឋបាលក៏ត្រូវបានកំណត់ដោយព្រំដែនត្រីកោណមួយដែររួមមាន៖ ទី១.សមត្ថកិច្ចតាមរយៈកាល ទី២.សមត្ថកិច្ចតាមទីតាំង និងទី៣.សមត្ថកិច្ចតាមលំដាប់ថ្នាក់។

**ទី១. សមត្ថកិច្ចតាមរយៈកាល**

តាមរយៈសមត្ថកិច្ចតាមរយៈកាល គឺជាអាជ្ញាធររដ្ឋបាលមិនអាចប្រើអំណាចរបស់ខ្លួនបានមុនពេលខ្លួនចូលកាន់តំណែងឡើយ។ ឬអាចនិយាយម្យ៉ាងទៀតថា អាជ្ញាធររដ្ឋបាលមិនអាចចេញសេចក្តីសម្រេចរបស់ខ្លួនមុនចូលកាន់តំណែងជាផ្លូវការ ហើយនៅពេលដែលបញ្ឈប់ពីមុខតំណែងសមត្ថកិច្ចនេះនឹងត្រូវអស់ទៅតាមនោះដែរ។

យោងតាមលក្ខណៈនេះបង្ហាញថា សមត្ថកិច្ចតាមរយៈកាល គឺជាពេលវេលា ឬអាណត្តិដែលបង្កើតឱ្យមានសមត្ថកិច្ច។ យោងតាមមាត្រា១៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីបានកំណត់ថា នាយករដ្ឋមន្ត្រីជាប្រមុខរាជរដ្ឋាភិបាល ដឹកនាំ បញ្ជារាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ។[52] យោងតាមមាត្រានេះបង្ហាញថា បុគ្គលណាម្នាក់ដែលអាចដឹកនាំ បញ្ជារាល់សកម្មភាពក៏ដូចជាចេញនូវសេចក្តីសម្រេចផ្សេងៗដូចជា៖ ព្រះរាជក្រឹត្យ ឬអនុក្រឹត្យ លុះត្រាតែបុគ្គលនោះត្រូវក្លាយជានាយករដ្ឋមន្ត្រីនៅក្នុងអាណត្តិជាមុនសិនទើបអាចបង្កើតអានុភាពតាមផ្លូវច្បាប់ដើម្បីដឹកនាំ និងចេញបទបញ្ជាបាន។ ដូច្នេះ បើយោងតាមប្រព័ន្ធច្បាប់ខ្មែរយើង ប្រសិនបើបុគ្គលនោះនៅជាបេក្ខជន ឬជាវរជនដែលត្រូវបានព្រះមហាក្សត្រចាត់តាំងឱ្យបង្កើតរាជរដ្ឋាភិបាល នឹងនាំសហការីរបស់ខ្លួនទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភារួចហើយក៏ដោយប្រសិនបើពុំ

[51] មាត្រា៣៥ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល, ព្រះរាជក្រមលេខ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៤

[52] មាត្រា១៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

មានព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូលទេ វរជននោះមិនអាចចេញបទបញ្ជា ឬសេចក្តីសម្រេចផ្សេងៗបានក្នុងសមត្ថកិច្ចរបស់នាយករដ្ឋមន្ត្រីបានឡើយ។

**ទី២. សមត្ថកិច្ចតាមទីតាំង**

សមត្ថកិច្ចតាមទីតាំង ជាសមត្ថកិច្ចដែលកើតឡើងនៅតាមទីកន្លែងដែលមានព្រំដែនសមត្ថកិច្ចច្បាស់លាស់។ មានន័យថា អាជ្ញាធររដ្ឋបាលដែលស្ថិតនៅទីតាំងណាមានសមត្ថកិច្ចចេញសេចក្តីសម្រេចត្រឹមតែព្រំប្រទល់នៃទីតាំងនោះប៉ុណ្ណោះ។ ឧទាហរណ៍៖ អភិបាលរាជធានីភ្នំពេញមានសិទ្ធិចេញសេចក្តីសម្រេចបានតែនៅក្នុងព្រំដែននៃរាជធានីភ្នំពេញតែប៉ុណ្ណោះ មិនអាចចេញសេចក្តីសម្រេចរដ្ឋបាលណាមួយហួសពីព្រំដែននៃរាជធានីភ្នំពេញនោះឡើយ។ ជាក់ស្តែង ដូចជាសេចក្តីសម្រេចរបស់អាជ្ញាធររដ្ឋបាលរាជធានីភ្នំពេញលេខ០៦៨/២១ សសរ. ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ ស្តីពីការអនុវត្តវិធានការរដ្ឋបាលជាបណ្តោះអាសន្នដើម្បីទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ-១៩ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ គេសង្កេតឃើញថា យោងតាមសេចក្តីសម្រេចនេះ គឺអនុវត្តបានតែនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញតែប៉ុណ្ណោះ ដោយមិនអាចអនុវត្តរហូតដល់ខេត្តកណ្តាល ឬខេត្តដទៃទៀតនោះទេ។

ម្យ៉ាងទៀត យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងមាត្រា៥៥ ដែលបានចែងថា ដីកាដែលចេញដោយក្រុមប្រឹក្សាត្រូវប្រតិបត្តិ និងអនុវត្តនៅក្នុងដែនសមត្ថកិច្ចទាំងមូលរបស់ខ្លួនលើកតែដីកាចែងផ្សេងពីនេះ ឬលើកលែងតែច្បាប់ណាមួយបានតម្រូវឱ្យដកចេញពីដីកានូវតំបន់ដែលបានកំណត់ព្រំប្រទល់ច្បាស់លាស់។

សមត្ថកិច្ចតាមទីតាំងនេះ គឺអនុវត្តបានតែចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិតែប៉ុណ្ណោះ។ ដូច្នេះតម្រូវឱ្យអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវមានការប្រុងប្រយ័ត្នចំពោះការចេញសេចក្តីសម្រេច និងអនុវត្តនូវសេចក្តីសម្រេចនោះមិនត្រូវហួសពីព្រំដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឡើយ។

**ទី៣. សមត្ថកិច្ចតាមលំដាប់ថ្នាក់**

នៅក្នុងលំដាប់ថ្នាក់ចាត់តាំងនីមួយៗ ត្រូវមានសមត្ថកិច្ចស្របតាមលំដាប់ថ្នាក់នោះ។ លំដាប់ថ្នាក់ណាធ្វើបានតែនៅក្នុងរង្វង់សមត្ថកិច្ចថ្នាក់នោះ ដោយមិនត្រូវឆ្លងទៅធ្វើសមត្ថកិច្ចថ្នាក់ណាមួយផ្សេងទៀតបានឡើយ។ ជាការពិតណាស់ សមត្ថកិច្ចតាមលំដាប់ថ្នាក់ គឺជាសមត្ថកិច្ចមួយដែលកើតចេញពីបច្ចេកទេសវិសហមជ្ឈការដែលគេច្រើនហៅថាអំណាចតាមឋានានុក្រម។ បើនិយាយឱ្យកាន់តែស៊ីជម្រៅទៅនោះ ការគ្រប់គ្រងរដ្ឋបាលតាមបែបវិសហមជ្ឈការគឺជាបច្ចេកទេសមួយដែលកើតចេញពីការគ្រប់គ្រងរដ្ឋបាលតាមបែបមជ្ឈការ។[53] ការគ្រប់គ្រង

[53] សៀវភៅនីតិរដ្ឋបាលទូទៅ, សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី៤ ឆ្នាំ២០១៧ ទំព័រទី១៦០

រដ្ឋបាលតាមបែបមជ្ឈការ គឺអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមគ្មានសិទ្ធិចេញសេចក្ដីសម្រេចអ្វីនោះឡើយ ហើយដើម្បីបញ្ចៀសនូវការកកស្ទះការងារ គេបានបញ្ចេញនូវបច្ចេកទេសវិសហមជ្ឈការដើម្បីឱ្យអាជ្ញាររដ្ឋបាលថ្នាក់ក្រោមមានសិទ្ធិចេញសេចក្ដីសម្រេចមួយចំនួនតាមរយៈការធ្វើប្រតិភូកម្មពីរដ្ឋបាលថ្នាក់ជាតិ ដែលបង្កើតឱ្យមានសមត្ថកិច្ចតាមលំដាប់ថ្នាក់។ ចំណែកព្រះរាជាណាចក្រកម្ពុជា តាមរយៈមាត្រា២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុង ខណ្ឌបានបញ្ញត្តិថា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើតជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដែលមានគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តំណាងឱ្យអង្គវិសហមជ្ឈការ។ ដូច្នេះ បើយោងតាមច្បាប់នេះឃើញថា ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានធ្វើឡើងតាមគោលការណ៍វិសហមជ្ឈការដែរ ដូច្នេះគេអាចសន្និដ្ឋានបានថា ក្នុងច្បាប់កម្ពុជាក៏មានសមត្ថកិច្ចតាមលំដាប់ដាប់ថ្នាក់ដែរ។

**ខ. នីតិវិធី និងបែបបទ**

បើកាលណាគេនិយាយដល់នីតិវិធី គឺគេច្រើនយល់ថាជាវិធីបង្កើតដោយច្បាប់សភាដូចជា៖ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណីជាដើម។ បើកាលណាគេនិយាយអំពីបែបបទគេច្រើនគេយល់ថា ជាវិធីដែលបង្កើតឡើងដោយអាជ្ញាធររដ្ឋបាលយោងតាមនីតិវិធីដូចជាការបំពេញបែបបទដាក់ពាក្យសុំប្រលងជាដើម។

ចំពោះការចងក្រងនូវនីតិវិធីទាំងឡាយមិនត្រូវឱ្យមាននីតិវិធីស្មុគស្មាញពេកទេ ព្រោះវាអាចនាំឱ្យមានការលំបាកចំពោះរាស្ត្រប្រជាដោយសារកើតរោគការិយាធិបតេយ្យដែលអាចបង្កើតជាអំពើពុករលួយ។ ទន្ទឹមនឹងនេះ គេក៏មិនត្រូវខ្វះវិធានចាំបាច់ដើម្បីឱ្យការគ្រប់គ្រងរដ្ឋបាលកាន់តែមានប្រសិទ្ធភាពនោះដែរ។

វិធានចាំបាច់នៅទីនេះ គឺជាវិធានដែលមានគោលដៅធំៗពីរគឺ៖ ប្រសិទ្ធភាពការងាររដ្ឋបាល និងការការពារសិទ្ធិរបស់រាស្ត្រប្រជា។ ដើម្បីជាគុណប្រយោជន៍ចំពោះកិច្ចរដ្ឋបាល គេនិយមសញ្ញាណនៃនីតិវិធីចំនួនបីយ៉ាងរួមមាន៖

***ទី១. សញ្ញាណវិធីបែបបទសំខាន់ចាំបាច់***

សញ្ញាណវិធីបែបបទសំខាន់ចាំបាច់ គឺជាកិច្ចមួយដែលអាជ្ញាធររដ្ឋបាលត្រូវតែគោរពជាដាច់ខាត បើពុំដូច្នេះទេ នឹងនាំឱ្យមោឃភាពដល់កិច្ចការរបស់ខ្លួន។ បើគេនិយាយនៅក្នុងច្បាប់កម្ពុជាវិញឃើញថា នីតិវិធីចាំបាច់ដែលត្រូវតែគោរពតាមនោះ គឺមានច្រើនមិនថាតែនៅក្នុងរឿងព្រហ្មទណ្ឌ ឬរឿងរដ្ឋប្បវេណីនោះទេ តែនៅក្នុងកិច្ចការរដ្ឋបាលក៏មានដែរ។

គេពិបាកក្នុងរកយុត្តិសាស្ត្ររបស់តុលាការ ដើម្បីធ្វើការបង្ហាញអំពីមោឃភាពនៃកិច្ចការរដ្ឋបាលប្រសិនបើមិនគោរពនីតិវិធីចាំបាច់។ តែគេឃើញមានសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញអំពីមោឃភាពនៃកិច្ចនីតិវិធី

នៃការអនុម័តច្បាប់ដែលជាទឡ្ហីករណ៍អំពីទណ្ឌកម្មនៃការមិនគោរពនីតិវិធីចាំបាច់។ ជាក់ស្តែង ក្រោយបានអនុម័តលើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ប្រធានរដ្ឋសភាបានផ្ញើអត្ថបទច្បាប់នេះជូនព្រឹទ្ធសភាដើម្បីពិនិត្យ និងផ្តល់យោបល់។[54] នៅក្នុងខ្លឹមសារនៃលិខិតលេខ០១៦/៥៩៩/ពស/នវ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩ របស់ប្រធានព្រឹទ្ធសភាជូនប្រធានរដ្ឋសភា ដោយបានបញ្ជាក់ថា ព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិច្បាប់លើកលែងតែមាត្រា៣ ដែលស្នើឱ្យរដ្ឋសភាពិនិត្យពិចារណាឡើងវិញ។ ក្រោយពីបានទទួលយោបល់ពីព្រឹទ្ធសភា រដ្ឋសភានៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៩៩ បានពិនិត្យពិភាក្សាជាលើកទីពីរនូវមាត្រា៣ នៃច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ហើយនៅថ្ងៃទី១៩ ខែឆ្នាំដដែររដ្ឋសភាបានអនុម័តដោយលើកដៃចំនួនសំឡេង៨៨សំឡេង ដោយរក្សាទុកនូវខ្លឹមសារមាត្រា៣ ដដែរ។ ដោយហេតុច្បាប់ស្តីពីការបង្កើតក្រសួង និងរដ្ឋលេខាធិការដ្ឋាន គឺជាច្បាប់រៀបចំអង្គការ ដូច្នេះបន្ទាប់ពីរដ្ឋសភាអនុម័តរួចហើយប្រធានរដ្ឋសភាបានបញ្ជូនច្បាប់នេះឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាព។

ក្រោយពីក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនូវសំណើដើម្បីត្រួតពិនិត្យធម្មនុញ្ញភាពនេះហើយ ក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើការត្រួតពិនិត្យដោយមោឃភាពទៅលើទម្រង់នៃការអនុម័តជាលើកទី២របស់រដ្ឋសភា ដោយសារផ្ទុយនឹងរដ្ឋធម្មនុញ្ញ។ ដោយយោងទៅមាត្រា១១៣ថ្មី វាក្យខ័ណ្ឌទី៧ នៃរដ្ឋធម្មនុញ្ញបានបញ្ញត្តិថា ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទីពីរនេះរដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត។ ដូច្នេះឃើញថា នៅក្នុងនីតិវិធីនៃដំណើរការធ្វើច្បាប់ គឺត្រូវគោរពនូវលក្ខខណ្ឌចាំបាច់ជាច្រើនដែលធ្វើយ៉ាងណាដើម្បីកុំផ្ទុយនឹងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមានបើពុំដូច្នេះទេកិច្ចការទាំងនោះនឹងត្រូវមោឃភាព។

**ទី២. សញ្ញាណវិធីបែបបទឥតប្រយោជន៍**

មានន័យថា ទោះបីមានច្បាប់កំណត់ក៏ដោយ ប្រសិនបើអាជ្ញាធរមិនគោរពតាមច្បាប់នោះក៏មិនអាចនាំឱ្យមោឃភាពនៃកិច្ចការរដ្ឋបាលនោះដែរ ព្រោះរាជការបានដឹងច្បាស់ជាមុនថាវាជាការឥតប្រយោជន៍ ពីព្រោះធ្លាប់មានពិសោធន៍រួចមកហើយ។ ឧទាហរណ៍៖ ក្នុងរឿងកំណែនច្បាប់បានតម្រូវឱ្យអាជ្ញាធររដ្ឋបាលសាកល្បងសុំការយល់ព្រមពីប្រជាពលរដ្ឋជាមុនសិន។ ប៉ុន្តែ អាជ្ញាធរបានដឹងថាពួកគាត់នឹងមិនយល់ព្រមដោយងាយៗទេ ក្រៅតែពីបង្ខំ ដូច្នេះអាជ្ញាធរមិនចាំបាច់ចំណាយពេលទៅពន្យល់ធ្វើអ្វីនោះទៀតទេ ព្រោះវាជាការឥតប្រយោជន៍នាំតែខាតពេលប៉ុណ្ណោះ។ ពាក់ព័ន្ធនឹងនីតិវិធីបែបបទឥតប្រយោជន៍នេះគេឃើញមានប្រើនៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍[55]

[54] សៀវភៅសេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ, បណ្ឌិត ឈុន ណាផត់ បោះពុម្ពឆ្នាំ២០១៧ ទំព័រទី៧៥

[55] ***អស្សាមិករណ៍*** *សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គល និងនីតិបុគ្គលសាធារណៈរួមមាន ដី សំណង់ ដំណាំដាំដុះសម្រាប់ដំណើរការស្ថាបនា និងពង្រីកហេដ្ឋារចនាសម្ព័ន្ធសាធារណៈដែលបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និងយុត្តិធម៌(និយមន័យតាមច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០)។*

ដែលអាចយកមកអះអាងបាននៅក្នុងកិច្ចការស្ថិតក្រោមនីតិរដ្ឋបាល។

យោងតាមមាត្រា១៩ កថាខណ្ឌទី១ នៃច្បាប់ស្តីពីអស្សាមិករណ៍បានប្បញ្ញត្តិថា ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុអាចធ្វើទៅបាន លុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ ឬម្ចាស់សិទ្ធិជាមុនដោយសមរម្យតាមគោលការណ៍ និងនីតិវិធីនៃការទូទាត់សំណង។ យោងតាមមាត្រា១៦ កថាខណ្ឌទី២ នៃច្បាប់ដដែរបានកំណត់ថា ក្នុងការធ្វើការអង្កេត គណៈកម្មាធិការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈនៅក្នុងកម្រិតអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងតំណាងភូមិ ឬសហគមន៍ដែលរងនូវអស្សាមិករណ៍ ដើម្បីផ្តល់ព័ត៌មានជាក់លាក់ ច្បាស់លាស់ និងទទួលបានមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ យោងតាមមាត្រា១០ កថាខណ្ឌទី១ នៃច្បាប់ដដែរ បានបន្តបញ្ញត្តិថា ក្នុងករណីពិសេស និងបន្ទាន់ដែលជាសុវត្ថិភាពសាធារណៈតម្រូវដូចជា៖ ប្រយុទ្ធប្រឆាំងគ្រោះអគ្គីភ័យ ទឹកជំនន់ ភ្លើងឆេះព្រៃ រញ្ជួយដី សង្គ្រាមដែលប្រុងនឹងកើតឡើង ឬការវាយប្រហារដោយអំពើភេរវកម្ម និងស្ថានភាពផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល រាជរដ្ឋាភិបាលអាចធ្វើការដកហូតលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុជាបណ្តោះអាសន្នដោយមិនចាំបាច់ធ្វើ ការពិគ្រោះយោបល់ឡើយហើយត្រូវប្រគល់ជូនម្ចាស់អចលនវត្ថុ ឬម្ចាស់សិទ្ធិវិញនៅពេលចប់ការដកហូត។

យោងតាមមាត្រា១៩ និងមាត្រា១៦ នៃច្បាប់ស្តីពីអស្សាមិករណ៍មានន័យថា រាល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុត្រូវមានការពិគ្រោះយោបល់ និងយល់ព្រមពីម្ចាស់សិទ្ធិជាមុនសិន។ តែផ្ទុយមកវិញ ប្រសិនបើអាជ្ញាធរយល់ឃើញថា វាជាការចាំបាច់ដែលត្រូវធ្វើអស្សាមិករណ៍ភ្លាមៗក្នុងករណីពិសេសណាមួយដែលដូចជា៖ ទឹកជំនន់ ភ្លើងឆេះព្រៃ ឬសង្គ្រាមជាដើម ដូច្នេះអាជ្ញាធរពុំចាំបាច់មានការពិគ្រោះយោបល់យល់ព្រមជាមុននោះឡើយដោយយល់ឃើញថាវាជាការឥតប្រយោជន៍ព្រោះថាការពិគ្រោះយោលបល់មិនប្រាកដ ថាភាគីដែលទទួលរងនូវអស្សាមិករណ៍យល់ព្រមនោះដែរ ម្យ៉ាងទៀតការពិគ្រោះយោបល់អាចចំណាយពេលយូរ ដូច្នេះការដកហូតនេះ មិនផ្ទុយនឹងច្បាប់ឡើយដែលស្របតាមមាត្រា១០ នៃច្បាប់ស្តីពីអស្សាមិករណ៍។ ដូច្នេះយោងតាមការបកស្រាយឃើញថា នៅក្នុងច្បាប់កម្ពុជាពាក់ព័ន្ធនឹងការធ្វើអស្សាមិករណ៍ច្បាប់បានអនុញ្ញាតឱ្យអាជ្ញាធរមិនចាំបាច់គោរពនូវទម្រង់បែបបទដែលឥតប្រយោជន៍នោះបាន។

**ទី៣. សញ្ញាណវិធីបែបបទដែលធ្វើមិនកើត**

សុភាសិតមួយពោលថា រឿងធ្វើមិនកើតគ្មាននរណាត្រូវតែធ្វើឡើយ។ ឧទាហរណ៍៖ នៅក្នុងនីតិវិធីដាក់ វិន័យចំពោះអ្នករាជការដែលត្រូវទទួលការចោទប្រកាន់ ប្រសិនមន្ត្រីរាជការនោះបាត់ខ្លួនរកពុំឃើញក្នុងរយៈពេល១៥ថ្ងៃជាបន្តបន្ទាប់ក្រោយពីការអញ្ជើញពីរលើក ត្រូវដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ។

បើផុតរយៈពេល៣ខែ បើសាមីខ្លួនដែលត្រូវចោទប្រកាន់នោះនៅតែពុំព្រមចូលខ្លួន ឬរកមិនឃើញក្រោយការជូនដំណឹង២ដង ច្បាប់តម្រូវឱ្យលុបឈ្មោះចេញពីក្របខ័ណ្ឌ។ ក្នុងករណីផ្សេងទៀត ឧបមាថាអាជ្ញាធរត្រូវសួរយោបល់ពីស្ថាប័នណាមួយទើបច្បាប់អនុញ្ញាតឱ្យធ្វើសេចក្តីសម្រេច។ ដូច្នេះប្រសិនបើស្ថាប័ននោះមិនរវល់ឆ្លើយមិនផ្តល់យោបល់សោះ ទោះបីមានការរំលឹកសុំយ៉ាងណាក៏ដោយ ក៏អាជ្ញាធរដែលធ្វើការស្នើសុំនោះអាចធ្វើសេចក្តីសម្រេចបានដោយមិនចាំបាច់មានយោបល់នោះឡើយ។

**គ. ទម្រង់**

ចំពោះទម្រង់គឺបានបកស្រាយពីខាងលើរួចមកហើយពាក់ព័ន្ធនឹងការយកទម្រង់ផ្សេងៗដែលត្រូវយោងទៅតាមច្បាប់ និងបទដ្ឋានគតិយុត្តដែលបានកំណត់។ នៅក្នុងច្បាប់កម្ពុជាក្រៅពីទម្រង់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងដីកាពុំមានវិធានណាបង្ខំឱ្យត្រូវគោរពទម្រង់របៀបណា សរសេររបៀបណា ធ្វើសេចក្តីសម្រេចដោយកាយវិការ ឬវាចារបៀបណាដែរ។

**២.១.២.២. នីត្យានុកូលភាពផ្ទៃក្នុង**

ច្បាប់ និងបទបញ្ជារដ្ឋបាលតែងមានគោលដៅ និងកម្មវត្ថុ។ គោលដៅ និងកម្មវត្ថុនៃច្បាប់ ឬបទបញ្ជារដ្ឋបាល គឺជានីត្យានុកូលភាពផ្ទៃក្នុង។[56]

អាជ្ញាធរដែលធ្វើសកម្មភាព ឬធ្វើកិច្ចការរដ្ឋបាលខុសនឹងគោលដៅនៃច្បាប់ ឬបទបញ្ជារដ្ឋបាលត្រូវចាត់ទុកថាបានប្រព្រឹត្តបន្លំអំណាច។ អាជ្ញាធរដែលធ្វើសកម្មភាព ឬធ្វើកិច្ចការរដ្ឋបាលខុសនឹងកម្មវត្ថុនៃច្បាប់ ឬបទបញ្ជារដ្ឋបាលត្រូវចាត់ទុកថាបានប្រព្រឹត្តបំពានច្បាប់។

**ក. ការបន្លំអំណាច**

គោលដៅនៃច្បាប់ ឬបទបញ្ជា ជួនកាលមានចែងច្បាស់ ប៉ុន្តែជួនកាលមិនមានការចែងច្បាស់ទេ តែចៅក្រមអាចរកឃើញដោយយោងទៅលើស្មារតីនៃច្បាប់ ឬបទបញ្ជានោះ។ ដូច្នេះ ទើបគេនិយាយថា ដោយយោងទៅលើអត្ថបទ ឬស្មារតីនៃច្បាប់ជាដើម។ ជាក់ស្តែងយោងតាមមាត្រា២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រីបានចែងថា ច្បាប់នេះមានគោលដៅ កំណត់អំពីសមាសភាព សមត្ថកិច្ច និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រីដែលជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។[57] គេឃើញថា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីឆ្នាំ២០១៨គឺបានចែងច្បាស់អំពីគោលដៅនៃច្បាប់ដែលមានភាពងាយស្រួលចំពោះចៅក្រមក្នុងការកំណត់គោលដៅនៃច្បាប់។

---

[56] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០០៦ ទំព័រទី២១១

[57] មាត្រា២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨

តែទន្ទឹមនឹងនេះ មានច្បាប់មួយចំនួនទៀតពុំបានកំណត់អំពីគោលដៅឱ្យបានច្បាស់លាស់ទេ ដូចជាច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ពុំមានប្រើពាក្យថាច្បាប់នេះមានគោលដៅដូចច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រីឡើយ។ តែដោយយោងទៅតាមស្មារតីនៃច្បាប់នេះ គេអាចនិយាយបានថាច្បាប់នេះមានគោលដៅរៀបចំ សហលក្ខន្តិកៈរួមមួយសម្រាប់មន្ត្រីរាជការស៊ីវិលក្រៅពីក្រុមមន្ត្រីតុលាការ និងក្រុមមន្ត្រីនីតិប្បញ្ញត្តិ។ ការបន្លំអំណាចមានពីរសណ្ឋានគឺ ទី១-ការបន្លំអំណាចក្នុងគោលបំណងផលប្រយោជន៍ផ្ទាល់ខ្លួន និងទី២-ការបន្លំអំណាចក្នុងគោលដៅផលប្រយោជន៍ទូទៅដែលមិនមែនជាផលប្រយោជន៍ទូទៅដែលច្បាប់ ឬបទបញ្ជាចង់សំដៅយក។

**ទី១. ការបន្លំអំណាចក្នុងផលប្រយោជន៍ផ្ទាល់ខ្លួន**

ការបន្លំអំណាចប្រភេទនេះ គឺកើតឡើងតាមរយៈការសងសឹកផ្ទាល់ខ្លួន និងក្នុងគំនិតរកស៊ីផ្ទាល់ខ្លួន។

**ការសងសឹកផ្ទាល់ខ្លួន៖** អាជ្ញាធរបានប្រើអំណាចដែលច្បាប់បានផ្តល់នីតិសម្បទាឱ្យដើម្បីជាការសងសឹកនឹងរឿងផ្ទាល់ខ្លួន។ ឧទាហរណ៍៖ អភិបាលស្រុកបានចេញដីកាបណ្តេញបុគ្គលិករបស់ក្រុមប្រឹក្សាណាមួយជាការសងសឹក។ ឧទាហរណ៍៖ លោក **ក** ក្រោយពីបានតែងតាំងជានាយករដ្ឋមន្ត្រីបានធ្វើសេចក្តីព្រាងច្បាប់ដើម្បីដាក់ទណ្ឌកម្មទៅលើ លោក **ខ** ដែលជាអតីតនាយករដ្ឋមន្ត្រីជាការសងសឹក ការធ្វើដូច្នេះគឺមិនអាចធ្វើទៅបានឡើយដោយយោងទៅតាមគោលការណ៍អប្រតិសកម្មនៃច្បាប់។[58]

**ក្នុងគំនិតរកស៊ីផ្ទាល់ខ្លួនវិញ៖** លោក **ក** ដែលជាមេឃុំបានធ្វើបាបលើលោក **ខ** ដែលជាប្រជាពលរដ្ឋសាមញ្ញដោយបណ្តេញលោក **ខ** មិនឱ្យលក់បន្លែត្រីសាច់នៅក្នុងផ្សារ ពីព្រោះលោក **ក** យល់ឃើញថាលោក **ខ** ដណ្តើមទីផ្សារលក់ត្រីសាច់ពីកូនរបស់ខ្លួន។ ប្រាំឆ្នាំក្រោយមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់លោក**ខ** បានឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ហើយគណបក្សរបស់លោក **ខ** បានឈ្នះ និងលោក **ខ** ត្រូវតែងតាំងជាមេឃុំ។ ក្រោយពីបានប្រកាសសុពលភាពរួចហើយលោក **ខ** បានប្រើសិទ្ធិអំណាចជាមេឃុំនេះដើម្បីសងសឹកទៅលើលោក **ក** វិញ។

**ទី២. ការបន្លំអំណាចក្នុងផលប្រយោជន៍ទូទៅដែលខុសពីច្បាប់កំណត់**

មានន័យថា អាជ្ញាររដ្ឋបាលមានគោលដៅរកផលប្រយោជន៍ទូទៅដែរ តែផលប្រយោជន៍នោះមិនមែនជាផលប្រយោជន៍ដែលច្បាប់ ឬបទបញ្ជាបានចែងនោះទេ។ ជាក់ស្តែងអនុក្រឹត្យលេខ៥៧ អនក្រ.បក. ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ

[58] មាត្រា១០ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ បញ្ញត្តិថា បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាងនឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ។

និងប្រកបដោយធ្ងន់ធ្ងរផ្សេងទៀត ដោយយោងតាមស្មារតីនៃបទបញ្ជានេះ គឺមានគោលដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ តែប្រសិនបើភ្នាក់ងាររដ្ឋបាលដែលទទួលតួនាទីធ្វើប្រតិបត្តិការនេះ បាននាំចូលថ្នាំព្យាលបាលពីបរទេសដោយគ្មានការអនុញ្ញាតពីរដ្ឋាភិបាល ដើម្បីព្យាបាលប្រជាពលរដ្ឋដែលកើតជំងឺឆ្លង ឬប្រើប្រាស់វិធីព្យាលបាលដែលមិនស្របតាមបច្ចេកទេសវេជ្ជសាស្ត្រនោះនឹងក្លាយជាការបន្លំអំណាចតុលាការអាចចោទប្រកាន់បានទោះបីក្នុងគោលដៅផលប្រយោជន៍សាធារណៈក៏ដោយ។

**ខ. ការបំពានច្បាប់**

ដូចបានបញ្ជាក់ពីខាងលើមកហើយថា អាជ្ញាធរដែលធ្វើសេចក្តីសម្រេច ឬកិច្ចការរដ្ឋបាលដែលខុសនឹងកម្មវត្ថុនៃច្បាប់ ឬបទបញ្ជាត្រូវចាត់ទុកថាជាការបំពានច្បាប់ ឬបទបញ្ជា។ កម្មវត្ថុនៃច្បាប់ ឬបទបញ្ជា គឺរាល់បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងមាត្រានៃច្បាប់ ឬបទបញ្ជា។[59] ការបំពានលើបទប្បញ្ញត្តិទាំងនេះជាការបំពានច្បាប់។ ក្នុងន័យទូលាយការបំពានច្បាប់ គឺជាការបំពានវិធាន និងឋានានុក្រមនៃច្បាប់។ គេសង្កេតឃើញមានច្រើនទិដ្ឋភាពតែគេអាចបញ្ចូលជាចំណុចពីរធំៗគឺៈ ការបំពានផ្ទាល់លើវិធានច្បាប់ និងការបំពានមិនផ្ទាល់លើវិធានច្បាប់។

**ចំណុចទី១. ការបំពានផ្ទាល់លើវិធានច្បាប់**

ការបំពានផ្ទាល់លើវិធានច្បាប់ គឺចៅក្រមគ្រាន់តែធ្វើការផ្ទៀងផ្ទាត់អត្ថបទបទបញ្ជារដ្ឋបាល ដែលគេសុំឱ្យពិនិត្យនីត្យានុកូលភាពទៅនឹងអត្ថបទច្បាប់ ឬទៅនឹងបទបញ្ជាតាមនីតិឋានានុក្រមទៅជាការស្រេច។ បើឃើញថាស្របគ្នា គឺត្រឹមត្រូវ បើឃើញថាមិនស្របគ្នាទេ គឺខុស។ ក្នុងករណីពិនិត្យអំពីនីត្យានុកូលភាពនេះ នៅកម្ពុជាគេឃើញមានច្រើនចំពោះការស្នើសុំឱ្យមានការពិនិត្យធម្មនុញ្ញភាពនៃអត្ថបទច្បាប់ទៅនឹងរដ្ឋធម្មនុញ្ញ ដែលក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ តែចំពោះបទបញ្ជារដ្ឋបាលណាមួយដែលត្រូវបានគេប្តឹងដើម្បីឱ្យតុលាការត្រួតពិនិត្យនីត្យានុកូលភាពសឹងតែមិនទាន់ឃើញមាននៅឡើយទេ។

**ចំណុចទី២. ការបំពានមិនផ្ទាល់លើវិធានច្បាប់**

ទិដ្ឋភាពនៃការបំពានប្រភេទនេះមានច្រើនយ៉ាង។ គេត្រូវវាយតម្លៃឱ្យបានត្រឹមត្រូវនូវហេតុការណ៍ដែលនាំឱ្យមានការសម្រេចរដ្ឋបាលដែលអ្នកដើមបណ្តឹងបានប្តឹងជំទាស់នោះ។ ចៅក្រមប្រើអំណាចស៊ើបអង្កេតរបស់ខ្លួនដើម្បីរកការពិតលើអង្គហេតុរួចទើបធ្វើការសម្រេចតាមអង្គច្បាប់។ ក្នុងក្របខ័ណ្ឌនេះ នីត្យានុកូលភាពអាចបាត់បង់ក្នុងករណីដូចតទៅៈ

---

[59] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០០៦ ទំព័រទី២១៥

➢ **ការភាន់ច្រឡំច្បាប់**

សេចក្ដីសម្រេចរដ្ឋបាលណាដែលយោង និងអនុវត្តដោយភាន់ច្រឡំអត្ថបទច្បាប់ ឬអត្ថបទណាមួយនៃបទបញ្ញាដែលពុំមានទាក់ទងទៅនឹងកម្មវត្ថុនៃសេចក្ដីសម្រេចនោះសោះជាសេចក្ដីសម្រេចខុសច្បាប់។ ការភាន់ច្រឡំនេះអាចបណ្ដាលមកពីការបកស្រាយភាន់ច្រឡំ ឬមកពីមិនបានដឹងថា អត្ថបទដែលយោងនោះត្រូវបានបាត់បង់មូលដ្ឋានស្របច្បាប់អស់ទៅហើយ។ ភាសាយុត្តិសាស្ត្របារាំងហៅថា ខ្វះមូលដ្ឋានច្បាប់។ ចៅក្រមមានកាតព្វកិច្ច ត្រូវលើកឡើងជាស្វ័យប្រវត្តិខានមិនបាននូវការខ្វះមូលដ្ឋានដ្ឋានស្របច្បាប់។ ចៅក្រមអាចលើកមកជំនួសណាមួយមកវិញប្រសិនបើជាមានមូលដ្ឋាននោះ ហើយបើខ្លឹមសារចុងក្រោយនៃសេចក្ដីសម្រេចរដ្ឋបាលនៅតែត្រឹមត្រូវដដែល។ គេហៅថា អាទេសកម្មមូលដ្ឋានស្របច្បាប់ ។[60]

➢ **ការភាន់ច្រឡំអង្គហេតុ**

គេត្រូវពិនិត្យទៅលើអង្គហេតុពីរចំណុចគឺ៖

- ត្រូវពិនិត្យមើលថាតើព្រឹត្តិហេតុមានពិតប្រាកដមែន ឬមិនមែន? ប្រសិនបើគ្មានទេចៅក្រមត្រូវរំលាយទុកជាមោឃៈនូវសេចក្ដីសម្រេចរដ្ឋបាលណាដែលអះអាងថាមានព្រឹត្តិហេតុ។ ឧទាហរណ៍៖ លោក **ក** ជាមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបាន អភិបាលខេត្តចេញដីកាព្យួរការងារតាមពាក្យស្នើសុំរបស់សាមីខ្លួន តែជាការពិតនោះលោក **ក** ពុំបានស្នើសុំឱ្យមានការព្យួរការងារនោះទេ។
- ត្រូវពិនិត្យមើលថាតើមានការភាន់ច្រឡំក្នុងការដាក់គុណសម្បត្តិគតិយុត្តឱ្យព្រឹត្តហេតុ ឬទេ? ក្នុងករណីសមត្ថកិច្ចជាប់ចំណងចៅក្រមធ្វើការត្រួតពិនិត្យធម្មតាលើគុណសម្បត្តិគតិយុត្តរបស់ព្រឹត្តិហេតុ ដែលមានចែងយ៉ាងច្បាស់រួចទៅហើយនៅក្នុងអត្ថបទច្បាប់។ ក្នុងករណីអំណាចឆន្ទានុសិទ្ធិវិញ ចៅក្រមធ្វើការត្រួតពិនិត្យតិចតួចបំផុតតាមអ្វីដែលគេហៅថាការភាន់ច្រឡំច្បាស់ក្រឡែត ក្នុងការវាយតម្លៃព្រឹត្តិហេតុ។ ដូច្នេះ មកដល់ត្រង់ចំណុចនេះ គេធ្វើការបែងចែករវាងការភាន់ច្រឡំមូលវិចារណ៍ និងការភាន់ច្រឡំច្បាស់ក្រឡែត។ ក្រៅពីនេះ នៅមានវិធានមួយទៀតដែលគេហៅថាតុល្យការ។

**ទី១. ការភាន់ច្រឡំមូលវិចារណ៍**

នៅក្នុងវិស័យដែលអាជ្ញាធររដ្ឋបាលមានអំណាចឆន្ទានុសិទ្ធិពិតប្រាកដ ចៅក្រមពុំមានសិទ្ធិត្រួតពិនិត្យអ្វីទាំងអស់។ អាជ្ញាធររដ្ឋបាលមានអំណាចគ្រប់គ្រាន់ក្នុងការវាយតម្លៃសភាពការណ៍ ការជ្រើសរើសមធ្យោបាយ និងការប្រើប្រាស់ពេលវេលា ពោលគឺក្នុងការជ្រើសរើសកាលានុវត្តភាពដើម្បីធ្វើ ឬមិនធ្វើអន្តរាគមន៍។ អំណាចក្នុងការវាយតម្លៃសភាពការណ៍នេះហៅថា អំណាចមូលវិចារណ៍។ ចៅក្រមគ្មានសិទ្ធិលូកដៃទៅក្នុងអំណាច

---

[60] *អាទេសកម្ម មានន័យថាជាការដាក់ជំនួស*

មូលវិចារណ៏របស់អាជ្ញាធរបានឡើយ។ ការធ្វើមូលវិចារណ៍របស់អាជ្ញាធររដ្ឋបាលក៏អាចកើតមានការភាន់ច្រឡំដែរអាចបង្កើតឱ្យមានការលំបាកចំពោះអ្នកដែលទទួលរងឥទ្ធិពលពីហេតុការណ៍នោះ។

តាមរយៈការប្រើប្រាស់អំណាចថៅហ្វាយនាយ ឬអំណាចឋានានុក្រម អាជ្ញាធរថ្នាក់លើអាចធ្វើការកែតម្រូវ ឬធ្វើការបដិសេធនូវអ្វីដែលបានធ្វើខុសដោយអាជ្ញាធរថ្នាក់ក្រោម ហើយអាចធ្វើដាក់ទណ្ឌកម្មរដ្ឋបាលខាងវិន័យថែមទៀតផងក៏បានលើមន្ត្រីដែលបានធ្វើខុស។ ដូច្នេះហើយ នៅក្នុងវង្វង់នៃការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិតាមរយៈ ការប្រើប្រាស់អំណាចមូលវិចារណ៍របស់អាជ្ញាធររដ្ឋបាលចៅក្រមគ្មានសិទ្ធិអ្វីដើម្បីត្រួតពិនិត្យឡើយ ដែលនេះជាការសបញ្ជាក់អំពីការទទួលស្គាល់អំណាចឆន្ទានុសិទ្ធិ ប៉ុន្តែកុំឱ្យការភាន់ច្រឡំនេះមានលក្ខណៈហួសហេតុពេកដែលអាចបណ្តាលជាការប្រើប្រាស់អំណាចតាមទំនើងចិត្ត។

**ទី២. ការភាន់ច្រឡំច្បាស់ក្រឡែត**

ការភាន់ច្រឡំច្បាស់ក្រឡែត គឺជាការភាន់ច្រឡំយ៉ាងច្បាស់ឥតប្រកែកបានឡើយ មានន័យថាទោះបីជាជនសាមញ្ញក៏អាចយល់បាន ដោយសារតែវាផ្ទុយនឹងវិចារណញ្ញាណខ្លាំងពេក។ ឧទាហរណ៍៖ រាជការបានសងសំណងជូនម្ចាស់អចលនវត្ថុមុននឹងធ្វើអស្សាមិករណ៍ដោយការភាន់ច្រឡំនូវចំនួនទឹកប្រាក់។

ការភាន់ច្រឡំច្បាស់ក្រឡែតនៃមូលវិចារណ៍ ឬការវាយតម្លៃសភាពការណ៍ក្លាយទៅជាវិធានយុត្តិសាស្ត្រមួយដែលចៅក្រមរដ្ឋបាលអនុវត្តសម្រាប់ការកាត់ក្តី ហើយនិងជាមធ្យោបាយដែលបណ្តឹងតែងតែយកប្រើជាញឹកញាប់។ ប៉ុន្តែ ចៅក្រមមិនងាយនឹងឱ្យឈ្នះតាមធ្យោបាយនេះឡើយ ពីព្រោះចៅក្រមមានឆន្ទៈដើម្បីកុំឱ្យរាំងស្ទះដល់ការងាររបស់អាជ្ញាធររដ្ឋបាល។

**ទី៣. ការពិនិត្យតុល្យការ**

ផ្ទុយពីវិធានយុត្តិសាស្ត្រនៃការភាន់ច្រឡំច្បាស់ក្រឡែតនៃមូលវិចារណ៍ដែលជាវិធានសម្រាប់ធ្វើការត្រួតពិនិត្យអប្បបរមា ការត្រួតពិនិត្យតុល្យការ គឺជាវិធានត្រួតពិនិត្យអតិបរមា ឬវិធានអតិបរមា។

គោលការណ៍តុល្យការ គឺជាវិធានថ្មីមួយដើម្បីផ្តល់ជាមូលដ្ឋានក្នុងការថ្លឹងថ្លែងអំពីគុណសម្បត្តិ និងគុណវិបត្តិ ឬផលប្រយោជន៍ និងផលប៉ះពាល់ ដែលអាជ្ញាធររដ្ឋបាលត្រូវធ្វើយ៉ាងណាឱ្យប្រយោជន៍សាធារណៈ ត្រូវធំជាងផលប៉ះពាល់ បើពុំដូច្នេះទេអាចនាំឱ្យមោឃភាពនៃកិច្ចរដ្ឋបាលនោះ។

## ២.២. នីត្យានុកូលភាពនៃអញ្ញត្រកម្ម

អញ្ញត្រកម្មមានន័យថាជាករណីពិសេស។ នីត្យានុកូលភាពនៃអញ្ញត្រកម្ម សំដៅទៅលើនីត្យានុកូភាពនៃករណីពិសេសប្លែកពីធម្មតា។ ពោលគឺជាស្ថានភាពមួយដែលសកម្មភាពមួយដែលធ្វើឡើងដោយរាជការអាចស្ថិតនៅក្រៅច្បាប់តែមានភាពស្របច្បាប់ ឬជាសកម្មភាព ឬអំពើដែលត្រូវមានទោសធ្ងន់ ប៉ុន្តែត្រូវទទួលទោសស្រាល ឬគ្មានទោសតែម្តង។

ជាគោលការណ៍ រាល់អំពើរបស់រាជការត្រូវស្ថិតក្នុងនីត្យានុកូលភាពយ៉ាងខ្ជាប់ខ្ជួន។ ប៉ុន្តែគេសង្កេតឃើញមានអញ្ញត្រកម្មពីរប្រភេទគឺៈ ប្រភេទទី១ ទាក់ទងនឹងភាពអចិន្ត្រៃយ៍ និងប្រភេទទី២ ទាក់ទងនឹងវិសាលភាពនៃគោលការណ៍នីត្យានុកូលភាព គឺជាអ្វីដែលគេហៅថាកាលៈទេសៈពិសេស។ ក្នុងប្រភេទទី១ គឺរាជការមិនស្ថិតជាប់នឹង ភាពអចិន្ត្រៃយ៍នៃគោលការណ៍នីត្យានុកូលភាព និងប្រភេទទី២ គឺអ្វីដែលគេហៅថា រដ្ឋាភិបាលកិច្ច។[61]

**២.២.១. កាលៈទេសៈពិសេស**

គឺជាទ្រឹស្តីមួយដែលចេញពីយុត្តិសាស្ត្ររដ្ឋបាលបារាំង។ ចំណែកនៅកម្ពុជាវិញ កាលៈទេសៈពិសេសថ្វីត្បិតតែមិនទាន់មាន យុត្តិសាស្ត្ររដ្ឋបាលពាក់ព័ន្ធនឹងទ្រឹស្តីកាលៈទេសៈពិសេសក៏មិនមានន័យថា កម្ពុជាមិនធ្លាប់កើតមានកាលៈទេសៈពិសេសនោះឡើយ។ ដើម្បីយល់កាន់តែច្បាស់អំពីកាលៈទេសៈពិសេសក្រោមច្បាប់កម្ពុជា គួរធ្វើការបកស្រាយអំពីទ្រឹស្តីនៃកាលៈទេសៈពិសេសជាមុនសិន។

**២.២.១.១. ទ្រឹស្តី និងលក្ខខណ្ឌនៃកាលៈទេសៈពិសេស**

កាលៈទេសៈពិសេសអាចកើតឡើងដោយសារសង្គ្រាម ឬស្ថានភាពវឹកវរផ្សេងទៀតដែលច្បាប់ធម្មតាមិនអាចអនុវត្តបាន ឬបើអនុវត្តសកម្មភាពទៅតាមច្បាប់ធម្មតា គឺមិនអាចទប់ទល់នូវស្ថានភាពនោះបានទេ ឬគេអាចនិយាយបានថា នៅក្នុងស្ថានភាពធម្មតាសេរីភាពបុគ្គលត្រូវមកមុនអ្វីៗទាំងអស់ ចំណែកនៅក្នុងកាលៈទេសៈពិសេស សង្គ្រាម ឬភាពវឹកវរ ស្ថិរភាព និងភាពស្របច្បាប់របស់រដ្ឋត្រូវដើរមុនអ្វីៗទាំងអស់។ ដូច្នេះហើយទើបមានទ្រឹស្តីនីត្យានុកូលភាពនៃអញ្ញត្រកម្មនេះកើតឡើង។

**ក. អត្ថន័យ និងលក្ខខណ្ឌនៃកាលៈទេសៈពិសេស**

កាលៈទេសៈពិសេស គឺជាស្ថានភាពវិបត្តិដ៏ធំ ដែលគំរាមកំហែងដល់ផលប្រយោជន៍សាធារណៈរបស់ប្រទេសជាតិ ដល់និរន្តរភាពនៃដំណើរការសេវាសាធារណៈ ហើយដែលអាជ្ញាធររដ្ឋបាលពុំអាចទប់ទល់បាន បើសិនជាត្រូវស្ថិតជាប់នៅក្នុងនីត្យានុកូលភាពធម្មតា។ ពោលជាស្ថានការណ៍ដែលបណ្តាលឱ្យរាជការព្យួរការអនុវត្តវិធានគតិយុត្តធម្មតាដោយប្រើនីត្យានុកូលភាពពិសេស ក្រោមការត្រួតពិនិត្យជាបច្ឆាកាលរបស់តុលាការយ៉ាងតឹងតែង។

កាលៈទេសៈពិសេសមិនត្រឹមតែជាស្ថានភាពនៅក្នុងសង្គ្រាមប៉ុណ្ណោះទេ តែនៅក្នុងស្ថានភាពផ្សេងទៀតគេក៏អាចចាត់ទុកជាកាលៈទេសៈពិសេសបានដែរ ប្រសិនបើមានលក្ខខណ្ឌទាំងបីដូចខាងក្រោមៈ

- មានស្ថានភាពមិនធម្មតាពិតប្រាកដមែន
- មានគ្រោះថ្នាក់ដល់ប្រយោជន៍សាធារណៈជាក់ស្តែង

[61] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០០៦ ទំព័រទី២២៧

- ច្បាប់ធម្មតាមិនអាចទប់ទល់បាន បើសិនជាធ្វើតែតាមច្បាប់ធម្មតា។[62]

ដូច្នេះនៅពេលដែលមានការធ្វើសកម្មភាព ឬអំពើណាមួយដោយអាជ្ញាធររដ្ឋបាលស្ថិតនៅក្នុងស្ថានភាពមួយដែលផ្ទុយទៅនឹងវិធានច្បាប់ ចៅក្រមត្រូវពិនិត្យថាតើស្ថានភាពនោះគោរពនូវលក្ខខណ្ឌទាំងបីខាងលើនេះដែរ ឬទេ?

### ខ. ប្រភេទនៃកាលៈទេសៈពិសេស

កាលៈទេសៈពិសេស គឺជាស្ថានភាពមួយដែលកម្រនឹងកើតមាន ប៉ុន្តែគេអាចរាប់បានមានបីប្រភេទធំៗគឺ៖

- សង្គ្រាមដូចជា៖ សង្គ្រាមលោក សង្គ្រាមស៊ីវិល ឬសង្គ្រាមនៅក្នុងស្រុកជាដើម។
- ព្រឹត្តិការណ៍ចលាចលក្នុងសង្គមដូចជា៖ ការបោះបោរទ្រង់ទ្រាយធំ ការធ្វើបាតុកម្ម ឬការធ្វើកូដកម្មនៅទូទាំងប្រទេសដែលធ្វើឱ្យរាំងស្ទះដល់ការប្រព្រឹត្តទៅនៃសេវាសាធារណៈ។
- មហន្តរាយធម្មជាតិដូចជា៖ ការផ្ទុះភ្នំភ្លើង គ្រោះទឹកជំនន់ជាដើម។

### គ. វិបាកនៃកាលៈទេសៈពិសេស

កាលណាមានស្ថានភាពកាលៈទេសៈពិសេសកើតឡើងនាំឱ្យមានផលវិស័យចំនួនបីកើតឡើងរួមមាន៖

- ទីមួយ រាជការក្នុងស្ថានភាពកាលៈទេសៈពិសេសអាចមិនគោរពវិធានគតិយុត្តធម្មតាបាន ពីព្រោះគេត្រូវប្រឈមមុខនឹងស្ថានភាពដ៏ធ្ងន់ធ្ងរឱ្យបានជោគជ័យជាដាច់ខាត។ អ្នកដែលគ្មានសមត្ថកិច្ចក៏អាចចាត់ការបាន គេឈប់គិតការគោរពបែបបទទម្រង់ធម្មតាទាំងអស់។ ស្ថានភាពនេះនៅកម្ពុជា គេឃើញមានអនុក្រឹត្យស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាច សាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត បានបញ្ញត្តិអំពីការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ។[63] ថ្វីត្បិតតែអនុក្រឹត្យនេះបានបញ្ញត្តិអំពីការបំបិទសិទ្ធិធ្វើដំណើររបស់ប្រជាពលរដ្ឋដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ តែដើម្បីធានានិរន្តរភាពផលប្រយោជន៍សាធារណៈអនុក្រឹត្យនេះ គឺមានភាពស្របច្បាប់ទៅវិញ។[64]
- ទីពីរ រដ្ឋត្រូវស្ថិតជាប់នឹងអ្វីដែលហៅថានីត្យានុកូលភាពនៃវិបត្តិដែលមានលក្ខខណ្ឌបីប្រការក្នុងនោះរួមមាន៖ ទី១ គោលដៅការពារផលប្រយោជន៍សាធារណៈ ទី២ រយៈពេលនៃវិបត្តិដែលមិនត្រូវឱ្យហួសផុតវិបត្តិ និងទី៣ មធ្យោបាយដែលត្រូវប្រើឱ្យសមស្របនឹងស្ថានការណ៍កុំឱ្យហួសហេតុ។

[62] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០០៦ ទំព័រទី២៣០

[63] មាត្រា៤ នៃអនុក្រឹត្យស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត, លេខ៩៧ អនក្រ.បក. ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

[64] មាត្រា៤០ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានប្បញ្ញត្តិថា សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំង ទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋត្រូវបានគោរព។

- ទីបី ការទទួលខុសត្រូវរបស់រាជការក្នុងពេលនោះពុំមានអ្វីធ្ងន់ធ្ងរដូចក្នុងរឿងធម្មតាឡើយ។ កំហុសខ្លះគេចាត់ទុកថាជាការត្រឹមត្រូវទៅវិញក្នុងស្ថានភាពកាលៈទេសៈពិសេស ហើយរឿងធម្មតាដែលគេចាត់ទុកជារឿងព្រហ្មទណ្ឌ បែរជាមកនៅត្រឹមកំហុសរដ្ឋបាលទៅវិញ។

**២.២.១.២. កាលៈទេសៈពិសេសក្រោមច្បាប់កម្ពុជា**

នៅក្នុងច្បាប់កម្ពុជា ជាពិសេសពាក់ព័ន្ធនឹងនីតិរដ្ឋបាលតែម្តងគេពុំឃើញមានយុត្តិសាស្ត្ររដ្ឋបាលអ្វីដូចនៅក្នុងប្រទេសបារាំងឡើយ។ ប៉ុន្តែនៅក្នុងពេលថ្មីៗនេះ កម្ពុជាបានអនុម័តច្បាប់ពីរដែលសុទ្ធសឹងតែបង្ហាញអំពីការគ្រប់គ្រងប្រទេសនៅក្នុងករណីមានគ្រោះអាសន្ន ឬកាលៈទេសៈពិសេស។ ទីមួយនោះ គឺច្បាប់ស្តីពីការគ្រប់គ្រងប្រទេសក្នុងស្ថិតក្នុងភាពអាសន្ន[65] និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។[66]

**ក. លក្ខខណ្ឌនៃការដាក់ប្រទេសក្នុងភាពអាសន្ន**

តាមមាត្រា៤នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នឆ្នាំ២០២២បានកំណត់លក្ខខណ្ឌដែលអាចធ្វើទៅបានក្នុងករណីដូចខាងក្រោម៖

- គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាម ឬការឈ្លានពានពីកម្លាំងបរទេស
- គ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្តាលមកពីការឆ្លងរីករាលដាលនៃជម្ងឺ
- ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ
- ព្រមទាំងគ្រោះមហន្តរាយធ្ងន់ធ្ងរដែលគំរាមកំហែង ឬអាចបង្កគ្រោះថ្នាក់រីករាលដាលដល់កម្រិតទូទាំងប្រទេស។

ទាំងនេះគឺជាអ្វីដែលមានចែងនៅក្នុងមាត្រា៤ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសស្ថិតនៅក្នុងភាពអាសន្ន។ យោងតាមមាត្រា៤នេះមិនមានន័យថា លុះត្រាតែចូលលក្ខខណ្ឌខាងលើទើបអាចដាក់ប្រទេសនៅក្នុងភាពអាសន្ននោះទេ ស្ថានភាពផ្សេងៗទៀតក៏អាចដាក់ប្រទេសស្ថិតក្នុងភាពអាសន្នបានដែរឱ្យតែគោរពលក្ខខណ្ឌនៃទ្រឹស្តីនៃកាលៈទេសៈពិសេស។

**ចំណុចទី១. នីតិវិធីនៃការដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន**

នៅក្នុងស្ថានភាពច្បាប់កម្ពុជាសព្វថ្ងៃ ដំណើរការនៃការដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន គឺគេអាចនិយាយបានថាមានសង្គតិភាពគតិយុត្ត ល្អប្រសើរដោយមានទាំងរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្នដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/០៤២០/០១៨ ចុះថ្ងៃទី២៩

[65] ព្រះរាជក្រមលេខនស/រកម/០៤២០/០១៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០

[66] ព្រះរាជក្រមលេខនស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១

ខែមេសា ឆ្នាំ២០២០។ យោងតាមរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ឃើញថា ច្បាប់កម្ពុជាមានភាពបរិបូណ៌ទៅលើវិធាននៃការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

យោងតាមមាត្រា២២ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣បានចែងថា នៅពេលប្រទេសជាតិប្រឈមមុខនឹងគ្រោះថ្នាក់ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។ យោងតាមមាត្រា៣ កថាខណ្ឌ ទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដែលចែងអំពីបែបបទ និងនីតិវិធីនៃការប្រកាសដាក់ប្រទេសស្ថិតក្នុងភាពអាសន្ន បានចែងថា ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចធ្វើឡើងសម្រាប់ចិរវេលាមិនឱ្យលើសពី៣ខែ។ ចិរវេលានេះអាចត្រូវបានប្រកាសបន្តបានក្នុងក្របខ័ណ្ឌដូចគ្នា។ កាលៈទេសៈពិសេសដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចត្រូវបញ្ចប់ទៅវិញដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ក្រោយពីមានការពិគ្រោះយោបល់ជាមួយប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា កាលបើកាលៈទេសៈពិសេសនេះបានបញ្ចប់ទៅវិញមុនកាលកំណត់នៃចិរវេលាដែលមានចែងនៅក្នុងព្រះរាជក្រឹត្យទាក់ទងនឹងការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។[67] យោងតាមមាត្រា៧៨ នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី៥ បានបញ្ញត្តិថាក្នុងពេលសង្គ្រាម ឬក្នុងពេល កាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចបន្តនីតិការរបស់ខ្លួនមួយដងបានមួយឆ្នាំតាមសំណើរបស់ព្រះមហាក្សត្រ។[68] យោងតាមមាត្រា៨៦ នៃរដ្ឋធម្មនុញ្ញចែងថា ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតនៅក្នុងស្ថានភាពអាសន្នរដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ។ រដ្ឋសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើបាន កាលបើសភាពការណ៍អនុញ្ញាត។ យោងតាមមាត្រា៣ កថាខណ្ឌទី៣ បានបន្តចែងថា បើរដ្ឋសភា ឬព្រឹទ្ធសភាមិនអាចប្រជុំបានទេដោយមូលហេតុចាំបាច់ជាអាទិ៍៖ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។[69]

យោងតាមបទប្បញ្ញត្តិដែលមានចែងទាំងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ឃើញថាព្រះមហាក្សត្រជាអ្នកប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីមានការឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ប្រធានព្រឹទ្ធសភាដែលការដាក់ប្រទេសស្ថិតក្នុងភាពអាសន្នត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យតាមសំណើនាយករដ្ឋមន្ត្រី។ ការបញ្ចប់ទៅវិញនូវភាពអាសន្នក៏ត្រូវធ្វើឡើងវិញដោយ

---

[67] មាត្រា៣ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសស្ថិតក្នុងភាពអាសន្ន, ព្រះរាជក្រមលេខនស/រកម/០៤២០/០១៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០២០

[68] មាត្រា៧៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[69] មាត្រា៨៦ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ព្រះរាជក្រឹត្យដែលតាមសំណើនាយករដ្ឋមន្ត្រីដោយមានការពិគ្រោះយោបល់ពីរដ្ឋសភា និងព្រឹទ្ធសភា។ ម្យ៉ាងទៀតក្រោយពីការដាក់ប្រទេសនៅក្នុងភាពអាសន្នរាជរដ្ឋាភិបាលត្រូវរាយការណ៍ជាប្រចាំអំពីវិធានការដែលខ្លួនបានដាក់ចេញក្នុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្នជូនទៅរដ្ឋសភា និងព្រឹទ្ធសភា។

**ចំណុចទី២. ការបង្កើនអំណាចដល់អង្គការនីតិប្រតិបត្តិ**

ដូចបានដឹងហើយថា អង្គការនីតិប្រតិបត្តិ គឺជាអ្នកធានានូវការអនុវត្តច្បាប់ដែលចេញដោយអង្គការនីតិបញ្ញត្តិ ដូច្នេះបើទោះបីពេលខ្លះការអនុវត្តច្បាប់នោះពុំបានល្អប្រសើរ ក៏មានតែអាជ្ញាធររដ្ឋបាលដែលស្ថិតក្នុងអំណាចនីតិប្រតិបត្តិនេះទេ ទើបដឹងពីស្ថានភាពពិតប្រាកដនៃស្ថានភាពកាលៈទេសៈទាំងអស់នោះ។ យោងតាមមូលហេតុនេះ អាចនិយាយបានថា ច្បាប់តែងប្រគល់អំណាច ឬក៏បង្កើនអំណាចខ្លាំង ឬពេលខ្លះទៀតការគ្រប់គ្រងប្រទេសត្រូវបានប្រគល់ទាំងស្រុងឱ្យអង្គការនីតិប្រតិបត្តិជាអ្នកគ្រប់គ្រងខ្លួនឯង។

**ចំណុចទី៣. សិទ្ធិនៃការចេញវិធានរបស់រដ្ឋាភិបាល**

នៅក្នុងកាលៈទេសៈពិសេសនេះដូចបានដឹងហើយថា ច្បាប់បានផ្តល់អំណាចខ្លាំងដល់រាជរដ្ឋាភិបាលដើម្បីចេញវិធានការផ្សេងៗដើម្បីការពារនូវភាពរឹងរ៉ា ទោះបីវិធាននោះពេលខ្លះគឺអាចនឹងផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬច្បាប់ដទៃទៀតក៏ដោយ ក៏គេមិនអាចថាវិធានដែលចេញដោយអាជ្ញាធររដ្ឋបាលនោះខុសច្បាប់ឡើយ ព្រោះវិធាននេះត្រូវភ្ជាប់នូវអ្វីម្យ៉ាងដែលគេហៅថា នីត្យានុកូលភាពនៃវិបត្តិ ឬកាលៈទេសៈពិសេស។ ត្រង់ចំណុចនេះហើយដែលអាចនិយាយបានថា នៅក្នុងកាលៈទេសៈពិសេស អំពើ ឬសកម្មភាពរបស់រាជការដែលផ្ទុយនឹងច្បាប់ប៉ុន្តែត្រូវនឹងច្បាប់ ឬអំពើដែលនៅក្នុងស្ថានភាពធម្មតាត្រូវមានទោសធ្ងន់ បែរជាមានទោសស្រាល ឬគ្មានទោសតែម្តង។ ពីព្រោះគេយល់ថា នៅក្នុងស្ថានភាពធម្មតាសេរីភាពបុគ្គលគឺដើរមុន តែនៅក្នុងកាលៈទេសៈពិសេសស្ថិរភាពរបស់រដ្ឋគឺជាអាទិភាព។

នៅពេលប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្នរាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញនូវវិធានការដូចជា៖

- ការហាមឃាត់ ឬការកម្រិតសេរីភាពក្នុងការធ្វើដំណើរ
- ការហាមឃាត់ ឬការកម្រិតសិទ្ធិសេរីភាពក្នុងការជួបជុំ ឬការប្រមូលផ្តុំមនុស្ស
- ការហាមឃាត់ ឬការកម្រិតការធ្វើសកម្មភាពការងារ ឬមុខរបរ។

វិធានការនេះអាចដាក់ឱ្យអនុវត្តនៅកម្រិតទូទាំងប្រទេស ឬមួយផ្នែកនៃដែនដីដែលកំណត់ជាក់លាក់។

**ចំណុចទី៤. សិទ្ធិផ្ទេរអំណាច និងការគ្រប់គ្រងរបស់រដ្ឋាភិបាល**

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន នៅក្នុងករណីចាំបាច់រាជរដ្ឋាភិបាលអាចបង្កើតយន្តការ ឬប្រគល់សិទ្ធិអំណាចទៅអាជ្ញាធរមានសមត្ថកិច្ចណាមួយ ឬប្រើប្រាស់កម្លាំងប្រដាប់អាវុធដើម្បីធានាដល់ការអនុវត្តវិធានការដែលដាក់ចេញដោយរាជរដ្ឋាភិបាល។

ត្រង់ចំណុចនេះមានន័យថា កិច្ចការកន្លងមកដែលធ្លាប់តែអនុវត្តដោយអាជ្ញាធរស៊ីវិលត្រូវបានប្រគល់ទៅកងកម្លាំងប្រដាប់អាវុធ ឬយោធាជាអ្នកអនុវត្ត។ ម្យ៉ាងវិញទៀតក្រៅពីមានសិទ្ធិផ្ទេរអំណាចហើយនោះ នៅក្នុងការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ប្រសិនបើប្រទេសជាតិត្រូវប្រឈមមុខនឹងសង្គ្រាម ឬកាលៈទេសៈដ៏ទៃទៀតអាចគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ប្រទេសជាតិ ការគ្រប់គ្រងប្រទេសអាចធ្វើឡើងតាមរបប អាជ្ញាសឹក។ ដូចបានហើយឃើញថា នៅក្នុងករណីដែលប្រទេសជាតិប្រឈមមុខនូវគ្រោះថ្នាក់ធ្ងន់ធ្ងរ ដែលជាបញ្ហាបន្ទាន់ដូច្នេះ នឹងធ្វើឱ្យការគ្រប់គ្រងប្រទេសជាតិនឹងប្រែប្រួលមួយរំពេច គឺប្រែប្រួលពីរបបប្រជាធិបតេយ្យទៅជារបបអាជ្ញាសឹកបែបផ្តាច់ការ។ គេមិនអាចនិយាយថាអំពើនេះ គឺផ្ទុយនឹងច្បាប់ឡើយ ពីព្រោះវាត្រូវបានចងភ្ជាប់នឹងអ្វីដែលហៅថា នីត្យានុកូលភាពនៃវិបត្តិ។ រឿងនេះគឺអាស្រ័យទៅលើឆន្ទៈរបស់អ្នកដឹកនាំប្រទេស ប្រសិនបើអ្នកដឹកនាំយកកាលៈទេសៈពិសេសមកបន្តដឹកនាំដើម្បីឈានទៅរករបបផ្តាច់ការនោះ គឺជារឿងគ្រោះថ្នាក់មួយសម្រាប់ប្រទេសជាតិ។ ប៉ុន្តែ សួរថាដើម្បីការពារប្រទេសជាតិចាំបាច់ត្រូវការរឹតបន្តឹងស្ថិរភាពរបស់រដ្ឋ ដូច្នេះចាំបាច់ត្រូវតែធ្វើបែបនេះ សួរថាតើមានវិធីអ្វីផ្សេងទៀតទេ ក្រៅពីវិធីរឹតបន្តឹងនេះ ចំណោទនេះនៅមិនទាន់មានអ្នកច្បាប់ណាមួយអាច ដោះស្រាយបាននៅឡើយទេ។

**ចំណុចទី៥. ការត្រួតពិនិត្យសកម្មភាពរបស់រាជការ**

នៅក្នុងប្រព័ន្ធច្បាប់បារាំងការត្រួតពិនិត្យ សកម្មភាពរដ្ឋការត្រូវបានធ្វើឡើងជាបច្ចាកាលដោយតុលាការរដ្ឋបាល។[70] ដោយឡែក នៅកម្ពុជាមិនទាន់មានតុលាការនាញរដ្ឋបាលនៅឡើយទេ ដូច្នេះគេមិនអាចនិយាយបានថា តើត្រូវធ្វើការត្រួតពិនិត្យដោយតុលាការរដ្ឋបាលដែរ ឬទេ? បើយោងតាមច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ននេះវិញ ឃើញថា រដ្ឋសភា ព្រឹទ្ធសភា គឺជាអ្នកត្រួតពិនិត្យនូវសកម្មភាពទាំងឡាយរបស់អាជ្ញាធររដ្ឋបាលនៅក្នុងករណីប្រទេសជាតិស្ថិតក្នុងភាពអាសន្នមិនមែនជាតុលាការរដ្ឋបាលនោះទេ។[71] ផ្ទុយមកវិញ ប្រសិនបើពលរដ្ឋណាម្នាក់ប្រព្រឹត្តផ្ទុយនឹងវិធានការ ដែលចេញដោយរាជរដ្ឋាភិបាលនៅពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន នោះនឹងត្រូវទទួលទោស ដែលនឹងត្រូវពិន័យជាប្រាក់ និងជាប់ពន្ធនាគារទៀតផង។ ត្រង់ចំណុចនេះឃើញថាអំពើរបស់អាជ្ញាធររដ្ឋបាល មិនត្រូវបានត្រួតពិនិត្យដោយតុលាការទេតែអំពើរបស់ប្រជាពលរដ្ឋត្រូវបានត្រួតពិនិត្យដោយតុលាការ។

---

[70] សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០០៦ ទំព័រទី២៣៣

[71] មាត្រា៦ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រទេសស្ថិតក្នុងភាពអាសន្ន, ព្រះរាជក្រមលេខនស/រកម/០៤២០/០១៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០

**ខ.ករណីមានជំងឺឆ្លង**

ក្នុងកាលៈទេសៈពិសេសក្រៅពីច្បាប់ស្តីពីការគ្រប់គ្រងប្រទេសស្ថិតក្នុងភាពអាសន្ន ហើយនោះ គេសង្កេតឃើញថា កម្ពុជានៅមានច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។[72] ដើម្បីសម្រួលដល់ការហៅនេះ សូមហៅច្បាប់នេះដោយខ្លីថាច្បាប់ស្តីពីវិធានការទប់ស្កាត់ជំងឺឆ្លង។

យោងតាមស្មារតីនៃច្បាប់នេះគឺដើម្បីកំណត់អំពីវិធានការសុខាភិបាលវិធានការរដ្ឋបាលនិងវិធានការផ្សេងៗទៀតដើម្បីទប់ស្កាត់ជំងឺឆ្លងហើយមានវិសាលភាពអនុវត្តចំពោះការរីករាលដាលនៃជំងឺឆ្លងកាចសាហាវផ្សេងៗ។[73] ដូច្នេះយោងតាមខ្លឹមសារទាំងស្រុងនៃច្បាប់នេះគឺច្បាប់នេះអាចអនុវត្តទៅបានឱ្យតែគោរពលក្ខខណ្ឌនីត្យាកូលភាពនៃជំងឺឆ្លង។

**២.២.២. រដ្ឋាភិបាលកិច្ច**

កិច្ចការរបស់រាជរដ្ឋាភិបាលត្រូវបានបែងចែកជាពីរគឺ៖

ទី១ កិច្ចការរដ្ឋបាល

ទី២ កិច្ចការនយោបាយ

កិច្ចការរដ្ឋបាល គឺរាល់លិខិតស្នាម និងរាល់ការគ្រប់គ្រងរដ្ឋបាលទាំងអស់នៅក្នុងរចនាសម្ព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលនៃស្ថាប័នទាំងឡាយរបស់រាជរដ្ឋាភិបាល។ កិច្ចការរដ្ឋបាលទាំងនេះ ត្រូវស្ថិតក្រោមនីតិរដ្ឋបាល ហើយត្រូវបានត្រួតពិនិត្យដោយតុលាការ ពោលគឺកិច្ចការទាំងនេះត្រូវគោរពនូវគោលការណ៍នីត្យានុកូល។

ចំណែកឯកិច្ចការនយោបាយវិញ សំដៅទៅលើកិច្ចដែលជាលិខិតស្នាមពាក់ព័ន្ធនឹងអង្គការនីតិប្បញ្ញត្តិ អង្គការអន្តរជាតិ និងរដ្ឋអំណាចបរទេស។ បច្ចុប្បន្ននេះ កម្ពុជាមិនទាន់មានលិខិតបទដ្ឋានគតិយុត្តណាមួយចែងអំពីរដ្ឋាភិបាលកិច្ចនៅឡើយទេ តែទ្រឹស្តីនេះ គឺយកមកពីយុត្តិសាស្ត្ររបស់តុលាការរដ្ឋបាលបារាំង។ តាមទ្រឹស្តីយុត្តិសាស្ត្រតុលាការរដ្ឋបាលបារាំង គឺរដ្ឋាភិបាលកិច្ចនេះមិនស្ថិតនៅក្រោម ឬចំណុះនឹងនីតិរដ្ឋបាល និងតុលាការរដ្ឋបាល ឬតុលាការណាមួយផ្សេងទៀតឡើយ។ គេសង្កេតឃើញថា រដ្ឋាភិបាលកិច្ចក្នុងផ្នែកនយោបាយមានពីរគឺ៖ ក្នុងប្រទេស និងក្រៅប្រទេស។

---

[72] ប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនាឆ្នាំ២០២១

[73] មាត្រា១ និងមាត្រា២ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត, ព្រះរាជក្រមលេខនស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនាឆ្នាំ២០២១

**២.២.២.១. ក្នុងប្រទេស**

រដ្ឋាភិបាលកិច្ចក្នុងប្រទេសភាគច្រើនគឺរាល់លិខិតស្នាម និងរាល់ទំនាក់ទំនងរវាងអង្គការនីតិប្រតិបត្តិនិងអង្គការនីតិប្បញ្ញត្តិ។ រាល់លិខិតស្នាម និងទំនាក់ទំនងនោះគឺគេឃើញមានដូចជា ការផ្តួចផ្តើមគំនិតធ្វើច្បាប់ ការកោះប្រជុំសភាជាវិសាមញ្ញជាដើមទាំងអស់នេះគឺមានអភ័យឯកសិទ្ធិយុត្តាធិការ។ រដ្ឋាភិបាលកិច្ចដែលធ្វើនៅក្នុងប្រទេសរវាងអង្គការនីតិប្រតិបត្តិ និងអង្គការនីតិប្បញ្ញត្តិ គឺភាគច្រើនមានអភ័យឯកសិទ្ធិយុត្តាធិការមែន តែមិនមែនមានអភ័យឯកសិទ្ធិទាំងស្រុងដែរ។ ព្រោះថ្វីត្បិតតែរាល់លិខិតស្នាមទាំងនេះមិនចំណុះក្រោមនីតិរដ្ឋបាលពិតមែន តែកិច្ចការទាំងអស់នេះ គឺត្រូវស្ថិតក្រោមរដ្ឋធម្មនុញ្ញ ដូច្នេះគេអាចនិយាយបានថាស្ថាប័នមានសមត្ថកិច្ចដែលអាចត្រួតពិនិត្យនូវរាល់លិខិតស្នាមរវាងអង្គការនីតិប្រតិបត្តិ និងអង្គការនីតិប្បញ្ញត្តិ គឺក្រុមប្រឹក្សាធម្មនុញ្ញជាពិសេសនៅក្នុងការផ្តួចផ្តើមគំនិតធ្វើច្បាប់ និងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ឬច្បាប់ផ្សេងៗ។

ជារួមមកវិញឃើញថា កិច្ចការទាំងអស់នេះគឺរួចផុតពីសមត្ថកច្ចិយុត្តាធិការតុលាការរដ្ឋបាល (បើមានតុលាការនាញរដ្ឋបាល) តែមិនផុតទាំងស្រុងពីស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញឡើយ។

ការរួចផុតពីសមត្ថកិច្ចយុត្តាធិការរដ្ឋបាលនេះ ដោយសារតែកម្ពុជាបានប្រកាន់នូវគោលការណ៍បែងចែកអំណាចជាបីគឺ៖ អំណាចនីតិប្រតិបត្តិ អំណាចនីតិប្បញ្ញត្តិ និងអំណាចតុលាការ។ មិនត្រឹមតែប៉ុណ្ណោះគោលការណ៍នេះក៏មានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ យោងទៅតាមគោលការណ៍បែងចែកអំណាចជាបីនេះឃើញថា រាល់កិច្ចការទាំងឡាយដែលធ្វើឡើងរវាងអង្គការនីតិប្រតិបត្តិ និងអង្គការនិតិប្បញ្ញត្តិ គឺតុលាកាពុំមានសិទ្ធិត្រួតពិនិត្យ ឬលូកដៃចូលឡើយព្រោះអសមត្ថកិច្ច។

**២.២.២.២. ក្រៅប្រទេស**

គឺរាល់លិខតស្នាម និងកិច្ចរបស់អង្គការនីតិប្រតិបត្តិជាមួយរដ្ឋអំណាចបរទេសដូចជាការចរចារចុះសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ការដាក់ខរក្សាសិទ្ធិមិនអនុវត្ត ការចូលជាធរមាននៃសន្ធិសញ្ញាដែលត្រូវមានកាតព្វកិច្ចបដិការរវាងរដ្ឋអំណាចទាំងពីរ។ ដូច្នេះប្រសិនបើរដ្ឋអំណាចណាមួយមិនអនុវត្តកាតព្វកិច្ចតាមសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិតុលាការមិនអាចមានសមត្ថកិច្ចដើម្បីត្រួតពិនិត្យឡើយ។ មូលហេតុដែលតុលាការមិនអាចត្រួតពិនិត្យបាន ដោយសាតែរដ្ឋនីមួយៗមានអធិបតេយ្យភាពរៀងៗខ្លួន ដោយមិនអាចឱ្យរដ្ឋណាមួយរំលោភបំពានឡើយគោលការណ៍នេះមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

នីត្យាលនុកូលភាពគឺជាភាពស្របច្បាប់ ដូច្នេះអាជ្ញាធររដ្ឋបាលដើម្បីឱ្យកិច្ចការរដ្ឋបាលរបស់ខ្លួនប្រកបដោយនីត្យានុកូលភាព ឬភាពស្របច្បាប់ កិច្ចការទាំងនោះត្រូវចងភ្ជាប់នឹងវិធានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ដែលវិធានគតិយុត្តទាំងនោះគេឃើញមានពីរសំខាន់ៗ ទីមួយវិធានគតិយុត្តដែលជាច្បាប់រួមមាន៖ រដ្ឋធម្មនុញ្ញ សន្ធិសញ្ញា និងច្បាប់ដែលអនុម័តដោយសភា ដែលវិធានទាំងនេះរាជការត្រូវតែគោរពតាមជាដាច់ខាត។ ទីពីរ វិធានគតិយុត្តដែលជាបទបញ្ញារួមមាន៖ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ដែលមានអានុភាពគតិយុត្ត និងនៅជាធរមាន។ ម្យ៉ាងទៀតតាមរយៈវិធានទាំងនេះបានបង្កើតឱ្យមាននូវសមត្ថកិច្ចរបស់អាជ្ញាធររដ្ឋបាល ដែលសមត្ថកិច្ចទាំងនោះមានទាំងសមត្ថកិច្ចដែលមានលក្ខណៈតឹងរឹងដែលអាជ្ញាធររដ្ឋបាលគ្មានលទ្ធភាពក្នុងកាលានុវត្តភាព នៃការជ្រើសរើសមធ្យោបាយដើម្បីធ្វើសេចក្តីសម្រេច និងសកម្មភាព និងសមត្ថកិច្ចដែលមានលក្ខណៈធូរដែលបង្កើតលទ្ធភាពឱ្យអាជ្ញាធររដ្ឋបាលមានកាលានុវត្តភាពក្នុងការជ្រើសរើសមធ្យោបាយដើម្បីធ្វើសេចក្តីសម្រេច និងសកម្មភាពស្របទៅតាមសមត្ថកិច្ចរបស់ខ្លួន និងផលប្រយោជន៍ទូទៅ។

លើសពីនេះទៅទៀតក្រៅពីការគោរពនូវគោលការណ៍នីត្យានុកូលភាពនៃវិធានគតិយុត្ត អាជ្ញាធររដ្ឋបាលក៏មាននូវអំណាចឆន្ទានុសិទ្ធិ និងអញ្ញត្រកម្មនៃការគោរពគោលការណ៍នីត្យានុកូលភាពផងដែរ។ ការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិរបស់អាជ្ញាធររដ្ឋបាល គឺជាចំណុចស្នូលនៃនីតិរដ្ឋបាល ពីព្រោះសកម្មភាពជាប្រក្រតីរបស់អាជ្ញាធររដ្ឋបាលត្រូវប្រើអំណាចឆន្ទានុសិទ្ធិនេះជាប្រចាំ។ ដោយសារតែអំណាចឆន្ទានុសិទ្ធិមានសញ្ញាណកើតចេញពីសមត្ថកិច្ចជាប់ចំណងធូរ ដូច្នេះអាចនិយាយបានថា អំពើរបស់រាជការមានអញ្ញត្រកម្មនៃវិធានច្បាប់ដែលកើតឡើងនៅក្នុងស្ថានភាពធម្មតា ឬស្ថានភាពប្រចាំថ្ងៃនៅក្នុងសង្គមដែលផ្ទុយពីគោលការណ៍អញ្ញត្រកម្ម ដែលកើតឡើងក្នុងស្ថានភាពពិសេស ឬកាលៈទេសៈពិសេស និងរដ្ឋាភិបាលកិច្ចដែលមានលក្ខណៈនយោបាយ ទន្ទឹមនឹងនេះអំណាចឆន្ទានុសិទ្ធិក៏មានព្រំដែនគឺនីត្យានុកូលភាពផ្ទៃក្រៅ និងផ្ទៃក្នុង។

ចំណែកឯការប្រើប្រាស់គោលការណ៍អញ្ញត្រកម្មវិញ គឺអាចនឹងមិនស្ថិតនៅក្នុងការគោរពគោលការណ៍នីត្យានុកូលភាពទេ តែវានៅតែមានភាពស្របច្បាប់ចំពោះអំពើរបស់រាជការ ព្រោះវាត្រូវបានចងភ្ជាប់នឹងអ្វីដែលហៅថានីត្យានុកូលភាពនៃវិបត្តិ ឬកាលៈទេសៈពិសេស។ ម្យ៉ាងវិញទៀត នៅក្នុងកិច្ចការនយោបាយដែលជារដ្ឋាភិបាលកិច្ចក៏មានភាពស្របច្បាប់ និងមិនស្ថិតនៅក្នុងការត្រួតពិនិត្យរបស់ចៅក្រមឡើយ ដោយនៅក្នុងកិច្ចការនយោបាយនេះ គឺមានកិច្ចការក្នុងប្រទេស និងក្រៅប្រទេសដែលរាល់កិច្ចការទាំងនេះគឺស្ថិតនៅក្នុងរង្វង់អំណាចនីតិប្រតិបត្តិ ដូច្នេះដោយយោងតាមគោលការណ៍ បែងចែកអំណាចចៅក្រមដែលមានអំណាចតុលាការមិនអាចត្រួតពិនិត្យកិច្ចការ ដែលជាលក្ខណៈនយោបាយបានឡើយ ដូច្នេះចៅក្រមដែលជានិច្ចកាលតែងគោរពគោលការណ៍នីត្យានុកូលភាព ឬគោរពនូវអ្វីដែលច្បាប់បានបញ្ញត្តិនឹងក្លាយជាអសមត្ថកិច្ច។

# អនុសាសន៍

# អនុសាសន៍

អត្ថបទសារណានេះឆ្លុះបានបញ្ចាំងនូវបញ្ហាសំខាន់ៗចម្បងចំនួនពីរនៃសកម្មភាពប្រព្រឹត្តទៅរបស់រាជការ។ ទីមួយនៅពេលមានវិវាទកើតឡើងរវាងប្រជាពលរដ្ឋ និងអាជ្ញាធររដ្ឋបាល ប្រជាពលរដ្ឋដែលជា រាស្ត្រសាមញ្ញ តែងយល់ថាខ្លួននឹងចាញ់ប្រសិនបើទៅតតាំងក្តីជាមួយមន្ត្រីដែលជាអ្នកមានអំណាចធំជាង។ ទីពីរ គឺពាក់ព័ន្ធនឹងស្ថាប័នដោះស្រាយវិវាទមានន័យថា កម្ពុជាមិនទាន់មានស្ថាប័នតុលាការនាញរដ្ឋបាលដើម្បីដោះស្រាយវិវាទរដ្ឋបាលនៅឡើយទេ ថ្វីបើតាមប្រព័ន្ធច្បាប់កម្ពុជាបានផ្តល់សម្បទាដល់តុលាការយុត្តិធម៌ដើម្បីដោះស្រាយវិវាទរដ្ឋបាលក៏ដោយ ក៏ការដោះស្រាយនេះនៅមិនទាន់មានលក្ខណៈទូលំទូលាយដែលនឹងទាក់ទាញសេចក្តីទុកចិត្តពីសាធារណជន។ ដោយសារកត្តាទាំងនេះហើយបានធ្វើឱ្យរឿងក្តីរដ្ឋបាលជាពិសេសវិវាទ ដែលកើតឡើងរវាងរាជការជាមួយប្រជាពលរដ្ឋច្រើនតែត្រូវបានដោះស្រាយក្រៅប្រព័ន្ធតុលាការ។ ថ្វីបើការដោះស្រាយនេះមិនបានបង្កើតជាវិធានយុត្តិសាស្ត្រដើម្បីយកទៅអនុវត្តបន្តទៀតក៏ដោយ ក៏យន្តការនេះអាចជួយសម្រួលបន្ទុករបស់ប្រជាពលរដ្ឋដែលអាចទទួលយកបាន។ ដូច្នេះការតម្រូវឱ្យមានតុលាការរដ្ឋបាលមួយគឺជារឿងដែលគួរពិចារណា។

ដោយផ្អែកទៅលើបញ្ហាខាងលើនេះខ្ញុំបាទសូមសំណូមពរៈ

- រាជរដ្ឋាភិបាលគួរតែបង្កើតឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការការពារនូវផលប្រយោជន៍របស់ខ្លួនចំពោះមុខច្បាប់ ដោយពុំមានការភ័យខ្លាចចំពោះមន្ត្រីរាជការដែលមានអំណាចធំជាង តាមរយៈការជម្រុញឱ្យមានការជួបប្រជុំ ការធ្វើសិក្ខាសាលា ដោយមានការចូលរួមពីអ្នកជំនាញការច្បាប់ ដូចជាមេធាវីជាដើម។
- ម្យ៉ាងទៀតក្រៅពីការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹងអំពីសិទ្ធិរបស់ខ្លួនហើយនោះ ក៏ត្រូវការជាចាំបាច់ផងដែរនូវស្ថាប័នតុលាការរដ្ឋបាល ដែលជាតុលាការជំនាញរដ្ឋបាលច្បាស់លាស់ដើម្បីឱ្យការដោះស្រាយរឿងក្តីរដ្ឋបាលកាន់តែមានភាពច្បាស់លាស់ ប្រកបដោយយុត្តិធម៌ និងទាក់ទាញជំនឿទុកចិត្តពីសាធារណជនគ្រប់រូប។
- ក្រៅពីនេះគួរតែមានឯកសារពាក់ព័ន្ធនឹងនីតិរដ្ឋបាល ឬក៏ចងជាក្រមរដ្ឋបាល និងក្រមនីតិវិធីរដ្ឋបាលមួយច្បាស់លាស់ ដើម្បីមានភាពងាយស្រួលដល់មន្ត្រីអនុវត្តច្បាប់ សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងនីតិរដ្ឋបាល

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត, ព្រះរាជក្រមលេខនស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១
- ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន, ព្រះរាជក្រមលេខនស/រកម/០៤២០/០១៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨
- ច្បាប់រៀបចំអង្គការតុលាការ, ព្រះរាជក្រមលេខនស/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧
- ច្បាប់ស្តីពីអស្សាមិករណ៍, ព្រះរាជក្រមលេខនស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩
- ច្បាប់ស្តីពីការគ្រប់គ្រង់រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ, ព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, ព្រះរាជក្រមលេខនស/រកម/០៣០១/០៥ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជាការស៊ីវិល, ព្រះរាជក្រមលេខ០៦.ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤
- អនុសញ្ញាទីក្រុងវីយ៉េនស្តីពីច្បាប់សន្ធិសញ្ញាឆ្នាំ១៩៦៩
- ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល, លេខនស/០៨១៥/៨៧២ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥
- អនុក្រឹត្យស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ដទៃទៀត, លេខ៥៧ អនុក្រ.បក.ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១
- សេចក្តីណែនាំលេខ០០៤.សណន ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៦ ស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរ ការតែងតាំងជំនួយការភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការរបស់ភូមិ, ក្រសួងមហាផ្ទៃ
- ព្រឹត្តិបត្រប្រចាំខែមេសា ឆ្នាំ២០០០, ទីស្តីការគណៈរដ្ឋមន្ត្រី

## ២. សៀវភៅ និងប្រភពឯកសារផ្សេងៗទៀត

- សៀវភៅនីតិរដ្ឋបាលទូទៅ, បណ្ឌិត សាយ បូរី បោះពុម្ពលើកទី៤ ឆ្នាំ២០០៦
- សៀវភៅសេចក្តីផ្តើមនីតិរដ្ឋធម្មនុញ្ញ, បណ្ឌិត ឈុន ណារ៉េត បោះពុម្ពឆ្នាំ២០១៦

- សៀវភៅសេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ, បណ្ឌិត ឈុន ណារ៉េត បោះពុម្ពឆ្នាំ២០១២
- សៀវភៅនីតិរដ្ឋបាលទូទៅ, សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពលើកទី៤ ឆ្នាំ២០១៧
- សៀវភៅមេរៀននីតិរដ្ឋធម្មនុញ្ញ, សាស្ត្រាចារ្យ យូ តូនី បោះពុម្ពឆ្នាំ២០១៨
- សៀវភៅវិវាទរដ្ឋបាល, បណ្ឌិត ឥន យឿន បោះពុម្ពឆ្នាំ២០១៦
- សៀវភៅនីតិមុខងារសាធារណៈ, បណ្ឌិត ឥន យឿន បោះពុម្ពឆ្នាំ២០២១
- សៀវភៅរដ្ឋធម្មនុញ្ញ, បណ្ឌិត កៅ មុយថង បោះពុម្ពលើកទី១ ឆ្នាំ២០០៦
- សៀវភៅសេចក្តីផ្តើមនៃនីតិកម្ពុជា, Mlle Beatrice BALIVET បោះពុម្ពឆ្នាំ២០០៦
- សៀវភៅច្បាប់ការទូត, អនុបណ្ឌិត នួន សុធិមន្ត, បោះពុម្ពឆ្នាំ២០០៤
- ឯកសារនីតិរដ្ឋបាល ចំណេះដឹង ការងាររដ្ឋបាល កិច្ចការលេខាធិការដ្ឋាន, សាស្ត្រាចារ្យ សំ សារ៉ាក់ បោះពុម្ពឆ្នាំ២០១១
- សន្ទានុក្រមវិទ្យាសាស្ត្រនយោបាយ និងការទូតខ្មែរ-អង់គ្លេស-បារាំង បោះពុម្ពឆ្នាំ២០១៤
- សៀវភៅគ្រប់គ្រងរដ្ឋបាលខេត្តតាមបែបវិមជ្ឈការ, សាលាជាតិរដ្ឋបាលមូលដ្ឋាន បោះពុម្ពឆ្នាំ២០១៩
- ឯកសារបច្ចេកទេសស្តីពីដីកាក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ, លេខាធិការដ្ឋាន គ.ជ.អ.ប បោះពុម្ពឆ្នាំ២០១៥

## បញ្ជីឧបសម្ព័ន្ធ

### ១. ឧបសម្ព័ន្ធរូបភាព

- ឧបសម្ព័ន្ធទី១៖ រូបព្រះសង្ការ
- ឧបសម្ព័ន្ធទី២៖ សាជីជ្រុងដែលបង្ហាញអំពីឋានានុក្រមនៃធម្មនិយាមគតិយុត្ត
- ឧបសម្ព័ន្ធទី៣៖ គំរូនៃព្រះរាជក្រម
- ឧបសម្ព័ន្ធទី៤៖ គំរូនៃព្រះរាជក្រឹត្យ
- ឧបសម្ព័ន្ធទី៥៖ គំរូនៃអនុក្រឹត្យ
- ឧបសម្ព័ន្ធទី៦៖ គំរូនៃប្រកាស
- ឧបសម្ព័ន្ធទី៧៖ សេចក្តីសម្រេចផ្សេងទៀត

### ២. ឧបសម្ព័ន្ធគតិយុត្ត

- ឧបសម្ព័ន្ធទី១៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីការវិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត, ព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១
- ឧបសម្ព័ន្ធទី៣៖ ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន, ព្រះរាជក្រមលេខ នស/រកម/០៤២០/០១៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០
- ឧបសម្ព័ន្ធទី៤៖ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី, ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨
- ឧបសម្ព័ន្ធទី៥៖ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ឧបសម្ព័ន្ធទី៦៖ ច្បាប់ស្តីពីអស្សាមិករណ៍, ព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ខែកុម្ភៈ ឆ្នាំ២០១០
- ឧបសម្ព័ន្ធទី៧៖ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ, ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨
- ឧបសម្ព័ន្ធទី៨៖ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា, ព្រះរាជក្រមលេខ ០៦.ន.ស៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤
- ឧបសម្ព័ន្ធទី៩៖ អនុក្រឹត្យស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត, លេខ៥៧ អនុក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

# ឧបសម្ព័ន្ធរូបភាព

ឧបសម្ព័ន្ធទី១៖ រូបព្រះសង្ហារ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ឧបសម្ព័ន្ធទី២៖ រូបសាជីជ្រុងបង្ហាញពីឋានានុក្រមធម្មនិយាមគតិយុត្ត



# ឧបសម្ព័ន្ធទី៣៖ គំរូនៃព្រះរាជក្រម

**(សញ្ញាជាតិ ឬព្រះសង្ហារ)**

សេចក្តីព្រាងព្រះរាជក្រម(រ.ក.ម)
ប្រកាសឲ្យប្រើច្បាប់
ស្តីពីការបង្កើត..............

**ព្រះរាជក្រម**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឲ្យប្រើ**

ច្បាប់ស្តីពីការបង្កើតក្រសួង...... ដែលរដ្ឋសភាបានអនុម័ត នាសម័យប្រជុំពេញអង្គលើកទី.....នីតិកាលទី...... ចុះថ្ងៃទី......... ខែ............. ឆ្នាំ........... ដែលមានសេចក្តីទាំងស្រុងដូចតទៅ:

**ច្បាប់**

**ស្តីពី**

**ការបង្កើតក្រសួង**...............................

**មាត្រា១** : ត្រូវបានបង្កើតក្រសួង.........................ចំណុះរាជរដ្ឋាភិបាលកម្ពុជា

**មាត្រា២** : ..........................................................................................

**មាត្រា៣** : ..........................................................................................

**មាត្រា៤** : មាត្រាទី៥ មាត្រាទី៦ ...។ល។ បានសេចក្តីថាចម្លងសេចក្តីទាំងស្រុងនៃច្បាប់ដែលរដ្ឋសភាបានអនុម័តរួច។

ធ្វើនៅ................, ថ្ងៃទី........ ខែ.......... ឆ្នាំ............

.........................................

**នរោត្តម សីហមុនី**

# ឧបសម្ព័ន្ធទី៤៖ គំរូនៃព្រះរាជក្រឹត្យ

| គំរូព្រះរាជក្រឹត្យ<br>ស្តីពីការតែងតាំង |
|---|

**(សញ្ញាជាតិ ឬព្រះសង្ហារ)**

**ព្រះរាជក្រឹត្យ**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់..............................(ច្បាប់ដែលពាក់ព័ន្ធ)..............................
- បាន..........................................................................
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (ឬរបស់...អ្នកស្នើ........)

**ត្រាស់បង្គាប់**

**មាត្រា១ :** តែងតាំងឥស្សរជន......................(ចំនួន)....................ជា................(តួនាទី.....) មានឋានៈ.................

**មាត្រា២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេច តាមព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅ................ ថ្ងៃទី....... ខែ.......... ឆ្នាំ...........

..............................................

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**
**សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ**
**នាយករដ្ឋមន្ត្រី**

..............................................

**ឈ្មោះ**

**នរោត្តម សីហមុនី**

# ឧបសម្ព័ន្ធទី៥៖ គំរូនៃអនុក្រឹត្យ

(រូបព្រះសង្ហារ ឬសញ្ញាជាតិ)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ...................អនក្រ/តត

| សេចក្តីព្រាង |
|---|
| អនក្រ.ត.ត |

**អនុក្រឹត្យ**
**ស្តីពី**
**ការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- យោងតាមសំណើ និងតម្រូវការចាំបាច់របស់..............................................។

**សម្រេច**

**មាត្រា១ :** តែងតាំងមន្ត្រី ២រូប នៃគណៈកម្មាធិការ................................ដែលមានឈ្មោះដូចតទៅ:

១. លោក......... ជាអគ្គនាយករងនៃគណៈកម្មាធិការ.......................

២. លោក......... ជាប្រធាននាយកដ្ឋាននៃគណៈកម្មាធិការ ទទួលបន្ទុករដ្ឋបាលបុគ្គលិក និងគណនេយ្យ។

**មាត្រា២ :** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការ ......រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នរដ្ឋដែលពាក់ព័ន្ធ និងសាមីជន ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចតាមអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ..............ថ្ងៃទី........ខែ.............ឆ្នាំ...........

**នាយករដ្ឋមន្ត្រី**

..................................................

ឈ្មោះ

**បានយកសេចក្តីគោរពជូន**
**សម្តេច ឬឯកឧត្តម នាយករដ្ឋមន្ត្រីដើម្បីសុំហត្ថលេខាដ៏ខ្ពង់ខ្ពស់**
**ប្រធានគណៈកម្មាធិការ (ឬងារ, ឋានៈរបស់ម្ចាស់សំណើ)**

..........................................

ឈ្មោះ

**<u>កន្លែងទទួល:</u>**

- ........................
- ........................

# ឧបសម្ព័ន្ធទី៦៖ គំរូនៃប្រកាសរបស់ក្រសួងស្ថាប័ន

(រូបព្រះសង្ហារ ឬសញ្ញាជាតិ)

| ប្រកាសរបស់រាជរដ្ឋាភិបាល |
|---|

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ......................

**ប្រកាស**
**ស្តីពី**
........................................**កម្មវត្ថុ**........................................

**អត្ថសេចក្តី ឬខ្លឹមសារ:** ............................យោងរាល់ហេតុការណ៍ដែលទាក់ទង.............................. ឬយោងអត្ថបទ ឬដំណឹងផ្សព្វផ្សាយ ឬអត្ថបទបទដ្ឋានគតិយុត្តិពាក់ព័ន្ធ........................................................
.....................................................................................................................................
.....................................................................................................................................
.....................................................................................................................................

ទន្ទឹមនេះរាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការណ៍មួយចំនួនដូចខាងក្រោម:

១. .....................................................................................................
២. .....................................................................................................
៣. .....................................................................................................
៤. .....................................................................................................

ឃ្លាបញ្ចប់: ទទួលបានសេចក្តីប្រកាសនេះគ្រប់ក្រសួង ស្ថាប័ន ឬ.......ដែលពាក់ព័ន្ធត្រូវចាត់តាំងអនុវត្ត ឲ្យបានសម្រេចលទ្ធផលជាផ្លៃមានស្របតាមភារកិច្ចរៀងៗខ្លួន។

ធ្វើនៅ.............ថ្ងៃទី........ខែ............ឆ្នាំ............
**នាយករដ្ឋមន្ត្រី**

..................................................

**ឈ្មោះ**

**<u>កន្លែងទទួល:</u>**

- ............(គ្រប់ក្រសួង ពាក់ព័ន្ធ)
- ................................
- ................................
- ................................

# ឧបសម្ព័ន្ធទី៧៖ សេចក្តីសម្រេចរបស់ក្រសួងស្ថាប័ន



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង**......................
លេខ:........................
* * * *

**សេចក្តីសម្រេច**
**ស្តីពី**

..................................................

**រដ្ឋមន្ត្រីក្រសួង**......................

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៨/ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៨
- ..................................................................................
- ..................................................................................
- តាមសំណើរបស់..........................................................

**សម្រេច**

ប្រការ១ : ..............................................................................................................
..............................................................................................................

ប្រការ២ : ..............................................................................................................
..............................................................................................................

រាជធានីភ្នំពេញ, ថ្ងៃទី......ខែ..........ឆ្នាំ...........

**<u>កន្លែងទទួល:</u>**

- ...................
- ...................
- ...................

# ឧបសម្ព័ន្ធគតិយុត្ត

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា

# អារម្ភកថា

ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នកំពូលមួយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ព្រមទាំងមានសិទ្ធិពិនិត្យ និងសម្រេច អំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ក្រុមប្រឹក្សាធម្មនុញ្ញថ្វាយមតិព្រះមហាក្សត្រ ចំពោះសេចក្តីស្នើសុំវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ។

ដោយយល់ឃើញថា រដ្ឋធម្មនុញ្ញជាច្បាប់កំពូល និង ជាមូលដ្ឋានគតិយុត្តសំខាន់បំផុតសម្រាប់ជាតិ និង ប្រជាពលរដ្ឋខ្មែរ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើការផ្ទៀងផ្ទាត់ និង ចងក្រងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះឡើង ដើម្បីបម្រើសេចក្តីត្រូវការរបស់មន្ត្រីរាជការស៊ីវិល និង យោធិន ជាអ្នកគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ យកទៅគោរពប្រតិបត្តិ ពេលបំពេញការងារតាមវិស័យ ឬ ជំនាញនីមួយៗ ដោយធានាឱ្យស្របតាមរដ្ឋធម្មនុញ្ញ ។

ការរៀបចំចងក្រងរដ្ឋធម្មនុញ្ញនេះ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើការស្រាវជ្រាវរកសំណៅដើមពីមន្ទីររដ្ឋសភា ក្រោយពេលដែលសភាធម្មនុញ្ញបានអនុម័តរួចពីថ្ងៃ អង្គារ ៦ កើត ខែ ភទ្របទ ឆ្នាំរកា បញ្ចស័ក ព.ស ២៥៣៧ ត្រូវនឹងថ្ងៃទី ២១ ខែ កញ្ញា

គ.ស ១៩៩៣ ហើយត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមពីថ្ងៃ សុក្រ ៩ កើត ខែ ភទ្របទ ឆ្នាំរកា ព.ស ២៥៣៧ ត្រូវនឹងថ្ងៃទី ២៤ ខែ កញ្ញា គ.ស ១៩៩៣ ព្រមទាំងរកសំណៅដើមនៃព្រះរាជក្រមទាំងឡាយប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ ចំនួន ៧ ក្រោយៗមកទៀត ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញសង្ឃឹមថា ការផ្សព្វផ្សាយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ ចាត់ទុកជាការរួមចំណែកក្នុងការអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលអាណត្តិទី៥ នៃរដ្ឋសភា ឱ្យបានជោគជ័យ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥

**អគ្គលេខាធិការ**

**ចាន់ រ៉ាស៊ី**

# មាតិកា

**ទំព័រ**


- បុព្វកថា ........................................................................................ ១
- ជំពូកទី ១ : អំពីអធិបតេយ្យ

  មាត្រា ១ ដល់ មាត្រា ៦ ................................................................ ២
- ជំពូកទី ២ : អំពីព្រះមហាក្សត្រ

  មាត្រា ៧ ដល់ មាត្រា ៣០ ថ្មី..........................................................៣
- ជំពូកទី ៣ : អំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

  មាត្រា ៣១ ដល់ មាត្រា ៥០........................................................ ១០
- ជំពូកទី ៤ : អំពីរបបនយោបាយ

  មាត្រា ៥១ ដល់ មាត្រា ៥៥........................................................ ១៧
- ជំពូកទី ៥ : អំពីសេដ្ឋកិច្ច

  មាត្រា ៥៦ ដល់ មាត្រា ៦៤..........................................................១៩
- ជំពូកទី ៦ : អំពីអប់រំ វប្បធម៌ និង សង្គមកិច្ច

  មាត្រា ៦៥ ដល់ មាត្រា ៧៥........................................................ ២២
- ជំពូកទី ៧ : អំពីរដ្ឋសភា

  មាត្រា ៧៦ ដល់ មាត្រា ៩៨ ថ្មី.....................................................២៤

- ជំពូកទី ៨ ថ្មី    :  អំពីព្រឹទ្ធសភា

មាត្រា ៩៩ ថ្មី ដល់ មាត្រា ១១៥ ថ្មី........................................ ៣៤

- ជំពូកទី ៩ ថ្មី    :  អំពីសមាជរដ្ឋសភា និង ព្រឹទ្ធសភា

មាត្រា ១១៦ ថ្មី ដល់ មាត្រា ១១៧ ថ្មី........................................៤២

- ជំពូកទី ១០ ថ្មី :  អំពីរាជរដ្ឋាភិបាល

មាត្រា ១១៨ ថ្មី ដល់ មាត្រា ១២៧ ថ្មី....................................... ៤៣

- ជំពូកទី ១១ ថ្មី :  អំពីអំណាចតុលាការ

មាត្រា ១២៨ ថ្មី ដល់ មាត្រា ១៣៥ ថ្មី....................................... ៤៥

- ជំពូកទី ១២ ថ្មី :  អំពីក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ១៣៦ ថ្មី ដល់ មាត្រា ១៤៤ ថ្មី........................................៤៨

- ជំពូកទី ១៣ ថ្មី :  អំពីការគ្រប់គ្រងរដ្ឋបាល

មាត្រា ១៤៥ ថ្មី (មួយ) ដល់ មាត្រា ១៤៦ ថ្មី (មួយ) ................. ៥០

- ជំពូកទី ១៤ ថ្មី :  អំពីសមាជជាតិ

មាត្រា ១៤៧ ថ្មី ដល់ មាត្រា ១៤៩ ថ្មី........................................៥១

- ជំពូកទី ១៥ ថ្មី (ពីរ):  អំពីអង្គការរៀបចំការបោះឆ្នោត

មាត្រា ១៥០ ថ្មី (ពីរ)ដល់ មាត្រា ១៥១ ថ្មី (ពីរ) .......................៥២

- ជំពូកទី ១៦ ថ្មី (ពីរ):  អំពីអានុភាព ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ

មាត្រា ១៥២ ថ្មី (ពីរ មាត្រា ១៥០ ថ្មី ) ដល់ មាត្រា ១៥៥ ថ្មី (ពីរ

មាត្រា ១៥៣ ថ្មី )...............................................................៥៤

- ជំពូកទី ១៧ ថ្មី :   អំពីអន្តរប្បញ្ញត្តិ

មាត្រា ១៥៦ ថ្មី ( ពីរ មាត្រា ១៥៤ ថ្មី ) ដល់ មាត្រា ១៦០ ថ្មី ( ពីរ

មាត្រា ១៥៨ ថ្មី )............................................................................ ៥៥

- ឧបសម្ព័ន្ធទី១ : ទង់ជាតិ............................................................................ ៥៧

- ឧបសម្ព័ន្ធទី២ : ភ្លេងជាតិ នគររាជ ............................................................ ៥៨

- ឧបសម្ព័ន្ធទី៣ : សញ្ញាជាតិ........................................................................ ៦០

- ឧបសម្ព័ន្ធទី៤ : សច្ចាប្រណិធាន ( ព្រះមហាក្សត្រ) .......................................... ៦១

- ឧបសម្ព័ន្ធទី៥ : សច្ចាប្រណិធាន ( រដ្ឋសភា).................................................... ៦២

- ឧបសម្ព័ន្ធទី៦ : សច្ចាប្រណិធាន ( រាជរដ្ឋាភិបាល) ........................................... ៦៥

- ឧបសម្ព័ន្ធទី៧ : សច្ចាប្រណិធាន ( ព្រឹទ្ធសភា)................................................. ៦៨

- គណៈកម្មការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ....................................................... ៧១

- ព្រះរាជក្រមចុះថ្ងៃទី ២៤ ខែ កញ្ញា គ.ស ១៩៩៣................................................ ៧៣

- ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១

ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤................................................................ ៧៤

- កំណត់សម្គាល់.............................................................................................. ៨០

- ព្រះរាជក្រម ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ១៩៩៤ .................................................. ៨២

- ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១

ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ១៩៩៩.......................................................................... ៨៤

- ព្រះរាជក្រមលេខ នស/រកម/០៧០១/១១

ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០០១.............................................................. ៨៦

- ព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨

ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០០៥.............................................................. ៨៨

- ព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦

ចុះថ្ងៃទី ៩ ខែ មីនា ឆ្នាំ២០០៦.............................................................. ៩០

- ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨

ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨.............................................................. ៩៣

- ព្រះរាជក្រមលេខ នស/រកម/១០១៤/០២២

ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ២០១៤.............................................................. ៩៥

# បុព្វកថា

* * * *

# យើង ប្រជារាស្ត្រខ្មែរ

ដែលធ្លាប់មានអារ្យធមិឧត្តុង្គឧត្តម ប្រទេសជាតិស្ដុកស្ដម្ភធំទូលាយ ថ្កុំថ្កើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ភ្លឺថ្លៃងចាំងដូចពេជ្រពណ្ណរាយ

បានធ្លាក់ខ្លួនដ៏សែនរន្ធត់ ក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយនេះ ឆ្លងកាត់ទុក្ខសោក វិនាសអន្តរាយ ទ្រុឌទ្រោម ឱនថយ មហាសោកស្ដាយ

បានភ្ញាក់រលឹក ក្រោកឈរឡើង ចងបាច់ឆន្ទះមោះមុត ប្ដូរផ្ដាច់រួបរួមគ្នា ពង្រឹង ឯកភាពជាតិ រក្សាការពារទឹកដីកម្ពុជា អធិបតេយ្យថ្លៃថ្លា និង អារ្យធម៌អង្គរដ៏បវរ កសាង ប្រទេសជាតិឱ្យទៅជា " កោះសន្តិភាព " ឡើងវិញ ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាអនាគតជាតិ ឱ្យបានឈានឡើងរីកចម្រើន លូតលាស់ សម្បូររុងរឿងជានិច្ចនិរន្តរ៍ ។

# ក្នុងឆន្ទៈមោះមុតនេះ

យើងសរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ ÷

## ជំពូកទី ១
## អំពីអធិបតេយ្យ

**មាត្រា ១ ._**

ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ។

**មាត្រា ២ ._**

បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ១៩៦៣-១៩៦៩ ។

**មាត្រា ៣ ._**

ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន ។

**មាត្រា ៤ ._**

បាវចនានៃព្រះរាជាណាចក្រកម្ពុជា គឺ : ជាតិ សាសនា ព្រះមហាក្សត្រ ។

**មាត្រា ៥ ._**

ភាសា និង អក្សរ ដែលប្រើជាផ្លូវការ គឺភាសា និង អក្សរខ្មែរ ។

**មាត្រា ៦ .-**

ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។

ទង់ជាតិ ភ្លេងជាតិ និង សញ្ញាជាតិមានកំណត់នៅក្នុងឧបសម្ព័ន្ធ ១ ២ និង ៣ ។

## ជំពូកទី ២

## អំពីព្រះមហាក្សត្រ

**មាត្រា ៧ .-**

ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ។

ព្រះមហាក្សត្រ ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត ។

អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ ។

**មាត្រា ៨ .-**

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ជានិមិត្តរូបនៃឯកភាពជាតិ និង និរន្តរភាពជាតិ ។

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋ និង ការគោរពសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៩ .-**

ព្រះមហាក្សត្រ ទ្រង់មានតួនាទីខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យមានភាពទៀងទាត់ ។

**មាត្រា ១០ .-**

របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង ។

ព្រះមហាក្សត្រ ទ្រង់ឥតមានព្រះរាជអំណាចចាត់តាំងព្រះរជ្ជទាយាទសម្រាប់គ្រងរាជសម្បត្តិឡើយ ។

**មាត្រា ១១ .- ថ្មី**

ក្នុងករណីដែលព្រះមហាក្សត្រ ពុំអាចបំពេញព្រះរាជភារៈ ជាព្រះប្រមុខរដ្ឋបានដូចធម្មតា ដោយព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ មានការបញ្ជាក់ដោយក្រុមគ្រូពេទ្យជំនាញជ្រើសរើសដោយប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រី នោះប្រធានព្រឹទ្ធសភាបំពេញភារកិច្ចប្រមុខរដ្ឋជំនួសព្រះអង្គ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រ ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ពេលព្រះអង្គទ្រង់ប្រឈួនជាទម្ងន់ ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ប្រធានរដ្ឋសភាជាអ្នកបំពេញភារកិច្ចនេះ ។

តំណែងជាប្រមុខរដ្ឋជំនួសព្រះមហាក្សត្រ ក្នុងឋានៈជាព្រះរាជានុសិទ្ធិនេះ អាចនឹងដូរឥស្សរជនផ្សេងទៀត ក្នុងករណីដូចដែលបានចែងក្នុងវាក្យខ័ណ្ឌខាងលើ តាមឋានានុក្រមដូចតទៅ :

**ក**-អនុប្រធានទី១ ព្រឹទ្ធសភា

**ខ**-អនុប្រធានទី១ រដ្ឋសភា

**គ**-អនុប្រធានទី២ ព្រឹទ្ធសភា

**ឃ**-អនុប្រធានទី២ រដ្ឋសភា

**មាត្រា ១២ .. ថ្មី**

នៅពេលព្រះមហាក្សត្រទ្រង់ចូលទីវង្គត ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិនៃព្រះរាជាណាចក្រកម្ពុជា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ក្នុងពេលព្រះអង្គចូលទីវង្គត ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ក្នុងឋានៈជាព្រះរាជានុសិទ្ធិ ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី២ និង ទី៣ នៃមាត្រា ១១ ថ្មី ។

**មាត្រា ១៣ .. ថ្មី**

ក្នុងរយៈវេលា ៧ ថ្ងៃយ៉ាងយូរ ព្រះមហាក្សត្រថ្មីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សារាជសម្បត្តិ ។

សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិមាន :

- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និង គណៈធម្មយុត្តិកនិកាយ
- អនុប្រធានទី១ និង អនុប្រធានទី២ ព្រឹទ្ធសភា
- អនុប្រធានទី១ និង អនុប្រធានទី២ រដ្ឋសភា

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ ។

**មាត្រា ១៤ ._**

ត្រូវបានជ្រើសរើសជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សមាជិកនៃព្រះរាជវង្សានុវង្សខ្មែរ ដែលមានព្រះជន្មាយុយ៉ាងតិច ៣០ ព្រះវស្សា ហើយដែលជាព្រះរាជបច្ឆាញាតិនៃព្រះមហាក្សត្រ **អង្គឌួង** ឬព្រះមហាក្សត្រ **នរោត្តម** ឬក៏ព្រះមហាក្សត្រ **ស៊ីសុវត្ថិ** ។

មុនចូលគ្រងរាជសម្បត្តិ ព្រះមហាក្សត្រទ្រង់ថ្លែងសច្ចាប្រណិធាន ដូចមានចែងក្នុងឧបសម្ព័ន្ធទី៤ ។

**មាត្រា ១៥ ._**

ព្រះជាយានៃព្រះមហាក្សត្រ មានព្រះរាជឋានៈជាព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៦ ._**

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានព្រះរាជសិទ្ធិធ្វើនយោបាយ ទទួលតួនាទីជាអ្នកដឹកនាំរដ្ឋ ឬជាអ្នកដឹកនាំរាជរដ្ឋាភិបាល ឬទទួលតួនាទីរដ្ឋបាល ឬនយោបាយឡើយ ។

ព្រះមហេសីនៃព្រះរាជាណាចក្រកម្ពុជា ទុកព្រះរាជកាយពលបំពេញព្រះរាជភារៈបម្រើប្រយោជន៍សង្គម មនុស្សធម៌ សាសនា និង ជួយព្រះមហាក្សត្រក្នុងព្រះរាជកាតព្វកិច្ចផ្នែកពិធីការ និង ការទូត ។

**មាត្រា ១៧ ._**

ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ ហើយដែលមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រា ៧ នៃរដ្ឋធម្មនុញ្ញនេះ មិនអាចសុំកែប្រែបានជាដាច់ខាត ។

**មាត្រា ១៨ ._ ថ្មី**

ព្រះមហាក្សត្រ ព្រះអង្គទ្រង់ទាក់ទងជាមួយព្រឹទ្ធសភានិងរដ្ឋសភាដោយព្រះរាជសារ ។

ព្រះរាជសារនេះ ព្រឹទ្ធសភានិងរដ្ឋសភា មិនអាចយកទៅជជែកពិភាក្សាឡើយ ។

**មាត្រា ១៩ ._ ថ្មី**

ព្រះមហាក្សត្រ ទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និង ទ្រង់តែងតាំងគណៈរដ្ឋមន្ត្រី តាមបែបបទដែលមានចែងក្នុងមាត្រា ១១៩ ថ្មី ។

**មាត្រា ២០ ._**

ព្រះមហាក្សត្រ ទ្រង់ទទួលសវនាការជាផ្លូវការពីរដងក្នុងមួយខែ ឱ្យនាយករដ្ឋមន្ត្រី និង គណៈរដ្ឋមន្ត្រីចូលគាល់រាយការណ៍ទូលថ្វាយទ្រង់ជ្រាបអំពីសភាពការណ៍នៃប្រទេសជាតិ ។

**មាត្រា ២១ ._**

តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល និង យោធា ឯកអគ្គរាជទូត និង ប្រេសិតវិសាមញ្ញ និង ពេញសមត្ថភាព ។

តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំង ផ្លាស់ប្តូរ ឬដកចៅក្រមផ្នែកយុត្តាធិការ ។

**មាត្រា ២២ ._ ថ្មី**

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈ ដាក់ប្រទេសជាតិឋិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និង ប្រធានព្រឹទ្ធសភា ។

**មាត្រា ២៣ ._**

ព្រះមហាក្សត្រ ទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ។ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវបានតែងតាំងឡើងដើម្បីបញ្ជាកងយោធពលខេមរភូមិន្ទនេះ។

**មាត្រា ២៤ ._ ថ្មី**

ព្រះមហាក្សត្រ ទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ ដែលនឹងត្រូវបង្កើតឡើងដោយច្បាប់មួយ ។

ព្រះមហាក្សត្រ ទ្រង់ប្រកាសសង្គ្រាមក្រោយការអនុម័តរបស់រដ្ឋសភា និង ព្រឹទ្ធសភា។

**មាត្រា ២៥ ._**

ព្រះមហាក្សត្រ ទ្រង់ទទួលសារតាំងឯកអគ្គរដ្ឋទូត ឬប្រេសិតវិសាមញ្ញ និង ពេញសមត្ថភាពនៃប្រទេសក្រៅមកប្រចាំព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៦ ._ ថ្មី**

ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្ថលេខាលើសន្ធិសញ្ញា និង អនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញា និង អនុសញ្ញាទាំងនេះ ក្រោយបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និង ព្រឹទ្ធសភា ។

**មាត្រា ២៧ ._**

ព្រះមហាក្សត្រ ទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និង លើកលែងទោស ។

## មាត្រា ២៨ .. ថ្មី

ព្រះមហាក្សត្រ ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ និង ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំពីគណៈរដ្ឋមន្ត្រី ។

ក្នុងពេលដែលព្រះមហាក្សត្រប្រឈួន ហើយត្រូវព្យាបាលព្រះរោគនៅបរទេស ក្នុងពេលនោះ ព្រះមហាក្សត្រមានសិទ្ធិផ្ទេរអំណាចឡាយព្រះហស្តលេខានៅលើព្រះរាជក្រម ឬព្រះរាជក្រឹត្យខាងលើនេះ ទៅប្រមុខរដ្ឋស្តីទីចុះហត្ថលេខាជំនួសដោយព្រះរាជសារប្រគល់សិទ្ធិ។

## មាត្រា ២៩ .. ថ្មី

ព្រះមហាក្សត្រ ទ្រង់បង្កើត និង ប្រទានគ្រឿងឥស្សរិយយសជាតិ ។

ព្រះមហាក្សត្រ ទ្រង់សម្រេចប្រទានឋានន្តរសក្តិ ឋានៈ យោធា និង ស៊ីវិល តាមច្បាប់កំណត់ ។

## មាត្រា ៣០ .. ថ្មី

ក្នុងរយៈពេលព្រះមហាក្សត្រទ្រង់អវត្តមាន ប្រធានព្រឹទ្ធសភាទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភា ពុំមានលទ្ធភាពបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីជំនួសព្រះមហាក្សត្រ ពេលព្រះអង្គទ្រង់អវត្តមាន ការទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទី ត្រូវអនុវត្តតាមវាក្យខ័ណ្ឌទី២ និង ទី៣ នៃមាត្រា ១១ ថ្មី ។

# ជំពូកទី ៣
# អំពីសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១ ._**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និង គោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និង កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និង ករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិ សេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២ ._**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាពនិងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា ៣៣ ._**

ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៤ .. ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤0ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និង សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៣៥ ..**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និង ដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

**មាត្រា ៣៦ ..**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាព

របស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៧ ._**

សិទ្ធិធ្វើកូដកម្ម និង ធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨ ._**

ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែដល់ អ្នករួមប្រព្រឹត្ត និង អ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩ .-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬ ប្តឹងទារសំណងជួសជុលការខូចខាតដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និង របស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និង សំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០ .-**

សេរីភាពក្នុងការដើរឆ្ងាយជិត និង តាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋ ត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និង អាថិកំបាំងនៃការឆ្លើយឆ្លងតាមលិខិតតាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និង តាមទូរស័ព្ទ ត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារវត្ថុ និង លើរូបបុគ្គល ត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១ .-**

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២ .-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និង គណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និង សណ្តាប់ធ្នាប់សង្គម ។

**មាត្រា ៤៣ .-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និង ការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤ .-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែ

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈ តម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌ ។

## មាត្រា ៤៥ .-

ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ត្រូវហាមឃាត់ ។

បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធមួយ ។

## មាត្រា ៤៦ .-

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និង អំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូនដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និង សង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

## មាត្រា ៤៧ .-

មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និង អប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹម និង បីបាច់ថែរក្សាមាតាបិតាដែលចាស់ជរា តាមទំនៀម-ទម្លាប់ខ្មែរ ។

## មាត្រា ៤៨ .-

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និង ការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និង ការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

## មាត្រា ៤៩ .-

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និង គោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០ ._**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និង លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និង កម្មសិទ្ធិស្របច្បាប់របស់ឯកជន ។

## ជំពូកទី ៤

## អំពីរបបនយោបាយ

**មាត្រា ៥១ ._ ថ្មី**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន ។

អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួន តាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និង សាលាជម្រះក្តី ។

អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និង អំណាចតុលាការ ។

**មាត្រា ៥២ ._**

រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញារក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ រក្សា

ការពារទំនៀមទម្លាប់ និង ប្រពៃណីល្អរបស់ជាតិ ។ រាជរដ្ឋាភិបាលកម្ពុជា ត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។ រដ្ឋយកចិត្តទុកដាក់ជាអាទិភាព ចំពោះជីវភាពរស់នៅ និង សុខុមាលភាពរបស់ប្រជាពលរដ្ឋ ។

**មាត្រា ៥៣ .-**

ព្រះរាជាណាចក្រកម្ពុជា ប្រកាន់ខ្ជាប់ជានិច្ចនូវនយោបាយអព្យាក្រឹតអចិន្ត្រៃយ៍ និងមិនចូលបក្សសម្ព័ន្ធ ។ ព្រះរាជាណាចក្រកម្ពុជា រួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង និង ប្រទេសដទៃទៀតទាំងអស់នៅលើសកលលោក ។

ព្រះរាជាណាចក្រកម្ពុជា មិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ ឬដោយប្រយោល ទោះបីក្រោមរូបភាពណាក៏ដោយ ដោះស្រាយរាល់បញ្ហាដោយសន្តិវិធី និង គោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក ។

ព្រះរាជាណាចក្រកម្ពុជា មិនចងសម្ព័ន្ធយោធា ឬចូលក្នុងកិច្ចព្រមព្រៀងយោធាណាមួយ ដែលមិនស្របនឹងអព្យាក្រឹតភាពរបស់ខ្លួនឡើយ ។

ព្រះរាជាណាចក្រកម្ពុជា មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីរបស់ខ្លួន ហើយក៏មិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធារបស់ខ្លួននៅបរទេសដែរ លើកលែងតែក្នុងក្របខ័ណ្ឌនៃសំណូមពររបស់អង្គការសហប្រជាជាតិ ។

ព្រះរាជាណាចក្រកម្ពុជា រក្សាសិទ្ធិទទួលយកជំនួយបរទេសជាសម្ភារៈ យោធា អាវុធ គ្រាប់រំសេវ ការហ្វឹកហ្វឺនកងកម្លាំងប្រដាប់អាវុធ និង ជំនួយផ្សេងៗទៀត ដើម្បីការពារខ្លួន និងធានាសណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈនៅផ្ទៃក្នុងប្រទេស ។

**មាត្រា ៥៤ .-**

ការផលិត ការប្រើប្រាស់ ការរក្សាទុកអាវុធបរមាណូ អាវុធគីមី ឬអាវុធជីវសាស្ត្រ ត្រូវហាមឃាត់ដាច់ខាត ។

**មាត្រា ៥៥ .-**

សន្ធិសញ្ញា និង កិច្ចព្រមព្រៀងទាំងឡាយណា ដែលមិនស្របនឹងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និង ឯកភាពជាតិរបស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល ។

## ជំពូកទី ៥
## អំពីសេដ្ឋកិច្ច

**មាត្រា ៥៦ .-**

ព្រះរាជាណាចក្រកម្ពុជា អនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋកិច្ចនេះ នឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៥៧ .-**

ការយកពន្ធដារនឹងអាចធ្វើទៅបាន លុះត្រាតែមានច្បាប់អនុញ្ញាត ។ ថវិកាជាតិត្រូវបានកំណត់ឱ្យអនុវត្តតាមច្បាប់ ។

របបគ្រប់គ្រងរូបិយវត្ថុ និង ប្រព័ន្ធហិរញ្ញវត្ថុត្រូវកំណត់ក្នុងច្បាប់ ។

## មាត្រា ៥៨ ._

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀត ដែលបានកំណត់ថាជារបស់រដ្ឋ ។

ការគ្រប់គ្រង ការប្រើប្រាស់ និង ការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ នឹងត្រូវកំណត់ក្នុងច្បាប់ ។

## មាត្រា ៥៩ ._

រដ្ឋត្រូវរក្សាការពារបរិស្ថាន និង តុល្យភាព នៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ ក្នុងការគ្រប់គ្រង មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និង ឧស្ម័ន ថ្ម និង ខ្សាច់ ត្បូងថ្ម ព្រៃឈើ និង អនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល ។

## មាត្រា ៦០ ._

ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី ។ ការតម្រូវឱ្យលក់ផលិតផលជូនរដ្ឋ ឬការយកភោគផល ឬទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ វៀរលែងតែក្នុងករណីពិសេស ដែលមានច្បាប់អនុញ្ញាត ។

**មាត្រា ៦១ .-**

រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូន បច្ចេកទេសទំនើប និង ប្រព័ន្ធឥណទាន ។

**មាត្រា ៦២ .-**

រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផលជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល ។

**មាត្រា ៦៣ .-**

រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ មានកម្រិតសមរម្យ ។

**មាត្រា ៦៤ .-**

រដ្ឋហាមឃាត់ និង ផ្តន្ទាទោសជាទម្ងន់ដល់ជនណាដែលនាំចូល ផលិត លក់ដូរគ្រឿងញៀន ទំនិញក្លែងក្លាយ ហួសរយៈពេលប្រើ ដែលប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់អ្នកប្រើ ។

# ជំពូកទី ៦
## អំពីអប់រំ វប្បធម៌ និង សង្គមកិច្ច

### មាត្រា ៦៥ .-

រដ្ឋត្រូវការពារ និង លើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត និង ត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហាន១ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប ។

រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និង កីឡា ដែលជាសុខុមាលភាពរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ។

### មាត្រា ៦៦ .-

រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និង ឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និង គោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត ។

### មាត្រា ៦៧ .-

រដ្ឋអនុវត្តកម្មវិធីសិក្សា និង គោលការណ៍គរុកោសល្យទំនើប រាប់បញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស ។

រដ្ឋគ្រប់គ្រងគ្រឹះស្ថានសិក្សា និង ថ្នាក់សិក្សាសាធារណៈ និង ឯកជននៅគ្រប់ភូមិសិក្សា ។

## មាត្រា ៦៨ .-

រដ្ឋផ្ដល់កិច្ចការអប់រំផ្នែកបឋម និង មធ្យមសិក្សា នៅសាលារៀនសាធារណៈ សម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ ។

ប្រជាពលរដ្ឋ ត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ ។

រដ្ឋជួយផ្សព្វផ្សាយ និង លើកតម្កើងសាលាបាលី និង ពុទ្ធិកសិក្សា ។

## មាត្រា ៦៩ .-

រដ្ឋមានកាតព្វកិច្ចថែរក្សា និង ពង្រីកវប្បធម៌ជាតិ ។

រដ្ឋមានកាតព្វកិច្ចការពារ និង ពង្រីកភាសាខ្មែរឱ្យសមស្របនឹងសេចក្ដីត្រូវការ ។

រដ្ឋមានកាតព្វកិច្ចថែរក្សា និង ការពារប្រាសាទបុរាណ វត្ថុសិល្បៈបុរាណ និង កែលំអរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ ។

## មាត្រា ៧០ .-

បទល្មើសទាំងឡាយ ដែលប៉ះពាល់ ឬទាក់ទងនឹងបេតិកភណ្ឌវប្បធម៌ និង បេតិកភណ្ឌសិល្បៈ ត្រូវផ្ដន្ទាទោសជាទម្ងន់ ។

## មាត្រា ៧១ .-

បរិវេណបេតិកភណ្ឌជាតិ ក៏ដូចជាបេតិកភណ្ឌដែលបានបញ្ចូលជាបេតិកភណ្ឌពិភពលោក ត្រូវទុកជាតំបន់អព្យាក្រឹត ដែលមិនឱ្យមានសកម្មភាពយោធា ។

**មាត្រា ៧២ .-**

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺ និង ព្យាបាលជំងឺ ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និង មន្ទីរសម្ភពសាធារណៈ ។

រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និង មន្ទីរសម្ភពដល់ជនបទ ។

**មាត្រា ៧៣ .-**

រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និង មាតា ។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និង ជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង ។

**មាត្រា ៧៤ .-**

រដ្ឋជួយឧបត្ថម្ភជនពិការ និង ដល់គ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។

**មាត្រា ៧៥ .-**

រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គមដល់កម្មករ និង និយោជិត ។

## ជំពូកទី ៧

## អំពីរដ្ឋសភា

**មាត្រា ៧៦ .- ថ្មី**

រដ្ឋសភាមានសមាជិកជាតំណាងរាស្ត្រយ៉ាងតិច ១២០រូប ។

តំណាងរាស្ត្រ ត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និង តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

តំណាងរាស្ត្រអាចឈរឈ្មោះបោះឆ្នោតសាជាថ្មីបាន ។

អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រ គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ២៥ ឆ្នាំ មានសញ្ជាតិជាខ្មែរតាំងពីកំណើត ។

បែបបទ និង ការប្រព្រឹត្តទៅនៃការបោះឆ្នោតត្រូវកំណត់ក្នុងច្បាប់បោះឆ្នោត ។

## មាត្រា ៧៧ ._

តំណាងរាស្ត្រក្នុងរដ្ឋសភា ជាតំណាងប្រជាជាតិខ្មែរទាំងមូល ពុំមែនគ្រាន់តែជាតំណាងប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួននោះទេ ។

អាណត្តិអាជ្ញាបញ្ជាទាំងឡាយ ត្រូវទុកជាមោឃៈ ។

## មាត្រា ៧៨ ._

នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង ។ រដ្ឋសភាមិនអាចត្រូវបានរំលាយមុនផុតអាណត្តិបានឡើយ វៀរលែងតែក្នុងករណីដែលរាជរដ្ឋាភិបាល ត្រូវបានទម្លាក់ពីរដងក្នុងរយៈ ១២ ខែ ។

ក្នុងករណីនេះ ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រី និង បន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា ។

ការបោះឆ្នោតដើម្បីជ្រើសរើសរដ្ឋសភាថ្មី នឹងប្រព្រឹត្តទៅក្នុងរយៈពេល ៦០ថ្ងៃយ៉ាងយូរ

ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភាមក ។

ក្នុងរយៈកាលនេះ រាជរដ្ឋាភិបាលមានតែភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ ។

ក្នុងពេលមានសង្គ្រាម ឬ ក្នុងកាលៈទេសៈពិសេសដទៃទៀត ដែលមិនអាចធ្វើការបោះឆ្នោតកើត រដ្ឋសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់រដ្ឋសភា ត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

## មាត្រា ៧៩ .-

អាណត្តិនៃសមាជិករដ្ឋសភា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ វៀរលែងតែទៅបំពេញមុខងារក្នុងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក្នុងករណីនេះ សមាជិករដ្ឋសភារូបនោះមានឋានៈជាសមាជិករដ្ឋសភាធម្មតា ប៉ុន្តែមិនត្រូវមានមុខតំណែងអ្វីទាំងអស់ក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ និងក្នុងគណៈកម្មការផ្សេងៗនៃរដ្ឋសភា ។

## មាត្រា ៨០ .-

តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា ។

តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃរដ្ឋសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីរដ្ឋសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីខាងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភា ត្រូវដាក់ជូនសម័យប្រជុំរដ្ឋសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់តំណាងរាស្ត្រណាមួយត្រូវផ្អាក ប្រសិនបើរដ្ឋសភាបានបញ្ចេញមតិឱ្យផ្អាក តាមមតិភាគច្រើនបីភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**មាត្រា ៨១ .-**

រដ្ឋសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។

តំណាងរាស្ត្រត្រូវទទួលប្រាក់បំណាច់ ។

**មាត្រា ៨២ .- ថ្មី**

រដ្ឋសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវ ប្រធាន អនុប្រធាន រដ្ឋសភា និង

សមាជិកទាំងអស់នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

តំណាងរាស្ត្រទាំងអស់ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៥ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ៨៣ .-**

រដ្ឋសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗ មានថិរវេលាយ៉ាងតិចបីខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬ ពីសមាជិករដ្ឋសភាចំនួនមួយភាគបីយ៉ាងតិច គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា កោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។

ក្នុងករណីនេះ របៀបវារៈជាក់លាក់នៃសម័យប្រជុំជាវិសាមញ្ញ ត្រូវផ្សាយដល់ប្រជារាស្ត្រជាមួយនឹងថ្ងៃកំណត់ប្រជុំ ។

**មាត្រា ៨៤ .-**

នៅចន្លោះសម័យប្រជុំរបស់រដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភារួមមាន : ប្រធានរដ្ឋសភា អនុប្រធានរដ្ឋសភា និងប្រធានគណៈកម្មការទាំងអស់របស់រដ្ឋសភា ។

**មាត្រា ៨៥ .–**

សម័យប្រជុំរដ្ឋសភា ត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់រដ្ឋសភា លើកលែងតែមានការសម្រេចផ្សេងចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើ និង ក្រៅពីកន្លែង និង ពីកាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់រដ្ឋសភាត្រូវទុកជាខុសច្បាប់ ហើយជាអសារសូន្យពេញលក្ខណៈ ។

**មាត្រា ៨៦ .–**

ក្នុងកាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន រដ្ឋសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ រដ្ឋសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើរដ្ឋសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ ជាអាទិ៍នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

នៅពេលដែលប្រទេសជាតិឋិតក្នុងភាពអាសន្ន រដ្ឋសភាមិនអាចត្រូវរំលាយបានឡើយ ។

**មាត្រា ៨៧ .–**

ប្រធានរដ្ឋសភាដឹកនាំអង្គប្រជុំរបស់រដ្ឋសភា ទទួលអាញត្តិច្បាប់ និង សេចក្តីសម្រេចចិត្តទាំងឡាយ ដែលរដ្ឋសភាបានអនុម័ត រ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់រដ្ឋសភា ។

ក្នុងករណីដែលប្រធានរដ្ឋសភាមានធុរៈមិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជំងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានរដ្ឋសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានរដ្ឋសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម រដ្ឋសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។

## មាត្រា ៨៨ ._ ថ្មី ( ពីរ )

ការប្រជុំរដ្ឋសភាត្រូវធ្វើជាសាធារណៈ ។

រដ្ឋសភាអាចប្រជុំជាសម្ងាត់បាន តាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ឬពីនាយករដ្ឋមន្ត្រី ។

ការប្រជុំរដ្ឋសភានឹងយកជាការបានលុះត្រាតែមាន :

**ក**-កូរ៉ុមលើសពី ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

**ខ**-កូរ៉ុមលើសពី ពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

## មាត្រា ៨៩ ._

តាមការសុំពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច រដ្ឋសភាអាចអញ្ជើញឥស្សរជនដ៏ឧត្តមណាមួយមកបំភ្លឺរដ្ឋសភា អំពីបញ្ហាដែលមានសារៈសំខាន់ពិសេស ។

## មាត្រា ៩០ .. ថ្មី ( ពីរ )

រដ្ឋសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួន ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន ។

រដ្ឋសភាអនុម័តថវិកាជាតិ ផែនការរដ្ឋ ការឱ្យរដ្ឋខ្ចីប្រាក់ពីគេ ការឱ្យរដ្ឋឱ្យប្រាក់គេខ្ចី ការសន្យានានាផ្នែកហិរញ្ញវត្ថុ និង ការបង្កើត កែប្រែ ឬលុបចោលពន្ធដារ ។

រដ្ឋសភាឱ្យសេចក្តីយល់ព្រមចំពោះគណនីរដ្ឋបាល ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ។

រដ្ឋសភាអនុម័តយល់ព្រម ឬលុបចោលសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ។

រដ្ឋសភាអនុម័តច្បាប់ស្តីពីការប្រកាសសង្គ្រាម ។

ការអនុម័តខាងលើនេះ ប្រព្រឹត្តទៅដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

រដ្ឋសភាបោះឆ្នោតទុកចិត្តដល់រាជរដ្ឋាភិបាល តាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

## មាត្រា ៩១ .. ថ្មី

សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និង នាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ។

តំណាងរាស្ត្រមានសិទ្ធិស្នើធ្វើវិសោធនកម្មច្បាប់ ប៉ុន្តែសំណើនេះមិនអាចទទួលយកបានទេ បើវិសោធនកម្មនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ ឬបន្ថែមបន្ទុកលើប្រជាពលរដ្ឋ។

## មាត្រា ៩២ .-

ការអនុម័តទាំងឡាយរបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍ រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិនឹងត្រូវចាត់ទុកជាអសារសូន្យ ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចពីមោឃភាពនេះ ។

## មាត្រា ៩៣ .- ថ្មី

ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញក្នុងរយៈពេលដប់ថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ និង នៅទូទាំងប្រទេសក្នុងរយៈពេលម្ភៃថ្ងៃគត់ ក្រោយពីថ្ងៃប្រកាសឱ្យប្រើ ។ ប៉ុន្តែបើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ ។

ច្បាប់ដែលព្រះមហាក្សត្រ ទ្រង់បានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចុះក្នុងរាជកិច្ច និង ផ្សព្វផ្សាយនៅទូទាំងប្រទេស ឱ្យទាន់តាមពេលកំណត់ខាងលើ ។

## មាត្រា ៩៤ .-

រដ្ឋសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និង ការប្រព្រឹត្តទៅនៃរដ្ឋសភានឹងមានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ។

**មាត្រា ៩៥ .-**

ក្នុងករណីមានសមាជិករដ្ឋសភាទទួលអនិច្ចកម្ម លាលែង ឬប្រាសចាកសមាជិកភាព ដែលកើតមានឡើង ៦ ខែ យ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់ការជ្រើសតាំងជំនួសសមាជិកនោះ តាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និង ក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៩៦ .-**

តំណាងរាស្ត្រមានសិទ្ធិដាក់សំណួរដល់រាជរដ្ឋាភិបាល ។ សំណួរនេះត្រូវសរសេរជាលាយល័ក្ខណ៏អក្សរ ប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា ។

ចម្លើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬច្រើនរូប អាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬច្រើនរូប ។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន ។

ចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៏អក្សរ ។

ចម្លើយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ ។

ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចបើកឱ្យមាន ឬមិនឱ្យមានការជជែកដេញដោល ។ បើគ្មានការបើកឱ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រីឬនាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង ។

បើមានការបើកឱ្យជជែកដេញដោល ម្ចាស់សំណួរ វាគ្មិនឯទៀត និង រដ្ឋមន្ត្រីពាក់ព័ន្ធឬនាយករដ្ឋមន្ត្រី អាចជជែកប្តូរយោបល់ក្នុងរយៈពេលដែលមិនអាចលើសពីមួយពេលប្រជុំឡើយ ។

រដ្ឋសភាកំណត់ទុកពេលមួយថ្ងៃក្នុងមួយសប្ដាហ៍ សម្រាប់ការឆ្លើយសំណួរ ។

ទោះបីយ៉ាងណាក៏ដោយ សម័យប្រជុំសម្រាប់ឆ្លើយសំណួរខាងលើនេះ មិនអាចបើកលទ្ធភាពឱ្យមានការបោះឆ្នោតប្រភេទណាមួយបានឡើយ ។

**មាត្រា ៩៧ ._**

គណៈកម្មការទាំងឡាយរបស់រដ្ឋសភា អាចអញ្ជើញរដ្ឋមន្ត្រីមកបំភ្លឺអំពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន ។

**មាត្រា ៩៨ ._ ថ្មី**

រដ្ឋសភាអាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលពីតំណែង ដោយអនុម័តញ្ញត្តិបន្ទោស តាមសំឡេងឆ្នោតភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ញត្តិបន្ទោសរាជរដ្ឋាភិបាលត្រូវបានលើកឡើងជូនរដ្ឋសភា ដោយតំណាងរាស្ត្រចំនួនសាមសិបនាក់ ទើបរដ្ឋសភាអាចលើកមកពិភាក្សាបាន ។

## ជំពូកទី ៨ ថ្មី
## អំពីព្រឹទ្ធសភា

**មាត្រា ៩៩ ._ ថ្មី**

ព្រឹទ្ធសភាជាអង្គការដែលមានអំណាចនីតិប្បញ្ញត្តិ ហើយបំពេញភារកិច្ចរបស់ខ្លួនដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់ជាធរមាន ។

ព្រឹទ្ធសភាមានចំនួនសមាជិកយ៉ាងច្រើន ស្មើនឹងពាក់កណ្តាលនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និង ត្រូវជ្រើសតាំងដោយការបោះឆ្នោតអសកលខ្លះ ។

សមាជិកព្រឹទ្ធសភាអាចត្រូវបានចាត់តាំង និង ជ្រើសតាំងសាជាថ្មីបាន ។ អ្នកដែលមានសិទ្ធិឈរឈ្មោះជាបេក្ខជនព្រឹទ្ធសភា គឺជាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានសិទ្ធិបោះឆ្នោត មានអាយុយ៉ាងតិច ៤0 ឆ្នាំ មានសញ្ជាតិខ្មែរតាំងពីកំណើត ។

**មាត្រា ១០០ .. ថ្មី**

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ ។

សមាជិកព្រឹទ្ធសភាចំនួន ២រូប ត្រូវបានរដ្ឋសភាជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀប ។

រីឯសមាជិកព្រឹទ្ធសភាឯទៀតត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល ។

**មាត្រា ១០១ .. ថ្មី**

ការរៀបចំបែបបទ និង ការប្រព្រឹត្តទៅនៃការចាត់តាំង និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ព្រមទាំងការកំណត់អំពីអ្នកបោះឆ្នោត អង្គបោះឆ្នោត និង មណ្ឌលបោះឆ្នោត ត្រូវចែងក្នុងច្បាប់មួយ ។

**មាត្រា ១០២ .. ថ្មី**

នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់ ៦ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

ក្នុងពេលមានសង្គ្រាម ឬក្នុងកាលៈទេសៈពិសេសដទៃទៀតដែលមិនអាចធ្វើការបោះឆ្នោតកើត ព្រឹទ្ធសភាអាចប្រកាសបន្តនីតិកាលរបស់ខ្លួនមួយដងបានមួយឆ្នាំ តាមសំណើរបស់ព្រះមហាក្សត្រ ។

ការប្រកាសបន្តនីតិកាលរបស់ព្រឹទ្ធសភា ត្រូវសម្រេចដោយមតិយល់ព្រមពីរភាគបីយ៉ាងតិចនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ ព្រឹទ្ធសភាប្រជុំរាល់ថ្ងៃជាប់ជាប្រចាំ ។ ព្រឹទ្ធសភាមានសិទ្ធិសម្រេចបញ្ចប់កាលៈទេសៈពិសេសខាងលើនេះ កាលបើសភាពការណ៍អនុញ្ញាត ។

បើព្រឹទ្ធសភាមិនអាចប្រជុំបានទេ ដោយមូលហេតុចាំបាច់ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ ។

## មាត្រា ១០៣ .. ថ្មី

អាណត្តិនៃសមាជិកព្រឹទ្ធសភា មានវិសមិតភាពជាមួយការបំពេញមុខងារសាធារណៈជាសកម្ម ជាមួយមុខងារជាតំណាងរាស្ត្រ និង ជាមួយមុខងារជាសមាជិកស្ថាប័នដទៃទៀតដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

## មាត្រា ១០៤ .. ថ្មី

សមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា ។

សមាជិកព្រឹទ្ធសភារូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬ បញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះ

ឡើយ ។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនសមាជិកណាមួយនៃព្រឹទ្ធសភា នឹងអាចធ្វើទៅកើត លុះត្រាតែមានការយល់ព្រមពីព្រឹទ្ធសភា ឬពីគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាក្នុងចន្លោះសម័យប្រជុំនៃព្រឹទ្ធសភា វៀរលែងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។ ក្នុងករណីចុងក្រោយនេះ ក្រសួងមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជូនព្រឹទ្ធសភា ឬជូនគណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាជាបន្ទាន់ដើម្បីសម្រេច ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភា ត្រូវដាក់ជូនសម័យប្រជុំព្រឹទ្ធសភាខាងមុខ ដើម្បីអនុម័តតាមមតិភាគច្រើនពីរភាគបីនៃសមាជិកព្រឹទ្ធសភាទាំងមូល ។

ក្នុងករណីទាំងអស់ខាងលើនេះ ការឃុំខ្លួន ការចោទប្រកាន់សមាជិកព្រឹទ្ធសភាណាមួយត្រូវផ្អាក ប្រសិនបើព្រឹទ្ធសភាបានបញ្ចេញមតិឱ្យផ្អាកតាមមតិភាគច្រើនបីភាគបួននៃសមាជិកព្រឹទ្ធសភាទាំងមូល ។

### មាត្រា ១០៥ .- ថ្មី

ព្រឹទ្ធសភាមានថវិកាស្វយ័តសម្រាប់ដំណើរការ ។

សមាជិកព្រឹទ្ធសភាត្រូវទទួលប្រាក់បំណាច់ ។

### មាត្រា ១០៦ .- ថ្មី ( មួយ )

ព្រឹទ្ធសភាបើកសម័យប្រជុំដំបូង ហុកសិបថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោត តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

មុនចាប់ផ្តើមការងាររបស់ខ្លួន ព្រឹទ្ធសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ និងត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធាន អនុប្រធានព្រឹទ្ធសភា និង សមាជិកទាំងអស់នៃគណៈកម្មការនានារបស់ព្រឹទ្ធសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

សមាជិកព្រឹទ្ធសភាទាំងអស់ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធទី៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ១០៧ ._ ថ្មី**

ព្រឹទ្ធសភាប្រជុំជាសាមញ្ញពីរដងក្នុងមួយឆ្នាំ ។

សម័យប្រជុំនីមួយៗ មានថិរវេលាយ៉ាងតិចបីខែ។ បើមានសំណូមពរពីព្រះមហាក្សត្រ ឬសេចក្តីស្នើសុំពីនាយករដ្ឋមន្ត្រី ឬពីសមាជិកព្រឹទ្ធសភាចំនួនមួយភាគបីយ៉ាងតិច ព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ ។

**មាត្រា ១០៨ ._ ថ្មី**

នៅចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាទទួលភារកិច្ចចាត់ចែងការងារ ។

គណៈកម្មាធិការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភារួមមាន : ប្រធានព្រឹទ្ធសភា អនុប្រធានព្រឹទ្ធសភា និង ប្រធានគណៈកម្មការទាំងអស់របស់ព្រឹទ្ធសភា ។

**មាត្រា ១០៩ ._ ថ្មី**

សម័យប្រជុំព្រឹទ្ធសភាត្រូវធ្វើនៅរាជធានីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងសាលប្រជុំរបស់

ព្រឹទ្ធសភា លើកលែងតែមានការសម្រេចផ្សេង ចុះក្នុងលិខិតកោះប្រជុំដោយកាលៈទេសៈតម្រូវ ។

ក្រៅពីករណីខាងលើ និង ក្រៅពីកន្លែង និង កាលបរិច្ឆេទដែលកំណត់ក្នុងសេចក្តីអញ្ជើញ ការប្រជុំណាក៏ដោយរបស់ព្រឹទ្ធសភាត្រូវទុកជាខុសច្បាប់ ហើយអសារសូន្យពេញលក្ខណៈ ។

**មាត្រា ១១០ .. ថ្មី**

ប្រធានព្រឹទ្ធសភាដឹកនាំអង្គប្រជុំរបស់ព្រឹទ្ធសភា ទទួលអាញត្តិច្បាប់ និង សេចក្តីសម្រេចចិត្តទាំងឡាយដែលព្រឹទ្ធសភាបានអនុម័ត រ៉ាប់រងការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា និង ចាត់ចែងការទាក់ទងអន្តរជាតិទាំងឡាយរបស់ព្រឹទ្ធសភា ។

ក្នុងករណីដែលប្រធានព្រឹទ្ធសភាមានធុរៈមិនអាចបំពេញមុខងារបាន ដោយហេតុមកពីមានជំងឺ ឬបំពេញមុខងារជាប្រមុខរដ្ឋស្តីទី ឬជាព្រះរាជានុសិទ្ធិ ឬបំពេញបេសកកម្មនៅបរទេស អនុប្រធានព្រឹទ្ធសភាមួយរូប ត្រូវទទួលភារកិច្ចចាត់ចែងការងារជំនួស ។

ក្នុងករណីដែលប្រធាន ឬអនុប្រធានព្រឹទ្ធសភាលាលែងពីមុខតំណែង ឬទទួលអនិច្ចកម្ម ព្រឹទ្ធសភាត្រូវបោះឆ្នោតជ្រើសតាំងប្រធាន ឬអនុប្រធានថ្មី ។

**មាត្រា ១១១ .. ថ្មី ( ពីរ )**

ការប្រជុំព្រឹទ្ធសភាត្រូវធ្វើជាសាធារណៈ ។

ព្រឹទ្ធសភាអាចប្រជុំជាសម្ងាត់បានតាមការស្នើសុំពីប្រធាន ឬពីសមាជិកចំនួនមួយភាគដប់យ៉ាងតិច ពីព្រះមហាក្សត្រ ពីនាយករដ្ឋមន្ត្រី ឬពីប្រធានរដ្ឋសភា ។

ការប្រជុំព្រឹទ្ធសភានឹងយកជាការបាន លុះត្រាតែមាន :

**ក**-កូរ៉ុមលើសពី ពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

**ខ**-កូរ៉ុមលើសពី ពាក់កណ្តាលនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណា ដែលតម្រូវឱ្យយកមតិភាគច្រើនដោយប្រៀប ឬយកមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

ចំនួនសំឡេងដែលតម្រូវសម្រាប់រដ្ឋសភាអនុម័តយល់ព្រម ហើយដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវយកមកប្រើសម្រាប់ព្រឹទ្ធសភាផងដែរ ។

## មាត្រា ១១២ ._ ថ្មី

ព្រឹទ្ធសភាមានភារកិច្ចសម្របសម្រួលការងាររវាងរដ្ឋសភា និង រដ្ឋាភិបាល ។

## មាត្រា ១១៣ ._ ថ្មី

ព្រឹទ្ធសភាពិនិត្យ ហើយឱ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរ លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួងដែលរដ្ឋសភាបានដាក់ឱ្យពិនិត្យ ។ បើជាការប្រញាប់ រយៈពេលនោះត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ ។

បើព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម ឬពុំបានឱ្យយោបល់សោះ ក្នុងរយៈពេលដែលមានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

បើព្រឹទ្ធសភាសុំឱ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទីពីរ ។ រដ្ឋសភាត្រូវពិនិត្យ និង សម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំឱ្យកែសម្រួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។

ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និង រដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និង ហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់ ។

បើរដ្ឋសភាទុកឱ្យហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និង ព្រឹទ្ធសភាត្រូវបន្ថែមឱ្យស្មើគ្នាដែរ ។

បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបាន មុនរយៈពេលមួយខែទេ ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និង ហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់ ។

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទី២នេះ រដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហ និង យកតាមមតិភាគច្រើនដាច់ខាត ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណា ដែលបានសម្រេចដូចខាងលើនេះ ហើយនោះនឹងត្រូវបានយកទៅប្រកាសឱ្យប្រើ ។

### មាត្រា ១១៤ ._ ថ្មី ( មួយ )

ព្រឹទ្ធសភាបង្កើតគណៈកម្មការផ្សេងៗដែលចាំបាច់ ។ ការរៀបចំ និង ការប្រព្រឹត្តទៅនៃព្រឹទ្ធសភានឹងកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា។ បទបញ្ជាផ្ទៃក្នុងនេះ ត្រូវអនុម័តយល់ព្រមដោយសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល ។

### មាត្រា ១១៥ ._ ថ្មី

ក្នុងករណីមានសមាជិកព្រឹទ្ធសភាទទួលអនិច្ចកម្ម លាលែង ឬប្រាសចាកសមាជិកភាពដែលកើតមានឡើងប្រាំមួយខែយ៉ាងតិចមុនចប់នីតិកាល ត្រូវចាត់តាំង ឬជ្រើសតាំងជំនួសសមាជិកនោះ តាមល័ក្ខខ័ណ្ឌកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា និង ក្នុងច្បាប់ស្ដីពីការចាត់តាំង និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## ជំពូកទី ៩ ថ្មី
## អំពីសមាជរដ្ឋសភា និង ព្រឹទ្ធសភា

### មាត្រា ១១៦ ._ ថ្មី

ក្នុងករណីចាំបាច់ រដ្ឋសភា និង ព្រឹទ្ធសភាអាចប្រជុំរួមគ្នាជាសមាជ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗ របស់ប្រទេសជាតិ ។

### មាត្រា ១១៧ ._ ថ្មី

បញ្ហាសំខាន់ៗរបស់ប្រទេសជាតិ ដូចមានចែងក្នុងមាត្រា ១១៦ ថ្មី ខាងលើ ព្រមទាំងការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

# ជំពូកទី ១០ ថ្មី
# អំពីរាជរដ្ឋាភិបាល

## មាត្រា ១១៨ .. ថ្មី ( មាត្រា ៩៩ ចាស់ )

គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈរដ្ឋមន្ត្រី ត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការជាសមាជិក ។

## មាត្រា ១១៩ .. ថ្មី ( មាត្រា ១០០ ចាស់ )

តាមសេចក្តីស្នើពីប្រធាន ដោយមានមតិឯកភាពពីអនុប្រធានទាំងពីរនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូប ក្នុងចំណោមតំណាងរាស្ត្រនៃគណបក្សដែលឈ្នះឆ្នោត ឱ្យបង្កើតរាជរដ្ឋាភិបាល ។ វរជនដែលត្រូវបានចាត់តាំងនេះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកគណបក្សតំណាងនៅក្នុងរដ្ឋសភា ដែលផ្តូលផ្តងឱ្យកាន់តំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល ។

មុនចូលកាន់តំណែងគណៈរដ្ឋមន្ត្រីត្រូវធ្វើសច្ចាប្រណិធាន ដូចមានខ្លឹមសារចែងក្នុងឧបសម្ព័ន្ធ ៦ ។

## មាត្រា ១២០ .. ថ្មី ( មាត្រា ១០១ ចាស់ )

មុខងារនៃសមាជិករាជរដ្ឋាភិបាល មានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈ ផ្នែកពាណិជ្ជកម្ម ឬឧស្សាហកម្ម ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ។

**មាត្រា ១២១ .. ថ្មី ( មាត្រា ១០២ ចាស់ )**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរួមគ្នាចំពោះរដ្ឋសភា អំពីនយោបាយទូទៅរបស់រាជរដ្ឋាភិបាល ។

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងខ្លួន ចំពោះនាយករដ្ឋមន្ត្រី និងចំពោះរដ្ឋសភា អំពីការដែលខ្លួនបានប្រព្រឹត្ត ។

**មាត្រា ១២២ .. ថ្មី ( មាត្រា ១០៣ ចាស់ )**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលមិនអាចយកសំអាងនៃសេចក្តីបង្គាប់ដោយលាយលក្ខណ៍អក្សរ ឬដោយវាចាអំពីនរណាមួយ ដើម្បីដោះសាឱ្យរួចខ្លួនពីការទទួលខុសត្រូវរបស់ខ្លួនបានឡើយ ។

**មាត្រា ១២៣ .. ថ្មី ( មាត្រា ១០៤ ចាស់ )**

គណៈរដ្ឋមន្ត្រី ត្រូវប្រជុំរាល់សប្តាហ៍ ជាប្រជុំធំ ឬជាប្រជុំពិនិត្យស្រាវជ្រាវ ។

អង្គប្រជុំធំ ត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

កំណត់ហេតុនៃអង្គប្រជុំទាំងអស់របស់គណៈរដ្ឋមន្ត្រី ត្រូវផ្ញើថ្វាយព្រះមហាក្សត្រទ្រង់ជ្រាប ។

**មាត្រា ១២៤ .. ថ្មី ( មាត្រា ១០៥ ចាស់ )**

នាយករដ្ឋមន្ត្រីអាចរំលែកអំណាចរបស់ខ្លួនឱ្យទៅឧបនាយករដ្ឋមន្ត្រី ឬសមាជិកណាមួយនៃរាជរដ្ឋាភិបាលបាន ។

### មាត្រា ១២៥ ._ ថ្មី ( មាត្រា ១០៦ ចាស់ )

បើតំណែងនាយករដ្ឋមន្ត្រីនៅទំនេរជាស្ថាពរនោះ ត្រូវតែងតាំងគណៈរដ្ឋមន្ត្រីមួយជាថ្មី ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ ។ បើការទំនេរនេះ ជាការទំនេរមួយកាលមួយគ្រាទេ ត្រូវចាត់តាំងនាយករដ្ឋមន្ត្រីស្តីទី ជាបណ្តោះអាសន្ន ។

### មាត្រា ១២៦ ._ ថ្មី ( មាត្រា ១០៧ ចាស់ )

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាល ត្រូវទទួលទណ្ឌកម្មពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលខ្លួនបានប្រព្រឹត្តក្នុងការបំពេញការងាររបស់ខ្លួន ។

ក្នុងករណីនេះ និង ក្នុងករណីធ្វើខុសជាទម្ងន់ក្នុងការបំពេញការងាររបស់ខ្លួន រដ្ឋសភាអាចសម្រេចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

រដ្ឋសភាសម្រេចក្នុងរឿងនេះ ដោយវិធីបោះឆ្នោតជាសម្ងាត់ តាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល ។

### មាត្រា ១២៧ ._ ថ្មី ( មាត្រា ១០៨ ចាស់ )

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

## ជំពូកទី ១១ ថ្មី

## អំពីអំណាចតុលាការ

### មាត្រា ១២៨ ._ ថ្មី ( មាត្រា ១០៩ ចាស់ )

អំណាចតុលាការជាអំណាចឯករាជ្យ ។

អំណាចតុលាការ ធានារក្សាអនាគតិ និង ការពារសិទ្ធិ សេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់ ។

**មាត្រា ១២៩ .. ថ្មី ( មាត្រា ១១០ ចាស់ )**

ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និង ច្បាប់ជាធរមាន ។

មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឱ្យអស់ពីដួងចិត្ត និង សម្បជញ្ញៈរបស់ខ្លួន ។

**មាត្រា ១៣០ .. ថ្មី ( មាត្រា ១១១ ចាស់ )**

គ្មានអង្គការណាមួយនៃអំណាចនីតិប្បញ្ញត្តិ ឬ នីតិប្រតិបត្តិ អាចទទួលអំណាចតុលាការអ្វីបានឡើយ ។

**មាត្រា ១៣១ .. ថ្មី ( មាត្រា ១១២ ចាស់ )**

មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា ។

**មាត្រា ១៣២ .. ថ្មី ( មាត្រា ១១៣ ចាស់ )**

ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ ។

**មាត្រា ១៣៣ ._ ថ្មី ( មាត្រា ១១៤ ចាស់ )**

ចៅក្រមមិនអាចត្រូវគេដកពីមុខងារបានទេ ។ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្រេចដាក់វិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស ។

**មាត្រា ១៣៤ ._ ថ្មី ( មាត្រា ១១៥ ចាស់ )**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវបង្កើតដោយច្បាប់រៀបចំអង្គការមួយ ដែលនឹងកំណត់សមាសភាព និង មុខងារ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។ ព្រះមហាក្សត្រ ព្រះអង្គទ្រង់អាចចាត់តាំងព្រះរាជតំណាងម្នាក់របស់ព្រះអង្គឱ្យធ្វើជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនេះ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតែងតាំងចៅក្រម និង ព្រះរាជអាជ្ញាអមសាលាជម្រះក្តីទាំងអស់ ។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងមុខការដាក់វិន័យចំពោះចៅក្រម និង ព្រះរាជអាជ្ញា ត្រូវប្រជុំក្រោមអធិបតីភាពនៃប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អាស្រ័យដោយករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា ។

**មាត្រា ១៣៥ ._ ថ្មី ( មាត្រា ១១៦ ចាស់ )**

លក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា និង ការរៀបចំអង្គការតុលាការនឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកពីគ្នា ។

# ជំពូកទី ១២ ថ្មី
# អំពីក្រុមប្រឹក្សាធម្មនុញ្ញ

## មាត្រា ១៣៦ ._ ថ្មី

ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។

ក្រុមប្រឹក្សាធម្មនុញ្ញមានសិទ្ធិពិនិត្យ និង សម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

## មាត្រា ១៣៧ ._ ថ្មី ( មាត្រា ១១៨ ចាស់ )

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិកប្រាំបួនរូប ដែលទទួលអាណត្តិប្រាំបួនឆ្នាំ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបី ត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង បីឆ្នាំម្តង ។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្រ បីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។ ប្រធានមានសំឡេងឧត្តមានុភាព ក្នុងករណីបែកសំឡេងជាពីរស្មើគ្នា ។

## មាត្រា ១៣៨ ._ ថ្មី ( មាត្រា ១១៩ ចាស់ )

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើសក្នុងចំណោមឥស្សរជន ដែលមានសញ្ញាបត្រចាប់ពីឧត្តមសិក្សាទៅ ខាងច្បាប់ ខាងរដ្ឋបាល ខាងការទូត ឬខាងសេដ្ឋកិច្ច ហើយមានពិសោធន៍ច្រើនក្នុងការងារ ។

## មាត្រា ១៣៩ .. ថ្មី

មុខងារសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមិតភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែង ការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធានគណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព។

## មាត្រា ១៤០ .. ថ្មី

ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា តំណាងរាស្ត្រចំនួនមួយភាគដប់ ប្រធានព្រឹទ្ធសភា ឬសមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន អាចបញ្ជូនច្បាប់ដែលរដ្ឋសភាបាន អនុម័តទៅឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ មុននឹងច្បាប់នោះត្រូវប្រកាសឱ្យប្រើ ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និង ច្បាប់រៀបចំអង្គការទាំងឡាយ ត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឱ្យប្រើ ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ សម្រេចក្នុងរយៈពេលសាមសិប ( ៣០ ) ថ្ងៃយ៉ាងយូរ ថាតើច្បាប់ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើ ស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

## មាត្រា ១៤១ .. ថ្មី

ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន តំណាងរាស្ត្រចំនួន មួយភាគដប់ ឬតុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ។

ប្រជារាស្ត្រមានសិទ្ធិប្ដឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាងរាស្ត្រ ឬប្រធាន រដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។

**មាត្រា ១៤២ .. ថ្មី ( មាត្រា ១២៣ ចាស់ )**

បទប្បញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញ មិនអាចយកទៅប្រកាសឱ្យប្រើ ឬយកទៅអនុវត្តបានឡើយ ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្តីសំរេចបិទផ្លូវតវ៉ា ។

**មាត្រា ១៤៣ .. ថ្មី ( មាត្រា ១២៤ ចាស់ )**

ព្រះមហាក្សត្រ ទ្រង់ពិគ្រោះមតិក្រុមប្រឹក្សាធម្មនុញ្ញ ចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ។

**មាត្រា ១៤៤ .. ថ្មី ( មាត្រា ១២៥ ចាស់ )**

ច្បាប់រៀបចំអង្គការមួយនឹងកំណត់ការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ១៣ ថ្មី

## អំពីការគ្រប់គ្រងរដ្ឋបាល

**មាត្រា ១៤៥ .. ថ្មី ( មួយ )**

ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

**មាត្រា ១៤៦ .. ថ្មី ( មួយ )**

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់រៀបចំអង្គការ ។

# ជំពូកទី ១៤ ថ្មី
# អំពីសមាជជាតិ

**មាត្រា ១៤៧ .. ថ្មី ( មាត្រា ១២៨ ចាស់ )**

សមាជជាតិបើកឱ្យប្រជារាស្ត្រជ្រាបដោយផ្ទាល់ អំពីកិច្ចការផ្សេងៗដែលជាប្រយោជន៍ជាតិ និងលើកបញ្ហា និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ ។

ប្រជារាស្ត្រខ្មែរទាំងពីរភេទ មានសិទ្ធិទៅចូលរួមក្នុងសមាជជាតិ ។

**មាត្រា ១៤៨ .. ថ្មី ( មាត្រា ១២៩ ចាស់ )**

សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំ នៅដើមខែធ្នូ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ។

សមាជជាតិ ប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ ។

**មាត្រា ១៤៩ .. ថ្មី**

សមាជជាតិអនុម័តសំណូមពរជូនព្រឹទ្ធសភា ជូនរដ្ឋសភា និង ជូនរដ្ឋអំណាចពិចារណា ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃសមាជជាតិនឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

# ជំពូកទី ១៥ ថ្មី (ពីរ)

## អំពីអង្គភាពរៀបចំការបោះឆ្នោត

### មាត្រា ១៥០._ ថ្មី ( ពីរ )

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

មុខងារជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានវិសមិតភាពជាមួយការបំពេញមុខងារតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាច ធ្វើជាសមាជិកនៃគណបក្សនយោបាយ ឬធ្វើជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬក្រុមហ៊ុនពាណិជ្ជកម្មណាមួយបានឡើយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ ។

### មាត្រា ១៥១._ ថ្មី ( ពីរ )

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានសមាសភាពប្រាំបួនរូបដែលទទួលអាណត្តិប្រាំឆ្នាំ ។ សមាសភាពបួនរូបត្រូវជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល បួនរូបត្រូវជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និង

មួយរូប ត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវដំណើរការរៀបចំឱ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាព នូវសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ គណៈកម្មា-ធិការអចិន្ត្រៃយ៍រដ្ឋសភា រៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ក្នុងករណីសមាជិកណាមួយនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បាត់បង់សមាជិកភាពរបស់ខ្លួន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវចាត់នីតិវិធីជ្រើសរើស សមាសភាពថ្មីជំនួស ក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ គិតពីថ្ងៃបាត់បង់សមាជិកភាព ។ នីតិវិធីលំអិតនៃការជ្រើសរើសសមាសភាពថ្មី ជំនួស ត្រូវកំណត់ដោយឡែកក្នុងច្បាប់ ។

ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នឹងត្រូវកំណត់ក្នុងច្បាប់មួយ ។

# ជំពូកទី ១៦ ថ្មី (ពីរ)
## អំពីអានុភាព ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ

### មាត្រា ១៥២ ._ ថ្មី ( ពីរ មាត្រា ១៥០ ថ្មី )

រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ និង សេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។

### មាត្រា ១៥៣ ._ ថ្មី ( ពីរ មាត្រា ១៥១ ថ្មី )

ការផ្តើមគំនិតសើរើ ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្ររបស់នាយករដ្ឋមន្ត្រី និងរបស់ប្រធានរដ្ឋសភា តាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយ ដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបី នៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

### មាត្រា ១៥៤ ._ ថ្មី ( ពីរ មាត្រា ១៥២ ថ្មី )

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឱ្យធ្វើ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។

### មាត្រា ១៥៥ ._ ថ្មី ( ពីរ មាត្រា ១៥៣ ថ្មី )

ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។

# ជំពូកទី ១៧ ថ្មី
# អំពីអន្តរប្បញ្ញត្តិ

**មាត្រា ១៥៦ .. ថ្មី ( ពីរ មាត្រា ១៥៤ ថ្មី )**

រដ្ឋធម្មនុញ្ញនេះ ក្រោយពីបានទទួលការអនុម័ត ត្រូវបានប្រកាសឱ្យចូលជាធរមានភ្លាម ដោយព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៥៧ .. ថ្មី ( ពីរ មាត្រា ១៥៥ ថ្មី )**

ក្រោយពេលរដ្ឋធម្មនុញ្ញនេះចូលជាធរមាន សភាធម្មនុញ្ញត្រូវក្លាយទៅជារដ្ឋសភា ។

បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាត្រូវចូលជាធរមាន ក្រោយទទួលបានការអនុម័តពីរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាមិនទាន់ចាប់ដំណើរការបាន ប្រធាន អនុប្រធានទីមួយ និង អនុប្រធានទីពីរនៃសភាធម្មនុញ្ញ នឹងចូលរួមបំពេញភារកិច្ចក្នុងក្រុមប្រឹក្សារាជសម្បត្តិ បើសភាពការណ៍ក្នុងប្រទេសទាមទារ ។

**មាត្រា ១៥៨ .. ថ្មី ( ពីរ មាត្រា ១៥៦ ថ្មី )**

ក្រោយរដ្ឋធម្មនុញ្ញនេះចូលជាធរមាន ព្រះមហាក្សត្រជ្រើសតាំងតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងមាត្រា ១៣ ថ្មី និង ១៤ ។

**មាត្រា ១៥៩ .. ថ្មី ( ពីរ មាត្រា ១៥៧ ថ្មី )**

នីតិកាលទី១ នៃព្រឹទ្ធសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលព្រឹទ្ធសភាថ្មីចូលកាន់តំណែង ។

សំរាប់នីតិកាលទី១ នៃព្រឹទ្ធសភា ៖

- សមាជិកព្រឹទ្ធសភាមានចំនួនសរុបហុកសិបមួយរូប ។

- ព្រះមហាក្សត្រទ្រង់តែងតាំងសមាជិកព្រឹទ្ធសភាពីររូប ព្រមទាំងប្រធាន អនុប្រធានទី ១ អនុប្រធានទី ២ នៃព្រឹទ្ធសភា ។

- សមាជិកដទៃទៀតនៃព្រឹទ្ធសភា ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ តាមសំណើរបស់ប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា ក្នុងចំណោមសមាជិក នៃគណបក្សដែលមានអាសនៈនៅក្នុងរដ្ឋសភា ។

- កិច្ចប្រជុំជាសមាជរដ្ឋសភា និងព្រឹទ្ធសភា ត្រូវដឹកនាំដោយសហប្រធាន ។

**មាត្រា ១៦០ ._ ថ្មី ( ពីរ មាត្រា ១៥៨ ថ្មី )**

ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានអត្ថបទថ្មីមកកែប្រែ ឬលុបចោល លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ ។

រដ្ឋធម្មនុញ្ញនេះ ត្រូវបានសភាធម្មនុញ្ញអនុម័ត

នៅភ្នំពេញថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ នាសម័យប្រជុំពេញអង្គលើកទី២

ភ្នំពេញ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ១៩៩៣

**ប្រធាន**

**ស៊ឹន សាន**

**ច្បាប់ចម្លង**

# ព្រះរាជក្រម

នស/រកម/០៣២១/០០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## វិធានការទប់ស្កាត់ការឆ្លងរាលដាល
## នៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ
## និងប្រកបដោយគ្រោះថ្នាក់
## ធ្ងន់ធ្ងរផ្សេងទៀត

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១ .- គោលបំណង

ច្បាប់នេះកំណត់អំពីវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលត្រូវអនុវត្ត ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គមនិងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### មាត្រា២ .- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមការកំណត់របស់ក្រសួងសុខាភិបាល។

## ជំពូកទី២
## វិធានការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

### មាត្រា៣ .- វិធានការសុខាភិបាល

ក្នុងគោលដៅប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញនូវវិធានការសុខាភិបាលចាំបាច់នានា មានជាអាទិ៍៖

- ការធ្វើអនាម័យ
- ការពាក់ម៉ាស
- ការរក្សាគម្លាតសុវត្ថិភាពសង្គម
- ការយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩
- ការធ្វើចត្តាឡីស័ក
- ការដាក់ឱ្យនៅដាច់ដោយឡែកដើម្បីទទួលការព្យាបាល
- ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
- ការធ្វើសេចក្តីប្រកាសសុខភាព និង
- វិធានការសុខាភិបាលផ្សេងទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ខ្លឹមសារលម្អិតនៃវិធានការសុខាភិបាលខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ។

ក្នុងករណីបន្ទាន់និងចាំបាច់ រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិដល់ក្រសួងសុខាភិបាល ដើម្បីដាក់ចេញនូវវិធានការសុខាភិបាលផ្សេងថែមទៀត សំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

**មាត្រា៤.- វិធានការរដ្ឋបាលនិងវិធានការផ្សេងទៀត**

រាជរដ្ឋាភិបាលអាចដាក់ចេញជាបណ្តោះអាសន្ននូវវិធានការរដ្ឋបាលនិងវិធានការផ្សេងទៀត ដែលមានភាពចាំបាច់និងមានប្រយោជន៍ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលា ក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មានជាអាទិ៍៖

- ការរឹតត្បិតឬការហាមឃាត់ការធ្វើដំណើរ
- ការរឹតត្បិតឬការហាមឃាត់ការជួបជុំនិងការប្រមូលផ្តុំមនុស្សដែលសកម្មភាពនេះអាចបណ្តាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការហាមឃាត់ឬការកម្រិតការធ្វើសកម្មភាពការងារឬមុខរបរដែលជាហានិភ័យឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការបិទខ្ទប់តំបន់ឬទីកន្លែងមួយចំនួនដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង
- វិធានការរដ្ឋបាលនិងវិធានការផ្សេងទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

ក្នុងករណីបន្ទាន់និងចាំបាច់ រាជរដ្ឋាភិបាលអាចប្រគល់សិទ្ធិអំណាចដល់ក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីដាក់ចេញនូវវិធានការខាងលើ និងធានាដល់ការអនុវត្តវិធានការខាងលើ សំដៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

## ជំពូកទី៣
## ទោសប្បញ្ញត្តិ

**មាត្រា៥.- ទណ្ឌកម្ម**

បុគ្គលដែលមិនអនុវត្តតាមវិធានការសុខាភិបាល វិធានការរដ្ឋបាល ឬវិធានការផ្សេងទៀត ដែលត្រូវបានដាក់ចេញស្របតាមច្បាប់នេះ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងច្បាប់នេះ។

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

ទណ្ឌកម្មរដ្ឋបាលរួមមាន៖

- ការព្យួរឬដកហូតអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតប្រកបអាជីវកម្ម
- ការបិទអាជីវកម្ម។

ទណ្ឌកម្មព្រហ្មទណ្ឌរួមមាន៖

- ពិន័យអន្តរការណ៍
- ពិន័យជាប្រាក់
- ដាក់ពន្ធនាគារ។

បទល្មើសផ្សេងទៀតដែលត្រូវផ្តន្ទាទោសជាពិន័យអន្តរការណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានវិធានការសុខាភិបាលជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។ ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានវិធានការរដ្ឋបាលនិងវិធានការផ្សេងទៀតជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចដែលចេញវិធានការនោះ។

ការបង់ប្រាក់ពិន័យអន្តរការណ៍រំលត់បណ្ដឹងអាជ្ញាចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះ។

ការបង់ប្រាក់ពិន័យអន្តរការណ៍មិននាំឱ្យរួចផុតពីកាតព្វកិច្ចអនុវត្តវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដែលបានដាក់ចេញស្របតាមច្បាប់នេះឡើយ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្ដីសម្រេចស្ដីពីការដាក់ពិន័យអន្តរការណ៍ មន្ត្រីដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌នៃក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធីជាធរមាន។

## មាត្រា៦ .- ក្រសួង ស្ថាប័នមានសមត្ថកិច្ចក្នុងការដាក់ទណ្ឌកម្មរដ្ឋបាល

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥នៃច្បាប់នេះ ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នដែលចេញអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត។

បុគ្គលដែលមិនសុខចិត្តចំពោះការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលខាងលើ អាចដាក់ពាក្យប្ដឹងតវ៉ាទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្ដីសម្រេចស្ដីពីការដាក់ទណ្ឌកម្មនោះ។

ក្នុងករណីបុគ្គលនោះនៅតែមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ បុគ្គលនោះអាចដាក់ពាក្យប្ដឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលបានសេចក្ដីសម្រេចលើបណ្ដឹងតវ៉ា។

ការដាក់ពាក្យប្ដឹងតវ៉ារបស់បុគ្គលខាងលើ មិនមានអានុភាពផ្អាកការអនុវត្តសេចក្ដីសម្រេចស្ដីពីការដាក់ទណ្ឌកម្មនោះទេ។

## មាត្រា៧ .- បទគេចវេះពីការធ្វើចត្តាឡីស័កឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័ក

អំពើគេចវេះពីការធ្វើចត្តាឡីស័កឬគេចចេញពីទីកន្លែងធ្វើចត្តាឡីស័កក្នុងអំឡុងពេលធ្វើចត្តាឡីស័កដែលកំណត់ដោយក្រសួងសុខាភិបាលឬអាជ្ញាធរមានសមត្ថកិច្ច ត្រូវទទួលពិន័យអន្តរការណ៍តាមការកំណត់នៅក្នុងអនុក្រឹត្យ។

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល កាលបើអំពើខាងលើនេះបានបណ្ដាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

## មាត្រា៨ .- បទគេចវេះពីការព្យាបាលឬគេចចេញពីទីកន្លែងព្យាបាល

អំពើគេចវេះពីការតម្រូវឱ្យទទួលការព្យាបាលឬគេចចេញពីទីកន្លែងព្យាបាល ដែលកំណត់ដោយក្រសួងសុខាភិបាលឬការប៉ុនប៉ងប្រព្រឹត្តអំពើនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ កាលបើអំពើខាងលើនេះបានបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

**មាត្រា៩ .- បទចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ**

អំពើចម្លងដោយចេតនានូវជំងឺកូវីដ-១៩ ដល់អ្នកដទៃ តាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០(ដប់)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ កាលបើអំពើខាងលើនេះ ត្រូវបានធ្វើឡើងដោយមានការរៀបចំជាក្រុមឬអង្គការចាត់តាំង។

**មាត្រា១០ .- បទមិនគោរពវិធានការរដ្ឋបាល**

ដោយមិនគិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនាមិនគោរពវិធានការរដ្ឋបាល ដែលបានដាក់ចេញស្របតាមច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ពី១.០០០.០០០(មួយលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។

**មាត្រា១១ .- បទរាំងដល់ការអនុវត្តវិធានការ**

អំពើរាំងឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការដែលបានដាក់ចេញស្របតាមច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែ ទៅ ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៥.០០០.០០០(ប្រាំលាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃឬប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ។

**មាត្រា១២ .- ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច**

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពានខុសពីគោលបំណងនៃច្បាប់នេះ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព បូរណភាពរូបរាងកាយ ឬធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៣ .- ការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវឬទទួលការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ**

ចំពោះបុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា១០ និងមាត្រា១១នៃ

ច្បាប់នេះ អាចត្រូវលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវ ឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ប្រសិនបើបុគ្គលនោះបានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាលឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

ការលើកលែងឱ្យរួចផុតពីការទទួលខុសត្រូវឬទទួលបាននូវការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌខាងលើ ក៏ត្រូវយកទៅអនុវត្តផងដែរ ក្នុងករណីដែលក្រុមគ្រួសារនៃបុគ្គលដែលបានប្រព្រឹត្តបទល្មើស ដែលមានចែងក្នុងមាត្រា៧ មាត្រា៨ មាត្រា១០ និងមាត្រា១១នៃច្បាប់នេះ បានបង្ហាញប្រាប់ព័ត៌មានដល់មន្ត្រីសុខាភិបាលឬមន្ត្រីមានសមត្ថកិច្ច ឬបានផ្តល់កិច្ចសហការចាំបាច់នានាដើម្បីជាប្រយោជន៍ក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា។

### មាត្រា១៤ .- ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី៣នៃច្បាប់នេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងច្បាប់នេះជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី៤
## ការអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

### មាត្រា១៥ .- ការអនុវត្តដូចគ្នានូវបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

វិធានការទាំងឡាយ ព្រមទាំងទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ ដើម្បីអនុវត្តចំពោះជំងឺកូវីដ-១៩ ត្រូវមានអានុភាពអនុវត្តដូចគ្នាចំពោះជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល ក្រោមវិសាលភាពអនុវត្តនៃច្បាប់នេះ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

### មាត្រា១៦ .- ការបន្តសុពលភាពនៃលិខិតបទដ្ឋានគតិយុត្តមុនច្បាប់នេះ

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការសុខាភិបាល វិធានការរដ្ឋបាល និងវិធានការផ្សេងទៀតដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលច្បាប់នេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងច្បាប់នេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៧ .- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ .- ការប្រកាសជាការប្រញាប់**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ ព្រហស្បតិ៍ ១៣រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២១

**ក្នុងព្រះបរមនាមនិងតាមព្រះរាជគ្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

នស/រកម/០៣២១/០០៤

**បានឡូវតាំងព្រះរាជលញ្ឆករហើយ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល** **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ម៉ម ប៊ុនហេង** **កើត រិទ្ធ**

# ព្រះរាជក្រម

នស/រកម/០៤២០/០១៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ២០២/០០២/២០២០ កបធ.ច ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់
# ស្តីពី
# ការគ្រប់គ្រងប្រទេសជាតិ
# ស្ថិតក្នុងភាពអាសន្ន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១ .- គោលបំណង

ច្បាប់នេះកំណត់អំពីបែបបទ នីតិវិធី និងលក្ខខណ្ឌនៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ននៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រមទាំងការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ននេះ ក្នុងគោលបំណងដើម្បីការពារសន្តិសុខជាតិនិងសណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិតនិងសុខភាពរបស់ប្រជាពលរដ្ឋ ព្រមទាំងការពារទ្រព្យសម្បត្តិនិងបរិស្ថាន។

### មាត្រា២ .- វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តនៅពេលដែលប្រទេសជាតិត្រូវបានដាក់ស្ថិតក្នុងភាពអាសន្ន ស្របតាមមាត្រា២២ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## បែបបទ នីតិវិធី និងលក្ខខណ្ឌ
## នៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

### មាត្រា៣.- បែបបទនិងនីតិវិធីនៃការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

នៅពេលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។

ការប្រកាសដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ។ ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចធ្វើឡើងសម្រាប់ថិរវេលាមិនឱ្យលើសពី ៣(បី)ខែ។ ថិរវេលានេះអាចត្រូវប្រកាសបន្តបានក្នុងលក្ខខណ្ឌដូចគ្នា។ កាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចត្រូវបញ្ចប់ទៅវិញដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានរដ្ឋសភានិងប្រធានព្រឹទ្ធសភា កាលបើកាលៈទេសៈពិសេសនេះបានចប់ទៅវិញមុនកាលកំណត់នៃថិរវេលាដែលមានចែងនៅក្នុងព្រះរាជក្រឹត្យទាក់ទងនឹងការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

នៅគ្រប់ករណីទាំងអស់ រដ្ឋសភាឬព្រឹទ្ធសភាមានសិទ្ធិបញ្ចប់កាលៈទេសៈដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្នកាលបើសភាពការណ៍អនុញ្ញាត ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

បន្ទាប់ពីមានការសម្រេចរបស់រដ្ឋសភាឬព្រឹទ្ធសភា ការបញ្ចប់កាលៈទេសៈពិសេសនេះត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។

បើរដ្ឋសភាឬព្រឹទ្ធសភាមិនអាចប្រជុំបានទេដោយមូលហេតុចាំបាច់ ជាអាទិ៍ នៅពេលដែលកម្លាំងបរទេសចូលមកកាន់កាប់ទឹកដី ការប្រកាសភាពអាសន្នត្រូវបន្តទៅមុខជាស្វ័យប្រវត្តិ។

### មាត្រា៤ .- លក្ខខណ្ឌនៃការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

ការដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចធ្វើឡើងនៅពេលដែលប្រជាជាតិប្រឈមមុខនឹងគ្រោះថ្នាក់ ជាអាទិ៍ គ្រោះថ្នាក់ដែលបង្កឡើងដោយសង្គ្រាមឬការឈ្លានពានពីកម្លាំងបរទេស គ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្ដាលមកពីការឆ្លងរាលដាលនៃជំងឺ ភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខជាតិនិងសណ្ដាប់ធ្នាប់សាធារណៈ ព្រមទាំងគ្រោះមហន្តរាយធ្ងន់ធ្ងរ ដែលគំរាមកំហែងឬអាចបង្កគ្រោះថ្នាក់រីករាលដាលដល់កម្រិតទូទាំងប្រទេស។

## ជំពូកទី៣
## ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

### មាត្រា៥ .- វិធានការក្នុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

នៅពេលប្រទេសជាតិត្រូវបានប្រកាសដាក់ស្ថិតនៅក្នុងភាពអាសន្ន រាជរដ្ឋាភិបាលមានសិទ្ធិដាក់ចេញវិធានការដូចខាងក្រោម៖

-ការហាមឃាត់ឬការកម្រិតសិទ្ធិសេរីភាពក្នុងការធ្វើដំណើរ។

-ការហាមឃាត់ឬការកម្រិតសិទ្ធិសេរីភាពក្នុងការជួបជុំឬការប្រមូលផ្ដុំមនុស្ស។

-ការហាមឃាត់ឬការកម្រិតការធ្វើសកម្មភាពការងារឬមុខរបរ។

-ការហាមឃាត់ឬការកម្រិតមិនឱ្យបុគ្គលចេញពីលំនៅឋានឬទីសំណាក់ណាមួយ។

-ការដាក់ចេញវិធានការចត្តាឡីស័កឬការដាក់ឱ្យនៅដោយឡែកក្នុងករណីគ្រោះអាសន្នបន្ទាន់ចំពោះសុខភាពសាធារណៈបណ្ដាលមកពីការឆ្លងរាលដាលនៃជំងឺ។

-ការដាក់ចេញវិធានការទាក់ទងនឹងកំណែននិងជម្លៀសពលរដ្ឋ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

-ការដាក់ចេញវិធានការទាក់ទងនឹងកំណែន ការដកហូត ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិនិងសេវារបស់រូបវន្តបុគ្គលឬនីតិបុគ្គល ដែលមានភាពចាំបាច់ដើម្បីឆ្លើយតប



www.moj.gov.kh

ចំពោះភាពអាសន្ន។ នីតិវិធីនៃកំណែន ការដកហូត ការគ្រប់គ្រង ការចាត់ចែង ព្រមទាំង ការផ្តល់សំណងត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

-ការដាក់ចេញវិធានការទាក់ទងនឹងការកំណត់ថ្លៃទំនិញនិងសេវា ដែលមានភាពចាំបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

-ការដាក់ចេញវិធានការទាក់ទងនឹងការបិទទីតាំងសាធារណៈឬឯកជនណាមួយ ដែលមានភាពចាំបាច់ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

-ការដាក់ចេញនូវវិធានការឃ្លាំមើលនិងតាមដានតាមគ្រប់មធ្យោបាយ ដើម្បីទទួលបានព័ត៌មានតាមរយៈប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍គ្រប់រូបភាព ក្នុងគោលបំណងឆ្លើយតបចំពោះភាពអាសន្ន។

-ការហាមឃាត់ ឬការកម្រិតការចែកចាយឬការផ្សព្វផ្សាយព័ត៌មានដែលអាចបង្កឱ្យមានការភ័យខ្លាចដល់សាធារណជន ឬចលាចល ឬដែលនាំឱ្យខូចខាតដល់សន្តិសុខជាតិ ឬធ្វើឱ្យមានការភាន់ច្រឡំអំពីស្ថានភាពនៃភាពអាសន្ន។

-ការដាក់ចេញវិធានការដទៃទៀតដែលសមស្របនិងចាំបាច់ ដើម្បីឆ្លើយតបចំពោះភាពអាសន្ន។

វិធានការអនុវត្តពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្នអាចត្រូវបានដាក់ចេញសម្រាប់ទូទាំងប្រទេស ឬដែនដីកំណត់ជាក់លាក់ណាមួយ។

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចបង្កើតយន្តការឬប្រគល់សិទ្ធិអំណាចទៅអាជ្ញាធរមានសមត្ថកិច្ចណាមួយ ឬប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ ដើម្បីធានាដល់ការអនុវត្តវិធានការខាងលើ។

ក្នុងពេលសង្គ្រាមឬក្នុងកាលៈទេសៈដទៃទៀតដែលសន្តិសុខជាតិប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដោយរាជរដ្ឋាភិបាល អាចធ្វើឡើងតាមរបបអាជ្ញាសឹក។

## មាត្រា៦ .- របាយការណ៍អំពីវិធានការក្នុងភាពអាសន្នជូនរដ្ឋសភានិងព្រឹទ្ធសភា

រាជរដ្ឋាភិបាលត្រូវរាយការណ៍ជាប្រចាំអំពីវិធានការដែលខ្លួនបានដាក់ចេញក្នុងពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ជូនទៅរដ្ឋសភានិងព្រឹទ្ធសភា។ រដ្ឋសភានិងព្រឹទ្ធសភាអាចស្នើសុំព័ត៌មានចាំបាច់បន្ថែមផ្សេងទៀតពីរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យនិងការវាយតម្លៃអំពីវិធានការដែលបានដាក់ចេញក្នុងពេលដែលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ជំពូកទី៤
# ទោសប្បញ្ញត្តិ

## មាត្រា៧ .- បទរារាំងដល់កិច្ចប្រតិបត្តិការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនារារាំងឬបង្កឧបសគ្គដល់កិច្ចប្រតិបត្តិការឆ្លើយតបចំពោះភាពអាសន្ន ឬការប៉ុនប៉ងប្រព្រឹត្តអំពើនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល។

អំពើរារាំងដល់កិច្ចប្រតិបត្តិការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ កាលបើអំពើនេះនាំឱ្យមានចលាចលជាសាធារណៈឬប៉ះពាល់ដល់សន្តិសុខជាតិ។

## មាត្រា៨ .- បទមិនគោរពវិធានការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត អំពើដោយចេតនាមិនគោរពវិធានការដាក់ចេញដោយរាជរដ្ឋាភិបាលក្រោមបញ្ញត្តិនៃមាត្រា៥នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០(មួយសែន)រៀល ទៅ ២.០០០.០០០(ពីរលាន)រៀល។

អំពើមិនគោរពតាមវិធានការពេលប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល កាលបើអំពើនេះនាំឱ្យមានចលាចលជាសាធារណៈ។

## មាត្រា៩ .- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៧នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០.០០០(មួយរយលាន)រៀល ទៅ ១.០០០.០០០.០០០(មួយប៊ីលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ក្រសួងព្រះបរមរាជវាំង

មាត្រា៨នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០.០០០(ហាសិបលាន)រៀល ទៅ ៥០០.០០០.០០០(ប្រាំរយលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

### មាត្រា១០ .- ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច

មន្ត្រីមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចតាមទំនើងចិត្តដោយរំលោភបំពាន ខុសពីគោលបំណងនៃច្បាប់នេះ ហើយបង្កការប៉ះពាល់ដល់រូបរាងកាយឬការខូចខាតដល់ទ្រព្យសម្បត្តិរបស់បុគ្គលដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

### មាត្រា១១ .- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

### មាត្រា១២ .- ការប្រកាសជាការប្រញាប់

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ៧កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០២០

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាប់**
**ប្រមុខរដ្ឋស្តីទី**

នស.៥០០៥-៥៩៦

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

នស/រកម/០៦១៨/០១២

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ក្រសួងមុខងារសាធារណៈ
ចូល
លេខ: ៥០៥៦
កាលបរិច្ឆេទ ០៥ ខែ ០៧ ឆ្នាំ ១៨
ម៉ោង ១០:៣៣

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៤/០០៦/២០១៨ កបធ.ច ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

# ស្តីពី

# ការរៀបចំ និងការប្រព្រឹត្តទៅ
# នៃគណៈរដ្ឋមន្ត្រី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .–**

ច្បាប់នេះមានគោលបំណងធានាប្រសិទ្ធភាពការងាររបស់គណៈរដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលជាអង្គការនីតិប្រតិបត្តិដូចបានបញ្ញត្តនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២ .–**

ច្បាប់នេះមានគោលដៅកំណត់អំពីសមាសភាព សមត្ថកិច្ច និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រីដែលជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣ .–**

ច្បាប់នេះមានវិសាលភាពអនុវត្តទៅលើអង្គការនីតិប្រតិបត្តិ ។

# ជំពូកទី ២

## សមត្ថកិច្ច និងសមាសភាពគណៈរដ្ឋមន្ត្រី

**មាត្រា៤ .–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ជាអង្គការនីតិប្រតិបត្តិ មានសមត្ថកិច្ចកំណត់និងអនុវត្តនយោបាយរបស់រដ្ឋស្របតាមគោលការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ ។ រាជរដ្ឋាភិបាលធានាការអនុវត្តច្បាប់ និងដឹកនាំកិច្ចការទូទៅរបស់រដ្ឋ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់អង្គការនីតិប្បញ្ញត្តិនិងអង្គការតុលាការ ។

**មាត្រា៥ .–**

រាជរដ្ឋាភិបាលដឹកនាំកិច្ចការទូទៅរបស់រដ្ឋស្របតាមកម្មវិធីនយោបាយរបស់ខ្លួន ។

**មាត្រា៦ .–**

រាជរដ្ឋាភិបាលត្រូវការពារនីត្យានុកូលភាព ធានាសណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

**មាត្រា៧ .–**

រាជរដ្ឋាភិបាលគ្រប់គ្រង ដឹកនាំ បញ្ជា ប្រើប្រាស់រដ្ឋបាលសាធារណៈគ្រប់ថ្នាក់ រួមទាំងកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងកម្លាំងប្រដាប់អាវុធផ្សេងៗទៀត ក្នុងការធ្វើសកម្មភាពរបស់ខ្លួន ។

**មាត្រា៨ .–**

សមាសភាពនៃរាជរដ្ឋាភិបាលមាន ៖

- នាយករដ្ឋមន្ត្រី
- ឧបនាយករដ្ឋមន្ត្រី
- ទេសរដ្ឋមន្ត្រី
- រដ្ឋមន្ត្រី ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៩ ._**

នាយករដ្ឋមន្ត្រីជាសមាជិករដ្ឋសភា ។ សមាជិករាជរដ្ឋាភិបាលឯទៀតអាចជ្រើសរើសយកក្នុងចំណោមសមាជិករដ្ឋសភា ឬក្រៅសមាជិករដ្ឋសភា ប៉ុន្តែត្រូវជាសមាជិកគណបក្សមានតំណាងនៅក្នុងរដ្ឋសភា ។ សមាជិករាជរដ្ឋាភិបាលទាំងអស់ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយពីរដ្ឋសភាបានបោះឆ្នោតទុកចិត្ត ។

**មាត្រា១០ ._**

មុខងារនៃសមាជិករាជរដ្ឋាភិបាលមានវិសមិតភាពនឹងសកម្មភាពខាងវិជ្ជាជីវៈ ការធ្វើអាជីវកម្មគ្រប់ប្រភេទ ឬការកាន់មុខតំណែងជាថ្នាក់ដឹកនាំ ឬគណៈគ្រប់គ្រង ឬសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងក្រុមហ៊ុនសហគ្រាស ហើយនិងការកាន់តំណែងណាមួយក្នុងមុខងារសាធារណៈ ។

**មាត្រា១១ ._**

នៅពេលផុតនីតិកាលរបស់រដ្ឋសភាឬពេលផ្លាស់ប្តូររាជរដ្ឋាភិបាល រាជរដ្ឋាភិបាលដែលត្រូវចេញពីតំណែង មានភារកិច្ចដឹកនាំការងារប្រចាំថ្ងៃតែប៉ុណ្ណោះ រហូតដល់មានរាជរដ្ឋាភិបាលថ្មីចូលកាន់តំណែង ។

**មាត្រា១២ ._**

នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលនៅក្នុងមុខតំណែង ត្រូវទទួលបានប្រាក់បំណាច់មុខងារក្នុងការបំពេញភារកិច្ចដែលកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣

## គណៈរដ្ឋមន្ត្រី សមត្ថកិច្ចរបស់នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាល

**មាត្រា១៣ ._**

គណៈរដ្ឋមន្ត្រីទទួលខុសត្រូវរួមចំពោះមុខរដ្ឋសភាអំពីនយោបាយទូទៅ និងសកម្មភាពរបស់រាជរដ្ឋាភិបាល ។

នាយករដ្ឋមន្ត្រី ជាប្រមុខរាជរដ្ឋាភិបាល ដឹកនាំ បញ្ជារាល់សកម្មភាពការងាររបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ។

**មាត្រា១៤ ._**

នាយករដ្ឋមន្ត្រីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី ។

អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រីមានអង្គប្រជុំធំ និងអង្គប្រជុំពិនិត្យស្រាវជ្រាវ ។

រាល់អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី ត្រូវមានកំណត់ហេតុ ។

**មាត្រា១៥ ._**

អង្គប្រជុំធំ គឺជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាល ។

អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី ។

នាយករដ្ឋមន្ត្រីអាចអញ្ជើញអ្នកពាក់ព័ន្ធនានាចូលរួមក្នុងកិច្ចប្រជុំគណៈរដ្ឋមន្ត្រី តាមការចាំបាច់ ។

នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា១៦ .—**

នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិជូនសមាជិករាជរដ្ឋាភិបាលណាម្នាក់កោះប្រជុំនិងធ្វើជាអធិបតីនៃអង្គប្រជុំអន្តរក្រសួង ប៉ុន្តែអង្គប្រជុំនេះគ្មានសិទ្ធិសម្រេចកិច្ចការតាងនាមរាជរដ្ឋាភិបាលឡើយ ។

**មាត្រា១៧ .—**

នាយករដ្ឋមន្ត្រីដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ការពារជាតិ សន្តិសុខជាតិ និងវិស័យផ្សេងទៀតដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ នាយករដ្ឋមន្ត្រីអាចប្រគល់សិទ្ធិឱ្យសមាជិករាជរដ្ឋាភិបាល ឬឥស្សរជនណាម្នាក់ជាអ្នកចរចា និងចុះហត្ថលេខា ។

បែបបទ និងនីតិវិធីនៃការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទាំងនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១៨ .—**

នាយករដ្ឋមន្ត្រីចុះហត្ថលេខាលើអនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា និងសារាចររបស់រាជរដ្ឋាភិបាល ។ លិខិតបទដ្ឋានគតិយុត្តនានាដែលមានអានុភាពទូទៅរបស់រាជរដ្ឋាភិបាល ត្រូវចុះក្នុងរាជកិច្ច ។

**មាត្រា១៩ .—**

នាយករដ្ឋមន្ត្រីមានសិទ្ធិស្នើសុំរដ្ឋសភា ដើម្បីកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ។

នាយករដ្ឋមន្ត្រីលើកសំណើជូនរដ្ឋសភា ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងច្បាប់ ។

**មាត្រា២០ .—**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ ដើម្បីបញ្ចប់មុខតំណែងសមាជិករាជរដ្ឋាភិបាលដោយព្រះរាជក្រឹត្យ ។

**មាត្រា២១ .—**

នាយករដ្ឋមន្ត្រីលើកសំណើផ្លាស់ប្តូរ និងជំនួសសមាជិករាជរដ្ឋាភិបាលជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្ត ។ ក្រោយពីរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយ សមាជិករាជរដ្ឋាភិបាលនោះត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

**មាត្រា២២ .—**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៅទីស្តីការគណៈរដ្ឋមន្ត្រី និងនៅតាមក្រសួង ស្ថាប័ននានា ដោយព្រះរាជក្រឹត្យ ។

**មាត្រា២៣ .—**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមុខតំណែងមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិដូចខាងក្រោម ៖

- ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ឬមុខតំណែងប្រហាក់ប្រហែល
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ឯកអគ្គរាជទូត ឬមុខតំណែងប្រហាក់ប្រហែល

- ប្រេសិតសៃមញ្ញ និងពេញសមត្ថភាព
- អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងនាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ
- អគ្គស្នងការនគរបាលជាតិ

មុខតំណែង និងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិចាប់ពីថ្នាក់ឧត្តមសេនីយ៍ឡើង ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ស្របតាមបទប្បញ្ញត្តិជាធរមាន ។

**មាត្រា២៤ .__**

នាយករដ្ឋមន្ត្រីតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិ ដែលមិនមានចែងក្នុងមាត្រា២៣ លើកលែងតែមន្ត្រីដែលមានចែងក្នុងកថាខណ្ឌទី២ មាត្រា៤៦ នៃច្បាប់នេះ ។

**មាត្រា២៥ .__**

នាយករដ្ឋមន្ត្រីលើកសំណើផ្តល់គោរមងារដល់ឥស្សរជន វរជន ឬសប្បុរសជនណាមួយ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា២៦ .__**

នាយករដ្ឋមន្ត្រីលើកសំណើផ្តល់ ឬអាចផ្តល់គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ យោធិននៃកងយោធពលខេមរភូមិន្ទ មន្ត្រីនគរបាលជាតិ ឥស្សរជន វរជន ឬសប្បុរសជន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា២៧ .__**

នាយករដ្ឋមន្ត្រី អាចលើកសំណើផ្តល់ងារកិត្តិយសជាប្រតិភូរាជរដ្ឋាភិបាលដល់ឥស្សរជនណាមួយដោយព្រះរាជក្រឹត្យ ។

**មាត្រា២៨ .__**

ក្នុងករណីពិសេស ឬប្រធានសក្តិ នាយករដ្ឋមន្ត្រីមានសិទ្ធិបញ្ជាចំណាយក្រៅពីការកំណត់ក្នុងថវិកាជាតិ ដើម្បីដោះស្រាយកិច្ចការចាំបាច់និងបន្ទាន់ រួចហើយត្រូវរាយការណ៍សុំការអនុម័តពីអង្គការនីតិប្បញ្ញត្តិ ស្របតាមបទប្បញ្ញត្តិជាធរមាន ។

**មាត្រា២៩ .__**

ក្នុងពេលដែលនាយករដ្ឋមន្ត្រីអវត្តមាន ឧបនាយករដ្ឋមន្ត្រី១(មួយ)រូប ទទួលការងារជំនួសតាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី។

**មាត្រា៣០ .__**

ឧបនាយករដ្ឋមន្ត្រីជាសមាជិករាជរដ្ឋាភិបាល ដែលមានអាសនានុក្រមលើទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ។

ឧបនាយករដ្ឋមន្ត្រីជួយការងារនាយករដ្ឋមន្ត្រី តាមការប្រគល់សិទ្ធិចំពោះមុខពីនាយករដ្ឋមន្ត្រី ។ កិច្ចការដែលពាក់ទងនឹងការដឹកនាំរួមរបស់រាជរដ្ឋាភិបាល បើគ្មានការយល់ព្រមពីនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រីគ្មានសិទ្ធិសម្រេចឡើយ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា៣១ .–**

សមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលដែលដឹកនាំ គ្រប់គ្រងក្រសួង ហៅថា រដ្ឋមន្ត្រី ។

សមាជិករាជរដ្ឋាភិបាលដែលមិនដឹកនាំក្រសួង ត្រូវទទួលភារកិច្ចតាមការកំណត់របស់នាយករដ្ឋមន្ត្រី ។

**មាត្រា៣២ .–**

នាយករដ្ឋមន្ត្រី និងសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាល មានខុទ្ទកាល័យរបស់ខ្លួនមួយនិងមានទីប្រឹក្សា ជំនួយការ លេខាធិការដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

**មាត្រា៣៣ .–**

សមាជិកមួយរូបៗនៃរាជរដ្ឋាភិបាលទទួលខុសត្រូវរៀងៗខ្លួនចំពោះនាយករដ្ឋមន្ត្រីនិងចំពោះរដ្ឋសភាអំពីអំពើដែលខ្លួនបានប្រព្រឹត្ត ។

នាយករដ្ឋមន្ត្រីត្រួតពិនិត្យការងារ សកម្មភាព អំពើប្រព្រឹត្ត និងការទទួលខុសត្រូវរបស់សមាជិករាជរដ្ឋាភិបាល ហើយមានសិទ្ធិដក និងដាក់ជំនួសសមាជិករាជរដ្ឋាភិបាលតាមបែបបទនិងនីតិវិធីជាធរមាន ។

## ជំពូកទី ៤
## ទីស្តីការគណៈរដ្ឋមន្ត្រី

**មាត្រា៣៤ .–**

ត្រូវបានបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលសម្រាប់សម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី ។

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានតួនាទីគ្រប់គ្រង និងចាត់ចែងការងារទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៣៥ .–**

ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់ ។

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បំពេញភារកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា៣៦ .–**

ទីស្តីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

តួនាទី ភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ។

**មាត្រា៣៧ .–**

ទីស្តីការគណៈរដ្ឋមន្ត្រីអាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់ ។

**មាត្រា៣៨ .–**

ការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រីត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៥
## ការបង្កើតក្រសួង

**មាត្រា៣៩ .–**

ការបង្កើតក្រសួងត្រូវកំណត់ដោយច្បាប់ ។

ក្រសួងនីមួយៗត្រូវអនុវត្តសមត្ថកិច្ចស្របតាមច្បាប់ដែលបង្កើតក្រសួងនោះ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ចាប់ពីថ្នាក់នាយកដ្ឋានឡើង ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាស ។

ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងក្រសួងពីរ ឬច្រើន គណៈរដ្ឋមន្ត្រីត្រូវពិនិត្យ និងសម្រេច ។

**មាត្រា៤០ .–**

រដ្ឋមន្ត្រីដឹកនាំការងារក្នុងក្រសួង និងគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក ដែលជាភ្នាក់ងាររដ្ឋបាលនៅក្រោមឱវាទរបស់ខ្លួន ។

**មាត្រា៤១ .–**

រដ្ឋមន្ត្រីមានភារកិច្ចដឹកនាំ គ្រប់គ្រងក្រសួង និងអង្គភាពចំណុះក្នុងក្របខ័ណ្ឌសមត្ថកិច្ចដែលកំណត់ក្នុងច្បាប់ ។

**មាត្រា៤២ .–**

នៅពេលដែលរដ្ឋមន្ត្រីណាម្នាក់អវត្តមាន ឬមានភារកិច្ចមិនអាចដឹកនាំ គ្រប់គ្រងក្រសួងបានជាបណ្តោះអាសន្ន រដ្ឋលេខាធិការប្រចាំការដូចមានចែងក្នុងមាត្រា៤៤ នៃច្បាប់នេះ ត្រូវទទួលដឹកនាំការងារប្រចាំថ្ងៃរបស់ក្រសួង ក្នុងឋានៈជារដ្ឋមន្ត្រីស្តីទី ហូតដល់មានវត្តមានរដ្ឋមន្ត្រីនៃក្រសួងសាមី ។ ក្នុងករណីដែលរដ្ឋលេខាធិការប្រចាំការ មិនអាចបំពេញតួនាទីជារដ្ឋមន្ត្រីស្តីទីបាន រដ្ឋមន្ត្រីអាចចាត់តាំងរដ្ឋលេខាធិការផ្សេងទៀតជារដ្ឋមន្ត្រីស្តីទី ។

រដ្ឋមន្ត្រីស្តីទីមិនមែនជាសមាជិករាជរដ្ឋាភិបាល ហើយត្រូវអនុវត្តសិទ្ធិអំណាចតាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រី ។

ក្នុងករណីដែលមានកិច្ចការចាំបាច់តាមរដ្ឋធម្មនុញ្ញ និងច្បាប់តម្រូវឱ្យរដ្ឋមន្ត្រីជាអ្នកបំពេញតួនាទីនោះ នាយករដ្ឋមន្ត្រីចាត់តាំងសមាជិករាជរដ្ឋាភិបាលណាម្នាក់ ដើម្បីបំពេញកិច្ចការនោះជំនួសឱ្យរដ្ឋមន្ត្រីដែលអវត្តមាន ។

តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទីត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៤៣ .–**

ក្រសួងនីមួយៗមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់ ។

រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ បំពេញភារកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីនៃក្រសួងសាមី ។

**មាត្រា៤៤ .–**

ក្រសួងនីមួយៗមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងសាមី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ក្រសួង ។

តួនាទី ភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល ។

**មាត្រា៤៥ .–**

ក្រសួងនីមួយៗអាចមានទីប្រឹក្សា និងជំនួយការតាមការចាំបាច់ ។

**មាត្រា៤៦ ._**

រដ្ឋមន្ត្រីមានសិទ្ធិលើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទតាមបែបបទនីតិវិធីជាធរមាន ចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ និងថ្នាក់វរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ។

រដ្ឋមន្ត្រីមានសិទ្ធិតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ តាមបែបបទនីតិវិធីជាធរមានដោយប្រកាស ចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល និងថ្នាក់ក្រោមវរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ។

រាជរដ្ឋាភិបាល អាចចេញអនុក្រឹត្យស្តីពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលរបស់ក្រសួងដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

**មាត្រា៤៧ ._**

រដ្ឋមន្ត្រីមានសិទ្ធិចេញប្រកាស សេចក្តីសម្រេច សារាចរ និងសេចក្តីណែនាំ ។

ប្រកាស សេចក្តីសម្រេច សារាចរ ឬសេចក្តីណែនាំរបស់ក្រសួង មិនអាចចែងអំពីកិច្ចការដែលមិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងនោះ ហើយក៏ពុំអាចមានទំនាស់ជាមួយលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាលឡើយ ។

## ជំពូកទី ៦

## ការបង្កើតស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា

**មាត្រា៤៨ ._**

រាជរដ្ឋាភិបាលអាចលើកសំណើបង្កើត ឬអាចបង្កើតស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា តាមការចាំបាច់ ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

**មាត្រា៤៩ ._**

ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានាដែលបានបង្កើតឡើង ស្របតាមមាត្រា៤៨ នៃច្បាប់នេះ មិនមានក្របខ័ណ្ឌមន្ត្រីរាជការដោយឡែករបស់ខ្លួនឡើយ ។ មន្ត្រីរាជការដែលបំពេញការងារនៅក្នុងស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា ត្រូវជ្រើសយកពីក្របខ័ណ្ឌមន្ត្រីរាជការនៃទីស្តីការគណៈរដ្ឋមន្ត្រី និង/ឬក្រសួងពាក់ព័ន្ធ លើកលែងតែមានកំណត់ក្នុងច្បាប់ដោយឡែក ។

ប្រធានស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា មានសិទ្ធិលើកសំណើតែងតាំង ឬមានសិទ្ធិតែងតាំង ផ្លាស់ប្តូរមន្ត្រីរាជការរបស់ខ្លួន ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។

ស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានា ដែលបានបង្កើតឡើង ស្របតាមមាត្រា៤៨ នៃច្បាប់នេះ មានសមត្ថកិច្ចដូចមានកំណត់នៅក្នុងច្បាប់ និង/ឬលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៥០ ._**

នាយករដ្ឋមន្ត្រីអាចចាត់តាំងសមាជិករាជរដ្ឋាភិបាល១(មួយ)រូប ឱ្យទទួលដឹកនាំ គ្រប់គ្រងស្ថាប័ន ក្រុមប្រឹក្សា អាជ្ញាធរ គណៈកម្មាធិការ និងយន្តការនានាដែលបានបង្កើតឡើងស្របតាមមាត្រា៤៨ នៃច្បាប់នេះ ។

## ជំពូកទី ៧
## រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
## រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា និងជំនួយការ

**មាត្រា៥១ ._**

នាយករដ្ឋមន្ត្រីលើកសំណើថ្វាយព្រះមហាក្សត្រ តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទីប្រឹក្សា និងជំនួយការដែលមានឋានៈស្មើអគ្គនាយកឡើងទៅ ។

**មាត្រា៥២ ._**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សា និងជំនួយការនាយករដ្ឋមន្ត្រី បំពេញការកិច្ចតាមការប្រគល់ពីនាយករដ្ឋមន្ត្រី ។

**មាត្រា៥៣ ._**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ មិនមែនជាសមាជិករាជរដ្ឋាភិបាលទេ ហើយក៏មិនមែនជាភ្នាក់ងាររដ្ឋបាលអចិន្ត្រៃយ៍ដែរ ។

នៅពេលណាដែលរាជរដ្ឋាភិបាលចប់អាណត្តិ ឬលាលែង ឬត្រូវបានទម្លាក់ដោយរដ្ឋសភា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការ ដូចមានចែងក្នុងមាត្រា៣២ មាត្រា៣៧ មាត្រា៤៥ និងមាត្រា៥២ នៃច្បាប់នេះ ក៏ត្រូវអស់តំណែងដែរ ។

**មាត្រា៥៤ ._**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការនៅក្នុងមុខតំណែង ទទួលបានប្រាក់បំណាច់មុខងារក្នុងការបំពេញការកិច្ច ។

ប្រាក់បំណាច់មុខងារនៃរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សា ជំនួយការ និងលេខាធិការ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា៥៥ ._**

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៣

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានច្បាប់និងលិខិតបទដ្ឋានគតិយុត្តថ្មី មកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

# ជំពូកទី៩
# អវសានប្បញ្ញត្តិ

**មាត្រា៥៦ .–**

ច្បាប់នេះត្រូវយកទៅអនុវត្តចាប់ពីនីតិកាលទី៦ នៃរដ្ឋសភាតទៅ ។

**មាត្រា៥៧ .–**

ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១៣/០១២ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៣ និងច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា៥៨ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥៩ .–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨

នរណ.១៨០៦.៦៨១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ហត្ថលេខា**
**សម្ដេចក្រឡាហោម ស ខេង**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**និងជារដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**ហត្ថលេខា**
**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

លេខ:៦៧១ ស.ណ
**សំណៅដែលមានតម្លៃជាការថតចម្លង**
ថ្ងៃសុក្រ ២រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

រដ្ឋសភា

ចូល លេខ........ ថ្ងៃទី........ឆ្នាំ២០១៤ ម៉ោង........ បញ្ជូនទៅ........

# ព្រះរាជក្រម

នស/រកម/០៧១៤/០១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ លើទម្រង់ និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នាសម័យប្រជុំលើកទី៥ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របតាមនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៤៩/០០៣/២០១៤ កបធ.ច ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្តីពី

# ការរៀបចំអង្គការតុលាការ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណង៖

- ធានាឯករាជ្យនៃអំណាចតុលាការ
- ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ
- ធានាឲ្យមានកិច្ចដំណើរការល្អរបស់អង្គការតុលាការ និងអង្គការអយ្យការ
- លើកកម្ពស់សេវាសាធារណៈឲ្យមានប្រសិទ្ធភាព និងឆាប់រហ័ស
- ធានាក្នុងការផ្តល់យុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹងសុវត្ថិភាពសង្គម ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅ៖

- កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការតុលាការគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់ដែលជាសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា
- កំណត់អំពីសមត្ថកិច្ចរបស់តុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ទៅតាមជំនាញ
- រៀបចំការងារគ្រប់គ្រង ការងាររដ្ឋបាល និងដំណើរការប្រព្រឹត្តទៅរបស់តុលាការ ។

**មាត្រា ៣.-**

សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖

- សាលាដំបូង
- សាលាឧទ្ធរណ៍
- តុលាការកំពូល ។

សាលាដំបូង ជាសាលាជម្រះក្តីជាន់ទាប ។ សាលាឧទ្ធរណ៍ និងតុលាការកំពូល ជាសាលាជម្រះក្តីជាន់ខ្ពស់ ។

ស្របទៅតាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង ការបង្កើតសាលាជម្រះក្តីណាមួយ ឬសាលាជម្រះក្តីឯកទេសណាមួយ ត្រូវធ្វើឡើងដោយច្បាប់ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

**មាត្រា ៤.-**

សាលាជម្រះក្ដីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ អនុវត្តអំណាចតុលាការ ដែលគ្របដណ្ដប់លើរឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផង ។

**មាត្រា ៥.-**

សាលាជម្រះក្ដីជាន់ទាបត្រូវបែងចែកជាតុលាការជំនាញ ។ ការបង្កើត ការលុបចោល និងការកែប្រែតុលាការជំនាញត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ប្រធានសាលាដំបូង មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើប្រធានតុលាការជំនាញទាំងអស់នៃសាលាដំបូងនោះ ។ ប្រធានតុលាការជំនាញនីមួយៗ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើចៅក្រមដែលជាសមាជិក ។ ប្រធានសាលាដំបូងមិនអាចធ្វើជាប្រធានតុលាការជំនាញណាមួយបានឡើយ ។ ប្រធានតុលាការជំនាញនីមួយៗ អាចធ្វើជាប្រធានតុលាការជំនាញបានតែមួយគត់នៃសាលាដំបូងនោះ ។

សាលាជម្រះក្ដីជាន់ខ្ពស់ត្រូវបែងចែកជាសភាជំនាញ ។ ការបង្កើត ការលុបចោល និងការកែប្រែសភាជំនាញ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ប្រធានសាលាជម្រះក្ដីជាន់ខ្ពស់ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើប្រធានសភាជំនាញទាំងអស់នៃសាលាជម្រះក្ដីជាន់ខ្ពស់នោះ ។ ប្រធានសភាជំនាញនីមួយៗ មានអំណាចឋានានុក្រមផ្នែករដ្ឋបាលដោយផ្ទាល់លើចៅក្រមដែលជាសមាជិក ។ ប្រធានសាលាជម្រះក្ដីជាន់ខ្ពស់មិនអាចធ្វើជាប្រធានសភាជំនាញណាមួយបានឡើយ ។ ប្រធានសភាជំនាញនីមួយៗ អាចធ្វើជាប្រធានសភាជំនាញបានតែមួយគត់នៃសាលាជម្រះក្ដីជាន់ខ្ពស់នោះ ។

**មាត្រា ៦.-**

មានតែចៅក្រមទេ ដែលមានសិទ្ធិជម្រះក្ដី ។ ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយឯករាជ្យ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្តនិងសម្បជញ្ញៈរបស់ខ្លួន ។

ការជម្រះក្ដីផ្ដល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន ។

មានតែសាលាជម្រះក្ដីប៉ុណ្ណោះ ទើបមានអំណាចកាត់សេចក្ដី និងចេញសេចក្ដីសម្រេចរបស់តុលាការបាន ។

**មាត្រា ៧.-**

សវនាការត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែសាធារណភាពនេះអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់ល្អ ឬមានបទប្បញ្ញត្តិពិសេសក្នុងច្បាប់ចែងផ្សេងពីនេះ ។

នៅគ្រប់ករណីទាំងអស់ សាលក្រម និងសាលដីកាតុលាការ ត្រូវប្រកាសនៅក្នុងសាលសវនាការដែលបើកជាសាធារណៈ ។

ការពិភាក្សាសម្រេចសេចក្ដីរបស់អង្គជំនុំជម្រះត្រូវធ្វើជាសម្ងាត់ ។

លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ ការប្រកាសសាលក្រម ឬសាលដីការបស់តុលាការត្រូវធ្វើឡើងដោយប្រធានអង្គជំនុំជម្រះ ឬចៅក្រមមួយរូបក្នុងចំណោមចៅក្រមដែលជាសមាសភាពនៃអង្គជំនុំជម្រះ ។

គ្រប់សាលក្រម និងសាលដីកាតុលាការ ត្រូវតែមានសំអាងហេតុ ។

លើកលែងតែមានបទប្បញ្ញត្តិផ្សេងពីនេះ សាលក្រម និងសាលដីកា ត្រូវចុះហត្ថលេខាដោយប្រធានអង្គជំនុំជម្រះ និងចុះហត្ថលេខាអមដោយក្រឡាបញ្ជីនៃសវនាការ ។

## មាត្រា ៨.-

នៅអមសាលាដំបូង ត្រូវមានអង្គការអយ្យការមួយ ហៅថា អយ្យការអមសាលាដំបូង ។

នៅអមសាលាឧទ្ធរណ៍ ត្រូវមានអង្គការអយ្យការមួយហៅថាមហាអយ្យការអមសាលាឧទ្ធរណ៍ ។

នៅអមតុលាការកំពូល ត្រូវមានអង្គការអយ្យការមួយ ហៅថា មហាអយ្យការអមតុលាការកំពូល ។

តំណាងអង្គការអយ្យការ ត្រូវមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្ដីព្រហ្មទណ្ឌ និងរឿងក្ដីផ្សេងៗទៀតដែលច្បាប់កំណត់ ។

## មាត្រា ៩.-

នៅគ្រប់អង្គការតុលាការ និងអង្គការអយ្យការគ្រប់ជាន់ថ្នាក់ មានក្រឡាបញ្ជី និងមន្ត្រីរដ្ឋបាលព្រមទាំងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ជាជំនួយការតាមការចាំបាច់ ។

ក្រឡាបញ្ជីជួយចៅក្រម និងព្រះរាជអាជ្ញានៅគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ និង អយ្យការ ។

តួនាទី និងមុខងាររបស់ក្រឡាបញ្ជី ត្រូវកំណត់ក្នុងលក្ខន្តិកៈក្រឡាបញ្ជី ។

បែបបទ និងលក្ខខណ្ឌនៃការជ្រើសរើសមន្ត្រីជំនាញផ្នែកច្បាប់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ១០.-

នៅសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់ មានអង្គភាពរដ្ឋបាលមួយ ដែលស្ថិតនៅក្រោមរដ្ឋបាលកណ្ដាលរបស់ក្រសួងយុត្តិធម៌ សម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់អង្គការតុលាការ និងអង្គការអយ្យការ។

នៅថ្នាក់សាលាដំបូង អង្គភាពរដ្ឋបាលនេះ ហៅថា លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងមានថ្នាក់ស្មើនឹងនាយកដ្ឋាន ។

នៅថ្នាក់សាលាឧទ្ធរណ៍ អង្គភាពរដ្ឋបាលនេះ ហៅថា អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍មានថ្នាក់ស្មើនឹងអគ្គនាយកដ្ឋាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

នៅថ្នាក់តុលាការកំពូល អង្គភាពរដ្ឋបាលនេះ ហៅថា អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល មានថ្នាក់ស្មើនឹងអគ្គនាយកដ្ឋាន ។

**មាត្រា ១១.-**

ក្រសួងយុត្តិធម៌ មានសិទ្ធិត្រួតពិនិត្យលើកិច្ចការរដ្ឋបាលរបស់សាលាជម្រះក្តីទាំងអស់ ដោយមានអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការមួយជាសេនាធិការ ។ ក្រសួងយុត្តិធម៌អាចចេញលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំចាំបាច់នានា ដើម្បីធានាដំណើរការប្រព្រឹត្តទៅល្អប្រសើរនៃការគ្រប់គ្រងរដ្ឋបាលតុលាការគ្រប់ជាន់ថ្នាក់ ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចាត់ឲ្យធ្វើអធិការកិច្ចលើបញ្ហាណាមួយជាកំណត់ រួចធ្វើរបាយការណ៍ជូនឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដើម្បីពិនិត្យ និងសម្រេច ។

សាលាជម្រះក្តីជាន់ខ្ពស់ មានសមត្ថកិច្ចត្រួតពិនិត្យលើកិច្ចការជម្រះក្តីរបស់សាលាជម្រះក្តីជាន់ទាប ។ ការត្រួតពិនិត្យនេះ ប្រព្រឹត្តទៅក្នុងក្របខណ្ឌនៃនីតិវិធីឧបាស្រ័យ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

## ជំពូកទី ២
## សាលាដំបូង និងអយ្យការអមសាលាដំបូង
### ផ្នែកទី ១
### សាលាដំបូង
#### អនុផ្នែកទី ១
#### ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាដំបូង

**មាត្រា ១២.-**

សាលាដំបូងជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលត្រូវបង្កើតឲ្យមាននៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។ ការដាក់ឲ្យដំណើរការសាលាដំបូងនានា ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

សាលាដំបូងត្រូវបែងចែកជាតុលាការជំនាញ ។ សាលាដំបូង គឺជាសាលាជម្រះក្តីទូទៅដែលមានសមត្ថកិច្ចជំនុំជម្រះក្តីទៅលើរឿងក្តីទាំងអស់ លើកលែងតែរឿងក្តីដែលស្ថិតនៅក្រោមសមត្ថកិច្ចនៃសាលាជម្រះក្តីពិសេស ឬសាលាជម្រះក្តីសោមញ្ញដែលបង្កើតឡើងដោយច្បាប់ដោយឡែក ។

**មាត្រា ១៣.-**

សមាសភាពសាលាដំបូង រួមមាន៖

- ប្រធាន

- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាដំបូង ។

**មាត្រា ១៤.–**

សាលាដំបូងនីមួយៗបែងចែកជាតុលាការជំនាញ ដូចខាងក្រោមៈ

- តុលាការរដ្ឋប្បវេណី
- តុលាការព្រហ្មទណ្ឌ
- តុលាការពាណិជ្ជកម្ម
- តុលាការការងារ ។

តុលាការជំនាញផ្សេងទៀតរបស់សាលាដំបូង អាចត្រូវបង្កើតឡើង ដោយយោងតាមសេចក្ដីត្រូវការចាំបាច់ ។ ការបង្កើតនេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

តុលាការជំនាញនីមួយៗរបស់សាលាដំបូង ចេញសេចក្ដីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងនាមសាលាដំបូងដែលតុលាការជំនាញនោះស្ថិតនៅ ។

**មាត្រា ១៥.–**

សមាសភាពរបស់តុលាការជំនាញនីមួយៗរួមមានៈ

- ប្រធានតុលាការ
- ចៅក្រម
- ក្រឡាបញ្ជី ។

ប្រធានតុលាការជំនាញនីមួយៗ រួមទាំងចៅក្រម និងក្រឡាបញ្ជី ត្រូវចាត់តាំងដោយប្រធានសាលាដំបូង ។ ដំណើរការរបស់តុលាការជំនាញទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាដំបូងដោយអនុលោមទៅតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ១៦.–**

តុលាការជំនាញនីមួយៗនៃសាលាដំបូង សម្រេចសេចក្ដីដោយមានចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុលោមតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិស្ដីពីនីតិវិធីជាធរមានផ្សេងទៀត ។ ក្នុងករណីចៅក្រមណាម្នាក់មានធុរៈ ឬស្ថិតក្នុងស្ថានភាពមិនអាចបំពេញកិច្ចការបាន ចៅក្រមនោះអាចជំនួសដោយចៅក្រមនៅក្នុងលំដាប់បន្តបន្ទាប់ ដែលមានតាមការកំណត់ក្នុងដីកាសម្រេចប្រចាំឆ្នាំរបស់ប្រធានសាលាដំបូង ។

ក្នុងករណីដែលតុលាការជំនាញណាមួយមិនអាចបើកសវនាការបាន ដោយមានមូលហេតុមកពីខ្វះចៅក្រម ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមពីតុលាការជំនាញផ្សេងមកបំពេញ ។ ប្រសិនបើត្រូវស្នើសុំចៅក្រមមួយរូប ឬច្រើនរូបនៃសាលាដំបូងផ្សេងសម្រាប់បំពេញសមាសភាពនៃតុលាការជំនាញនេះ ប្រធានសាលាដំបូងត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ១៧.-

ប្រធានសាលាដំបូងចាត់វិធានការគ្រប់គ្រងជាចាំបាច់សម្រាប់ដំណើរការនៃសាលាដំបូង ។ ក្នុងករណីប្រធានសាលាដំបូងស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងប្រធានសាលាដំបូងស្ថិតក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអនុប្រធានសាលាដំបូងម្នាក់ ឬបើគ្មានអនុប្រធានទេ អាចចាត់តាំងចៅក្រមណាម្នាក់ឲ្យធ្វើជាប្រធានស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់សាលាដំបូង រហូតដល់មានការតែងតាំងប្រធានសាលាដំបូងជាផ្លូវការ ។ ការតែងតាំងប្រធានសាលាដំបូង ត្រូវធ្វើក្នុងរយៈពេលខ្លីបំផុត និងយ៉ាងយូរបំផុតមិនឲ្យលើសពី ៣០(សាមសិប) ថ្ងៃ ។

ប្រធានសាលាដំបូងត្រូវចេញដីកាសម្រេចដើម្បីៈ

- ចាត់តាំងអនុប្រធានសាលាដំបូងណាម្នាក់ ឲ្យចាត់ចែងការងារជំនួសខ្លួនបាន ក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានសាលាដំបូង ឲ្យទទួលបន្ទុកធ្វើជាប្រធានតុលាការជំនាញនីមួយៗដោយផ្អែកតាមជំនាញ ឬបទពិសោធន៍ការងារ ។ ក្នុងករណីខ្វះអនុប្រធានប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមណាម្នាក់ ដែលមានឋានន្តរស័ក្តិខ្ពស់ ឬមានបទពិសោធន៍ច្រើនឲ្យធ្វើជាប្រធានតុលាការជំនាញបាន
- កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងតុលាការជំនាញនីមួយៗ និងនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការជំនាញទាំងនេះ ក្នុងករណីដែលចៅក្រមណាម្នាក់អវត្តមាន ឬមានធុរៈ
- ចាត់តាំង និងផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុងតុលាការជំនាញនីមួយៗ តាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង ។

## មាត្រា ១៨.-

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចអនុញ្ញាតឲ្យសាលាដំបូងបើកសវនាការនៅក្រៅទីតាំងស្នាក់ការរបស់ខ្លួនបាន តាមការស្នើសុំពីប្រធានសាលាដំបូង ។

# អនុផ្នែកទី ២
## សមត្ថកិច្ច

**មាត្រា ១៩.-**

សាលាដំបូងមានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យសាលាជម្រះក្តីផ្សេងទៀត ។

ក្នុងករណីចាំបាច់ ដើម្បីជាប្រយោជន៍សាធារណៈ សុវត្ថិភាព សន្តិសុខសង្គម និងដំណើរការល្អនៃយុត្តិធម៌តុលាការ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចសម្រេចផ្ទេរសមត្ថកិច្ចក្នុងការចាត់ការរឿងក្តីពីសាលាដំបូងមួយទៅសាលាដំបូងមួយទៀតបាន ។

ក្នុងករណីមានវិវាទសមត្ថកិច្ចរវាងតុលាការជំនាញផ្សេងៗនៅក្នុងសាលាដំបូង ប្រធានសាលាដំបូងត្រូវកោះប្រជុំប្រធានតុលាការជំនាញដែលពាក់ព័ន្ធដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមសំណើរបស់ប្រធានតុលាការជំនាញណាមួយដើម្បីសម្រេចអំពីសមត្ថកិច្ច ។ប្រធានសាលាដំបូងសម្រេចលើវិវាទសមត្ថកិច្ចនេះដោយដីកាសម្រេច ។ ដីកាសម្រេចនេះ គឺជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

**មាត្រា ២០.-**

តុលាការព្រហ្មទណ្ឌនៃសាលាដំបូងជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌទាំងឡាយ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ លើកលែងតែមានបទប្បញ្ញត្តិច្បាប់ចែងផ្សេងពីនេះ ។

តុលាការព្រហ្មទណ្ឌនៃសាលាដំបូងជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ដោយចៅក្រមទោល ឬដោយក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

មន្ទីរស៊ើបសួរនៃសាលាដំបូង គឺជាផ្នែកមួយនៃតុលាការព្រហ្មទណ្ឌ និងមានសមត្ថកិច្ចស៊ើបសួររឿងក្តីព្រហ្មទណ្ឌ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមយ៉ាងតិច ០២ (ពីរ) រូប តាមដីកាសម្រេចឲ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរនៅមន្ទីរស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង ។ ដីកាសម្រេចនេះ ត្រូវកំណត់ផងដែរអំពីលំដាប់លេខរៀងសម្រាប់ការទទួលបំពេញការងារ ។ ក្នុងករណីពុំមានចៅក្រមស៊ើបសួរ ឬខ្វះចៅក្រមស៊ើបសួរប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមនៃតុលាការជំនាញផ្សេង ដើម្បីបំពេញមុខងារស៊ើបសួរបាន ។

ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរអាចបំពេញការងារជាចៅក្រមនៅតុលាការជំនាញផ្សេងទៀតបាន តាមការចាត់តាំងរបស់ប្រធានសាលាដំបូង ។

**មាត្រា ២១.-**

តុលាការរដ្ឋប្បវេណីនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីទាំង

ឡាយណាដែលពុំមានបទប្បញ្ញត្តិណាមួយ ប្រគល់សមត្ថកិច្ចទៅឲ្យតុលាការជំនាញផ្សេងទៀត ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណី ។

តុលាការរដ្ឋប្បវេណីនៃសាលាដំបូងជំនុំជម្រះរឿងក្ដីរដ្ឋប្បវេណីដោយមានចៅក្រមទោល ឬ ដោយមានក្រុមប្រឹក្សាជំនុំជម្រះ ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីរដ្ឋប្បវេណី ។

## មាត្រា ២២.-

តុលាការពាណិជ្ជកម្មនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីពាណិជ្ជកម្ម ដោយរួមទាំងរឿងក្ដីក្ស័យធនក្នុងរឿងពាណិជ្ជកម្ម ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីពាណិជ្ជកម្ម ។

## មាត្រា ២៣.-

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយមានចៅក្រម ០៣ (បី) រូប និងអមដោយទីប្រឹក្សា ០២ (ពីរ) រូប ជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្មក្នុងករណីរឿងក្ដីពាណិជ្ជកម្ម ដែលកម្មវត្ថុបណ្ដឹងមានតម្លៃចាប់ពី ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ឡើងទៅ ។

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយមានចៅក្រម ០១ (មួយ) រូប និងអមដោយទីប្រឹក្សា ០២ (ពីរ) រូប ជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្មក្នុងករណីរឿងក្ដីពាណិជ្ជកម្ម ដែលកម្មវត្ថុបណ្ដឹងមានតម្លៃចាប់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ដល់ក្រោម ១.០០០.០០០.០០០ (មួយពាន់លាន) រៀល ។

តុលាការពាណិជ្ជកម្មជំនុំជម្រះដោយចៅក្រម ០១ (មួយ) រូប ដោយមិនចាំបាច់មានការចូលរួមពីទីប្រឹក្សាពាណិជ្ជកម្មឡើយក្នុងករណីរឿងក្ដីពាណិជ្ជកម្ម ដែលកម្មវត្ថុបណ្ដឹងមានតម្លៃក្រោម ១០០.០០០.០០០ (មួយរយលាន) រៀល ។

សាលក្រមរបស់តុលាការពាណិជ្ជកម្មត្រូវសម្រេចដោយចៅក្រម ០១ (មួយ) រូប ឬ ០៣ (បី) រូប យោងទៅតាមកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្ម ។

ទីប្រឹក្សាពាណិជ្ជកម្មមិនបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងតុលាការពាណិជ្ជកម្មនៃសាលាដំបូងឡើយ ។ ទីប្រឹក្សាពាណិជ្ជកម្មត្រូវចូលមកបំពេញមុខងាររបស់ខ្លួននៅសាលាដំបូងតាមការអញ្ជើញរបស់ប្រធានតុលាការពាណិជ្ជកម្មនៃសាលាដំបូង ។

## មាត្រា ២៤.-

របៀបបទនៃការជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

## មាត្រា ២៥.-

តុលាការការងារនៃសាលាដំបូង មានសមត្ថកិច្ចជំនុំជម្រះលើរឿងក្តីការងារ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីការងារ ។

## មាត្រា ២៦.-

តុលាការការងារនៃសាលាដំបូងត្រូវជំនុំជម្រះដោយចៅក្រម ០១ (មួយ) រូប អមដោយទីប្រឹក្សាការងារ ០២ (ពីរ) រូប ដែល ០១ (មួយ) រូបជាកម្មករនិយោជិត និង០១ (មួយ) រូបទៀតជានិយោជក ។

សាលក្រមរបស់តុលាការការងារនៃសាលាដំបូង ត្រូវសម្រេចដោយចៅក្រម ០១(មួយ) រូប ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាការងារ ។

ទីប្រឹក្សាការងារ ពុំបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងតុលាការការងារនៃសាលាដំបូងឡើយ ។ ទីប្រឹក្សាការងារត្រូវចូលរួមបំពេញមុខងាររបស់ខ្លួននៅសាលាដំបូង តាមការអញ្ជើញរបស់ប្រធានតុលាការការងារ ។

## មាត្រា ២៧.-

តុលាការការងារដែលមានសមត្ថកិច្ច គឺតុលាការការងារនៃសាលាដំបូងនាទីកន្លែងវិវាទការងារ ។

ទោះបីមានការកំណត់សមត្ថកិច្ចដូចកថាខណ្ឌខាងលើក៏ដោយ ក៏កម្មករនិយោជិតអាចប្តឹងទៅសាលាដំបូងតាមការកំណត់ដូចខាងក្រោម លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ៖

- នាលំនៅឋានរបស់ខ្លួន ឬ
- នាទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បងរបស់ក្រុមហ៊ុន ឬ
- នាលំនៅឋានរបស់អ្នកតំណាង ឬអ្នកទទួលខុសត្រូវរបស់ក្រុមហ៊ុន ប្រសិនបើគ្មានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បងរបស់ក្រុមហ៊ុនទេ ។

## មាត្រា ២៨.-

បែបបទនៃការបោះឆ្នោតជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាការងារ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ។

# ផ្នែកទី ២
# អយ្យការអមសាលាដំបូង

## មាត្រា ២៩.-

សមាសភាពអយ្យការអមសាលាដំបូង រួមមាន៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅអយ្យការអមសាលាដំបូង ។

**មាត្រា ៣០.-**

អង្គការអយ្យការជាអង្គអវិភាគ ។ អយ្យការមានមុខងារធ្វើបណ្តឹងអាជ្ញា និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ ព្រមទាំងអនុវត្តមុខងារផ្សេងទៀតតាមការកំណត់របស់ច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង គឺជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ ។ ព្រះរាជអាជ្ញារង ចូលរួមអនុវត្តមុខងាររបស់អយ្យការក្រោមការដឹកនាំ និងទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន ព្រះរាជអាជ្ញាត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសបាន ។ ក្នុងករណីដែលព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឲ្យធ្វើជាព្រះរាជអាជ្ញាស្តីទីជំនួសបាន ដើម្បីធានាដំណើរការរបស់អយ្យការអមសាលាដំបូងរហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ ។

**មាត្រា ៣១.-**

ព្រះរាជអាជ្ញាមានអំណាចលើព្រះរាជអាជ្ញារងទាំងអស់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ ព្រះរាជអាជ្ញាចាត់តាំង និងបែងចែកការងារដល់ព្រះរាជអាជ្ញារងទាំងអស់ ។

ព្រះរាជអាជ្ញាមានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារងធ្វើការចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ ។ សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារង ត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្តីសន្និដ្ឋាននោះទេ ហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្តីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាមព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្តង ឲ្យធ្វើជាតំណាងអយ្យការនៅក្នុងសវនាការនៃសាលាដំបូង ។

ប៉ុន្តែ នៅពេលសវនាការ ព្រះរាជអាជ្ញារងអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរីតាមគំនិតដែលខ្លួនយល់ឃើញថា ស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននៅពេលសវនាការ ខុសពីសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

# ផ្នែកទី ៣
# លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង

**មាត្រា៣២.–**

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង គឺជាសេនាធិការឲ្យសាលាដំបូង និងអយ្យការអមសាលាដំបូងលើះ

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការ សម្រាប់ជាជំនួយបច្ចេកទេសដល់កម្មវិធីការងាររបស់សាលាដំបូង និងអយ្យការអមសាលាដំបូង
- ការងាររៀបចំគម្រោងថវិកាជូនប្រធានសាលាដំបូងនិងព្រះរាជអាជ្ញា ដើម្បីពិនិត្យ និងសម្រេច
- រាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានសាលាដំបូង និងព្រះរាជអាជ្ញា
- ការអនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត
- ការងារទំនាក់ទំនងសាធារណៈ
- ការងារបញ្ជូនសាលក្រមរបស់សាលាដំបូង ជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំ និងបញ្ជូនរបាយការណ៍ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌
- ការងារផ្សេងទៀតដែលប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងប្រគល់ឲ្យ
- អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត ។

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវបែងចែកជាការិយាល័យតាមចំនួនចាំបាច់ជាក់ស្តែង ។ ការិយាល័យដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៣៣.–**

លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។ ប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ។ មន្ត្រីបម្រើការងារនៅលេខាធិការដ្ឋានថ្នាក់ក្រោមប្រធានលេខាធិការដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ប្រធាន និងអនុប្រធានលេខាធិការដ្ឋាន ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។ ប្រធាន និង អនុប្រធានការិយាល័យ ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅលេខាធិការដ្ឋានទាំងអស់ ដោយរួមទាំងប្រធានលេខាធិការដ្ឋានផងត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។

**មាត្រា ៣៤.-**

សន្និបាតរបស់សាលាដំបូង ប្រព្រឹត្តទៅក្រោមអធិបតីភាពនៃប្រធានសាលាដំបូង និងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង ដើម្បីបូកសរុបលទ្ធផលការងារកន្លងមក និងកំណត់ទិសដៅការងាររដ្ឋបាលរបស់សាលាដំបូងសម្រាប់ឆ្នាំបន្ទាប់ទៀត ។ របាយការណ៍សន្និបាតរបស់សាលាដំបូងត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌ ។

## ជំពូកទី ៣
## សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
## ផ្នែកទី ១
## សាលាឧទ្ធរណ៍
## អនុផ្នែកទី ១
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់សាលាឧទ្ធរណ៍

**មាត្រា ៣៥.-**

សាលាឧទ្ធរណ៍ គឺជាសាលាជម្រះក្តីថ្នាក់ទីពីរ ។

សាលាឧទ្ធរណ៍រួមមានសាលាឧទ្ធរណ៍ភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់ ។ ការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍តំបន់នីមួយៗ និងការកំណត់ពីសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍តំបន់នេះ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ ។

**មាត្រា ៣៦.-**

សមាសភាពសាលាឧទ្ធរណ៍រួមមាន៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជីនិង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅសាលាឧទ្ធរណ៍ ។

**មាត្រា ៣៧.-**

សាលាឧទ្ធរណ៍មានសភាជំនាញ ដូចខាងក្រោម៖

- សភាព្រហ្មទណ្ឌ
- សភារដ្ឋប្បវេណី
- សភាស៊ើបសួរ
- សភាពាណិជ្ជកម្ម
- សភាការងារ ។

ក្នុងករណីចាំបាច់សភា ជំនាញផ្សេងទៀតនៃសាលាឧទ្ធរណ៍អាចត្រូវបង្កើតឡើង ដោយព្រះរាជក្រឹត្យ ។

សភានីមួយៗ ចេញសេចក្តីសម្រេចដោយស្វ័យភាព ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងនាមសាលាឧទ្ធរណ៍ដែលសភានោះស្ថិតនៅ ។

**មាត្រា ៣៨.-**

សមាសភាពរបស់សភានីមួយៗរួមមាន៖

- ប្រធានសភា
- ចៅក្រម និង
- ក្រឡាបញ្ជី ។

ប្រធានសភានីមួយៗ ត្រូវចាត់តាំងដោយប្រធានសាលាឧទ្ធរណ៍ ។

ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានសាលាឧទ្ធរណ៍ ។

**មាត្រា ៣៩.-**

សភានីមួយៗនៃសាលាឧទ្ធរណ៍សម្រេចសេចក្តីដោយមានចៅក្រម ០៣(បី) រូប ដែល ០១(មួយ) រូបជាប្រធាន ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

រឿងក្តីណាដែលតុលាការកំពូលបានបង្វិលមកវិញ នោះសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះនៅក្នុងសវនាការមួយ ដែលមានចៅក្រម ០៥ (ប្រាំ) រូប ហើយសុទ្ធតែជាចៅក្រមដែលមិនបានចូលរួមជំនុំជម្រះលើកមុន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៤០.-**

ប្រធានសាលាឧទ្ធរណ៍ ចាត់វិធានការគ្រប់គ្រងជាចាំបាច់សម្រាប់ដំណើរការនៃសាលាឧទ្ធរណ៍ ។ ប្រធានសាលាឧទ្ធរណ៍ត្រូវចេញដីកាសម្រេចដើម្បីៈ

- ចាត់តាំងអនុប្រធានសាលាឧទ្ធរណ៍ណាម្នាក់ ឲ្យចាត់ចែងការងារជំនួសខ្លួនបានក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានសាលាឧទ្ធរណ៍ ឲ្យទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗទៅតាមជំនាញ និងបទពិសោធន៍ការងារ ។ ក្នុងករណីខ្វះអនុប្រធានសាលាឧទ្ធរណ៍ ប្រធានសាលាឧទ្ធរណ៍ អាចចាត់តាំងចៅក្រមណាម្នាក់ដែលមានឋានន្តរស័ក្តិខ្ពស់ ឬមានបទពិសោធន៍ការងារច្រើន ឲ្យធ្វើជាប្រធានសភាបាន
- កំណត់លំដាប់សម្រាប់ជំនួសចៅក្រមនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនៃសភានីមួយៗ ក្នុងករណីចៅក្រមណាម្នាក់អវត្តមាន ឬមានធុរៈ
- ចាត់តាំង និងផ្លាស់ប្តូរក្រឡាបញ្ជីនៅក្នុងសភានីមួយៗ តាមការចាំបាច់ជាក់ស្តែង ។

## អនុផ្នែកទី ២
## សមត្ថកិច្ច

**មាត្រា ៤១.-**

សាលាឧទ្ធរណ៍មានសមត្ថកិច្ចជំនុំជម្រះរឿងក្តី ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួនលើកលែងតែរឿងក្តីទាំងឡាយណាដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឲ្យតុលាការផ្សេងទៀត ។

**មាត្រា ៤២.-**

សាលាឧទ្ធរណ៍សម្រេចសេចក្តីទាំងអង្គហេតុ និងអង្គច្បាប់ លើរឿងក្តីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៤៣.-**

សភាព្រហ្មទណ្ឌមានសមត្ថកិច្ចជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូង និងរឿងក្តីផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៤៤.-**

សភារដ្ឋប្បវេណីមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីផ្សេងទៀតដែលស្ថិតក្នុងដែន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជាធរមាន ។ សេចក្តីសម្រេចត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី) រូប ដែល ០១ (មួយ) រូប ជាប្រធាន ។

**មាត្រា ៤៥.-**

សភាស៊ើបសួរមានសមត្ថកិច្ចដោះស្រាយលើបណ្តឹងនានាចំពោះកិច្ចស៊ើបសួរ ឬដីកាសម្រេចនានារបស់ចៅក្រមស៊ើបសួរ និងរឿងក្តីផ្សេងទៀតដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។ សេចក្តីសម្រេចរបស់សភាស៊ើបសួរត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី) រូបដែល ០១ (មួយ) រូប ជាប្រធាន ។

**មាត្រា ៤៦.-**

សភាពាណិជ្ជកម្មមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូងក្នុងរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។ សភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះដោយចៅក្រម ០៣ (បី) រូប ដែល ០១(មួយ) រូប ជាប្រធាននិងអមដោយទីប្រឹក្សា ០២ (ពីរ) រូបជាពាណិជ្ជករ ឬអ្នកដែលមានចំណេះដឹងផ្នែកច្បាប់ពាណិជ្ជកម្ម និងមិនមែនជាទីប្រឹក្សាពាណិជ្ជកម្មនៅក្នុងរឿងក្តីតែមួយ ដែលត្រូវបានជំនុំជម្រះដោយសាលាដំបូង និងសាលាឧទ្ធរណ៍ ។ សាលដីការបស់សភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី)រូបដែល ០១(មួយ)រូប ជាប្រធានក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាពាណិជ្ជកម្ម ។

ទីប្រឹក្សាពាណិជ្ជកម្មមិនបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ឡើយ ។ ទីប្រឹក្សាពាណិជ្ជកម្មត្រូវចូលមកបំពេញមុខងាររបស់ខ្លួនតាមការអញ្ជើញរបស់ប្រធានសភាពាណិជ្ជកម្មនៃសាលាឧទ្ធរណ៍ប៉ុណ្ណោះ ។

បែបបទនៃការជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាពាណិជ្ជកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៤៧.-**

សភាការងារនៃសាលាឧទ្ធរណ៍ មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នឹងសាលក្រម និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចរបស់សាលាដំបូង ក្នុងរឿងក្តីការងារ និងរឿងក្តីផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីការងារ ។ សភាការងារនៃសាលាឧទ្ធរណ៍ត្រូវជំនុំជម្រះដោយចៅក្រម ០៣ (បី) រូប ដែល ០១(មួយ) រូប ជាប្រធាន និងអមដោយទីប្រឹក្សា ០២ (ពីរ) រូបដែល ០១ (មួយ) រូប ជាកម្មករនិយោជិត និង ០១ (មួយ) រូប ទៀតជានិយោជក និងមិនមែនជាទីប្រឹក្សាការងារនៅក្នុងរឿងក្តីតែមួយ ដែលត្រូវបានជំនុំជម្រះដោយសាលាដំបូង និង

សាលាឧទ្ធរណ៍ ។ សេចក្ដីសម្រេចរបស់សភាការងារនៃសាលាឧទ្ធរណ៍ ត្រូវធ្វើឡើងដោយចៅក្រម ០៣ (បី) រូប ដែល ០១ (មួយ) រូប ជាប្រធាន ក្រោយពីបានពិគ្រោះយោបល់ជាមួយទីប្រឹក្សាការងារ ។

ទីប្រឹក្សាការងារមិនបំពេញមុខងាររបស់ខ្លួនជាអចិន្ត្រៃយ៍ នៅក្នុងសភាការងារនៃសាលាឧទ្ធរណ៍ឡើយ ។ ទីប្រឹក្សាការងារត្រូវចូលមកបំពេញមុខងាររបស់ខ្លួន តាមការអញ្ជើញរបស់ប្រធានសភាការងារនៃសាលាឧទ្ធរណ៍ប៉ុណ្ណោះ ។

បែបបទនៃការជ្រើសតាំង និងការបំពេញភារកិច្ចរបស់ទីប្រឹក្សាការងារត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ។

## មាត្រា ៤៨.-

សភារួមក្រុមអាចត្រូវបង្កើតឲ្យមានដំណើរការបាន ដោយដីកាសម្រេចរបស់ប្រធានសាលាឧទ្ធរណ៍ តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយ កាលណាមានរឿងក្ដីណាមួយចោទជាបញ្ហាដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នា នៅចំពោះមុខសភាផ្សេងគ្នានៃសាលាឧទ្ធរណ៍តែមួយ ។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានសាលាឧទ្ធរណ៍ ។

សេចក្ដីសម្រេចរបស់សភារួមក្រុម អំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទច្បាប់ មានអំណាចបង្ខំឲ្យសភាទាំងអស់នៃសាលាឧទ្ធរណ៍គោរពតាម ។

កាលបើសភារួមក្រុមត្រូវបង្កើតឡើង សភានេះត្រូវមានសមាសភាពជាចៅក្រមយ៉ាងតិច ០៥ (ប្រាំ) រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ ។ សភារួមក្រុមស្ថិតក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍ ។

ប្រធានសាលាឧទ្ធរណ៍ចេញដីកាសម្រេច ដោយអនុលោមតាមសេចក្ដីសម្រេចរបស់សភារួមក្រុម ។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទច្បាប់ គឺជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា ។

# ផ្នែកទី ២
# មហាអយ្យការអមសាលាឧទ្ធរណ៍

## មាត្រា ៤៩.-

នៅអមសាលាឧទ្ធរណ៍មានមហាអយ្យការដែលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង

- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## មាត្រា ៥០.-

មុខងាររបស់មហាអយ្យការអមសាលាឧទ្ធរណ៍ ត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន ។

ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ស្ថិតក្នុងស្ថានភាពទំនេររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ ឲ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់មហាអយ្យការអមសាលាឧទ្ធរណ៍ រហូតដល់មានការតែងតាំងអគ្គព្រះរាជអាជ្ញាជាផ្លូវការ ។

## មាត្រា ៥១.-

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទៅក្នុងការងារផ្សេងៗនៃមហាអយ្យការនិងអង្គជំនុំជម្រះ ។

សេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មិនយល់ព្រមលើសេចក្ដីសន្និដ្ឋាននោះទេ ហើយតំណាងមហាអយ្យការដែលជាអ្នកធ្វើសេចក្ដីសន្និដ្ឋាននោះ នៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្ដងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ ។

ប៉ុន្តែ នៅពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរី តាមការដែលខ្លួនយល់ឃើញថា ស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងមហាអយ្យការដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការ ខុសពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់បាន ដោយអនុវត្តតាមបទប្បញ្ញត្តិស្ដីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

# ផ្នែកទី ៣
# អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍

## មាត្រា ៥២.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ គឺជាសេនាធិការឲ្យសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍លើៈ

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការសម្រាប់ជាជំនួយការបច្ចេកទេសដល់កម្មវិធីការងាររបស់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- ការងាររៀបចំគម្រោងថវិកាជូនប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដើម្បីពិនិត្យ និងសម្រេច
- ការអនុវត្តការងារថវិកាតាមគម្រោងដែលបានអនុម័ត
- រាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ការងារទំនាក់ទំនងសាធារណៈ
- ការងារបញ្ជូនសាលដីការបស់សាលាឧទ្ធរណ៍ជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំ និងបញ្ជូនរបាយការណ៍ ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌
- ការងារផ្សេងទៀតដែលប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ប្រគល់ឲ្យ
- អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត។

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍បែងចែកជានាយកដ្ឋាន ដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៥៣.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលសាលាឧទ្ធរណ៍ ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ។ អគ្គលេខាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិគ្រោះយោបល់ជាមួយប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

អាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ដើម្បីលើកសំណើជូននាយករដ្ឋមន្ត្រី ។ អគ្គលេខាធិការត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ។

អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការ ដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានថ្នាក់ក្រោមប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ អនុប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន និងអនុប្រធានការិយាល័យត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានទាំងអស់ដោយរួមទាំងអគ្គលេខាធិការផង ត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។

**មាត្រា ៥៤.-**

សន្និបាតរបស់សាលាឧទ្ធរណ៍នីមួយៗ ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍នោះ ដើម្បីបូកសរុបលទ្ធផលការងារកន្លងមក និងកំណត់ទិសដៅការងាររដ្ឋបាលរបស់សាលាឧទ្ធរណ៍សម្រាប់ឆ្នាំបន្ទាប់ទៀត ។ របាយការណ៍សន្និបាតរបស់សាលាឧទ្ធរណ៍ ត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌ ។

## ជំពូកទី ៤
## តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
## ផ្នែកទី ១
## តុលាការកំពូល
## អនុផ្នែកទី ១
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការកំពូល

**មាត្រា ៥៥.-**

តុលាការកំពូលមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ៥៦.-**

សមាសភាពតុលាការកំពូលរួមមាន៖

- ប្រធាន
- អនុប្រធាន
- ចៅក្រម
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅតុលាការកំពូល ។

**មាត្រា ៥៧.-**

តុលាការកំពូលមានសភាជំនាញ ដូចខាងក្រោម៖

- សភាព្រហ្មទណ្ឌ
- សភារដ្ឋប្បវេណី
- សភាពាណិជ្ជកម្ម
- សភាការងារ ។

ក្នុងករណីចាំបាច់ សភាជំនាញផ្សេងទៀតរបស់តុលាការកំពូល អាចត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

សភានីមួយៗ ចេញសេចក្តីសម្រេចរបស់ខ្លួនប្រកបដោយស្វ័យភាព ក្នុងនាមតុលាការកំពូល ។

**មាត្រា ៥៨.-**

សមាសភាពរបស់សភានីមួយៗរួមមាន៖

- ប្រធានសភា
- ចៅក្រម និង
- ក្រឡាបញ្ជី ។

ប្រធានសភានីមួយៗត្រូវបានចាត់តាំងដោយប្រធានតុលាការកំពូល ។ ចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាទាំងនេះ ត្រូវកំណត់ដោយប្រធានតុលាការកំពូល។

**មាត្រា ៥៩.-**

សភានីមួយៗនៃតុលាការកំពូលសម្រេចសេចក្តីដោយចៅក្រម ០៥(ប្រាំ)រូប ដែល ០១ (មួយ) រូបជាប្រធាន ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។

## មាត្រា ៦០.-

ប្រធានតុលាការកំពូល ចាត់វិធានការគ្រប់គ្រងជាចាំបាច់ក្នុងការប្រព្រឹត្តទៅនៃតុលាការកំពូល និងណែនាំសភាទាំងអស់របស់តុលាការកំពូលឲ្យអនុវត្តច្បាប់ ។

ប្រធានតុលាការកំពូលត្រូវចេញដីកាសម្រេចដើម្បី៖

- ចាត់តាំងអនុប្រធានតុលាការកំពូលណាម្នាក់ ឲ្យចាត់ចែងការងារជំនួសខ្លួនបានក្នុងករណីចាំបាច់
- ចាត់តាំងអនុប្រធានតុលាការកំពូល ឲ្យទទួលបន្ទុកធ្វើជាប្រធានសភានីមួយៗ ទៅតាមជំនាញ និងបទពិសោធន៍ការងារ ។ ក្នុងករណីខ្វះអនុប្រធាន ប្រធានតុលាការកំពូលអាចចាត់តាំងចៅក្រមណាម្នាក់ឲ្យធ្វើជាប្រធានសភាបាន ។

# អនុផ្នែកទី ២
# សមត្ថកិច្ច

## មាត្រា ៦១.-

តុលាការកំពូល មានសមត្ថកិច្ចដោះស្រាយរឿងក្តីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់របស់ច្បាប់ ។

## មាត្រា ៦២.-

សភាពេញអង្គត្រូវបង្កើតឲ្យមានដំណើរការ ដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល ដើម្បីជំនុំជម្រះ ជាអាទិ៍៖

- លើបណ្តឹងសាទុក្ខលើកទីពីរចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ស្របតាមនីតិវិធីជាធរមាន
- លើបណ្តឹងសើរើចំពោះសាលក្រម និងសាលដីកាស្ថាពរ ស្របតាមនីតិវិធីជាធរមាន ។

សភាពេញអង្គក៏អាចត្រូវបង្កើតឲ្យមានដំណើរការផងដែរ ដើម្បីជំនុំជម្រះលើបណ្តឹងសើរើ ឬបណ្តឹងជំនុំជម្រះសាជាថ្មី ក្នុងករណីដែលមានការស្នើសុំឲ្យមានការពិនិត្យ និងសម្រេចឡើងវិញចំពោះរឿងក្តីណាមួយ ពីព្រះមហាក្សត្រដែលជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

សភាពេញអង្គប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ។

សភាពេញអង្គនៃតុលាការកំពូល គឺជាអង្គជំនុំជម្រះដែលចេញសេចក្តីសម្រេចក្នុងនាមតុលាការកំពូល ។

កាលបើសភាពេញអង្គត្រូវបង្កើតឲ្យមានឡើង សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩ (ប្រាំបួន) រូប ដែលមានចៅក្រមជាតំណាងនៃសភាទាំងអស់របស់តុលាការកំពូល ។

សភាពេញអង្គស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## មាត្រា ៦៣.-

សភារួមក្រុមអាចត្រូវបង្កើតឲ្យមានដំណើរការបាន ដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល តាមគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ប្រធានសភាណាមួយកាលណាមានរឿងក្តីណាមួយចោទជាបញ្ហាដែលត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាច្រើន ឬប្រសិនបើបញ្ហានោះបានទទួលនូវដំណោះស្រាយខ្វែងគ្នា នៅចំពោះមុខសភាផ្សេងគ្នានៃតុលាការកំពូល ។ សភារួមក្រុមប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល ។

សេចក្តីសម្រេចរបស់សភារួមក្រុមអំពីសមត្ថកិច្ចរវាងសភាផ្សេងៗ និងវិវាទអំពីច្បាប់ មានអំណាចបង្ខំឲ្យសភាទាំងអស់នៃតុលាការកំពូល និងតុលាការថ្នាក់ក្រោមគោរពតាម ។

កាលបើសភារួមក្រុមត្រូវបង្កើតឲ្យមានឡើង សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩ (ប្រាំបួន) រូប ដែលបែងចែកស្មើគ្នារវាងចៅក្រមជាតំណាងនៃសភាពាក់ព័ន្ធ ។ សភារួមក្រុមស្ថិតក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល ។

ប្រធានតុលាការកំពូលចេញដីកាសម្រេច ដោយអនុលោមតាមសេចក្តីសម្រេចរបស់សភារួមក្រុម ។ ដីកាសម្រេចលើវិវាទសមត្ថកិច្ច និងវិវាទអំពីច្បាប់ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា ។

## មាត្រា ៦៤.-

សភាព្រហ្មទណ្ឌនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ចំពោះសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## មាត្រា ៦៥.-

សភារដ្ឋប្បវេណីនៃតុលាការកំពូលមានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ចំពោះសាលដីកា និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងរដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ព្រមទាំងលើបណ្តឹងសាទុក្ខចំពោះសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូង និងរឿងក្តីផ្សេងទៀតដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីជាធរមាន ។

## មាត្រា ៦៦.-

សភាពាណិជ្ជកម្មនៃតុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលដីកា និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងពាណិជ្ជកម្មរបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ។

## មាត្រា ៦៧.-

សភាការងារនៃតុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខចំពោះសាលដីកា និងបណ្តឹងជំទាស់ចំពោះដីកាសម្រេចក្នុងរឿងការងាររបស់សាលាឧទ្ធរណ៍ ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីការងារ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ២
## មហាអយ្យការអមតុលាការកំពូល

### មាត្រា ៦៨.-

មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចខាងក្រោម៖

- អគ្គព្រះរាជអាជ្ញា
- អគ្គព្រះរាជអាជ្ញារង
- ព្រះរាជអាជ្ញា
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅមហាអយ្យការអមតុលាការកំពូល ។

### មាត្រា ៦៩.-

មុខងាររបស់មហាអយ្យការអមតុលាការកំពូល ត្រូវបានប្រគល់ឲ្យអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមអនុវត្តមុខងារនេះ ក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

ក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមាន អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងមួយរូប ឬបើគ្មានអគ្គព្រះរាជអាជ្ញារងទេ អាចចាត់តាំងព្រះរាជអាជ្ញាណាម្នាក់ដើម្បីជំនួសខ្លួនបាន ។

ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលស្ថិតក្នុងស្ថានភាពទំនេររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងអគ្គព្រះរាជអាជ្ញារងណាម្នាក់ ឲ្យធ្វើជាអគ្គព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់មហាអយ្យការអមតុលាការកំពូល រហូតដល់មានការតែងតាំងអគ្គព្រះរាជអាជ្ញាជាផ្លូវការ ។

### មាត្រា ៧០.-

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានអំណាចគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល ។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចាត់តាំង និងបែងចែកដល់អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទៅក្នុងការងារផ្សេងៗនៃមហាអយ្យការ និងក្នុងអង្គជំនុំជម្រះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

សេចក្ដីសន្និដ្ឋានរបស់អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលត្រូវតែបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដើម្បីពិនិត្យនៅមុនពេលសវនាការ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលមិនយល់ព្រមលើសេចក្ដីសន្និដ្ឋាននោះទេ ហើយតំណាងមហាអយ្យការដែលជាអ្នកធ្វើសេចក្ដីសន្និដ្ឋាននោះ នៅតែមិនព្រមធ្វើតាម អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលអាចចាត់តាំងអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាផ្សេងទៀត ឬក៏ចាត់តាំងខ្លួនឯងតែម្ដងឲ្យធ្វើជាតំណាងមហាអយ្យការនៅក្នុងសវនាការ ។

ប៉ុន្តែ នៅពេលសវនាការ អគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមតុលាការកំពូលអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់បានដោយសេរី តាមការដែលខ្លួនយល់ឃើញថាស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន ។ គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងមហាអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការ ខុសពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ ។

## ផ្នែកទី ៣
## អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល

### មាត្រា ៧១.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល គឺជាសេនាធិការឲ្យតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូលលើ៖

- ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ
- ការងារគ្រប់គ្រងរដ្ឋបាលតុលាការសម្រាប់ជាជំនួយការបច្ចេកទេសដល់កម្មវិធីការងាររបស់តុលាការ
- ការងាររៀបចំគម្រោងថវិកាជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលដើម្បីពិនិត្យ និងសម្រេច
- របាយការណ៍អំពីការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុជាប្រចាំជូនប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- ការងារទំនាក់ទំនងសាធារណៈ
- ការងារបញ្ជូនសាលដីការបស់តុលាការកំពូលជូនទៅក្រសួងយុត្តិធម៌ឲ្យបានទៀងទាត់
- រៀបចំ និងបញ្ជូនរបាយការណ៍ ការងារបុគ្គលិក រដ្ឋបាល និងហិរញ្ញវត្ថុ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនទៅក្រសួងយុត្តិធម៌

- ការងារផ្សេងទៀតដែលប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលប្រគល់ឲ្យ
- អនុវត្តការងារផ្សេងទៀតតាមការកំណត់នៃបទដ្ឋានគតិយុត្ត ។

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូលបែងចែកជានាយកដ្ឋាន ដែលដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៧២.-

អគ្គលេខាធិការដ្ឋានរដ្ឋបាលតុលាការកំពូល ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ ។

អគ្គលេខាធិការ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីលើកសំណើជូននាយករដ្ឋមន្ត្រី ។ អគ្គលេខាធិការត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុយ៉ាងតិចចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ។

អគ្គលេខាធិការរង និងប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។ អគ្គលេខាធិការរង និងប្រធាននាយកដ្ឋាន ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៥ (ប្រាំ) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានថ្នាក់ក្រោមប្រធាននាយកដ្ឋាន ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ អនុប្រធាននាយកដ្ឋាន ព្រមទាំងប្រធាន និងអនុប្រធានការិយាល័យ ត្រូវជ្រើសរើសចេញពីមន្ត្រីរាជការដែលមានបទពិសោធន៍បម្រើការងារក្នុងជំនាញច្បាប់ រដ្ឋបាល ឬហិរញ្ញវត្ថុ យ៉ាងតិចចំនួន ០៣ (បី) ឆ្នាំ ។

មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋានទាំងអស់ដោយរួមទាំងអគ្គលេខាធិការផង ត្រូវមានក្របខណ្ឌរបស់ខ្លួននៅក្រសួងយុត្តិធម៌ ។

## មាត្រា ៧៣.-

សន្និបាតរបស់តុលាការកំពូល ត្រូវប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ដើម្បីបូកសរុបលទ្ធផលការងារកន្លងមក និង

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

កំណត់ទិសដៅការងាររដ្ឋបាលរបស់តុលាការកំពូលសម្រាប់ឆ្នាំបន្ទាប់ទៀត ។ របាយការណ៍សន្និបាតរបស់តុលាការកំពូល ត្រូវបញ្ជូនទៅក្រសួងយុត្តិធម៌ ។

## ជំពូកទី ៥
## វិសមិតភាព

### មាត្រា ៧៤.-

មុខងារធ្វើបណ្តឹងអាជ្ញា មុខងារស៊ើបសួរ និងមុខងារជំនុំជម្រះ ត្រូវបែងចែកដាច់ពីគ្នា ។ ចៅក្រមណាម្នាក់ដែលបានទទួលបន្ទុកចាត់ការរឿងក្តីណាមួយក្នុងឋានៈជាតំណាងអយ្យការ ឬជាចៅក្រមស៊ើបសួររួចហើយមិនអាចជំនុំជម្រះ ឬចូលរួមជំនុំជម្រះរឿងក្តីដែលខ្លួនបានទទួលចាត់ការនោះឡើយ បើពុំដូច្នោះទេ សាលក្រម ឬសាលដីកានឹងត្រូវទុកជាមោឃៈ ។

### មាត្រា ៧៥.-

ចៅក្រមមិនអាចចូលរួមជំនុំជម្រះរឿងក្តីតែមួយជាមួយគ្នានឹងចៅក្រមម្នាក់ ឬច្រើននាក់ដែលជាសហព័ទ្ធ ឬញាតិលោហិត រហូតដល់ថ្នាក់ទី ៤ (បួន) រាប់ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផងទោះក្នុងឋានៈជាចៅក្រមជំនុំជម្រះក្តី ឬជាតំណាងអយ្យការក្តី ។ គោលការណ៍នេះត្រូវអនុវត្តដូចគ្នាផងដែរសម្រាប់ចៅក្រមនៅសាលាជម្រះក្តីជាន់ខ្ពស់ ចំពោះរឿងក្តីដែលត្រូវបានជំនុំជម្រះដោយចៅក្រមនៅសាលាជម្រះក្តីជាន់ទាបដែលជាសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី ៤ (បួន) រាប់ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ។

### មាត្រា ៧៦.-

ចៅក្រមទាំងឡាយដែលមានសហព័ទ្ធ ឬញាតិលោហិត រហូតដល់ថ្នាក់ទី៤ (បួន) រាប់ ទាំងថ្នាក់ទី ៤ (បួន) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ធ្វើជាមេធាវីឲ្យភាគីម្ខាងនៃរឿងក្តីណាមួយ មិនអាចចូលរួមជំនុំជម្រះរឿងក្តីនោះបានឡើយ ។

### មាត្រា ៧៧.-

ចៅក្រមមិនអាចចូលរួមជំនុំជម្រះរឿងក្តីណាមួយ ដែលមានភាគីម្ខាងជាសហព័ទ្ធ ឬញាតិលោហិតរហូតដល់ថ្នាក់ទី ៦ (ប្រាំមួយ) រាប់ទាំងថ្នាក់ទី ៦ (ប្រាំមួយ) នេះផង ឬញាតិពន្ធ រហូតដល់ថ្នាក់ទី ៣ (បី) រាប់ទាំងថ្នាក់ទី ៣ (បី) នេះផង ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៧៨.-**

លើកលែងតែមានបទប្បញ្ញត្តិស្តីពីនីតិវិធីចែងផ្សេងពីនេះ ភាគីទាំងឡាយនៅក្នុងរឿងក្តី និងបុគ្គលដែលមានប្រយោជន៍ក្នុងរឿងក្តី ដោយរួមទាំងតំណាងអយ្យការផង អាចប្តឹងសុំមោឃកម្មចំពោះសាលក្រម ឬសាលដីការបស់តុលាការ ដោយហេតុបំពានវិធានស្តីពីវិសមិតភាពដូចមានចែងក្នុងមាត្រា ៧៤ មាត្រា ៧៥ មាត្រា ៧៦ និងមាត្រា ៧៧ ខាងលើ ។

បណ្តឹងសុំមោឃកម្មនេះ អាចធ្វើបានគ្រប់ពេលវេលា នៅចំពោះមុខតុលាការ នៅក្នុងនីតិវិធីឧបាស្រ័យដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីជាធរមាន ។ បើទោះបីជាសាលក្រមឬសាលដីកានោះបានចូលស្ថាពរហើយក៏ដោយ ក៏បណ្តឹងសុំមោឃកម្ម នៅតែអាចធ្វើឡើងបានដដែលក្នុងអំឡុងពេល ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃបានដឹងអំពីមូលហេតុដូចមានចែងក្នុងមាត្រា ៧៤ មាត្រា ៧៥ មាត្រា ៧៦ និងមាត្រា ៧៧ ខាងលើក្រោយពេលសាលក្រម ឬសាលដីកាបានចូលជាស្ថាពរ ។ ក្នុងករណីចុងក្រោយនេះ បណ្តឹងសុំមោឃកម្ម ត្រូវដាក់នៅសាលាជម្រះក្តីដែលបានចេញសាលក្រម ឬសាលដីកាស្ថាពរ ប៉ុន្តែ ត្រូវមានសមាសភាពចៅក្រមជំនុំជម្រះផ្សេងដើម្បីពិនិត្យ និងសម្រេចអំពីមោឃកម្មនៃសាលក្រម ឬសាលដីកាស្ថាពរនោះ និងអនុវត្តនីតិវិធីបន្តស្របតាមបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ៦
## ថវិកាសាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តី

**មាត្រា ៧៩.-**

សាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការ ដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌ ។

ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ជាអាណាប័កផ្ទេរសិទ្ធិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ការគ្រប់គ្រង និងការចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីដូចបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៨០.-**

សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ ព្រមទាំងអង្គការអយ្យការនៅអមសាលាជម្រះក្តីទាំងនេះ ដែលត្រូវបានបង្កើតឡើង នៅមុនពេលច្បាប់នេះចូលជាធរមាន ត្រូវបន្តដំណើរការរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨១.-**

បទប្បញ្ញត្តិពីមុនពាក់ព័ន្ធនឹងតុលាការយោធា និងអយ្យការអមតុលាការយោធា ព្រមទាំងបទប្បញ្ញត្តិស្តីពីសមត្ថកិច្ច និងនីតិវិធី ដែលអនុវត្តសម្រាប់ដំណើរការរឿងក្តីបទល្មើសយោធា ត្រូវបន្តមានអានុភាពអនុវត្តក្រោយច្បាប់នេះចូលជាធរមាន រហូតដល់មានបទប្បញ្ញត្តិថ្មីមកជំនួស ។

**មាត្រា ៨២.-**

នៅពេលរង់ចាំការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍ផ្សេងទៀត សាលាឧទ្ធរណ៍បច្ចុប្បន្នដែលមានទីតាំងនៅរាជធានីភ្នំពេញ មានសមត្ថកិច្ចដែនដីលាតសន្ធឹងលើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨៣.-**

ការដាក់ឲ្យដំណើរការតុលាការជំនាញនានារបស់សាលាដំបូងដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៨៤.-**

ក្នុងករណីដែលសាលាដំបូងនៃខេត្តណាមួយមិនទាន់ត្រូវបានដាក់ឲ្យដំណើរការ ឬមិនអាចដាក់ឲ្យដំណើរការបាន សមត្ថកិច្ចជំនុំជម្រះរឿងក្តីទាំងឡាយនៅក្នុងខេត្តនោះ ត្រូវប្រគល់ទៅឲ្យសាលាដំបូងណាមួយដោយព្រះរាជក្រឹត្យ ។

**មាត្រា ៨៥.-**

កាលបើសភាពាណិជ្ជកម្ម និងសភាការងារនៃសាលាជម្រះក្តីជាន់ខ្ពស់ មិនអាចដំណើរការបានដោយមូលហេតុខ្វះចៅក្រម ការជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីការងារ គឺជាសមត្ថកិច្ចនៃសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់ ។ កិច្ចការទាំងនេះ ត្រូវចាត់ចែងដោយប្រធានសាលាជម្រះក្តីជាន់ខ្ពស់ ដែលសភាជំនាញនោះស្ថិតនៅ ។

កាលបើសភាជំនាញណាមួយខាងលើមានដំណើរការស្របតាមច្បាប់នេះ សភាជំនាញផ្សេងទៀតត្រូវផ្ទេររឿងក្តីដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន ហើយមិនទាន់ចាត់ការ ទៅសភាជំនាញដែលមានសមត្ថកិច្ចវិញ ។

**មាត្រា ៨៦.-**

ក្នុងករណីដែលមិនទាន់មានចៅក្រមគ្រប់គ្រាន់ ចៅក្រមស៊ើបសួរអាចបំពេញមុខងារជាចៅក្រមជំនុំជម្រះក្តីបាន ប៉ុន្តែ មិនអាចជំនុំជម្រះរឿងក្តីដែលខ្លួនស៊ើបសួរបានឡើយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា ៨៧.-

ក្នុងករណីមិនទាន់មានសាលាជម្រះក្តីរដ្ឋបាល សមត្ថកិច្ចជំនុំជម្រះរឿងក្តីរដ្ឋបាលត្រូវប្រគល់ឲ្យតុលាការរដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ទាប និងសភារដ្ឋប្បវេណីនៃសាលាជម្រះក្តីជាន់ខ្ពស់ ។

## មាត្រា ៨៨.-

នៅពេលដែលមិនទាន់មានទីប្រឹក្សាពាណិជ្ជកម្ម ឬទីប្រឹក្សាការងារ សមាសភាពជំនុំជម្រះរឿងក្តីពាណិជ្ជកម្ម និងរឿងក្តីការងារ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី ។

## មាត្រា ៨៩.-

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីពាណិជ្ជកម្ម ការជំនុំជម្រះរឿងក្តីពាណិជ្ជកម្មត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីការងារការជំនុំជម្រះរឿងក្តីការងារ ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

នៅពេលដែលមិនទាន់មានបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋបាល ការជំនុំជម្រះរឿងក្តីរដ្ឋបាលត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណី និងបទប្បញ្ញត្តិច្បាប់ផ្សេងៗ ទៀតជាធរមាន ។

## មាត្រា ៩០.-

ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំដំបូងបន្ទាប់ពីច្បាប់នេះចូលជាធរមាន ការតែងតាំងថ្នាក់ដឹកនាំនៃអង្គភាពរដ្ឋបាលរបស់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ អាចអនុវត្តបានយោងទៅតាមលក្ខខណ្ឌគុណវុឌ្ឍិជាក់ស្តែង ។

នាយកក្រឡាបញ្ជីនៃសាលាដំបូង អាចត្រូវបានតែងតាំងជាប្រធាន ឬអនុប្រធាននៃលេខាធិការដ្ឋានរដ្ឋបាលនៃសាលាដំបូងដែលខ្លួនកំពុងបំពេញការងារនោះបាន ។

នាយកក្រឡាបញ្ជីនៃសាលាជម្រះក្តីជាន់ខ្ពស់ អាចត្រូវបានតែងតាំងជាអគ្គលេខាធិការ ឬអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរដ្ឋបាលនៃសាលាជម្រះក្តីជាន់ខ្ពស់ ដែលខ្លួនកំពុងបំពេញការងារនោះបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៩១.-**

បទប្បញ្ញត្តិស្ដីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ និងច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជាដែលប្រកាសឲ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ហើយត្រូវជំនួសដោយច្បាប់នេះ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម/០៧១៤/០១៦

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្សវឌ្ឍនា**

លេខ: ៩០៣ ស.ណ

**សំណៅចេញមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សូយ សុខា**

ថតចម្លង
នាយកដ្ឋាន.រដ្ឋបាល.

# ព្រះរាជក្រម

នស/រកម/០៤១០/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នត្តយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១០៨/០០១/២០១០ ក.ធ.ច ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

# ស្ដីពី

# អស្សាមិករណ៍

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.—**

ច្បាប់នេះ មានគោលដៅកំណត់ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និង សំណងឱ្យបានសមរម្យ និង យុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្ដារ និង គម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើឱ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.—**

ច្បាប់នេះ មានគោលបំណងជាអាទិ៍ :

- ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និង យុត្តិធម៌
- ធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌
- បម្រើផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ
- ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

**មាត្រា ៣.—**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការធ្វើអស្សាមិករណ៍ដែលមានពាក់ព័ន្ធទៅនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះ មិនគ្របដណ្តប់លើកិច្ចព្រមព្រៀង ឬ អនុស្សារណៈ ស្តីពីការគាំពារវិនិយោគរវាងរាជរដ្ឋាភិបាល និង ប្រទេសជាដៃគូដែលមានចែងពីអស្សាមិករណ៍ទេ ។ ក្នុងករណីដែលពុំមានកិច្ចព្រមព្រៀងនេះទេ ឬ ក្នុងករណីដែលកិច្ចព្រមព្រៀង ឬ អនុស្សារណៈពុំមានចែងពីអស្សាមិករណ៍ គឺត្រូវស្ថិតនៅក្រោមអានុភាពនៃច្បាប់នេះ ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានដូចតទៅ :

**អស្សាមិករណ៍** សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬ សិទ្ធិប្រត្យក្ស លើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន ដី សំណង់ និង ដំណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្ថារ និង ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និង យុត្តិធម៌ ។

**ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ** សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន កម្មសិទ្ធិករ ភោគី និង អ្នកមានសិទ្ធិទាំងឡាយនៅលើទីតាំងដីដែលជាអ្នកទទួលរងនូវផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍ ។

**ផលប្រយោជន៍សាធារណៈ ឬ ទូទៅ** សំដៅដល់ការប្រើប្រាស់ដី ឬ ទ្រព្យសម្បត្តិ ដោយសាធារណជនទូទៅ ឬ ដោយទីភ្នាក់ងារ ឬ ស្ថាប័នរដ្ឋ ឬ សាធារណៈ ។

**តម្រូវការនៃផលប្រយោជន៍ជាតិ** សំដៅដល់សកម្មភាព ឬ គម្រោងមានជាអាទិ៍ :

- ការសាងសង់ ស្តារ ថែទាំ ឬ ពង្រីក សំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬ ការងារសន្តិសុខ

- ការកាន់កាប់ដី ឬ ទ្រព្យសម្បត្តិ ដើម្បីអនុវត្តជាក់ស្តែងនយោបាយការពារបូរណភាពទឹកដី ។

**អ្នកអនុវត្តគម្រោង** សំដៅដល់រដ្ឋ សហគ្រាស និង គ្រឹះស្ថានសាធារណៈ អ្នកម៉ៅការ ឬវិនិយោគិន ។

**ភតិកៈ** សំដៅដល់ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និង សិទ្ធិប្រើប្រាស់លើអចលនវត្ថុ ពីម្ចាស់អចលនវត្ថុ ។

**បុគ្គលដែលធ្វើការរារាំង** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនទាំងឡាយណាដែលជាមេក្លោង អ្នកសមគំនិត អ្នកញុះញង់ ដែលធ្វើសកម្មភាពដោយផ្ទាល់ ឬ ដោយប្រយោល ដោយគំនិតទុច្ចរិតក្នុងគោលដៅធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តសេចក្តីសម្រេចអស្សាមិករណ៍ ។



Ksl

**មាត្រា ៥.-**

គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ មានជាអាទិ៍ :

ក- ការសាងសង់ ឬ ពង្រីកផ្លូវអយស្ម័យយាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយរួមទាំងរចនាសម្ព័ន្ធ និង ឧបករណ៍ ។

ខ- ការសាងសង់ ឬ ពង្រីកស្ថានីយថាមពល រចនាសម្ព័ន្ធ ឧបករណ៍ និង ខ្សែសម្រាប់ការបញ្ជូន និង ចែកចាយថាមពលអគ្គិសនី ។

គ- ការសាងសង់ ឬ ពង្រីកអគារ និង ឧបករណ៍សម្រាប់ប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ប្រព័ន្ធព័ត៌មានវិទ្យា ។

ឃ- ការសាងសង់ ឬ ពង្រីកផ្លូវ ថ្នាក្រុង ចំណតយានយន្ត ទីផ្សារ សួនច្បារ និង ទីលានសាធារណៈ ។

ង- ការសាងសង់ ឬ ពង្រីកប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធលូទឹកកខ្វក់ និង កន្លែងបម្រើសេវាសាធារណៈផ្សេងទៀត ។

ច- ការសាងសង់ ឬ ពង្រីកអគារ សម្រាប់អប់រំបណ្តុះបណ្តាលវិទ្យាសាស្ត្រ វប្បធម៌ ថែរក្សាសុខភាព សន្តិសុខសង្គម និង កីឡាដ្ឋានសម្រាប់សម្តែងជូនជាសាធារណៈ ។

ឆ- ការសាងសង់ ឬ ពង្រីកកន្លែងចម្រាញ់ និង កន្លែងប្រព្រឹត្តកម្ម សំណង់ ឧបករណ៍ សម្រាប់ការការពារធម្មជាតិ និង បរិស្ថាន ។

ជ- ការសាងសង់ ឬ ពង្រីកអគារ និង ឧបករណ៍សម្រាប់ស្រាវជ្រាវ និង សម្រាប់ការធ្វើអាជីវកម្មរ៉ែ និង ធនធានធម្មជាតិផ្សេងទៀត ។

ឈ- ការសាងសង់ ឬ ពង្រីកបណ្តាញឧស្ម័ន បណ្តាញបំពង់ប្រេងឥន្ធនៈ រោងចក្រចម្រាញ់ប្រេង រោងចក្របូមប្រេង និង បណ្តាញដទៃទៀត ។

ញ- ការសាងសង់ ឬ ពង្រីកអគារតាំងទីលំនៅដែលបណ្តាលមកពីការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីធម្មជាតិមាន រញ្ជួយផែនដី ទឹកជំនន់ អគ្គិភ័យ និង គ្រោះបាក់ដីជាដើម និង ការរៀបចំសម្រាប់ការតាំងទីលំនៅឡើងវិញ ។

ដ- ការសាងសង់ ឬ ពង្រីកអគារសម្រាប់ការការពារ និង ការគាំពារប្រជាជន ។

ឋ- ការសាងសង់ ឬ ពង្រីកទីកន្លែងឆ្លងកាត់ព្រំដែន ។

ឌ- ការកសាង ពង្រីក ឬ ការរៀបចំសំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬ ការពារសន្តិសុខ ។

ល- ការបង្កើតឡើងថ្មីនូវតំបន់ការពារធនធានធម្មជាតិ ព្រៃឈើ បេតិកភ័ណ្ឌវប្បធម៌បុរាណវិទ្យា ឬ ការពារបរិស្ថាន ។

ឈ- ការអនុវត្តតាមតម្រូវការរបស់ជាតិ តាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី ២
## គោលការណ៍ទូទៅ

**មាត្រា ៦.-**

អស្សាមិករណ៍ អាចធ្វើលើអចលនវត្ថុមួយផ្នែកឬទាំងស្រុង ឬ លើសិទ្ធិប្រត្យក្សនៃអចលនវត្ថុ ។

**មាត្រា ៧.-**

មានតែរដ្ឋទេដែលជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ។

អស្សាមិករណ៍អាចអនុវត្តទៅបាន លុះត្រាតែយកទៅអនុវត្តគម្រោង ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

**មាត្រា ៨.-**

រដ្ឋត្រូវតែទទួលទិញយកនូវចំណែកនៃអចលនវត្ថុ ដែលនៅសេសសល់ពីអស្សាមិករណ៍ ដោយថ្លៃសមរម្យ និង យុត្តិធម៌ តាមសំណើរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដែលពុំអាចរស់នៅក្បែរគម្រោងបាន ឬ ពុំអាចសាងសង់លំនៅឋានបាន ឬ ពុំអាចប្រកបអាជីវកម្មអ្វីផ្សេងទៀតបាន ។

**មាត្រា ៩.-**

អចលនវត្ថុដែលត្រូវបានដកហូតនេះ ត្រូវប្រើប្រាស់សម្រាប់តែក្នុងគោលដៅដែលបានគ្រោងទុកនៅក្នុងប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដើម្បីប្រយោជន៍សាធារណៈ ឬ តម្រូវការនៃផលប្រយោជន៍ជាតិប៉ុណ្ណោះ និង មិនអាចឱ្យទុកនៅចោលទំនេរដោយគ្មានហេតុផលសមស្រប ឬ ផ្ទេរឱ្យឯកជនណាម្នាក់ក្នុងគោលដៅបម្រើផលប្រយោជន៍ឯកជនបានឡើយ ។

អចលនវត្ថុដែលនៅសល់ពីតម្រូវការប្រើប្រាស់ ត្រូវផ្ដល់អាទិភាពលក់ជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ តាមអត្រាតម្លៃនៃការទូទាត់សំណង ។ ក្នុងករណីដែលម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិមិនព្រមទទួលយកអចលនវត្ថុដែលសល់ពីតម្រូវការប្រើប្រាស់វិញទេ ត្រូវរក្សាទុកអចលនវត្ថុនោះជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

**មាត្រា ១០.–**

ក្នុងករណីពិសេស និង បន្ទាន់ ដែលសុវត្ថិភាពសាធារណៈតម្រូវ ដូចជា ប្រយុទ្ធប្រឆាំងគ្រោះអគ្គិភ័យ ទឹកជំនន់ ភ្លើងឆេះព្រៃ រញ្ជួយដី សង្គ្រាមដែលប្រុងនឹងកើតឡើង ឬ ការវាយប្រហារដោយភេរវកម្ម និង ស្ថានភាពផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល រាជ-រដ្ឋាភិបាលអាចធ្វើការដកហូតអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុជាបណ្ដោះអាសន្នដោយមិនចាំបាច់ធ្វើការពិគ្រោះយោបល់ឡើយ ហើយត្រូវប្រគល់ជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិវិញនៅពេលចប់ការដកហូតនេះ ។

ក្នុងករណីបន្ទាន់ និង ចាំបាច់ដែលផលប្រយោជន៍ជាតិតម្រូវ រាជរដ្ឋាភិបាលមានអំណាចឆន្ទានុសិទ្ធិក្នុងការធ្វើអស្សាមិករណ៍ ដោយមិនចាំបាច់រៀបចំធ្វើការពិគ្រោះយោបល់តាមនីតិវិធី ដូចមានចែងក្នុងជំពូកទី ៤ នៃច្បាប់នេះទេ ។

**មាត្រា ១១.–**

មុននឹងដំណើរការការងារអស្សាមិករណ៍ រាជរដ្ឋាភិបាលត្រូវគ្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់គ្រាន់ ហើយត្រូវផ្ដល់ឥណទានឱ្យគ្រប់ចំនួន និង ទាន់ពេលវេលាជូនគណៈ-កម្មាធិការអស្សាមិករណ៍ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់យកទៅទូទាត់សំណងជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលរងនូវផលប៉ះពាល់ដោយសារអស្សាមិករណ៍ ។

## ជំពូកទី ៣
## យន្តការអស្សាមិករណ៍

**មាត្រា ១២.–**

គណៈកម្មាធិការអស្សាមិករណ៍មួយត្រូវបានបង្កើតឡើង និង ដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៣.–**

អនុគណៈកម្មាធិការអស្សាមិករណ៍ ជាសេនាធិការនៃគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបានបង្កើតឡើង និង ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និង មានតំណាងមន្ទីរជំនាញ អាជ្ញាធរពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

**មាត្រា ១៤.–**

គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានបង្កើតឡើង និង ដឹកនាំដោយតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង មានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ជំពូកទី ៤
## នីតិវិធីនៃអស្សាមិករណ៍
### ផ្នែកទី ១
### នីតិវិធីមុនអស្សាមិករណ៍

**មាត្រា ១៥.–**

អស្សាមិករណ៍ ត្រូវធ្វើឡើងដោយផ្អែកលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និង មានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួង ស្ថាប័នសាមី ។

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវរៀបចំសំណើស្តីពីគម្រោងអស្សាមិករណ៍ដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និង សម្រេច ។

**មាត្រា១៦.-**

មុននឹងធ្វើសំណើស្តីពីគម្រោងអស្សាមិករណ៍ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើការអង្កេតជាសាធារណៈ ដោយត្រូវកត់ត្រាភិនភាគឱ្យបានលម្អិតចំពោះរាល់សិទ្ធិរបស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ លើអចលនវត្ថុ និង ទ្រព្យសម្បត្តិផ្សេងៗទៀតដែលមានជាប់ពាក់ព័ន្ធនឹងការផ្តល់សំណង ព្រមទាំងត្រូវកត់ត្រានូវរាល់បញ្ហាពាក់ព័ន្ធ ។

ក្នុងការធ្វើការអង្កេតនេះ គណៈកម្មាធិការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និង តំណាងភូមិ ឬ សហគមន៍ដែលរងនូវអស្សាមិករណ៍ ដើម្បីផ្តល់ពត៌មាន ជាក់លាក់ ច្បាស់លាស់ និង ទទួលបាននូវមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

ដើម្បីកំណត់ពេលវេលាដកហូត ឬ ទីកន្លែងដែលផ្តល់ថ្មី ឬ សំណង គណៈកម្មាធិការអស្សាមិករណ៍ ត្រូវសាកសួរគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យបានគ្រប់ជ្រុងជ្រោយ អំពីបញ្ហាអចលនវត្ថុ ដែលពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានាជាក់ជូន និង សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា១៧.-**

ផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល គណៈកម្មាធិការអស្សាមិករណ៍ត្រូវចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលក្នុងនោះត្រូវជម្រាបដល់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិឱ្យបានដឹងអំពីអចលនវត្ថុដែលជាកម្មវត្ថុនៃការដកហូតនោះ និង ត្រូវចែងអំពីគោលបំណង នៃការដកហូតកម្មសិទ្ធិ និង/ ឬ សិទ្ធិលើអចលនវត្ថុឱ្យបានច្បាស់លាស់ ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម :

ក- កំណត់អំពីកម្មវត្ថុនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ទីតាំងគម្រោង និង រយៈពេលសម្រាប់អនុវត្តគម្រោង និង អាជ្ញាធរមានសមត្ថកិច្ច ដែលមានសិទ្ធិរៀបចំធ្វើការដកហូតកម្មសិទ្ធិ និង/ ឬ សិទ្ធិ ឬ ទ្រព្យសម្បត្តិឯកជន

ខ- កំណត់អំពីសំណងសមរម្យ និង យុត្តិធម៌

គ- កំណត់រយៈពេលនៃបណ្តឹងតវ៉ា

ឃ- ផ្ញើសេចក្តីប្រកាសទៅដល់គ្រប់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិដោយភ្ជាប់នូវលិខិតចតចម្លងនៃច្បាប់នេះ

ង- ដាក់ស្លាកសម្គាល់ថា អចលនវត្ថុនេះជាកម្មវត្ថុត្រូវដកហូតសម្រាប់បម្រើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ

ច- ផ្សព្វផ្សាយសេចក្តីប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយ

ឆ- បិទផ្សាយសេចក្តីប្រកាសនៅសាលាឃុំ សង្កាត់ ពាក់ព័ន្ធនឹងទីតាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ហើយសេចក្តីប្រកាសនេះត្រូវផ្សព្វផ្សាយជូនដល់ប្រជាជនដែលមានអចលនវត្ថុពាក់ព័ន្ធដោយមេភូមិ ។

**មាត្រា ១៨.-**

បន្ទាប់ពីទទួលបាននូវសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិអាចធ្វើបណ្តឹងសុំឱ្យមានការអង្កេត ដើម្បីឱ្យដឹងថាជាតម្រូវការមួយចាំបាច់ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិពិតប្រាកដមែន ឬ ក៏អាចបង្វែរទីតាំងគម្រោងទៅកន្លែងណាផ្សេងវិញបាន ។ បណ្តឹងនេះអាចធ្វើឡើងតាមរយៈមេធាវី ឬ តំណាងរបស់ខ្លួន ។

បណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបានទទួលសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ជូនចំពោះគណៈ-កម្មាធិការដោះស្រាយបណ្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។ ខ្លឹមសារសំខាន់ៗនៃបណ្តឹងមាន ជាអាទិ៍ :

- ឈ្មោះម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាសយដ្ឋាន និង លេខទូរស័ព្ទ
- មូលហេតុនៃការធ្វើបណ្តឹង
- ការរៀបរាប់អំពីលក្ខណៈស្របច្បាប់នៃដីនោះ
- ផលប្រយោជន៍របស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិនៅលើដីដែលត្រូវដកហូតនោះ ។

ប៉ុន្តែម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិមិនអាចធ្វើពាក្យបណ្តឹងតវ៉ាសុំឱ្យមានធ្វើការអង្កេតបានទេ ចំពោះតម្រូវការសម្រាប់កិច្ចអភិវឌ្ឍផ្លូវជាតិធំៗ ស្ពាន ផ្លូវរទេះភ្លើង ការតភ្ជាប់ការចែកចាយបណ្តាញទឹក ភ្លើង បំពង់បង្ហូរប្រេងកាត បំពង់បង្ហូរទឹកកខ្វក់ ខ្សែបណ្តាញ ឬលូមេបង្ហូរទឹក ប្រព័ន្ធធារាសាស្ត្រ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានា និង សុំការសម្រេចពីរាជរដ្ឋាភិបាល ។

## ផ្នែកទី ២
## កិច្ចដំណើរការអស្សាមិករណ៍

**មាត្រា ១៩.-**

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ អាចធ្វើទៅបានលុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និង យុត្តិធម៌ តាមគោលការណ៍ និង នីតិវិធីនៃការទូទាត់សំណងដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ៤ នៃច្បាប់នេះ ។

ការដកហូតនៅតែអាចប្រព្រឹត្តទៅបាន ទោះបីទំនាស់នៅមិនទាន់បានដោះស្រាយរួចរាល់ហើយក្តី ។ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលបានទទួលប្រាក់សំណងតាមការកំណត់របស់គណៈកម្មាធិការអស្សាមិករណ៍ នៅតែមានសិទ្ធិបន្តការប្តឹងរបស់ខ្លួនទៅតាមនីតិវិធីនៃការជំទាស់ និង ការដោះស្រាយទំនាស់ដូចបានកំណត់ក្នុងមាត្រា ៣៤ ជំពូកទី ៦ នៃច្បាប់នេះ ។

**មាត្រា ២០.-**

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដទៃទៀត ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ ។ សេចក្តីសម្រេចអស្សាមិករណ៍ ត្រូវកំណត់ជាអាទិ៍ :

- កម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដែលត្រូវដកហូត

- សំណងដែលត្រូវទូទាត់

- កាលបរិច្ឆេទដែលតម្រូវឱ្យម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិធ្វើការរុះរើ ចាកចេញពីទីតាំង និង ធ្វើការប្រគល់អចលនវត្ថុ ជូនគណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២១.-**

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចអស្សាមិករណ៍ និង ត្រូវផ្ដល់សំណងគ្រប់ចំនួនដល់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ មុននឹងធ្វើអស្សាមិករណ៍ ។

## ផ្នែកទី ៣
## ការទូទាត់សំណងនៃអស្សាមិករណ៍

**មាត្រា ២២.-**

ប្រាក់សំណងដែលត្រូវផ្ដល់ឱ្យទៅម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ត្រូវគិតតាមថ្លៃទីផ្សារ ឬ ថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍ ។

ថ្លៃទីផ្សារ ឬ ថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២៣.-**

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ មានសិទ្ធិទទួលបាននូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្ដែង ដែលមានចាប់ពីថ្ងៃចេញសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍ ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបាននូវសំណងសមរម្យ និង យុត្តិធម៌ ។

**មាត្រា ២៤.-**

សំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬ ជាសិទ្ធិជំនួសទៅតាមភាពជាក់ស្ដែង ដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ និង ពីគណៈកម្មាធិការអស្សាមិករណ៍ ។

បែបបទ និង នីតិវិធីនៃការទូទាត់សំណង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២៥.-**

ប្រាក់សំណងត្រូវគិតតាមតម្លៃសំណងសរុប ដកចំនួនទឹកប្រាក់បន្ទុកពន្ធប្រថាប់ត្រា និង/ ឬ ពន្ធលើដីធ្លីមិនប្រើប្រាស់ដែលកន្លងមកមិនទាន់បានបង់ជូនរដ្ឋ ហើយគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបង់ប្រាក់ពន្ធកាត់ទុកទាំងនោះចូលថវិកាជាតិ តាមនីតិវិធីជាធរមាន ។

**មាត្រា ២៦.-**

ប្រាក់សំណងចំពោះកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ មិនត្រូវបានគិតដល់ការប្រែប្រួលនៃតម្លៃដែលកើតមានឡើង ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍នោះឡើយ ដោយការប្រែប្រួលទាំងនោះអាចពាក់ព័ន្ធដល់ការផ្លាស់ប្តូរវិធានការបម្រុងផ្ទៃដីទុកដែលមានក្នុងផែនការនគរូបនីយកម្ម ដែលកំណត់តំបន់ប្រើប្រាស់ដីធ្លី ឬ ផែនការប្រើប្រាស់ដីធ្លីដែលបានអនុម័តត្រឹមត្រូវ ឬ ដោយការប្រែប្រួលនោះបណ្តាលមកពីសេចក្តីប្រកាស ស្តីពីគម្រោងអស្សាមិករណ៍ ។

**មាត្រា ២៧.-**

បន្ទាប់ពីទទួលបានប្រាក់សំណងគ្រប់ចំនួនរួចហើយ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ត្រូវទទួលខុសត្រូវក្នុងការថែរក្សា ស្នាក់អាស្រ័យ កាន់កាប់ និង ទទួលផលដែលលើសិទ្ធិ និង អចលនវត្ថុ រហូតដល់មានការទទួលយកអចលនវត្ថុទាំងនោះ ដោយគណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២៨.-**

គណៈកម្មាធិការអស្សាមិករណ៍អាចទទួលយកអចលនវត្ថុ ឬ សិទ្ធិលើអចលនវត្ថុនោះក្រោយពី :

- បានអនុវត្តតាមនីតិវិធី និង លក្ខខណ្ឌដូចមានចែងក្នុងផ្នែកទី ១ និង ផ្នែកទី ២ ជំពូកទី ៥ នៃច្បាប់នេះ

- ការផ្តល់ប្រាក់សំណងត្រូវបានអនុវត្តតាមគោលការណ៍ និង នីតិវិធីដូចមានចែងក្នុងផ្នែកទី៣ ជំពូកទី ៤ នៃច្បាប់នេះ ។

**មាត្រា ២៩.–**

ភតិកៈអចលនវត្ថុដែលមានកិច្ចសន្យាត្រឹមត្រូវ ត្រូវទទួលបាននូវសំណងសម្រាប់ការវិខាននានា ពាក់ព័ន្ធនឹងការដកហូតជាអាទិ៍ ការរុះរើសំណង់ សម្ភារៈ ការដឹកជញ្ជូនទៅកាន់ទីតាំងថ្មី ។

ចំពោះភតិកៈអចលនវត្ថុដែលកំពុងប្រកបអាជីវកម្ម ត្រូវមានសិទ្ធិទទួលបាននូវសំណងលើផលប៉ះពាល់ដល់អាជីវកម្មនិងការឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និង យុត្តិធម៌ លើតម្លៃដើមទុនដែលបានចំណាយជាក់ស្តែង សម្រាប់សកម្មភាពនៃការប្រកបរបរអាជីវកម្មនោះ ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

ចំពោះការដកហូតយកទីតាំងដែលកំពុងមានសកម្មភាពអាជីវកម្ម ម្ចាស់អចលនវត្ថុត្រូវមានសិទ្ធិទទួលបានសំណងឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និង យុត្តិធម៌ លើតម្លៃនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ជាក់ស្តែង ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

## ជំពូកទី ៥
## អន្តរកាលនៃការកាន់កាប់ និង គ្រប់គ្រងអចលនវត្ថុ

**មាត្រា ៣០.–**

ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិពុំអាចលក់ ឬ ផ្ទេរអចលនវត្ថុនោះឱ្យអ្នកដទៃបានឡើយ ។ លិខិតឯកសារនានា និង នីតិវិធីទាំងអស់ដែលផ្ទុយនឹងបទប្បញ្ញត្តិនេះ ត្រូវចាត់ទុកជាមោឃៈ ។

ចំពោះការប្រើប្រាស់ដី ឬ អចលនវត្ថុពាក់ព័ន្ធ ត្រូវរក្សាលក្ខណៈ និង ទំហំប្រើប្រាស់ដូចមាននៅពេលចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ហើយមិនត្រូវសាងសង់សំណង់នៅលើដីនោះថែមទៀតឡើយ ។ សកម្មភាពណាដែលផ្ទុយនឹងបញ្ញត្តិខាងលើនេះ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មិនត្រូវមានសិទ្ធិទទួលបានសំណងលើការសាងសង់សំណង់ថ្មីបន្ថែមនោះឡើយ ។

**មាត្រា ៣១.-**

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាចកាន់កាប់អចលនវត្ថុទាំងនោះបានត្រឹមរយៈពេល ១ ( មួយ ) ខែ បន្ទាប់ពីគណៈកម្មាធិការអស្សាមិករណ៍បានទូទាត់សំណងគ្រប់ចំនួនស្របតាមនីតិវិធី ដូចមានចែងនៅក្នុងជំពូកទី ៤ នៃច្បាប់នេះ លើកលែងតែមានការព្រមព្រៀង ឬ មានការអនុញ្ញាតផ្ទុយពីនេះ ។

ក្នុងករណីម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិពុំព្រមចាកចេញពីទីកន្លែងនោះ គណៈ-កម្មាធិការអស្សាមិករណ៍អាចស្នើសុំទៅស្ថាប័នមានសមត្ថកិច្ច ឬ អាជ្ញាធរសាធារណៈ ដើម្បីចាត់វិធានការ តម្រូវឱ្យជននោះចាកចេញពីទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ។

## ជំពូកទី ៦

## ការដោះស្រាយទំនាស់

**មាត្រា ៣២.-**

គណៈកម្មាធិការអស្សាមិករណ៍ និង គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា មានសមត្ថកិច្ចទទួលពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា ។

**មាត្រា ៣៣.-**

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលមិនយល់ស្របនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ អាចប្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ។

**មាត្រា ៣៤.-**

ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាចប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និង យុត្តិធម៌ ។

[illegible]បទ និង នីតិវិធីប្តឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៥.-**

មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀតស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៣៦.-**

បុគ្គលណាដែលធ្វើការរារាំងដល់ការអនុវត្តសេចក្តីសម្រេចអស្សាមិករណ៍ដោយគំនិតទុច្ចរិត ធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តគម្រោងដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ( មួយ ) ខែ ដល់ ១ ( មួយ ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ ( មួយសែន ) រៀល ដល់ ២.០០០.០០០ ( ពីរលាន ) រៀល ។

**មាត្រា ៣៧.-**

បុគ្គលណាដែលបានកាន់កាប់ ប្រើប្រាស់ដោយរំលោភបំពានលើទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន ។

# ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ROYAUME DU CAMBODGE

**មាត្រា ៣៩.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១០

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣ស/ល.១០០២.១០៤៩

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្ដេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

**លេខៈ១៨៥ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០១០

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ០៦ ន.ស.៩៤

# ព្រះរាជក្រម

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស

អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើនៅថ្ងៃទី២៤-៩-១៩៩៣
- បានទ្រង់យល់ព្រះរាជក្រិត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១-១១-១៩៩៣
- គណៈរដ្ឋមន្ត្រីបានយល់ព្រមផង

## ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នាថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃ ព្រះរាជាណាចក្រកម្ពុជា ដូចមានសេចក្តីតទៅនេះ ÷

# ច្បាប់

## ស្តីពី

## សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

## នៃព្រះរាជាណាចក្រកម្ពុជា

## ជំពូកទី ១

## បញ្ញត្តិទូទៅ

មាត្រា ១.-

អ្នករាជការក្របខ័ណ្ឌទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ក្រៅពីអ្នករាជការដែលស្ថិតនៅក្នុងក្រុមតុលាការ និងក្រុមនីតិបញ្ញត្តិដែលមានលក្ខណៈពិសេសនោះត្រូវស្ថិតនៅក្នុងសហវិធាននេះ ។

មាត្រា ២.-

ច្បាប់នេះអនុវត្តចំពោះអ្នករាជការនៃព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខ័ណ្ឌទាំងពួងដែលបានបង្កើតនិងរៀបចំឡើងតាមព្រះរាជក្រឹត្យ ហើយបានចូលធ្វើការនៅតាមក្រសួង ស្ថាប័ននានាដោយមានសិទ្ធិទទួលប្រាក់សោធននិវត្តន៍ ។

មាត្រា ៣.-

ក្របខ័ណ្ឌទាំងឡាយនៃអ្នករាជការត្រូវកំណត់ដោយលក្ខន្តិកៈដោយឡែកតាមព្រះរាជក្រឹត្យ។

មាត្រា ៤.-

ប្រភេទក្របខ័ណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សអ្នករាជការក្នុងព្រះរាជាណាចក្រ-កម្ពុជា ព្រមទាំងលក្ខន្តិកៈដោយឡែកនៃអង្គផ្សេងៗ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

### មាត្រា ៥

ការតែងតាំង ការតំឡើងថ្នាក់ ការផ្លាស់ប្តូរ ការដាក់ក្រៅតំណែង ឬការដាក់អោយនៅក្រៅក្របខ័ណ្ឌ ត្រូវសំរេចដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ។

ការបញ្ឈប់លែងអោយធ្វើការដោយបង្ខំ ការដាក់អោយចូលនិវត្តន៍មុនកំណត់ និងការហូតងារនៃអ្នករាជការក្របខ័ណ្ឌ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ស្របតាមលក្ខន្តិកៈដោយឡែកនៃអ្នករាជការនេះ ។

### មាត្រា ៦

អ្នករាជការម្នាក់ៗមានសិទ្ធិសុំមើលកំណត់ត្រា និងឯកសារផ្សេងៗដែលជាសំណុំរឿងផ្ទាល់ខ្លួន មុននឹងត្រូវទទួលទណ្ឌកម្មខាងវិន័យ ឬមុននឹងត្រូវផ្លាស់ដោយបង្ខំ ។ សិទ្ធិដែលនេះត្រូវបានអនុញ្ញាតអោយដល់អ្នករាជការណាដែលយឺតយូរមិនបានឡើងឋានន្តរស័ក្តិ ឬថ្នាក់តាមវេនអតីតភាព ។

### មាត្រា ៧

អ្នករាជការក្របខ័ណ្ឌអាចដាក់អោយទៅបំរើការ ឬបំពេញមុខងារក្រៅពីក្របខ័ណ្ឌដើមរបស់ខ្លួនបាន ក្នុងករណីចាំបាច់និងមានការយល់ព្រមពីសាមីខ្លួន ។

អ្នករាជការក្របខ័ណ្ឌមានសិទ្ធិសុំផ្លាស់កន្លែងធ្វើការទៅតាមប្តី ឬប្រពន្ធបាន ។

### មាត្រា ៨

នៅក្នុងក្របខ័ណ្ឌនីមួយៗ តាមគោលការណ៍ អ្នករាជការក្នុងឋានន្តរស័ក្តិ ឬថ្នាក់ណាមួយមិនអាចចាត់អោយទៅធ្វើការក្រោមបង្គាប់អ្នករាជការម្នាក់ទៀតដែលមានឋានន្តរស័ក្តិ ឬថ្នាក់ទាបជាងខ្លួនទេ លើកលែងតែក្នុងករណីចាំបាច់ហើយសាមីខ្លួនដែលមានឋានន្តរស័ក្តិ ឬថ្នាក់ធំជាងនោះយល់ព្រម ។

### មាត្រា ៩

របបស្តីពីការសុំច្បាប់ និងការឈប់សំរាកប្រចាំឆ្នាំ ប្រាក់បំណាច់បេសកកម្ម ប្រាក់បំណាច់ព្យាបាលរោគក្នុងមន្ទីរពេទ្យ និងប្រាក់សោធននិវត្តន៍ ។ល។ ត្រូវកំណត់តាមច្បាប់ដោយឡែក ។

### មាត្រា ១០

បៀវត្សនិងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ដូចជាប្រាក់បំណាច់បន្ថែមនិងប្រាក់បំណាច់ទទួលខុសត្រូវ ប្រាក់តំបន់ ប្រាក់ឧបត្ថម្ភកូននិងប្រពន្ធ ប្រាក់ថ្លៃឈ្នួលផ្ទះ ថ្លៃសង្ហារឹមក្នុងផ្ទះ ថ្លៃជាវមធ្យោបាយការងារ ថ្លៃទឹក និងថ្លៃភ្លើង ។ល។ នៃអ្នករាជការត្រូវកំណត់តាមច្បាប់ដោយឡែក ។

# ជំពូកទី ២
# ការជ្រើសរើសអោយចូលធ្វើការ

មាត្រា ១១

បេក្ខជនទាំងពីរភេទអាចទទួលអោយចូលធ្វើការក្នុងក្របខ័ណ្ឌរាជការបាន លុះត្រាតែបេក្ខជននោះបានបំពេញនូវលក្ខខ័ណ្ឌដូចខាងក្រោម ៖

១_ មានសញ្ជាតិជាខ្មែរ ។

២_ មានអាយុយ៉ាងតិច ១៨ ឆ្នាំ ហើយមិនលើសពី ២៥ ឆ្នាំ ប៉ុន្តែមានករណីលើកលែងខ្លះដូចមានចែងខាងក្រោមនេះ ៖

ក_ ចំពោះបេក្ខជនដែលមានសញ្ញាប័ត្រឧត្តមសិក្សា ការកំរិតអាយុ ត្រូវបានរំកិលពី ២៥ ឆ្នាំ ដល់ ៣០ ឆ្នាំ យ៉ាងច្រើនបំផុត ។

ខ_ ចំពោះបេក្ខជនដែលបានរៀននៅគ្រឹះស្ថានឧត្តមសិក្សា មួយឆ្នាំ ឬច្រើនឆ្នាំ ហើយមិនបានសញ្ញាប័ត្រនោះ ការកំរិតអាយុ ២៥ ឆ្នាំ និងត្រូវរំកិលតាមចំនួនឆ្នាំដែលបានរៀនក្នុងគ្រឹះស្ថានឧត្តមសិក្សាទាំងនោះ តែមិនឱ្យលើសពីអាយុ ៣០ ឆ្នាំ ។

គ_ ចំពោះបេក្ខជនដែលបានបំពេញកាតព្វកិច្ចយោធា ការកំរិតអាយុត្រូវរំកិលតាមចំនួនឆ្នាំដែលបានបំពេញកាតព្វកិច្ចយោធានោះ ។

ឃ_ ក្នុងពេលចាំបាច់ រាជរដ្ឋាភិបាលអាចចេញអនុក្រិត្យលើកលែងការកំណត់អាយុនៃបេក្ខជនដើម្បីបំពេញសេចក្តីត្រូវការជាអាទិភាព និងដើម្បីផលប្រយោជន៍ជាតិ ។

៣_ មិនបានប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិជាពលរដ្ឋ សិទ្ធិខាងនយោបាយ ។

៤_ មិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈឹមពីរឿងល្មើសប៉ះពាល់ដល់ទំនៀមទំលាប់ កិត្តិយស និងភាពសុចរិត ។

៥_ ត្រូវមានកាយសម្បទាគ្រប់គ្រាន់ក្នុងការបំពេញការងារដែលលក្ខណៈសម្បត្តិមានចែងទុកជាមុននៅក្នុងសេចក្តីណែនាំ និងបទបញ្ជាជាធរមាន ។

៦_ បងប្អូនជនជាតិភាគតិច បងប្អូននៅតំបន់ដាច់ស្រយាល និងបងប្អូននារីភេទអាចត្រូវបានផ្តល់អាទិភាព និងភាពងាយស្រួល ។

៧_ ត្រូវបំពេញលក្ខខ័ណ្ឌខាងសមត្ថភាពគ្រប់គ្រាន់ ដូចមានចែងក្នុងបទបញ្ជាដោយឡែកនៃអង្គដែលខ្លួនមានបំណងសុំចូលបំពេញការងារ ។

មាត្រា ១២.-

លក្ខខណ្ឌស្តីពីសញ្ជាតិ និងវ័យត្រូវបញ្ជាក់តាមសំបុត្រអត្រានុកូលដ្ឋាន ឬតាមសាលក្រមជំនួសអត្រានុកូលដ្ឋាននោះ ។

សេចក្តីបញ្ជាក់ថាគ្មានទោសត្រូវកំណត់ក្នុងសំបុត្រថ្កោលទោសមួយមានសុពលភាព ៣ ខែ ដែលចេញអោយដោយក្រសួងយុត្តិធម៌ ។

មាត្រា ១៣.-

ជាគោលការណ៍ រាល់ការជ្រើសរើសបេក្ខជនឱ្យចូលក្នុងក្របខ័ណ្ឌ ត្រូវធ្វើឡើងតាមការប្រឡងប្រជែង លើកលែងតែមានការកំណត់ផ្សេងពីនេះដោយរាជរដ្ឋាភិបាល ។

មាត្រា ១៤.-

កាលបរិច្ឆេទនៃការប្រឡងប្រជែងជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌរាជការ ត្រូវកំណត់ និងផ្សព្វផ្សាយយ៉ាងតិច ៣ ខែមុនថ្ងៃដែលបើកអោយចូលប្រឡង ។ ក្នុងករណីដែលមានការប្រញាប់ ការផ្សព្វផ្សាយត្រូវធ្វើយ៉ាងតិច ៣០ ថ្ងៃ ។

មាត្រា ១៥.-

ជាគោលការណ៍ រាល់ការប្រឡងប្រជែងជ្រើសរើសអោយចូលក្របខ័ណ្ឌរាជការ ត្រូវមានតំណាងស្ថាប័នមុខងារសាធារណៈចូលរួម ។

## ជំពូកទី ៣
## ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ
## ការបញ្ចេញពីក្របខ័ណ្ឌ

មាត្រា ១៦.-

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការនឹងអាចសំរេចបានជាស្ថាពរ ក្រោយពីបានធ្វើកម្មសិក្សាសាកល្បងមួយ ។ ផ្ទុយទៅវិញ អាចលើកលែងមិនបាច់ធ្វើកម្មសិក្សា ចំពោះបេក្ខជនទាំងឡាយដែលបានប្រឡងជាប់ទៅកាន់ប្រភេទក្របខ័ណ្ឌខ្ពស់ជាងនៃអង្គដែលខ្លួនធ្លាប់ជាមន្ត្រី រាជការចាស់តាំងស៊ប់ក្នុងក្របខ័ណ្ឌម្តងរួចហើយ ។

មាត្រា ១៧.-

បៀវត្សរបស់កម្មសិក្សាការីត្រូវកាត់ទុកប្រាក់សម្រាប់សោធននិវត្តន៍ ។ បើសិនជាកម្មសិក្សាការីនោះមិនបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការទេនោះ ប្រាក់ដែលបានកាត់ទុកសម្រាប់សោធននិវត្តន៍នេះត្រូវសងបកសាមីខ្លួនវិញ ។

មាត្រា ១៨.-

រយៈពេលកម្មសិក្សាត្រូវកំរិត ១២ ខែ ។ រយៈពេលកម្មសិក្សាត្រូវគិតពីថ្ងៃតែងតាំងកម្មសិក្សាការីនោះ ។ កម្មសិក្សានេះមិនត្រូវយកជាការបានទេ បើកាលណាសាមីជនអាក់ខានមកធ្វើកម្មសិក្សាសរុបលើសពី ៣០ ថ្ងៃ ។ ក្នុងករណីនេះ សាមីជនត្រូវបន្តធ្វើកម្មសិក្សានៅឆ្នាំទី ២ ទៀត ។

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌរាជការនឹងធ្វើទៅបានលុះត្រាតែកម្មសិក្សាការីបានបំពេញកម្មសិក្សាចំនួន ១២ ខែជាពិតប្រាកដ ។ រយៈពេលកម្មសិក្សានេះត្រូវបន្ថយ ៦ ខែចំពោះមន្ត្រីរាជការក្របខ័ណ្ឌចាស់ដែលបានប្រឡងជាប់ចូលក្របខ័ណ្ឌថ្មីមួយទៀតដោយរក្សាអតីតភាពដែលមានពីមុន ។

ការតាំងស៊ប់ក្នុងក្របខ័ណ្ឌត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចតែងតាំង តាមសំណើពីប្រធានអង្គភាព ។ ការតែងតាំងស៊ប់នៃកម្មសិក្សាការីត្រូវតែមានការរួមយោបល់ពីគណៈកម្មការមួយ ។

សមាសភាពគណៈកម្មការនេះមាន ៖

| | |
|---|---|
| ១- ប្រធានស្ថាប័ន ឬតំណាង | ប្រធាន |
| ២- ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង | សមាជិក |
| ៣- ប្រធានការិយាល័យបុគ្គលិក ឬតំណាង | សមាជិក |
| ៤- អ្នករាជការមួយរូបដែលមានក្របខ័ណ្ឌជាមួយគ្នា | សមាជិក |

កម្មសិក្សាការីណាដែលមិនបានបង្ហាញឱ្យឃើញថាខ្លួនមានសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ ឬក៏ពិនិត្យឃើញថារបៀបធ្វើការងារមានការខ្ជិលខ្ជា ឬក៏គ្មានកំលាំងពលនឹងកាន់មុខតំណែងបាន តាមលក្ខខ័ណ្ឌដែលបានកំណត់ក្នុងសេចក្តីណែនាំជាធរមាន អាចបញ្ឈប់មិនឱ្យធ្វើការនេះពេលណាក៏បានក្នុងរយៈពេលកម្មសិក្សា ។ ត្រូវបញ្ឈប់មិនឱ្យធ្វើការដូចគ្នាដែរ ចំពោះអ្នករាជការណាដែលបានប្រព្រឹត្តបទល្មើសនឹងមាត្រា ៣៣ និងមាត្រាបន្តបន្ទាប់ទៅមុខទៀតនៃច្បាប់នេះ ដែលចែងពីការដាក់វិន័យចំពោះមន្ត្រីរាជការ ។

ការបញ្ឈប់មិនឱ្យធ្វើការ ឬការតាំងស៊ប់ក្នុងក្របខ័ណ្ឌ តោងតែសំរេចជាដាច់ខាតក្នុងរយៈពេល ៣ខែ ក្រោយថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា ១២ ខែកន្លងមក ។ ការតែងតាំងស៊ប់ក្នុងក្របខ័ណ្ឌ

ចាប់ផ្តើមមានប្រសិទ្ធភាព ក្នុងផ្នែកបៀវត្សក៏ដូចជាអតីតភាពការងារសម្រាប់ឡើងឋានន្តរស័ក្តិ ឬថ្នាក់ ចាប់ពីថ្ងៃផុតកំណត់នៃកម្មសិក្សានេះ ។ ប៉ុន្តែអតីតភាពការងារសំរាប់ចូលនិវត្តន៍ត្រូវបានគិតបញ្ចូលតាំងពីថ្ងៃចាប់ផ្តើមធ្វើកម្មសិក្សា ។

មាត្រា ១៩.-

អ្នករាជការណាដែលធ្វើការតទៅទៀតមិនបាន ដោយហេតុមកពីបាត់បង់សម្បទាវិជ្ជាជីវៈ ហើយដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីទទួលសោធននិវត្តន៍អាចនឹងត្រូវបញ្ឈប់មិនឱ្យធ្វើការតទៅទៀតនៅពេលណាក៏បាន ។

អ្នករាជការមានអតីតភាពការងារចាប់ពី ២០ ឆ្នាំឡើងទៅ ដែលត្រូវឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ មានសិទ្ធិទទួលសោធនសមាមាត្រ ។ បើអតីតភាពការងារក្រោម ២០ ឆ្នាំ អ្នករាជការដែលបាត់បង់សម្បទាវិជ្ជាជីវៈ មានសិទ្ធិទទួលប្រាក់សោធនដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់រដ្ឋតែមួយលើក ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសំរេចដោយគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោមនេះ ៖

| | |
|---|---|
| ១. ប្រធានស្ថាប័ន ឬតំណាង | ប្រធាន |
| ២. ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង | សមាជិក |
| ៣. ប្រធានការិយាល័យបុគ្គលិក ឬតំណាង | សមាជិក |
| ៤. គ្រូពេទ្យដែលបានទទួលសញ្ញាប្រណិធាន ហើយដែលបានតាំងឡើងដោយក្រសួងសុខាភិបាល | សមាជិក |
| ៥. អ្នករាជការដែលនៅក្នុងក្របខណ្ឌជាមួយគ្នាពីរនាក់ដែលមានឋានន្តរស័ក្តិយ៉ាងហោចណាស់ស្មើនឹងសាមីខ្លួន | សមាជិក |

## ជំពូកទី ៤
## ការឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់

មាត្រា ២០ .

ការឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់នៃអ្នករាជការត្រូវធ្វើតាមវេនជ្រើសរើសក៏បាន ឬតាមវេនជ្រើសរើស និងអតីតភាពជាមួយគ្នាក៏បាន ។

តាមចម្មតា រយៈពេលអប្បបរមានៃការឡើងថ្នាក់ត្រូវកំរិត ២ ឆ្នាំ ។ ដើម្បីនឹងអាចឱ្យឡើងថ្នាក់តាមការជ្រើសរើសយកនោះ ត្រូវមានចុះឈ្មោះក្នុងតារាងឡើងថ្នាក់ ។ ក្នុងករណីអ្នករាជការណាម្នាក់បំពេញការងារមានស្នាដៃល្អពិសេសត្រូវបានតំឡើងថ្នាក់ជាស្វ័យប្រវត្តិ ដោយពុំគិតពីលក្ខខ័ណ្ឌអតីតភាពឡើយ ។

ចំពោះក្របខ័ណ្ឌទាំងអស់ ការតម្លើងថ្នាក់ត្រូវមានការយល់ព្រមពីស្ថាប័នមានសមត្ថកិច្ចក្នុងការតែងតាំងដែលសំដៅឱ្យតាមកំរិតនៃកន្លែងទំនេរក្នុងឋានន្តរស័ក្តិនីមួយៗ និងតាមកំរិតមុខចំណាយថវិកា ។

## មាត្រា ២១.-

អ្នករាជការក្នុងឋានន្តរស័ក្តិតែមួយអាចឡើងថ្នាក់បានម្តងមួយថ្នាក់ បើឋានន្តរស័ក្តិត្រូវឡើងទៅថ្នាក់ក្រោមបំផុតនៃស័ក្តិខ្ពស់ជាងនោះ ។ នៅពេលដែលអ្នករាជការត្រូវប្តូរប្រភេទក្របខ័ណ្ឌ ដោយសារបានប្រឡងជាប់ទៅប្រភេទក្របខ័ណ្ឌខ្ពស់ សន្ទស្សន៍បៀវត្សត្រូវគិតត្រឹមថ្នាក់ដែលមានកំរិតស្មើ ឬខ្ពស់បន្ទាប់ពីសន្ទស្សន៍បៀវត្សចាស់នៃអ្នករាជការនោះ ។

ការតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ទាំងឡាយ ត្រូវគិតលើផ្នែកបៀវត្សនិងអតីតភាពចាប់ពីកាលបរិច្ឆេទដែលការតម្លើងឋានន្តរស័ក្តិនេះត្រូវបានប្រកាស ។

## មាត្រា ២២.-

ជារៀងរាល់ឆ្នាំ នៅខែមករា អ្នករាជការទាំងអស់ដែលមានសិទ្ធិត្រូវតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ ត្រូវបំពេញព្រឹត្តិបត្រពិន្ទុសម្រាប់តម្លើងថ្នាក់របស់ខ្លួន ។ ព្រឹត្តិបត្រពិន្ទុនេះត្រូវបានប្រធានអង្គភាពធ្វើការកត់សម្គាល់ និងបញ្ជាក់បន្ថែម ព្រមទាំងកំណត់ជាពិន្ទុ ។

អភិបាលខេត្ត ក្រុង មានភារៈផ្តល់យោបល់ទៅលើកិរិយាមារយាទ ការគោរពវិន័យ សាមគ្គីភាពរបស់ប្រធានមន្ទីរនានានៅខេត្ត ក្រុង ។

តារាងពិន្ទុទាំងនោះត្រូវបញ្ជូនតាមលិខិតសំងាត់ទៅប្រធានស្ថាប័នសាមី ។

## មាត្រា ២៣.-

ក្រោយពីបានចារលើព្រឹត្តិបត្រពិន្ទុ តាមក្របខ័ណ្ឌ និងលំដាប់លំដោយអតីតភាព ប្រធានអង្គភាព ឬប្រធានស្ថាប័នមានសមត្ថកិច្ចបញ្ឈប់បញ្ជីស្នើសុំឡើងថ្នាក់នោះ ។

បញ្ជីខាងលើនេះ ត្រូវចុះឈ្មោះអ្នករាជការដែលបានបំពេញលក្ខខ័ណ្ឌដូចខាងក្រោម ៖

១- តាមធម្មតា អតីតភាពការងារយ៉ាងតិចបាន ២ ឆ្នាំ ចំពោះឋានន្តរស័ក្តិ ឬថ្នាក់ដែលបានទទួលគិតចាប់ពីថ្ងៃចូលឆ្នាំខ្មែរដែលជាថ្ងៃធ្វើតារាងឡើងថ្នាក់ ។

២- ត្រូវមានសេចក្តីស្នើសុំឱ្យឡើងថ្នាក់ត្រឹមត្រូវតាមច្បាប់ ពីថ្នាក់គ្រប់គ្រងបន្តបន្ទាប់ដែលសាមីខ្លួននៅក្រោមបង្គាប់ ។

មាត្រា ២៤ -

ព្រឹត្តិបត្រកំណត់ពិន្ទុវិជ្ជាជីវៈ និងស្ថានភាពសេវាកម្មនៃរាជការម្នាក់ៗដែលស្នើសុំឡើងឋានន្តរស័ក្តិ ឬថ្នាក់ ត្រូវបោតឱ្យគណៈកម្មការចំណាត់ថ្នាក់ពិនិត្យ ។

មាត្រា ២៥ -

តារាងតម្លើងឋានន្តរស័ក្តិ ឬថ្នាក់ ត្រូវធ្វើដោយគណៈកម្មការចំណាត់ថ្នាក់តែងតាំងតាមសំណើប្រធានអង្គភាព ឬពីប្រធានស្ថាប័នសាមី ។

គណៈកម្មការនេះ ត្រូវតែងតាំងឡើងតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬ តាមប្រកាសក្រសួង ហើយត្រូវមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- ប្រធានស្ថាប័ន ឬតំណាង | ប្រធាន |
| ២- ប្រធានអង្គភាពដែលគ្រប់គ្រង ឬតំណាង | សមាជិក |
| ៣- ប្រធានការិយាល័យបុគ្គលិក ឬតំណាង | សមាជិក |
| ៤- អ្នករាជការពីរនាក់ ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នា តែមានឋានន្តរស័ក្តិ និងថ្នាក់ខ្ពស់ជាង ឬបើគ្មានទេ ត្រូវយកអ្នករាជការក្នុងក្របខ័ណ្ឌឯទៀតក៏បានដែរ ។ អ្នករាជការទាំងនេះត្រូវជ្រើសរើសឡើងដោយការបោះឆ្នោត | សមាជិក |

មាត្រា ២៦ -

តារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់ ត្រូវធ្វើឡើងក្នុងត្រីមាសទី ៤ នៃឆ្នាំនីមួយៗ(ត្រីមាសទី ៤ នៃឆ្នាំខ្មែរ )។ តារាងនេះប្រើការសំរាប់ឆ្នាំបន្ទាប់ និងមានតែឈ្មោះអ្នកដែលស្នើឡើងតាមជនជ្រើសរើស ។

គណៈកម្មការចំណាត់ថ្នាក់ប្រជុំពេញអង្គ កំណត់មធ្យមភាគនៃពិន្ទុចំពោះបេក្ខជនម្នាក់ៗពីពិន្ទុ ០ ដល់ពិន្ទុ ២០ រួចគណៈកម្មការនេះស្រង់ឈ្មោះបេក្ខជនតាមលំដាប់លំដោយពិន្ទុ ។

ការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់ ត្រូវធ្វើតាមចំនួនកន្លែងដែលមានសល់ទំនេរ ។

ចំនួនឈ្មោះដែលចុះក្នុងតារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់ប្រចាំឆ្នាំសំរាប់ក្របខ័ណ្ឌនីមួយៗនៅក្នុងឋានន្តរស័ក្តិឬថ្នាក់នីមួយៗ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ អនុក្រឹត្យឬប្រកាសតាមចំនួនកន្លែងទំនេរ និងតាមមុខចំណាយដែលមានគ្រោងទុកក្នុងថវិកា ។

មាត្រា ២៧ -

ក្នុងករណីដែលមិនអាចចុះឈ្មោះបេក្ខជនទាំងអស់ក្នុងតារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់នៃឆ្នាំនេះបានទេ សាមីជនត្រូវមានសិទ្ធិចុះឈ្មោះមុនគេបង្អស់តាមលេខរៀង ក្នុងតារាងតម្លើងឋានន្តរស័ក្តិ ឬ

ថ្នាក់ឆ្នាំបន្ទាប់មកទៀត លើកលែងតែគណៈកម្មការសំរេចផ្ទុយពីនេះ ដោយមានសេចក្តីរាយការណ៍សមហេតុផល ពីប្រធានគ្រប់គ្រងសាមី ។

មាត្រា ២៨ .

ដើម្បីចុះឈ្មោះក្នុងតារាងឡើងឋានន្តរស័ក្តិឬថ្នាក់បាននៅថ្ងៃ ១៣ ខែ មេសា ក្នុងឆ្នាំនីមួយៗ បេក្ខជនត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលមានចែងក្នុងលក្ខន្តិកៈដោយឡែកនៃអង្គរបស់ខ្លួន ដើម្បីឡើងថ្នាក់ ។ ក្នុងករណីពិសេស គណៈកម្មការចំណាត់ថ្នាក់មានសិទ្ធិចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់បាននូវអ្នករាជការណាដែលអង្គភាពគ្រប់គ្រងមិនបានស្នើសុំតម្លើងឋានន្តរស័ក្តិឬថ្នាក់ ។

មាត្រា ២៩ .

អតីតភាពការងារមន្ត្រី រាជការដែលធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាល តំបន់ប៉ះពាល់សុខភាពឬគ្រោះថ្នាក់ ត្រូវគិតបន្ថែមពាក់កណ្តាលនៃអតីតភាពនេះទៀត ក្នុងការចុះឈ្មោះលើតារាងរាយនាមសំរាប់ស្នើសុំតម្លើងឋានន្តរស័ក្តិឬថ្នាក់ ។

មាត្រា ៣០ .

ការតម្លើងឋានន្តរស័ក្តិឬថ្នាក់តាមវេនអតីតភាព ត្រូវឆ្លាស់គ្នាជាមួយការឡើងឋានន្តរ-ស័ក្តិឬថ្នាក់តាមវេនជ្រើសរើស ទៅតាមសមាមាត្រដែលបានគ្រោងទុកក្នុងលក្ខន្តិកៈដោយឡែកសំរាប់អង្គនីមួយៗ ។

ការឡើងឋានន្តរស័ក្តិឬថ្នាក់តាមវេនអតីតភាព ត្រូវសំរេចតាមលំដាប់លំដោយអតីតភាពជាដាច់ខាតក្នុងបញ្ជីរាយនាមអ្នករាជការដែលត្រូវសុំឱ្យឡើងឋានន្តរស័ក្តិឬថ្នាក់នោះ ។

មាត្រា ៣១ .

សិទ្ធិត្រូវបានឡើងឋានន្តរស័ក្តិឬថ្នាក់ ដោយវេនជ្រើសរើស ក៏ដូចជាដោយវេនអតីត-ភាព ត្រូវផ្អាកចំពោះអ្នករាជការណាដែលជាប់ចោទជាបទវិន័យឬជាបទតុលាការ ។.

មាត្រា ៣២ .

ឋានន្តរស័ក្តិកិត្តិយស អាចផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចតែងតាំងជូនមន្ត្រីរាជការចូលនិវត្តន៍ឬលាលែង ឬដែលបានដាក់ឱ្យឈប់ធ្វើការងារដោយបាត់បង់សមត្ថភាពការងារ ។

ឋានន្តរស័ក្តិកិត្តិយសជាកិច្ចបច្ឆាមរណៈអាចផ្តល់ជូនមន្ត្រី រាជការដែលបានទទួលមរណ-ភាព។

# ជំពូកទី ៥
## វិន័យ

មាត្រា ៣៣ -

អ្នករាជការរាល់រូប ត្រូវតែគោរពអនុវត្តច្បាប់និងបទបញ្ជា ហើយនិងការណែនាំ លើរបស់ខ្លួន ។

អ្នករាជការត្រូវទទួលខុសត្រូវចំពោះមុខថ្នាក់លើអំពីកិច្ចការរបស់ខ្លួន និងអំពើដែល ធ្វើឱ្យប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់ខ្លួន ។

អ្នករាជការក្នុងក្របខ័ណ្ឌទាំងអស់ ត្រូវតែគោរពបញ្ជាថ្នាក់លើដែលបានចាត់ឱ្យ បំពើការងារ ទោះបីទីតំបន់ណាក៏ដោយ ទាំងក្នុងនិងក្រៅប្រទេស ។

មាត្រា ៣៤ -

អ្នករាជការទាំងឡាយមិនអាចឈប់ធ្វើការដោយគ្មានបានទទួលការអនុញ្ញាតជាមុ ថ្នាក់លើរបស់ខ្លួន ឬដោយគ្មានមូលហេតុត្រឹមត្រូវ ។ ការឈប់ធ្វើការ ឬការខានទៅធ្វើការដោយគ្មានការអ ញ្ញាត ឬដោយគ្មានមូលហេតុត្រឹមត្រូវ អាចបង្ខំឱ្យអ្នករាជការនោះនៅទំនេរគ្មានបៀវត្ស ឬត្រូវផ្អាកបៀវត្ស អ្នករាជការនោះអាចនឹងត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ។

មាត្រា ៣៥ -

ត្រូវហាមឃាត់ជាដាច់ខាត ចំពោះអ្នករាជការនូវប្រការខាងក្រោម ៖

១- យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ។

២- យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផល ប្រយោជន៍អ្វីមួយឬដើម្បីសំឡុត គំរាមកំហែង បំពានសិទ្ធិរបស់ពលរដ្ឋ ។

៣- ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃអ្នករាជការ។

៤- ចូលជាសមាជិកក្នុងក្រុមប្រឹក្សាភិបាល ឬគ្រប់គ្រងក្រុមហ៊ុនឯកជនដោយផ្ទាល់ឬ ដោយប្រយោល ។

៥- បោះពុម្ពផ្សាយ ឬធ្វើការផ្សព្វផ្សាយព័ត៌មានដែលមានពាក់ព័ន្ធនៅក្នុងមុខងារក្រសួង ដោយពុំមានការអនុញ្ញាតជាមុនពីប្រធានស្ថាប័នដែលសាមីខ្លួននៅក្រោមឱវាទ ។

៦_ ប្រកបមុខរបរបន្ថែមត្រួតលើមុខងាររបស់ខ្លួនជាអ្នករាជការ ក្នុងករណីដែលលក្ខន្តិកៈដោយឡែកនៃអង្គនីមួយៗហាមឃាត់ ។

អំពើបំពាននឹងបទបញ្ញត្តិនៃមាត្រានេះអាចបណ្តាលឱ្យទទួលទណ្ឌកម្មផ្នែកវិន័យណាមួយដែលមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ ដោយមិនទាន់គិតដល់ការចោទប្រកាន់ជាបទអាជ្ញាដែលអាចកើតមានឡើងទៀតផង ។

មាត្រា ៣៦._

អ្នករាជការទាំងឡាយមានសិទ្ធិចូលជាសមាជិក ឬចូលរួមក្នុងការគ្រប់គ្រងសមាគមស្របច្បាប់ ។

មាត្រា ៣៧._

មន្ត្រី រាជការត្រូវមានអព្យាក្រឹតភាពក្នុងសកម្មភាពការងារ និងហាមឃាត់ដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋដើម្បីបំពេញសកម្មភាពនយោបាយដូចខាងក្រោម ៖

១_ ធ្វើការដើម្បីផលប្រយោជន៍ដល់បេក្ខជននយោបាយ ឬប្រឆាំងនឹងបេក្ខជននយោបាយណាមួយ ។

២_ ធ្វើការដើម្បីផលប្រយោជន៍គណបក្សនយោបាយ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ។

ការប្រព្រឹត្តិផ្ទុយនឹងមាត្រានេះចាត់ទុកជាកំហុសនិងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ ។

មាត្រា ៣៨._

អ្នករាជការទាំងអស់ត្រូវបង្ហាញឱ្យឃើញថា ខ្លួនមានសមត្ថភាពក្នុងវិជ្ជាជីវៈជាងរាបក្នុងការប្រតិបត្តិមុខងាររបស់ខ្លួន ។ អ្នករាជការទាំងអស់ត្រូវទទួលខុសត្រូវពីកំហុស និងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈព្រមទាំងបទល្មើសដែលខ្លួនបានប្រព្រឹត្តក្នុងមុខងាររបស់ខ្លួន ។

មាត្រា ៣៩._

កំហុសនិងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ ត្រូវយកទណ្ឌកម្មខាងវិន័យទៅអនុវត្ត ។ ការខ្វះខាតឬបាត់បង់សម្បទាវិជ្ជាជីវៈអាចត្រូវដាក់ឱ្យចូលនិវត្តន៍ បើសាមីខ្លួនបំពេញលក្ខខណ្ឌដើម្បីទទួលប្រាក់សោធននិវត្តន៍ ឬបញ្ឈប់ពីការងាររាជការក្នុងករណីមិនគ្រប់លក្ខខណ្ឌដើម្បីទទួលប្រាក់សោធននិវត្តន៍ ។

មាត្រា ៤០ _

ទណ្ឌកម្មខាងវិន័យមានដូចតទៅ ៖

ទណ្ឌកម្មថ្នាក់ទី ១

ក_ ស្តីបន្ទោស

ខ_ ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ_ ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ

ឃ_ លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិឬថ្នាក់

២_ ទណ្ឌកម្មថ្នាក់ទី ២

ក_ ស្តីបន្ទោសជាទម្ងន់បណ្តាលឱ្យលុបចេញពីតារាងឡើងឋានន្តរស័ក្តិឬថ្នាក់ បើសិនជាមានចុះឈ្មោះហើយ ឬធ្វើឱ្យយឺតក្នុងការតម្លើងឋានន្តរស័ក្តិឬថ្នាក់ក្នុងថេរៈវេលាមួយមានកំណត់ តែមិនត្រូវឱ្យលើសពី ២ ឆ្នាំ ក្នុងការតម្លើងឋានន្តរស័ក្តិឬថ្នាក់តាមវេនជ្រើសរើសឬតាមវេនអតីតភាព ។

ខ_ ដាក់ឱ្យនៅទំនេរគ្មានបៀវត្សមិនឱ្យលើសពីមួយឆ្នាំ ។

គ_ បន្ថយឋានន្តរស័ក្តិឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់ ។

ឃ_ ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងារដោយបង្ខំ ។

ង_ បណ្តេញចេញពីមុខតំណែងរាជការ ។

មាត្រា ៤១ _

ការស្តីបន្ទោសត្រូវធ្វើជាលិខិតផ្ញើទៅសាមីខ្លួន ដោយប្រធានអង្គភាព ឬប្រធានស្ថាប័ន ។

ការស្តីបន្ទោសដែលមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យនិងការលុបឈ្មោះចេញពីតារាងតម្លើងឋានន្តរស័ក្តិឬថ្នាក់ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស តាមសេចក្តីរាយការណ៍ពីប្រធានអង្គភាព និងក្រោយពីសាមីខ្លួនបានដោះសា ។

មាត្រា ៤២ _

រាល់ទណ្ឌកម្មខាងវិន័យថ្នាក់ទី ២ ត្រូវសំរេចតាមព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសក្រោយពីមានយោបល់របស់ក្រុមប្រឹក្សាវិន័យ ។

មាត្រា ៤៣ _

អ្នករាជការដែលត្រូវបន្ថយថ្នាក់ ឬឋានន្តរស័ក្តិ ត្រូវបញ្ចូលទៅក្នុងថ្នាក់ថ្មីឬឋានន្តរស័ក្តិថ្មី ចាប់គិតពីថ្ងៃដែលមានសេចក្តីសំរេចជាផ្លូវការ ។

មាត្រា ៤៤ -

ការបណ្តេញមន្ត្រី រាជការចេញពីមុខតំណែងឬការងារមុខងារឬអំណាច និងឋានន្តរ ដែលបានប្រគល់ឱ្យពីមុនដល់មន្ត្រី រាជការនោះ ។ ក្នុងករណីដែលត្រូវលុបចោលនូវសិទ្ធិទទួលប្រាក់សោធននិវត្តន៍ ឬ ប្រាក់ដែលកាត់ទុកក្នុងបេឡាសោធននិវត្តន៍ នោះត្រូវមានសេចក្តីសំរេចជាលាយលក្ខណ៍អក្សរ ។

មាត្រា ៤៥ -

ការចោទប្រកាន់អំពីកំហុសខាងវិន័យត្រូវធ្វើដោយសេចក្តីសំរេចរបស់ថ្នាក់គ្រប់គ្រង ដែលមានសមត្ថកិច្ច ក្រោយពីមានសេចក្តីរាយការណ៍ពីស្ថាប័ន ពីប្រធានអង្គភាពឬប្រធានស្ថាប័ន ។

មាត្រា ៤៦ -

អនុក្រឹត្យ ឬប្រកាសដែលសំរេចចោទប្រកាន់អំពីកំហុសខាងវិន័យនាំឱ្យមានការផ្អាកមុខ-ងារនៃអ្នករាជការនោះជាបណ្តោះអាសន្ន តែមិនមានការបន្ថយបៀវត្សទេ ។ ក្នុងរយៈពេលមួយខែយ៉ាងយូរ ក្រុមប្រឹក្សាវិន័យត្រូវកោះប្រជុំដើម្បីផ្តល់យោបល់ ។

សេចក្តីសំរេចផ្អាកការងារអ្នករាជការឱ្យឈប់ពីតំណែងមានកំណត់ត្រឹម៣ខែ ប៉ុន្តែបើជាករណីពិសេសអាចសំរេចឱ្យបន្តជាថ្មីទៀតបាន កំណត់ ០១ ខែម្តង ប៉ុន្តែការបន្តនោះមិនត្រូវលើសពី៣ដងឡើយ ។

មាត្រា ៤៧ -

ការចោទប្រកាន់អំពីកំហុសខាងវិន័យ ត្រូវធ្វើការអង្កេតជាមុនសិនចំពោះទណ្ឌកម្មខាងវិន័យថ្នាក់ទី ២ ។ ការអង្កេតត្រូវប្រគល់ឱ្យតំណាងប្រធានស្ថាប័នសាមីមួយរូបឬច្រើនរូប ដែលមានឋានន្តរស័ក្តិ និងថ្នាក់ខ្ពស់ជាង ឬអតីតភាពច្រើនជាងអ្នករាជការដែលត្រូវជាប់ចោទ ។

សំណុំរឿងអង្កេតត្រូវបញ្ជូនទៅប្រធានស្ថាប័នដើម្បីពិនិត្យ និងសំរេចថានូវបញ្ជូនអ្នក-រាជការជាប់ចោទនោះទៅឱ្យក្រុមប្រឹក្សាវិន័យ ឬក៏សំរេចថានូវបញ្ឈប់ការចោទប្រកាន់វិញ ។ ក្នុងករណីដែលប្រធានស្ថាប័នយល់ថានូវបន្តការចោទប្រកាន់ សំណុំរឿងត្រូវបញ្ជូនទៅក្រុមប្រឹក្សាវិន័យដែលត្រូវអញ្ជើញអ្នករាជការជាប់ចោទមកពន្យល់ដោះសាដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរមុននឹងក្រុមប្រឹក្សាវិន័យធ្វើការសន្និដ្ឋានអំពីកំហុសនិងទណ្ឌកម្ម ដើម្បីជាយោបល់ដល់ថ្នាក់មានសមត្ថកិច្ចសំរេច ។

មាត្រា ៤៨ -

ក្រុមប្រឹក្សាវិន័យ ត្រូវមានសមាជិក ៥ នាក់

- អ្នករាជការ ៣ នាក់ ចាត់តាំងដោយប្រធានស្ថាប័ន ដែលអ្នករាជការជាប់ចោទនោះនៅក្រោមឱវាទ ម្នាក់បំពេញមុខងារជាប្រធាន និងម្នាក់ទៀតបំពេញមុខងារជាអ្នកធ្វើរបាយការណ៍ ។

- អ្នករាជការ ២នាក់ ដែលនៅក្នុងក្របខ័ណ្ឌជាមួយគ្នានឹងអ្នករាជការជាប់ចោទក៏ប៉ុន្តែមានឋានន្តរស័ក្តិខ្ពស់ជាង ឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា ។

មិនអាចចាត់តាំងឱ្យចូលក្នុងក្រុមប្រឹក្សាវិន័យនេះបាន អ្នករាជការណាដែលជាអ្នកធ្វើពាក្យបណ្តឹងចំពោះអ្នករាជការជាប់ចោទ ឬជាក្រុមញាតិរហូតដល់ជួរទី ៣របស់អ្នករាជការជាប់ចោទនោះ ។

មាត្រា ៤៩.-

អ្នកធ្វើរបាយការណ៍មានកាតព្វកិច្ចប្រាប់ទៅអ្នករាជការជាប់ចោទនូវសិទ្ធិរបស់អ្នករាជការនោះដូចតទៅ :

១- សិទ្ធិសុំមើលសំណុំរឿងផ្ទាល់ខ្លួន
២- សិទ្ធិសំអាងសាក្សី
៣- សិទ្ធិជ្រើសរើសតំណាងការពារខ្លួន
៤- សិទ្ធិពន្យល់ដោះសាជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ។

មាត្រា ៥០ -

ក្រោយពេលបានទទួលរបាយការណ៍ ក្រុមប្រឹក្សាវិន័យអាចបង្គាប់ឱ្យអ្នកធ្វើរបាយការណ៍រកព័ត៌មានបន្ថែមទៀតបាន ។

ប្រធានអាចពន្យាពេលប្រជុំក្រុមប្រឹក្សាវិន័យទៅថ្ងៃក្រោយបាន ព្រមទាំងអាចចាត់វិធានការផ្សេងៗដែលមានសារប្រយោជន៍ដើម្បីរកការពិត និងកុំឱ្យប៉ះពាល់ដល់សេចក្តីវិនិច្ឆ័យរបស់តុលាការ ក្នុងករណីដែលតុលាការបានសំរេចជាមុនមកហើយ ។

នីតិវិធីនៃការអនុវត្តវិន័យនឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៦
## ការចោទប្រកាន់តាមផ្លូវតុលាការ

មាត្រា ៥១.-

អ្នករាជការដែលជាប់បណ្តឹងពីបទមជ្ឈិមឬបទឧក្រិដ្ឋចំពោះមុខតុលាការ អាចត្រូវចោទប្រកាន់បានលុះត្រាមានសេចក្តីអនុញ្ញាតបើកឱ្យចោទប្រកាន់ជាមុនពីគណៈរដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចំពោះមន្ត្រីដែលមានបៀវត្សស្មើឬលើសបៀវត្សឧត្តមមន្ត្រីថ្នាក់លេខ ៣ ឬមានឋានៈជាប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីនិងក្រុង អភិបាលខេត្ត ក្រុង ។ ចំពោះអ្នករាជការដែលមានបៀវត្សទាបជាងបៀវត្សឧត្តមមន្ត្រីថ្នាក់លេខ ៣ វិញ សេចក្តីអនុញ្ញាតជាមុនឱ្យចោទប្រកាន់នោះត្រូវសំរេចត្រឹមប្រធានស្ថាប័នសាមី ។

ក្នុងករណីបណ្តើសជាក់ស្តែង តុលាការអាចបង្គាប់ឱ្យឃុំខ្លួនភ្លាមមិនចាំបាច់មានសេចក្តីអនុញ្ញាតឱ្យចោទប្រកាន់ទេ ប៉ុន្តែត្រូវជូនដំណឹងអំពីរឿងនេះជាបន្ទាន់ទៅប្រធានស្ថាប័នសាមី ។

មាត្រា ៥២ .

អ្នករាជការណាដែលកំពុងជាប់ការចោទប្រកាន់ទៅតុលាការជំនុំជំរះ អាចត្រូវបានផ្អាកពីមុខងារសិនក្នុងករណីចាំបាច់ ។

ក្នុងករណីដែលអ្នករាជការត្រូវផ្អាកពីការងារដោយផ្អាកបៀវត្ស អ្នករាជការនោះត្រូវបានទទួលឱ្យចូលធ្វើការវិញភ្លាមដោយគិតពីអតីតភាព ឋានន្តរស័ក្តិ សោធននិវត្តន៍ និងទទួលបៀវត្សប្រតិសកម្មផង បើតុលាការប្រកាសឱ្យរួចខ្លួនជាស្ថាពរ ។

មាត្រា ៥៣ .

ការផ្តន្ទាទោសជាបទឧក្រិដ្ឋ ឬជាបទមជ្ឈិមដោយឥតព្យួរទោស បណ្តាលឱ្យមានកាហូតងារអ្នករាជការនោះ គិតពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

អ្នករាជការដែលតវ៉ាសុំឧទ្ធរណ៍ត្រូវដាក់ឱ្យនៅទំនេរគ្មានបៀវត្សជាបណ្តោះអាសន្នដោយស្វ័យប្រវត្តិ ។

## ជំពូកទី ៧
## ការចូលនិវត្តន៍

មាត្រា ៥៤ .

អ្នករាជការទាំងពីរភេទត្រូវដាក់ឱ្យចូលនិវត្តន៍ជាកំហិត ពេលដល់អាយុ ៥៥ ឆ្នាំ ។

អាយុកំហិតនេះអាចរំកិលឡើងដល់ ៦០ ឆ្នាំហើយក្តិកៈដោយឡែកបានកំណត់ ។

ដើម្បីមានសិទ្ធិទទួលសោធននិវត្តន៍អតីតភាពបាន អ្នករាជការត្រូវបំពេញលក្ខខណ្ឌដូចតទៅៈ

- មានអាយុ ៥៥ ឆ្នាំ
- មានអតីតភាពការងារ ៣០ ឆ្នាំ

ប៉ុន្តែអ្នករាជការដែលបានបំពេញការងារអស់រយៈពេល ៣០ ឆ្នាំហើយ អាចសុំចូលនិវត្តន៍មុនអាយុ ៥៥ ឆ្នាំបានដោយទទួលប្រាក់សោធននិវត្តន៍អតីតភាព ។

មាត្រា ៥៥.-

អ្នករាជការដែលបំពេញការងារបាន ៣០ ឆ្នាំយ៉ាងតិច ត្រូវទទួលប្រាក់សោធននិវត្តន៍អតិតភាព ។

អ្នករាជការដែលបានបំពេញការងារក្រោម ២០ ឆ្នាំ ត្រូវទទួលប្រាក់សោធននិវត្តន៍ដែលបានកាត់ទុក និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់រដ្ឋតែមួយលើក ។

អ្នករាជការដែលបំពេញការងារក្នុងចន្លោះរយៈពេលពី ២០ ឆ្នាំដល់ក្រោម ៣០ ឆ្នាំ ត្រូវបានទទួលប្រាក់សោធននិវត្តន៍សមាមាត្រ ។

មាត្រា ៥៦.-

ក្នុងរយៈពេលបន្តការងារក្រោយពេលដល់អាយុចូលនិវត្តន៍ ចំពោះអ្នករាជការដែលមានអតីតភាពគ្រប់ ៣០ ឆ្នាំហើយ មិនត្រូវកាត់ទុកប្រាក់សោធននិវត្តន៍ឡើយ ប៉ុន្តែបើអតីតភាពការងារមិនទាន់គ្រប់ ៣០ ឆ្នាំនោះ ត្រូវកាត់ទុកប្រាក់សោធននិវត្តន៍ ហើយរាប់បញ្ចូលចំនួនឆ្នាំដែលបានបន្តការងារ ដើម្បីទទួលប្រាក់សោធននិវត្តន៍ ។

មាត្រា ៥៧.-

អតីតភាពការងាររបស់អ្នករាជការត្រូវគិតតាំងពីថ្ងៃដែលសាមីខ្លួនបានចូលបំរើការងាររដ្ឋ ទោះក្នុងសម័យណាក៏ដោយ ។

## ជំពូកទី ៨
## ការដោះស្រាយទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ

មាត្រា ៥៨.-

អ្នករាជការមានសិទ្ធិប្តឹងតវ៉ាទៅតុលាការ អំពីករណីដែលពាក់ព័ន្ធទៅនឹងកិច្ចការមុខងារសាធារណៈ ។ ប៉ុន្តែជាការចាំបាច់ អ្នករាជការនោះត្រូវរកវិធីដោះស្រាយតាមផ្លូវរដ្ឋបាលជាមុនសិន ។

មាត្រា ៥៩.-

- សមត្ថកិច្ចដើម្បីដោះស្រាយទំនាស់ខាងលើនេះ ត្រូវប្រគល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍មួយមានឈ្មោះថា គណៈកម្មាធិការសំរុះសំរួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ដែលមានប្រធានស្ថាប័នមុខងារសាធារណៈជាប្រធាន ហើយនឹងមានសមាសភាពដែលកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ៩
# បទបញ្ញត្តិដោយឡែក

មាត្រា ៦០ -

ការកែសម្រួលចំនួនអ្នករាជការតាមសភាពជាក់ស្តែងជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ ក្នុងករណីដែលត្រូវកាត់បន្ថយចំនួនអ្នករាជការជាការចាំបាច់ ជាគោលការណ៍ ការរំសាយត្រូវប៉ះពាល់ជាបឋមចំពោះអ្នករាជការដែលជិតដល់អាយុចូលនិវត្តន៍ ដែលមានសម្បទាវិជ្ជាជីវៈថមថយ និងអ្នកដែលស្ម័គ្រចិត្តឈប់ពីការងារ ។

មាត្រា ៦១

ជាគោលការណ៍ អ្នករាជការក្រប់ខ័ណ្ឌមានអាទិភាពក្នុងការទទួលមុខតំណែងណាមួយ ។ តែក្នុងករណីពិសេស ផ្អែកលើការចាំបាច់ រាជរដ្ឋាភិបាលអាចតែងតាំងវរជនណាម្នាក់ ឬជនដែលមានសញ្ញាប័ត្រខ្ពស់ ឱ្យកាន់មុខតំណែងអ្វីមួយក៏បាន ទោះវរជនឬជននោះពុំមែនជាមន្ត្រីក្របខ័ណ្ឌក៏ដោយ ។

ក្នុងលក្ខណៈនេះ សាមីខ្លួនមានសិទ្ធិទទួលបៀវត្សជាធម្មតា តែគ្មានសិទ្ធិទទួលសោធន-និវត្តន៍ទេ ។

មាត្រា ៦២

រាជរដ្ឋាភិបាលអាចតែងតាំងឱ្យចូលក្របខ័ណ្ឌអ្នករាជការនៅពេលណាក៏បាន ចំពោះវរជន ឬជនដែលមានសញ្ញាប័ត្រខ្ពស់ ដែលមានផលប្រយោជន៍ដល់ការងាររដ្ឋ ដោយមិនគិតពីលក្ខខ័ណ្ឌអាយុ ។

# ជំពូកទី ១០
# អន្តរប្បញ្ញត្តិ

មាត្រា ៦៣ -

ចាប់តាំងពីច្បាប់នេះចូលជាធរមាន រហូតដល់ឆ្នាំ ២០០០ អ្នករាជការដែលមានអាយុលើសពី ៥៥ ឆ្នាំ អាចអនុញ្ញាតបន្តឱ្យធ្វើការងារបាន តាមការស្នើសុំរបស់សាមីខ្លួន និងតាមការសម្រេចដោយអនុក្រឹត្យផ្អែកលើយោបល់ឯកភាពពីស្ថាប័នមុខងារសាធារណៈ និងប្រធានស្ថាប័នសាមី ។ ការបន្តនេះមានរយៈពេលមួយឆ្នាំម្តងៗ តែមិនឱ្យលើសពី ៥ ឆ្នាំទេ ។

# ជំពូកទី ១១
# អវសានប្បញ្ញត្តិ

**មាត្រា ៦៤** -

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ សុក្រ ទី ២១ ខែ តុលា ឆ្នាំ ១៩៩៤
នាសម័យប្រជុំសាមញ្ញលើកទី ៣ នីតិកាលទី ១ ។

ភ្នំពេញ.ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤
ប្រធានរដ្ឋសភាស្តីទី

ឡោយ ស៊ីមឈាង

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៦៤ –**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៨

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

បានបង្គំទូលថ្វាយនិងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន វ៉េង សិរីវុឌ្ឍ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# វិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមតម្រូវការចាំបាច់ក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១.- គោលបំណង

អនុក្រឹត្យនេះ កំណត់អំពីវិធានការរដ្ឋបាល ស្របតាមច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត សំដៅការពារអាយុជីវិតរបស់ប្រជាពលរដ្ឋ សុខភាពសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងកាត់បន្ថយឱ្យបានជាអតិបរមានូវផលប៉ះពាល់នៃការឆ្លងជំងឺនេះ ចំពោះវិស័យសង្គម និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ .. វិសាលភាព**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀតតាមការកំណត់របស់ក្រសួងសុខាភិបាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## វិធានការរដ្ឋបាលដែលត្រូវអនុវត្ត
### ផ្នែកទី១
### ប្រភេទនៃវិធានការរដ្ឋបាល

**មាត្រា៣ .. វិធានការរដ្ឋបាលនានា**

ក្នុងគោលដៅប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា វិធានការរដ្ឋបាលចាំបាច់នានាដែលត្រូវអនុវត្ត មានជាអាទិ៍៖

- ការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ
- ការរឹតត្បិត ឬការហាមឃាត់ការជួបជុំនិងការប្រមូលផ្ដុំមនុស្សដែលសកម្មភាពនេះអាចបណ្ដាលឱ្យមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការហាមឃាត់ ឬការកម្រិតការធ្វើសកម្មភាពការងារឬមុខរបរដែលជាហានិភ័យឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬហាមឃាត់ការធ្វើចរាចរណ៍ចេញ-ចូលតំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- បម្រាមគោចរ
- ការបិទខ្ទប់តំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និង
- វិធានការរដ្ឋបាលផ្សេងទៀតដែលមានភាពចាំបាច់ ដើម្បីឆ្លើយតបនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

### ផ្នែកទី២
### ខ្លឹមសារនៃវិធានការរដ្ឋបាល

**មាត្រា៤ .. ការរឹតត្បិត ឬការហាមឃាត់ការធ្វើដំណើរ**

ការធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការធ្វើដំណើរទៅបំពេញការងារ ឬប្រកបមុខរបរ ឬអាជីវកម្ម ដែលមិនមានការរឹតត្បិត ឬហាមឃាត់ និងដោយមានភ្ជាប់លិខិតបញ្ជាក់អំពីការងារ មុខរបរ ឬអាជីវកម្ម
- ការធ្វើដំណើរទៅស្វែងរកគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃ
- ការធ្វើដំណើរទៅមន្ទីរពេទ្យ មណ្ឌលសុខភាព សម្ភព ទីកន្លែងព្យាបាល ឬឱសថស្ថាន ដោយមូលហេតុសុខភាពបន្ទាន់
- ការធ្វើដំណើរដើម្បីទៅបង្ហាញខ្លួនឱ្យមន្ត្រីសុខាភិបាលធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងដើម្បីទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ តាមកាលកំណត់

- ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលក្នុងរង្វង់ភូមិសាស្ត្រឃុំ-សង្កាត់ដែលខ្លួនរស់នៅ ដោយចៀសវាងការជួបជុំប្រមូលផ្តុំមនុស្ស
- ការធ្វើដំណើរដើម្បីអនុវត្តកាតព្វកិច្ចតាមផ្លូវច្បាប់នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ឬសាលាជម្រះក្តី
- ការធ្វើដំណើរដើម្បីចូលរួមក្នុងសកម្មភាពដែលបម្រើផលប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាធរសាធារណៈ និង
- ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ ជាអាទិ៍ ករណីមានសមាជិកគ្រួសារកំពុងមានជំងឺធ្ងន់ធ្ងរនិងត្រូវសង្គ្រោះបន្ទាន់ ឬករណីមានសមាជិកគ្រួសារទទួលមរណភាព។

## មាត្រា៥.- ការរឹតត្បិត ឬការហាមឃាត់ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស

រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋានឬទីសំណាក់ជាមួយគ្នា
- ការរៀបចំពិធីបុណ្យសព ដោយគោរពតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច
- ការប្រមូលផ្តុំមនុស្សដើម្បីអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
- ការជួបជុំមនុស្សដើម្បីផ្តល់ជំនួយចាំបាច់នានាដល់ជនងាយរងគ្រោះ ឬជនរងគ្រោះ
- ការជួបជុំមនុស្សក្នុងអំឡុងពេលនៃកិច្ចនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬរបស់សាលាជម្រះក្តី និង
- ការជួបជុំមនុស្សដែលមានភាពចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬក្នុងគោលបំណងផ្សេងទៀតតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។

## មាត្រា៦.- ការហាមឃាត់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម

រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម អាចត្រូវបានផ្អាកជាបណ្តោះអាសន្ន លើកលែងតែក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- សកម្មភាពការងារនៅក្នុងក្របខណ្ឌមុខងារសាធារណៈ ឬការងារដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈតាមការកំណត់របស់ស្ថាប័ននីមួយៗ ជាអាទិ៍ សេវាផ្គត់ផ្គង់អគ្គិសនី, ទឹក, សេវាប្រមូលសំរាម
- រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ
- សេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល និងឱសថស្ថាន
- ការផ្គត់ផ្គង់ទំនិញ ឬសេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ ហាងលក់ទំនិញ, ស្ថានីយ៍ប្រេងឥន្ធនៈ, សេវាប្រៃសណីយ៍ និងទូរគមនាគមន៍
- ភោជនីយដ្ឋាន និងអាហារដ្ឋានដែលលក់អាហារវេចខ្ចប់
- សេវាកម្មដឹកជញ្ជូនទំនិញ និង
- សកម្មភាពការងារ មុខរបរ ឬអាជីវកម្មចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

## មាត្រា៧.- ការរឹតត្បិត ឬហាមឃាត់ការធ្វើចរាចរណ៍ចេញ-ចូល

ការធ្វើចរាចរណ៍ចេញ-ចូលភូមិសាស្ត្រនៃតំបន់ ឬទីកន្លែងណាមួយ ដែលមានការឆ្លងរាលដាលជំងឺ

កូវីដ-១៩ អាចត្រូវបានរឹតត្បិត ឬហាមឃាត់ លើកលែងតែសេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ ឬសេវាដឹកជញ្ជូនទំនិញ។

### មាត្រា៨ .. បម្រាមគោចរ

រាល់ការធ្វើដំណើរដែលត្រូវបានអនុញ្ញាតដូចមានចែងក្នុងមាត្រា៤ នៃអនុក្រឹត្យនេះ មិនត្រូវធ្វើឡើងនៅចន្លោះពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) លើកលែងចំពោះការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់ មូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ ការដឹកជញ្ជូនទំនិញ ការបំពេញកាតព្វកិច្ចដែលបម្រើផលប្រយោជន៍សាធារណៈ ការធ្វើដំណើរទៅទីកន្លែងបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន ឬទីតាំងអាជីវកម្មដែលត្រូវបានលើកលែងឱ្យបើកដំណើរការដូចមានចែងក្នុងកថាខណ្ឌខាងក្រោមនេះ និងករណីចាំបាច់ដទៃទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់គ្រឹះស្ថានសាធារណៈ សហគ្រាសឬគ្រឹះស្ថានឯកជន ឬទីតាំងអាជីវកម្មដែលត្រូវបានអនុញ្ញាតឱ្យនៅបើកដំណើរការស្របតាមមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវផ្អាកប្រតិបត្តិការរបស់ខ្លួនចាប់ពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) សម្រាប់ទទួលអតិថិជនដោយផ្ទាល់ លើកលែងចំពោះសេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ឱសថស្ថាន ស្ថានីយ៍ប្រេងឥន្ធនៈ និងសេវាសាធារណៈចាំបាច់ដទៃទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

### មាត្រា៩ .. ការបិទខ្ទប់តំបន់ ឬទីកន្លែងដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

រាល់ការធ្វើដំណើរចេញ-ចូលភូមិសាស្ត្រនៃតំបន់ ឬទីកន្លែងដែលត្រូវបានបិទខ្ទប់ អាចត្រូវបានហាមឃាត់ លើកលែងតែការធ្វើដំណើរដើម្បីបំពេញមុខងារក្នុងការផ្តល់សេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ ឬសេវាដឹកជញ្ជូនទំនិញ និងករណីចាំបាច់ផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងអំឡុងពេលនៃការបិទខ្ទប់ វិធានការរដ្ឋបាលដែលមានចែងក្នុងមាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា៧ មាត្រា៨ និងមាត្រា១០ នៃអនុក្រឹត្យនេះ ត្រូវបានយកមកអនុវត្តទាំងស្រុង ឬដោយផ្នែក។

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាលរួមមានការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កំដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

### មាត្រា១០ .. ការរឹតត្បិត ឬការហាមឃាត់ការធ្វើពាណិជ្ជកម្មលើទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

ទំនិញដែលជាហានិភ័យ ឬជាប្រភពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលកំណត់ដោយក្រសួងសុខាភិបាល អាចត្រូវបានរឹតត្បិត ឬហាមឃាត់ការធ្វើពាណិជ្ជកម្មតាមគ្រប់រូបភាពនៅលើទីផ្សារ និងការផ្គត់ផ្គង់នៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣
## សិទ្ធិអំណាចក្នុងការដាក់ចេញវិធានការរដ្ឋបាល

### មាត្រា១១ .. សមត្ថកិច្ចក្នុងការដាក់ចេញវិធានការរដ្ឋបាល

ការដាក់ចេញវិធានការបិទខ្ទប់រាជធានីឬខេត្ត និងការដាក់ចេញវិធានការរដ្ឋបាលផ្សេងទៀតដែលមានវិសាលភាពអនុវត្តលើសពីដែនដីនៃរាជធានី ឬខេត្តមួយ ឬមានវិសាលភាពអនុវត្តនៅទូទាំងប្រទេស ត្រូវធ្វើឡើងតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

គណៈអភិបាលរាជធានី ខេត្ត ត្រូវបានប្រគល់សមត្ថកិច្ចក្នុងការសម្រេចដាក់ចេញវិធានការរដ្ឋបាលណាមួយដែលមានវិសាលភាពអនុវត្តសម្រាប់ផ្នែកខ្លះ ឬទីកន្លែងខ្លះក្នុងដែនដីនៃរាជធានីខេត្ត ឬមានវិសាលភាពអនុវត្តទូទាំងរាជធានី ឬខេត្តរបស់ខ្លួនដែលមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**មាត្រា១២.- លក្ខខណ្ឌនៃការដាក់ចេញវិធានការរដ្ឋបាល**

ការដាក់ចេញវិធានការរដ្ឋបាលណាមួយស្របតាមអនុក្រឹត្យនេះ ត្រូវធ្វើឡើងជាបណ្ដោះអាសន្នសម្រាប់ថិរវេលាមិនឱ្យលើសពី ២ (ពីរ) សប្ដាហ៍។ ថិរវេលានេះអាចត្រូវបានសម្រេចបន្ត ឬបញ្ចប់មុនថិរវេលាកំណត់ ក្នុងលក្ខខណ្ឌដូចគ្នានឹងការសម្រេចដាក់ចេញវិធានការរដ្ឋបាល ស្របតាមមាត្រា១១ នៃអនុក្រឹត្យនេះ។

**មាត្រា១៣.- សិទ្ធិអំណាចរបស់គណៈអភិបាលរាជធានី ខេត្ត**

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ ត្រូវបានប្រគល់ភារកិច្ចក្នុងការធានាការអនុវត្តវិធានការដែលត្រូវបានដាក់ចេញស្របតាមកថាខណ្ឌទី១ នៃមាត្រា១១ នៃអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ មានសិទ្ធិបង្កើតយន្តការចាំបាច់នានា ដើម្បីតាមដាន ត្រួតពិនិត្យ និងអនុវត្តវិធានការដែលត្រូវបានដាក់ចេញស្របតាមមាត្រា១១ នៃអនុក្រឹត្យនេះ ក្រោមសមត្ថកិច្ចរបស់ខ្លួន។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ អាចចេញសេចក្ដីណែនាំលម្អិតអំពីការអនុវត្តវិធានការរដ្ឋបាលនានាដែលបានដាក់ចេញស្របតាមអនុក្រឹត្យនេះ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្ត នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ មានសិទ្ធិបន្ធូរបន្ថយនូវវិធានការរដ្ឋបាលណាមួយដែលត្រូវបានដាក់ចេញស្របតាមកថាខណ្ឌទី២ នៃមាត្រា១១ នៃអនុក្រឹត្យនេះ ប៉ុន្តែត្រូវគោរពឱ្យបាននូវរាល់លក្ខខណ្ឌលើកលែងដាក់លាក់នៃវិធានការរដ្ឋបាលនីមួយៗ ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ។

ក្នុងករណីបន្ទាន់និងចាំបាច់ គណៈអភិបាលរាជធានី ខេត្តមានសិទ្ធិដាក់ចេញវិធានការរដ្ឋបាលផ្សេងទៀត សំដៅធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនដីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន និងទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត។

**ជំពូកទី៤**

**ទោសប្បញ្ញត្តិ**

**មាត្រា១៤.- ទណ្ឌកម្មចំពោះអំពើមិនគោរពវិធានការរដ្ឋបាល**

ត្រូវផ្ដន្ទាទោសស្របតាមមាត្រា១០ នៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលមិនគោរពដោយចេតនានូវវិធានការរដ្ឋបាលដែលមានចែងក្នុងជំពូកទី២ និងជំពូកទី៣ នៃអនុក្រឹត្យនេះ។

ការសម្រេចដាក់ពិន័យអន្តរការណ៍ចំពោះការបំពានវិធានការរដ្ឋបាល ជាសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ បែបបទនីតិវិធីលម្អិតសម្រាប់ការដាក់ពិន័យអន្តរការណ៍ ត្រូវកំណត់ដោយគណៈអភិបាលរាជធានី ខេត្ត។

ទម្រង់បែបបទនៃបង្កាន់ដៃពិន័យ និងការគ្រប់គ្រងប្រាក់ដែលបានមកពីការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា១៥.- ទណ្ឌកម្មចំពោះអំពើរាំងខ្ទប់ដល់ការអនុវត្តវិធានការរដ្ឋបាល**

ត្រូវផ្ដន្ទាទោសស្របតាមមាត្រា១១ នៃច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ចំពោះបុគ្គលដែលប្រព្រឹត្តអំពើរាំងឬបង្កឧបសគ្គដោយចេតនាដល់ការអនុវត្តវិធានការរដ្ឋបាលដូចមានចែងក្នុងជំពូកទី២ និងជំពូកទី៣ នៃអនុក្រឹត្យនេះ។

ដែលត្រូវបានកំណត់ដោយក្រសួងសុខាភិបាល ក្រោមវិសាលភាពអនុវត្តនៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

### មាត្រា២១.- ការបន្តសុពលភាពនៃលិខិតបទដ្ឋានគតិយុត្តមុនអនុក្រឹត្យនេះ

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការរដ្ឋបាលនានា ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលអនុក្រឹត្យនេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

### មាត្រា២២.- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

### មាត្រា២៣.- ស្ថាប័នអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៣រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ